# ព្រះភិក្ខុពនេចរ

ដោយ

# ធម្មឃោស




បកប្រែជាខេមរភាសាដោយដូនជី

ចំរើន ចារូន

គេហដ្ឋាន អភិរក្សមរតកព្រះពុទ្ធសាសនាខ្មែរ

ក្រុងម៉ុងរេអាល - កេបិក - កាណាដា

ព.ស. ២៥៥៩ - គ.ស. ២០១៦

ព្រះភិក្ខុ ធម្មឃោស

# រឿង ព្រះភិក្ខុពាទោស ភាគ ២

* បកប្រែដោយ

ភូនរី សុភចម ចំរើន ចារូន ( ចារុវណ្ណា )

* កម្រងកំណាព្យដោយ

មុិញ សាវ៉ាន / ហុិម ឆាន់

* ចម្លងអត្ថបទ និងរចនាដោយ

វ៉ាត តិរក្ស / ធឹម អរុណី

* ផ្សព្វផ្សាយដោយ

គេហដ្ឋាន អភិរក្សមរតកព្រះពុទ្ធសាសនាខ្មែរ

ក្រុងម៉ុងរ៉េអាល - កេបិក - កាណាដា

ព.ស. ២៥៥៩ - គ.ស. ២០១៦

សម្រាប់ចែកជាធម្មទាន

# សៀវភៅចាស់ដែលបានចម្លងជាថ្មី ៖

១. ស្នាព្រះហស្ដក្រោយបង្អស់នៃសម្ដេចព្រះមហាសុមេធាធិបតី **ជួន ណាត**
២. ធម៌នមស្ការព្រះរតនត្រ័យ ពិស្ដារ - សង្ខេប ( វ៉ាត ភិរក្ស ) ថ្មី
៣. ប្រស្នា គិហិប្រតិបត្តិពិស្ដារ ( ឈឹម ទូច, សុង ស៊ីវ )
៤. ប្រជុំនានាធម៌សង្វេគ ( ជ័យ ម៉ៃ )
៥. អានាបាណស្សតិកម្មដ្ឋាន វិបស្សនាបញ្ហាធម្មបរិយាយ ( គង់ ឌឹប )
៦. ធម្មនិយាម ៣០ និងកំណាព្យផ្សេង ៗ ( ប៊ុត សាវង្ស, ភិក្ខុ សាន សុជា )
៧. ជីវិតកថា ( ម៉ិញ សារ៉ាន ) ថ្មី
៨. ធម្មប្រទីប ( ប្រជុំកងធម៌ យិន វន់ )
៩. រឿង ព្រះភិក្ខុពនេចរ ( ឱម ណាគ្រី )
១០. រឿង នគរកាយ ( ចាប ពិន )
១១. ច្បាប់គោរពមាតាបិតា ( អ៊ូ ចុង )
១២. នត្ថិធម្មាធិប្បាយ ( ព្រះបិដកធម្ម អ៊ុម ស៊ុម )
១៣. ត្រៃកូដធម៌ ( សុង ស៊ីវ )
១៤. ឱវាទបាតិមោក្ខ ( ចាប ពិន )
១៥. កម្រងកំណាព្យ ( ហ៊ុម ឆាន់ ) ថ្មី
១៦. ឧបនីយតិសូត្រ ( ព្រះមហាវីរិយបណ្ឌិតោ ប៉ាង ខាត់ )
១៧. ធម្មទ្វេស ៤ យ៉ាង ( ម៉ិញ សារ៉ាន ) ថ្មី
១៨. ធម៌នមស្ការសម្រាប់យុវវ័យ Khmer – Français ( វ៉ាត ភិរក្ស ) ថ្មី
១៩. ធម៌នមស្ការសម្រាប់យុវវ័យ Khmer – Anglais ( វ៉ាត ភិរក្ស ) ថ្មី
២០. លោកនីតិបករណ៍ ( ព្រះ អ៊ុក ជា វជិរញ្ញាណាភយវង្ស )
២១. អធិប្បាយមង្គលសូត្រ ( ព្រះវិន័យធរ អនុគណ ឯក ញឹម ធម្មិស្សរោ )
២៣. ព្រះបាឡាត់ឃោសនាគ ហែម ចៀវ (គង់ សម្ការ)
២៤. ចំណងដៃឆ្នាំថ្មី( ម៉ិញ សារ៉ាន ) ថ្មី
២៥. ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាសង្ខេប (សម្ដេចព្រះពោធិវង្ស ហួត តាត)
២៦. ឱវាទ ៤ «ខ» របស់លោក លៀវ ហ្វាន (បកប្រែដោយលោកយាយ ចំរើន ចារូន)
២៧. គុណមាតាបិតា ( ម៉ិញ សារ៉ាន ) ថ្មី
២៨. ទស្សនៈសម្ដេចព្រះសង្ឃរាជ ជួន ណាត (គង់ សម្ការ )
២៩. អភិធម្មបរមត្ថសង្ខេប (ព្រះគ្រូ. យ៉ាង ផាន់ និង ព្រះមហា. អ៊ុម ប៉ុណ្ណ)

# សាធុ! សាធុ! សាធុ...

**នៅ**ទីបញ្ចប់ សៀវភៅរឿង "**ព្រះភិក្ខុពនេចរ ភាគទី ២** " បានលេចចេញជារូបរាងតាមពាក្យសន្យា...

រឿងព្រះភិក្ខុពនេចរ ភាគទី ២ នេះ មិនមានទំនាក់ទំនងទៅនឹងរឿងព្រះភិក្ខុពនេចរ របស់លោកសាស្ត្រាចារ្យ **ឱម ណាត្រី** ទេ ។ រឿងនេះ ត្រូវបានបកប្រែពីភាសាថៃមកជាខេមរភាសាដោយទឹកចិត្តព្យាយាម និងសទ្ធារបស់លោកយាយ **សុភចម ចំរើន ចារូន** (**ចារុវណ្ណា**), លោកបានប្រគល់មកឲ្យខ្ញុំព្រះករុណា ខ្ញុំបាទសរសេរចងក្រងចេញជាសៀវភៅ ដោយក្នុងនោះមានអ្នកស្រី **ធឹម អរុណី** (Aruny Smiley) ដែលមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា បានចូលរួមចំណែកក្នុងការចម្លងសៀវភៅនេះបានឆាប់រហ័សនិងចប់ជាស្ថាពរ ។

ខ្ញុំព្រះករុណា ខ្ញុំបាទសង្ឃឹមថា រឿងព្រះភិក្ខុពនេចរ ភាគទី ២ នេះនឹងមិនធ្វើឲ្យព្រះតេជព្រះគុណ អស់លោក-អ្នកអានខកបំណងឡើយ នឹងបានជាចំណែកមួយជាបញ្ញាជំនួយស្មារតី ដល់ជនានុជនគ្រប់រូប ដែលនឹងប្រឈមមុខតទល់ជាមួយសេចក្ដីភ័យខ្លាច និងតក់ស្លុតរន្ធត់ញាប់ញ័រជាមួយគ្រោះថ្នាក់ផ្សេងៗ ជាពិសេសចំពោះក្ដីមរណៈនោះឯង ។

ខ្ញុំបាទសូមលំឱនកាយ គោរពវន្ទានូវវីរភាពដ៏ឧត្ដុង្គ-ឧត្ដមរបស់លោកយាយ **ចំរើន ចារូន** ដែលលោកបានខិតខំ

ចំណាយពេលវេលា និងខិតខំបកប្រែរឿងនេះពីភាសាថៃមកជាខេមរភាសា ។

ហើយខ្ញុំព្រះករុណា សូមអរព្រះគុណជាពិសេសចំពោះព្រះតេជព្រះគុណ **ធឹង ធីម** (**ចន្ទត្ថេរ**) ព្រះគ្រូចៅអធិការវត្តឆម្មិការាម (ក្រុងប៉ុងរោអាល), ព្រះតេជព្រះគុណ **សុំ ម៉ុន ផៀម**(**សុវណ្ណត្ថេរោ**) វត្តពុទ្ធសុទ្ធារាម (ក្រុងប៉ុងរោអាល) ដែលព្រះតេជព្រះគុណ បានឆ្លៀតពិនិត្យអត្ថបទ ផ្តល់យោបល់បន្ថែមបន្ថយធ្វើឲ្យសៀវភៅនេះចប់ដោយបរិបូរណ៍ ។

សូមអរគុណចំពោះលោកបង **ម៉ិញ សាវ៉ាន** លោកបង **ហ៊ិម ឆាន់** ដែលលោកតែងតែផ្តល់នូវកម្លាំងចិត្តដល់ខ្ញុំ ព្រមទាំងការផ្ទៀងផ្ទាត់នូវអក្ខរាវិរុទ្ធ បន្ថែមបន្ថយពាក្យពេចន៍ និងកំណាព្យថ្មី ធ្វើឲ្យសៀវភៅនេះរឹងរឹតតែមានលក្ខណៈប្រសើរជាពិសេសទៅទៀត ។

ខ្ញុំព្រះករុណា ខ្ញុំបាទសូមប្រមូលនូវបុណ្យកុសលដែលបានសម្រេចដោយការរៀបចំបោះពុម្ពសៀវភៅនេះ ជូនដល់បុព្វការីជនទាំងអស់ គ្រូឧបជ្ឈាយាចារ្យ ព្រមទាំងកល្យាណមិត្តធម៌ទាំងឡាយសូមជួបប្រទះនូវធម៌ប្រសើរគឺអាយុ វណ្ណៈ សុខៈ ពលៈហើយបាននូវឧបនិស្ស័យសម្រេចនូវសម្មាទិដ្ឋិនិងសេចក្តីសុខក្នុងវដ្តៈរហូតដល់ត្រើយខាងនាយ គឺព្រះនិព្វាន ។

ក្រុងប៉ុងរោអាល,ថ្ងៃចន្ទ ទី២៤ ខែសីហា គ.ស.២០១៥

អ្នកសរសេរចម្លង

**វ៉ាត តិរក្ស**

# អារម្ភបទព្រះភិក្ខុពនេចរ ភាគ ២

**បទពាក្យ ៧**

*គ. អ. ម. ព. [១] វរវន្ទា*
*ព្រះពុទ្ធព្រះធម៌សង្ឃសាវក*
*បង្គំព្រះសម្មតិសង្ឃ*
*ជាថ្នាលស្រែបុណ្យជនប្រុសស្រី*
*គារវៈភក្ដីធម្មមិត្ត*
*រឿងព្រះភិក្ខុពនេចរ*
*ឥឡូវសម្រេចដូចចិត្តប៉ង*
*កំសាន្តអានស្ដាប់ដោយមេត្រី*
*ជូនបុណ្យកុសលបុព្វការី*
*អ្នកប្រាជ្ញបណ្ឌិតព្រឹទ្ធាចារ្យ*
*សូមអានិសន្ទានុភាព [២]*
*ទុក្ខសោកទាំងពួងរួចរំដោះ*

*ដល់ត្រៃរតនាម្លប់អមតៈ*
*បូជាសច្ចៈទ្វារទាំងបី ។*
*ដោយចិត្តស្មោះត្រង់ស្ម័គ្រភក្ដី*
*បូជាទ្វារបីថ្វាយព្រះធម៌ ។*
*ទោះនៅឆ្ងាយជិតធ្លាប់គ្រេកអរ*
*មិត្តខ្លះសាទរ រក៍ ភាគថ្មី ។*
*សូមមិត្តប្អូនបងក្សាន្តហឫទ័យ*
*ភាគ២ ភាគថ្មី ផ្គុំហត្ថា ។*
*លោករស់នៅក្ដីឬមរណា*
*ធម្មមិត្តយាយតាញាតិទាំងអស់ ។*
*ផ្ដល់ផលដោគលាភជួបធម្មរស*
*ធម្មយាននាំឆ្ពោះព្រះនិព្វាន ។៚*

ដោយឧបាសក ហ៊ិម ឆាង់

---

( ១ ) គ.អ.ម.ព. = គេហដ្ឋាន អភិរក្សមរតកព្រះពុទ្ធសាសនាខ្មែរ
( ២ ) អានិសន្ទានុភាព = អានុភាពនៃអានិសង្ស ដែលបង្ហូរផលមកឲ្យ

# សមាសភាពចូលរួម

(ពិនិត្យខ្លឹមសារ, អក្ខរាវិរុទ្ធ និងរចនាផ្សេងៗ)

០១. ព្រះតេជព្រះគុណ **ធឹម ធីម** (**ចន្ទត្ថេរ**)

ព្រះចៅអធិការវត្ត **ធម្មិការាម** (ក្រុងប៉ុនសេអាល)

០២. ព្រះតេជព្រះគុណ **សុំ ប៊ុនធឿម** (**សុវណ្ណត្ថេរោ**)

វត្ត**ពុទ្ធសុទ្ធារាម**(ក្រុងប៉ុនសេអាល - កេបិក - កាណាដា)

០៣. លោកយាយ **សុកចម ចំរើន ចារូន** (**ចារុវណ្ណា**)

០៤. ឧបាសក **ម៉ិញ សាវ៉ាន**

០៥. ឧបាសក **ហ៊ិម ឆាន់**

០៦. អ្នកស្រី **ធឹម អរុណី** (Aruny Smiley)

០៧. លោក **វ៉ាត សុគន្ធ**

០៨. លោក **វ៉ាត តារា** (ទី៧)

០៩. លោក **វ៉ាត ម៉ូលីវណ្ណា**

១០. កញ្ញា **វ៉ាត វារីយ៉ា**

# មាតិការឿង


| | | |
|---|---|---|
| ០១. | សាធុ! សាធុ! សាធុ! ............................ | III |
| ០២. | អារម្ភបទ ឧបាសក ហ៊ិម ឆាន់ .......... | V |
| ០៣. | សមាសភាពចូលរួម ............................ | VI |
| ០៤. | មាតិការឿង ...................................... | VII |
| ០៥. | ពាក្យប្រារព្ធ (ដូនជី ចរយូន) .................... | IX |
| ០៦. | ធម្មកថា ដោយព្រះ ធម្មឃោស .......... | X |
| ០៧. | សំនាំដើម ...................................... | ១៣ |
| ០៨. | លេខ ២ ៤ ខ្ទង់ ...................................... | ១៧ |
| ០៩. | ព្រះពិត ៣ អង្គ ............................ | ២៧ |
| ១០. | សាសនា ជាថ្នាំកែរោគទុក្ខ .................... | ៣៩ |
| ១១. | ចិត្តានុភាព ...................................... | ៥១ |
| ១២. | ឆ្ពោះទៅកាន់ដែនដីទិព្វ .................... | ៦៥ |
| ១៣. | លោភានុភាព ...................................... | ៧៩ |
| ១៤. | ទន្លេគោក ...................................... | ៩៣ |
| ១៥. | ម្ចាស់ទ្រព្យពិតប្រាកដ ............................ | ១០៧ |
| ១៦. | ទុកចិត្តមនុស្ស ប្រទូស្តចិត្តយើង .......... | ១២១ |
| ១៧. | សេចក្តីល្អដែលបានពិសោធរួចហើយ ...... | ១៣៥ |
| ១៨. | ឥទ្ធិពលនៃក្រសែស្លូវិលោក .................... | ១៤៧ |

១៩. ជិនន់តាមគ្រប់គ្រងផ្ទៃលោក ..................... ១៦១
២០. ជួបប្រទះនឹងមច្ចុរាជ ................................ ១៧១
២១. យកឈ្នះអំពើអាក្រក់ ដោយអំពើល្អ ........ ១៨៥
២២. កុំឲ្យអភ័យទោសដល់ខ្លួនឯង ........... ១៩៩
២៣. កល្យាណមិត្ត ........................................ ២០៩
២៤. ពុទ្ធជិន និងបុគ្គលវិសេស ....................... ២២១
២៥. មនុស្ស គឺបិសាចលបញ្ឆោត...................... ២៣៥
២៦. មេត្តា ព្រហ្មវិហារ ................................ ២៤៩
២៧. ពុទ្ធបរិស័ទមានសទ្ធា ................................ ២៦៣
២៨. ផ្សេងៗពីគេហដ្ឋាន ................................. ២៧០




# ពាក្យប្រារព្ធ

(ដូនជី **ចំរើន ចារូន**)

សៀវភៅនេះ ខ្ញុំបានអានចប់ច្រើនដងហើយ ឃើញថាមានន័យ មានប្រយោជន៍ល្អណាស់ ទើបព្យាយាមបកប្រែពីភាសាថៃមកជាខេមរភាសា ដោយមានសំណូមពរអំពីលោក **ជី ចំរុង** ផង កាលគាត់នៅមានជីវិតនៅឡើយ ហើយគាត់បានប្រគល់សៀវភៅនេះមកឲ្យខ្ញុំ ដោយផ្ញើសៀវភៅនេះតាមប៉ៃ **ស៊ុន គុយអេង** យកពីប្រទេសកាណាដាមកស្រុកបារាំង ។ បានបកប្រែចប់ហើយ ក៏ប្រគល់សំណៅនេះទៅឲ្យក្មួយ **ម៉ាត តិរត្ន** នៅទីក្រុងម៉ុងរេអាល - កេបិក - កាណាដា សរសេរចម្លងចងក្រងជាសៀវភៅឡើងវិញ ។

ហេតុនេះបើមានពាក្យ ឃ្លាណាមិនសមរម្យ សូមលោកអ្នក-អានទាំងឡាយ មេត្តាអភ័យទោស និងសូមជួយកែឲ្យទានផង សូមអរគុណទុកជាមុន ។

ប្រែចប់នៅក្រុងម៉ុងរេអាល, ខែតុលា គ.ស.២០១៣
ដោយដូនជី **ចំរើន ចារូន** គ្រួសារ **សុភចម**
ក្នុងបាលី **ចារុវណ្ណា**

# ធម្មកថា

ដោយ **ធម្មឃោស**

ជារឿងនិទានដែលបង្កប់នូវព្រះធម៌ ដ៏មានឱជារស យ៉ាងសំខាន់ទ្រាញ់ ។ មានពេលមួយ កាលអាត្មាទៅចាំវស្សា នៅវត្តនាងជើងភ្នំសុថេប ស្រុកឆៀងម៉ៃ មានញោម **ចំណាន** បានបវារណាសូមធ្វើជាញោមឧបដ្ឋាក[១] ក្នុងរយៈពេលមួយវស្សានេះ ដោយគាត់មានសេចក្តីជ្រះថ្លាក្នុងជីវិតរបស់អាត្មានេះ ហើយគាត់បានប្រគេនយោបល់ថា បើសិនជាអាត្មាបានសរសេររឿងរបស់អាត្មា ឲ្យជនទូទៅបានស្តាប់ នឹងអាចបានជាប្រយោជន៍ច្រើន ទើបគាត់បានមកអារាធនា គឺសូមនិមន្តឲ្យអាត្មាសរសេរអំពីជីវិតរបស់ខ្លួនជាមួយឃ្លាៗ ដើម្បីនឹងនាំយកទៅចុះក្នុងសារព័ត៌មាន «**ពុទ្ធជន**» របស់ពុទ្ធនិយមឆៀងម៉ៃ ។

អាត្មាបានឆ្លើយទៅញោម ដែលជាអ្នកមានចេតនាល្អនេះវិញថា ៖

- អាត្មាមិនមានថ្វីដៃក្នុងការសរសេរ ឬតែងរឿងដែលគេហៅថាអ្នកនិពន្ធនោះទេ បើឲ្យអាត្មាសរសេរ អាចសរសេរបាន ប៉ុន្តែសរសេរបែបនិពន្ធជារឿងធម្មតាប៉ុណ្ណោះ ជាពិសេសនោះ ជីវិតរបស់អាត្មា ជាជីវិតធម្មតាៗ មិនមាន

---

(១) អ្នកទំនុកបម្រុង, អ្នកផ្គត់ផ្គង់, អ្នកផ្គង់ចតុប្បច្ច័យឬផ្គង់ចង្ហាន់ ញោមឧបដ្ឋាក ឧបាសកឬទាយកជាអ្នកផ្គត់ផ្គង់បព្វជិត ។

ហេតុការណ៍អ្វីដែលគួរឲ្យភ្ញាក់ផ្អើលអ្វីផង ក្រែងតែងទៅជារឿងសោះកក្រោះ មិនជាទីពេញចិត្តរបស់អ្នកអាន ។

ញោមឆ្លើយថា៖

- មិនអីទេទាន សូមទានសាកល្បងសរសេរមើល !

នៅទីបំផុត អាត្មាក៏ចាប់ផ្ដើមសាកល្បងសរសេរមែន ដូច្នេះនៅពេលទំនេរអំពីការបដិបត្តិធម៌ ក៏ចាប់ផ្ដើមយកក្រដាសខ្មៅដៃ មកសរសេរមួយថ្ងៃបន្តិចៗ លុះគ្រាបានសម្រេច ១ វគ្គក្នុង ១ ខែ រួចហើយក៏បាននាំយកអត្ថបទនេះទៅចុះផ្សាយក្នុងសារព័ត៌មាន «**ពុទ្ធជន**» ។

ក្រោយពេលចុះផ្សាយបានច្រើនវគ្គ ក៏ឃើញថាមានមនុស្សគេចូលចិត្តខ្លះៗ ដោយសង្កេតឃើញថា មានមនុស្សមួយចំនួនគេបានសរសេរសំបុត្រមកសរសើរ ។ មានអ្នកខ្លះសរសើរថា អ្នកដែលសរសេរនេះជាអ្នកទាន់សម័យ អាចអធិប្បាយធម៌អាថ៌របស់ព្រះសម្មាសម្ពុទ្ធ បានច្បាស់លាស់យល់បានងាយគ្រប់ជ្រុងជ្រោយ មានអ្នកខ្លះទៀតសុខចិត្តធ្វើដំណើរមកសាកសួរផ្ទាល់ នៅពេលយល់ឃើញថារឿងរបស់ខ្លួនមានប្រយោជន៍ ហើយអាត្មាក៏តាំងចិត្តសរសេរជាបន្តបន្ទាប់ ។ ក៏ប៉ុន្តែជាការសរសេរមិនមានសាច់រឿង ឬសរសេរមុនរឿងកើត គឺសរសេរនៅពេលមានការកើតឡើង. . . ចំណុចដែលសំខាន់ គឺដើម្បីផ្សព្វផ្សាយព្រះធម៌ឲ្យ

អស់លោក-អ្នកអានកើតសម្មាទិដ្ឋិក្នុងព្រះពុទ្ធសាសនា មិនមានប្រាថ្នាឲ្យកើតសេចក្ដីសប្បាយរីករាយ អំពីសាច់រឿងដូចជាប្រលោមលោកនោះទេ ។

រឿងនេះមិនទាន់ចប់ ហើយក៏មិនអាចនឹងចប់បានដោយងាយៗនោះទេ លុះត្រាតែជីវិតរបស់អាត្មាចប់ ។ ដោយសារជីវិតរបស់អាត្មាប្រៀបដូចជាការដើរផ្លូវទៅក្នុងព្រៃ ដោយមិនមានទីដៅអ្វីមុន បានជួបប្រទះរបស់អ្វីផ្សេងៗនៅពេលដើរទៅតាមផ្លូវ ក៏នាំយកមកអធិប្បាយប្រាយប្រាប់ចែកគ្នាស្ដាប់ ។

ប្រសិនជាមានរឿងល្អផ្សេងៗ កើតឡើងអំពីការនិទានរឿងនេះ អាត្មាភាព សូមឧទ្ទិសបុណ្យកុសលជូនដល់ញោមប្រុសដែលបានចែកឋានទៅហើយ ប្រសិនជាលោកបានទៅចាប់កំណើតក្នុងទុគ្គតិភព សូមឲ្យលោកបានរួចចាកទុក្ខនោះដោយឆាប់ ប្រសិនជាលោកបានទៅចាប់កំណើតក្នុងសុគតិភពវិញ សូមឲ្យលោកបានសោយទិព្វសុខក្នុងសុគតិភពនោះឲ្យបានយឺនយូរតទៀងទៅ ។

ដោយ **ធម្មឃោស**

# លំនាំដើម...

ក្នុងឋានៈជាលោកុត្តរ ដែលជាអ្នកបានលះបង់នូវផ្លូវលោកហើយ អាត្មាបានស្ពាយបាត្រនិងឆត្រ ដើរទៅលុះគ្រាចប់ដែនដីថៃដោយសេរី ដូចជាសត្វតូចដែលហើរនៅក្នុងអាកាស ឬដូចមច្ឆាជាតិដែលហែលនៅក្នុងសមុទ្រសាគរ មានផ្ទះតូច ស្រុកធំរាប់មិនអស់ អាត្មាបានឃើញគ្រប់សព្វអស់ហើយ ប៉ុន្តែសំរាប់អាត្មាវិញ មិនឃើញមានទីណាដែលគួរឲ្យរីករាយស្មើនឹងព្រៃភ្នំ ដែលនៅឆ្ងាយពីមនុស្សនិងពន្លឺអារ្យធម៌ មានម្លប់ត្រជាក់, ជ្រលងភ្នំ និងរុក្ខជាតិក្នុងព្រៃ គួរឲ្យចង់រស់នៅ មិនចាញ់ផ្ទះនឹធំស្កឹមស្កៃ សំឡេងទឹកហូរធ្លាក់មកតាមចន្លោះភ្នំ, សំឡេងរៃយំ ស្តាប់ហើយពីរោះរណ្តំ មិនចាញ់សំឡេងភ្លេងប្រគំដោយតន្ត្រីនៃអ្នកស្រុក, ពន្លឺនៃផ្កាយនៅលើមេឃ មើលហើយត្រជាក់ភ្នែកគួរឲ្យសរសើរ មិនចាញ់ភ្លើងពណ៌ដែលបំភ្លឺក្នុងទីក្រុង, សត្វចតុប្បាទ បក្សាបក្សីក្នុងព្រៃ ប្រសិនយើងជួបប្រទះវាដោយចិត្តមេត្តាធម៌ដ៏បរិសុទ្ធ ក៏ដូចជាយើងបានជួបមនុស្សដែលចំរើនទៅដោយវិញ្ញូនធម៌ និងអរិយធម៌ដែរ ។

អាត្មាដើរទៅដោយចិត្តរីករាយ ដូចជាកូនសត្វតូចទើបតែបានរួចពីទ្រុង ដោយមានខ្លួនស្រាលដូចសំឡី ហើរទៅក្នុងអាកាសវេហាពីព្រោះរបស់ដែលធ្ងន់ផ្សេងៗ អាត្មា

*បានដាក់ចុះអស់ហើយ ទ្រព្យសម្បត្តិដែលអាត្មាត្រូវមើលថែរក្សានោះគឺបរិក្ខាររបស់ភិក្ខុ បុគ្គលដែលរស់នៅត្រូវចិញ្ចឹមមើលថែនោះគឺខន្ធ ៥ របស់ខ្លួនឯងការងារដែលត្រូវបំពេញនោះគឺ រំលត់នូវភ្លើងកិលេស ដែលពិភពលោកទាំងមូលជាផ្ទះរបស់អាត្មា ផែនដីជាកំរាល ព្រៃភ្នំជាជញ្ជាំង មេឃជាដំបូល ផ្កាយជាភ្លើងបំភ្លឺ អាត្មាដើរទៅមុខដោយមិនបានគិតជាមុនដល់ខាងមុខខាងក្រោយនោះទេ ។ យប់នៅភូមិណាដាក់មុងរៀបចំសំរាកនៅទីនោះ ពេលព្រឹកឡើងក៏ដើរចេញទៅបិណ្ឌបាតតាមភូមិអ្នកស្រុក ពេលបានអាហារល្មមហើយក៏ត្រឡប់មកវិញរៀបចំឆាន់ ប្រសិនជាមានញាតិញោមណាមកនិមន្តទៅធ្វើបុណ្យ ក៏ទៅទេសនាឲ្យគេស្តាប់ ឲ្យបានយល់អំពីការបដិបត្តិធម៌ បើមានញាតិញោមមកនិមន្តទៅតាមផ្ទះ មិនមែនជាក្នុងវត្តទេនោះ ក៏នៅយូរដើម្បីអនុគ្រោះដល់គេ ប៉ុន្តែមិនដែលនៅហួសពីប្រាំពីរថ្ងៃនោះទេ ។ ដល់ពេលគ្រប់កំណត់ហើយ ក៏ស្ពាយបាត្រលីក្រុត[១] ដើរតទៅទៀត លុះគ្រាតែដល់រដូវភ្លៀង នៅពេលមានភ្លៀងធ្លាក់ខ្លាំងតាមផ្លូវពិបាកដើរ ទីដីពោរពេញទៅដោយ សត្វល្អិតមានស្រមោច សន្ធារជាដើមហើយចំណែកជំងឺគ្រុនចាញ់ក៏ចាប់ផ្តើមរាតត្បាត ទើបឈប់ហើយនៅចាំវស្សាក្នុងទីកន្លែងណាមួយ ដែលសមរម្យទៅតាមអ្នកបដិបត្តិធម៌ ។*

---

(១) គឺជាឆ័ត្រម៉្យាង ដែលមានស្បៃទំលាក់មកដូចជាមុង សំរាប់លោកធុតង្គប្រើ ។

ក្នុងរយៈពេលដ៏វែងឆ្ងាយ ដែលបានដើរធុតង្គមក អាត្មាបានជួបប្រទះឃើញបុគ្គល ទីកន្លែង និងហេតុការណ៍ជាច្រើនហួសគណនា មានទាំងជាទីរីករាយពេញចិត្ត ទាំងមិនជាទីពេញចិត្ត ប្រសិនជានាំមកបរិយាយឲ្យអស់ នឹងមិនបានជាសៀវភៅតូចនេះទេ ប៉ុន្តែគឺជាទូដាក់សៀវភៅដ៏ធំនោះតែម្ដង គឺដោយការចាំក៏ជាអនិច្ចំ... ព្រមទាំងមិនសូវជាបានយកចិត្តទុកដាក់ និងចងចាំយកមកសរសេររឿងរ៉ាវនោះផង ជាពិសេសភ្លេចខ្លះ នៅចាំខ្លះបន្តិចបន្តួចដែលមានរឿងណាសំខាន់ៗ ។ ប្រសិនជាមានពាក្យវគ្គឃ្លាងឃ្លាណា ដែលស្ដាប់ទៅហើយមិនសមត្រចៀក ក៏សូមអភ័យទោសផង ពីព្រោះអាត្មាមិនមែនជាអ្នកសរសេរនិពន្ធរឿងទេ ហេតុដូចនេះសូមអស់លោក-អ្នក ញាតិញោមទាំងអស់អញ្ជើញផ្ទៀងស្ដាប់ដូចតទៅនេះ ...

# ស្ដាប់ពិចារណា

**ពាក្យប្រាំពីរ**

***ស្ដាប់ច្រើនអានច្រើនកើនស្មារតី ស្ដាប់ចាប់អត្ថន័យពិចារណា***
***សង្កេតពិនិត្យតាមហេតុការណ៍ បង្កើតបញ្ញាការអនុវត្តន៍ ។***
***កុំអានបានស្ដាប់ឆាប់ជឿងាយ ភ្លើតភ្លើនរីករាយក្លាយភ្លាំងភ្លាត់***
***មិនយល់អត្ថន័យឲ្យប្រាកដ ស្ដាប់អានបានអត់ខាតវេលា ៕***

ដោយឧបាសក ម៉ិញ សារ៉ាង




**ក្លស់ ឬ ក្រុត** ៖ *គឺជាឆ័ត្រម៉្យាង ដែលមានស្បៃទំលាក់មក ដូចជាមុង សំរាប់លោកធុតង្គប្រើ ។*

# ១. លេខ ៩ ខ្ទង់

ពេលមួយ អាត្មាបានដើរធុតង្គឆ្លាក់រហូតទៅដល់ឆៀងម៉ៃ ហើយបានឈប់សំរាកដើម្បីបំពេញព្យាយាម នៅទីវត្តមួយ ដែលស្ថិតនៅជើងភ្នំសុថេប ក្នុងបរិវេណវត្ត នោះត្រជាក់ មានម្លប់ត្រឈើងត្រឈៃដោយរុក្ខជាតិផ្សេងៗច្រើនប្រភេទ ។ នៅឆ្ងាយពីផ្ទះភូមិអ្នកស្រុក បរិយាកាសស្ងប់ស្ងាត់ល្មមគួរដល់ការបដិបត្តិធម៌ នៅក្នុងវត្តនេះមានព្រះសង្ឃគង់នៅតិចទេ ព្រះសង្ឃគ្រប់រូបមានការបដិបត្តិល្អគួរឲ្យជ្រះថ្លា ហើយដំណើរនៃការបដិបត្តិទៅតាមផ្លូវនៃសេចក្តីបរិសុទ្ធ លះបង់ដូចអាត្មាដែរ ។ ជាវត្តដែលគួរឲ្យរីករាយជាទីបំផុតដែលអាត្មាបានមកជួប នៅចំកណ្តាលវត្តមានអាងទឹកមួយយ៉ាងធំ មានទឹកថ្លាត្រជាក់ ដែលអាចទុកទឹកបានរហូតមួយឆ្នាំ ។ នៅជុំវិញមានដើមឈើពោរពេញទៅដោយសន្លឹកមើលទៅស្អាតដូចជាអនោតត្តស្រះ ដែលស្ថិតនៅកណ្តាលព្រៃហិមពាន្ត ។ រាល់ៗពេលថ្ងៃរសៀលអាត្មា តែងចូលចិត្តទៅអង្គុយលេងនៅលើគ្រែធ្វើអំពីឫស្សីនៅក្រោមដើមឈើជិតមាត់ស្រះ មើលទៅរលកទឹក ដែលរត់មកប៉ះនឹងមាត់ច្រាំងហើយបាត់ទៅ តែងគិតប្រៀបធៀបទៅនឹងជីវិតរបស់ខ្លួន ទៅតាមវិធីដែលលោកគ្រូអាចារ្យបានបង្រៀនមក គឺជីវិតរបស់យើងប្រៀបបានដូចជារលកទឹកឯការលវេលាដូចជាខ្យល់ដែលបក់ដេញនូវរលកឲ្យចូលមក

ប៉ះនឹងមាត់ច្រាំង គឺសេចក្តីស្លាប់ . . .

នាចុងសប្តាហ៍ថ្ងៃសៅរ៍និងថ្ងៃអាទិត្យ តែងតែមានគំលោះ ក្រមុំ អ្នកស្រុក ចូលចិត្តនាំគ្នាមកដើរលេងកំសាន្តក្នុងវិត្តនេះ ៗ មានក្រុមខ្លះហ៊ានចូលមកសន្ទនាជាមួយអាត្មានៅពេលឃើញអាត្មាអង្គុយនៅលើគ្រែមាត់ស្រះប៉ុន្តែដែលគេប្រាថ្នាចូលមកសួរសំណេះសំណាលនោះ អំពីធម៌អាថ៌នោះមានតិចទេ ភាគច្រើនគឺគេមានបំណងមកសូមរបស់ស័ក្តិសិទ្ធ និងលេខឆ្នោត ៗ

ថ្ងៃមួយមានបុរសម្នាក់បានចូលមករកអាត្មា ៗ នៅពេលគ្រាបច្ច័យបន្តិចរួចហើយ គេក៏ចាប់ផ្តើមសុំគន្លុយលេខ

- ញោមចង់បានគន្លុយ ប៉ុន្មានលេខ? អាត្មាសួរគេ
- ប៉ុន្មានលេខក៏បានដែរ ស្រេចលើតែព្រះអង្គមេត្តា, គេឆ្លើយដោយទឹកមុខញញឹមខ្ជិប សំដែងនូវការពេញចិត្ត
- ពីរលេខក៏បាន ឬបីលេខក៏បាន ...
- ញោមធ្លាប់ទិញមកហើយឬនៅ? ហើយដែលត្រូវឬទេ? អាត្មាសួរគេ
- ខ្ញុំករុណាធ្លាប់លេងមកច្រើនឆ្នាំមកហើយ ប៉ុន្តែមិនដែលត្រូវសោះ បើព្រះអង្គមេត្តា សូមទានឲ្យលេខច្បាស់ៗតែម្តងមក ខ្ញុំនឹងចុះដើមទុនលេងលើកចុងក្រោយនេះហើយនឹងឈប់លេងទៀតហើយ...
- អាត្មានឹងឲ្យលេខដែលប្រាកដបំផុត ហើយដល់ទៅ៤លេខផង

បុរសនោះឱនក្បាលគ្រប់អាត្មាដោយសេចក្ដីរីករាយ ហើយសូមអរគុណ ( ឃើញយ៉ាងជាក់ច្បាស់ ) ហើយពោលពាក្យចេញមកដោយសំឡេងស្រួលៗថា៖

- សូមមេត្តាផងចុះលោកម្ចាស់អើយ ខ្ញុំកូណានឹងមិនភ្លេចគុណព្រះអង្គអស់មួយជីវិត!

អាត្មាក៏ចាប់និយាយតទៅទៀតថា៖

- ជានិបូង ញោមត្រូវធ្វើនូវខសន្យាជាមួយអាត្មាជាមុនសិនថា នឹងធ្វើតាមពាក្យរបស់អាត្មាគ្រប់យ៉ាង និងមិនមានការប្រកែកតវ៉ា ឬជំទាស់នូវពាក្យរបស់អាត្មា ប្រសិនជាញោមសន្យាបាន អាត្មាហ៊ានធានាអះអាងថាញោមនឹងទៅជាអ្នកមានពិតប្រាកដ

- ខ្ញុំព្រះករុណារីករាយ និងធ្វើតាមពាក្យសន្យារបស់ព្រះអង្គគ្រប់យ៉ាង, គេបានឲ្យពាក្យសន្យាយ៉ាងពិតប្រាកដ

- បើដូច្នេះ អាត្មានឹងប្រាប់គន្លឹះនេះលេខទាំង « ៤ » លេខនេះមិនមែនជាលេខរបស់អាត្មាទេ គឺជាលេខរបស់ព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គបានប្រទានទុកមក មានមនុស្សជាច្រើនដែលជឿនិងគោរពតាមព្រះអង្គ ហើយបានជួបប្រសព្វនូវសេចក្ដីរីកចំរើន ទៅជាសេដ្ឋីរហូត ២៥០១ ឆ្នាំមកហើយ ចូរតាំងចិត្តចាំឲ្យល្អណា៎ អាត្មានឹងប្រាប់គន្លឹះនេះហើយ...

- លេខទី ១ មានឈ្មោះថា **ឧដ្ឋានសម្បទា** ប្រែថាដល់ព្រមដោយការខ្នះខ្នែងព្យាយាមប្រឹងប្រែង ចាត់ចែងការងារ

ដែលខ្លួនត្រូវប្រកបនោះៗ ដែលជាការប្រាសចាកទោស ;

- លេខទី ២ មានឈ្មោះថា **អារក្ខសម្បទា** ប្រែថាដល់ព្រមដោយការថែរក្សាទ្រព្យដែលរកបានមក មិនឲ្យវិនាសទៅដោយហេតុផ្សេងៗ មានភ្លើងឆេះ ចោរលួច និង លេងល្បែងភ្នាល់ជាដើម ;

- លេខទី ៣ មានឈ្មោះថា **កល្យាណមិត្តតា** ប្រែថាដល់ព្រមដោយការសេពគប់មិត្រល្អ គឺជាមិត្រដែលមានចិត្តល្អ ដែលតែងនាំឲ្យរកប្រយោជន៍ក្នុងបច្ចុប្បន្ន គឺជាមនុស្សត្រង់មិនចេះបោកប្រាស់ ;

- លេខទី ៤ មានឈ្មោះថា **សមជីវិតា** ប្រែថាចិញ្ចឹមជីវិតស្មើ គឺរកទ្រព្យបានមកហើយចាយវាយតាមកម្លាំងខ្លួនដែលបានមក មិនឲ្យខ្ជះខ្ជាយហួស ។

សូមឲ្យញោមចងចាំ « ៤ » លេខនេះទុក ហើយនាំយកទៅបដិបត្តិតាម ប្រសិនជាញោមមិនក្លាយទៅជាអ្នកមានទេក្នុងរវាង ៥ ឆ្នាំសូមត្រឡប់មកតវ៉ាជាមួយអាត្មាវិញ ។

បុរសនោះ សំឡឹងមើលមកអាត្មាដោយក្រសែភ្នែកឆ្ងល់ស្លុកយ៉ាងយូរ ហើយទើបឱនចុះគ្រាបថ្វាយបង្គំអាត្មាតែម្តង រួចក៏ក្រោកចេញទៅ ដើរចេញដោយមិននិយាយអ្វីសោះ ប្រហែលជាគេខុសបំណងយ៉ាងខ្លាំងហើយមើលទៅនៅពេលគេដើរចេញបាត់ទៅក្នុងព្រៃហើយ អាត្មានឹកអាណិតដល់គេដែរ ប៉ុន្តែមិនអាចជួយគេបាន អាត្មាបានយល់ថា គឺបានធ្វើនូវនាទីរបស់ភិក្ខុយ៉ាងត្រឹមត្រូវហើយពីព្រោះព្រះសង្ឃ មិនមាននាទីដែលនឹងទៅលើកតម្កើងនូវ

ការលេងល្បែងភ្នាល់នោះទេ គឺមានតែការដឹកនាំអ្នកដែលវង្វេងវង្វាន់ឲ្យចូលមករកផ្លូវត្រូវតាមព្រះពុទ្ធសាសនា សូម្បីលេខ « ៤ » ខ្ញុំដែលអាត្មាបានប្រាប់គេនោះ ក៏មិនមែនជារឿងអាក្រក់ឥតប្រយោជន៍អ្វីដែរ ប្រសិនជាគេបដិបត្តិតាមបានពិតប្រាកដមែននោះ គេនឹងទៅជាអ្នកមានពិត គ្រាន់បើជាងទៅផ្សងសំណាង ដែលមិនពិតប្រាកដខាងផ្លូវល្បែងនោះ ។

ក្រោយពីហេតុការណ៍ ដែលកើតឡើងបន្តិចបន្តួចនោះមក ប្រមាណជា ៤ ឬ ៥ ថ្ងៃក្រោយមក នៅពេលអាត្មាកំពុងអង្គុយពិចារណានូវធម៌ខណៈមួយ នៅខាងអាងទឹកនោះ ស្រាប់តែឃើញស្រីនិងប្រុសមួយគូដើរតំរង់មករកអាត្មា ។ នៅពេលគេជិតមកដល់ អាត្មានូវចាំបានថាគេ គឺជាបុរសដែលមកសុំកន្ទុយលេខកាលពី ៤ ឬ ៥ ថ្ងៃមុននោះឯង ។ នឹកប្លែកក្នុងចិត្តថា តើដូចម្តេចបានជាគេត្រឡប់មកវិញទៀត រំពេចនោះអាត្មាបានគិតភ្លាមថា ប្រហែលជាគេមកធ្វើបាបអាត្មាហើយមើលទៅ ! ប៉ុន្តែមិនបានភ័យអ្វីទេ ពីព្រោះបានជឿជាក់ក្នុងព្រះធម៌ថា មនុស្សយើងបើមិនមែនគូកម្មនឹងគ្នាអំពីជាតិមុននោះទេ មិនអាចធ្វើបាបគ្នាបានដោយងាយៗនោះទេ ថាបើគេមកធ្វើបាបប្រហារជីវិតអាត្មាពិតមែននោះ ក៏ជាការល្អម៉្យាងដែរ ដោយគូទាំងពីរខាងបានសងកម្មនឹងគ្នាឲ្យរួចហើយទៅ គិតដូច្នេះហើយក៏អង្គុយរង់ចាំគេដោយចិត្តស្ងប់ស្ងៀម ។

អ្នកទាំងពីរមកអង្គុយខាងមុខអាត្មា ក្រាបបង្គំយ៉ាង

ឱ្យនំទាន ៗ បុរសជាប្តីបាននិយាយថា៖

- ព្រះអង្គ! ខ្ញុំម្ចាស់នាំភរិយា មកថ្វាយបង្គំសូមអរព្រះគុណ

អាត្មាសួរគេវិញដោយឆ្ងល់៖

- អរគុណអាត្មារឿងអ្វីដែរញោម?

- រឿងដែលព្រះតេជព្រះគុណម្ចាស់បានឱ្យគន្លុយលេខទៅប្តីរបស់ខ្ញុំព្រះករុណានោះអីទាន, ភរិយារបស់គេឆ្លើយ, កាលពីថ្ងៃនោះ នៅពេលគាត់បានលេខពីព្រះអង្គភ្លាម បងគាត់ក៏ទៅទិញលេខ ២, ៣, ៤ គាត់ប្រាកដក្នុងចិត្ត មានប៉ុន្មានគាត់ទិញទាំងអស់ ហើយក៏ត្រូវបានមួយសែន ធ្វើឱ្យមេឌួលអស់ពីខ្លួនតែម្តង

នៅពេលឮរឿងនេះ ដោយមិនបានគិតមកសោះអាត្មានឹកឆ្ងល់ក្នុងចិត្ត ទាំងចង់អស់សំណើច ទាំងមិនសប្បាយចិត្ត នឹកឆ្ងល់ដល់ហេតុការណ៍ដែលមិនគួរឱ្យជឿគិតដល់ការមិនទៀងរបស់មនុស្ស រឿងសំណាង វាសនាហើយ មិនសប្បាយចិត្តដែលហេតុការណ៍នេះបានកើតឡើង ដោយមិនបានតាំងចិត្តរបស់ខ្លួន អ្នកទាំងពីរប្រហែលជាដើរប្រាប់គេឯងថា មាន បាន នេះដោយសារអាត្មាហើយគេនឹងនាំគ្នាមកសុំ អាត្មាក៏ទៅជាលោកសង្ឃឱ្យគន្លុយលេខ ៗ ប្រសិនជាដូច្នេះមែន តើអាត្មារកពេលវេលាឯណានឹងបដិបត្តិធម៌នោះ ដើម្បីកំចាត់បង់នូវ ភ្លើងទុក្ខភ្លើងកិលេស អាត្មាគិតថាគួរតែរត់គេចចេញទៅនៅវត្តណាផ្សេង តែដោយសេចក្តីសោកស្តាយ ពីព្រោះអាត្មាបួល

ចិត្តវិត្តនេះណាស់ គឺកំពុងតាំងចិត្តប្រតិបត្តិធម៌បានចំរើនទៅមុខ ៗ ចង់នៅឲ្យបានយូរ ៗ

- តើញោមមាននិយាយប្រាប់រឿងនេះ ទៅដល់អ្នកណាខ្លះហើយឬនៅ? អាត្មាសួរ

- ព្រះករុណា នៅទេ! ស្វាមីឆ្លើយ, ដែលធ្វើឲ្យអាត្មាបានធូរស្រាលចិត្តខ្លះ

- ញោមអាចជួយអាត្មាអ្វីប៉ុន្មានបានឬទេ ?

- ករុណាបានទាន , គេឆ្លើយយ៉ាងច្បាស់, សូមនិមន្តប្រាប់មកចុះ ខ្ញុំករុណាពេញចិត្តនឹងជួយព្រះអង្គគ្រប់យ៉ាងដារតារសងគុណ

- សូមឲ្យញោមទុករឿងនេះ ជារឿងអាថ៌កំបាំងសូមកុំប្រាប់អ្នកណាដាច់ខាត នេះជា ១ ទីមួយ, ១ មួយទៀតសូមឲ្យញោមឈប់លេងកន្ទុយលេខនេះទៀតទៅ អាត្មាសូមតែពីរយ៉ាងនេះទេ តើញោមអាចទទួលបាន ថាអាចធ្វើតាមអាត្មាសំណូមពរបានឬទេ ?

- ខ្ញុំករុណាសូមទទួលថា នឹងបដិបត្តិតាមពាក្យទូន្មានរបស់ព្រះករុណាម្ចាស់បានគ្រប់យ៉ាង ពីព្រោះខ្ញុំករុណាបានតាំងចិត្តរួចជាស្រេចមកហើយថា នឹងនាំយកប្រាក់ចំនួននេះទៅទិញដីមួយកន្លែង ហើយដាំដើមមៀនបាន ១០០ ដើម ឬ ២០០ ដើម ចំណែកដែលនៅសល់ ខ្ញុំករុណានឹងយកទៅបើកហាងលក់របស់បន្តិចបន្តួច ល្មមនឹងចិញ្ចឹមជីវិតសិនទៅ នៅពេលជាមួយគ្នានេះ ខំព្យាយាមសន្សំ

ដើម្បីឲ្យបានដើមទុនច្រើនឡើងហើយ ទើបគិតពង្រីកកិច្ចការនោះនៅពេលក្រោយ

- នេះជាការគិតដ៏ល្អណាស់ ! អាត្មានិយាយដោយសេចក្តីពេញចិត្ត, សូមឲ្យញោមតាំងចិត្តប្រកបកិច្ចការតាមគោលលេខ « ៤ » ខ្ទង់ ដែលអាត្មាបានប្រាប់ហើយ សូមឲ្យចំរើនសុខក្នុងលោកិយវិស័យទៅចុះ

ទាំងពីរនាក់ប្តីប្រពន្ធលើកដៃសំពះ ហើយពោលថា ៖

- សាធុ ! សាធុ ! សាធុ ! ព្រមគ្នា, ពេលរួចហើយភរិយា ក៏លើកកញ្ចប់ក្រដាសមួយចេញមកអំពីតាបូបយួរហើយពោលថា ៖

- ដើម្បីជាការសងព្រះគុណ យើងខ្ញុំបានសំរេចគ្នាថាសូមប្រគេនបច្ច័យដល់ព្រះអង្គ មានចំនួន ១០០០ បាត សូមព្រះអង្គមេត្តាទទួលយកផងចុះ, ថាហើយគេក៏លើកយកកញ្ចប់នោះហុចមកអាត្មា

- ញោមដាក់នៅលើដីនេះសិនចុះ អាត្មាភាពជាសង្ឃមិនអាចទទួលប្រាក់នេះបានទេ ហើយអាត្មាក៏គ្មានការចាំបាច់ប្រើប្រាស់នូវមាសប្រាក់នោះដែរ អាត្មានៅម្នាក់ឯងក្នុងលោក អាហារមួយថ្ងៃមួយពេល ដើម្បីនឹងការពារមិនឲ្យស្លាប់ ចីវរបីផ្ទាំងសំរាប់ការពារក្តៅត្រជាក់គ្រប់គ្រាន់ហើយសំរាប់អាត្មា, តែបើញោមមានសេចក្តីប្រាថ្នាចង់ធ្វើបុណ្យដោយប្រាក់ចំនួននេះ ចូរនាំទៅចូលរួមមូលនិធិក្នុងវិត្តនេះ

ចុះ ប្រាក់របស់ញោម នឹងកើតជាប្រយោជន៍ក្នុងព្រះពុទ្ធសាសនាយ៉ាងច្រើន ហើយបានឃូរអង្វែង ញោមនឹងបានបុណ្យច្រើនជាងយកមកឲ្យអាត្មា

- ខ្ញុំករុណានឹងធ្វើតាមពាក្យពន្យល់របស់ព្រះអង្គ!, គេទាំងពីរនាក់នោះ ពោលដោយសេចក្ដីគោរព

នេះជាហេតុការណ៍លើកទីមួយ នៅក្នុងជីវិតរបស់អាត្មា...

# ឈ្នះចិត្តឯង

## ពាក្យប្រាំពីរ

**បើឈ្នះល្បែងភ្នាល់ផងទាំងឡាយ ត្រេកអរសប្បាយបានមួយគ្រា**
**ព្រោះនាំឲ្យកើតពៀរវេរា ពេលស៊ីយដល់គ្រាចាញ់វិញបាន។**
**បើឈ្នះកិលេសចិត្តខ្លួនឯង ប្រាកដជាក់ស្ដែងបានស្ងប់ក្សាន្ត**
**គឺជាជម្នះដ៏ថ្កើនថ្កាន ឥតព្រួយរំខានពីចាញ់វិញ ។**

ដោយឧបាសក ម៉ិញ សារ៉ាង

# ព្យាបាលរោគចិត្ត

**ពាក្យប្រាំពីរ**

*សត្វលោកមានរោគគឺកិលេស　　បណ្ដាញចាក់ស្រែះចិត្តយប់ថ្ងៃ*
*តណ្ហាដឹកមុខគ្រប់វិស័យ　　ក្មេងចាស់ប្រុសស្រីឈ្លក់វង្វេង ។*
*ឥតយល់នូវអ្វីជាក្ដីពិត　　ចូលចិត្តរបស់បន្លំក្លែង*
*តម្រូវតាមចំណង់ចិត្តឯង　　ដោយភាពវង្វេងវែងយល់ធម៌ ។*
*រីករាយចង់បានពាក្យសរសើរ　　បញ្ចើចបញ្ចើតែខាងល្អ*
*លង់តាមសម្ដីពាក្យភូតភរ　　ផលត្រូវបានមកគឺខកចិត្ត ។*
*ជំនឿប្រាសចាកសច្ចៈធម៌　　បន់ស្រន់សួររកវត្ថុស័ក្ដិសិទ្ធិ*
*អាគមអូមអាមតាមគំនិត　　ប្រាថ្នាតាំងចិត្តគិតរកផល ។*
*ជាខ្ញុំកញ្ជះនៃតណ្ហា　　គ្មានបានសិក្សាចិន្តាយល់*
*ប្រាប់ពីក្ដីពិតឥតបើខ្វល់　　វង្វេងវែងស្គាល់ហេតុផលពិត ។*
*ត្រូវខំព្យាបាលរោគកិលេស　　កុំឲ្យចាក់ស្រែះក្នុងដួងចិត្ត*
*ដោយការបដិបត្តិតាមធម៌ពិត　　បង្កើតគំនិតនិងបញ្ញា ។*
*ត្រាច់ចរតាមផ្លូវទាំងប្រាំបី　　គឺអង្គអរិយមគ្គា*
*កំណត់កត់ស្គាល់អរិយសច្ចា　　ដកហូតតណ្ហាចាកចិត្តបាន ៕*

ដោយឧបាសក មិញ សាវ៉ាង

# ២. ព្រះគិត ៣ អង្គ

ការរំលត់នូវភ្លើងកិលេសរបស់អាត្មា ដែលនៅក្នុងវត្តនាជើងភ្នំ សុបេប បានប្រព្រឹត្តទៅដោយស្រួល ៗ អាត្មាភ្ញាក់ពីការចាំវត្តនៅវេលាម៉ោង ៤ ព្រឹក ដុសធ្មេញ លាងមុខរួចរាល់អស់ហើយ ចូលក្នុងបន្ទប់ថ្វាយបង្គំព្រះ សូត្រមន្តឧទ្ទិសបុណ្យកុសលជូនដល់មាតាបិតា គ្រូបាអាចារ្យ និងគ្រប់សត្វនិករទាំងអស់ក្នុងភពទាំង ៣ អស់វេលាប្រហែលជាកន្លះម៉ោង គឺដល់ម៉ោង ៤ កន្លះ ក៏គ្រងចីពរចេញដើរទៅចង្ក្រមតាមផ្លូវ ចង្ក្រមនេះគឺវាងដើមកគោះ ២ ដើម ៗ នៃទាំងពីរដាក់ខ្ញែងគ្នានៅខាងមុខ បោលភ្នែកទៅ ៤ ព្យាមដើរតិចៗទៅមកៗ សង្រួមចិត្តឲ្យទៅជាសមាធិ តាំងសតិក្នុងកិរិយាលើកជើង ឈានដើរអស់រយៈវេលាប្រមាណម៉ោង ៥ ៗ ឈប់ដើរចង្ក្រម ទៅអង្គុយសំរាកសម្រួលឥរិយាបថនៅរានហាលខាងមុខកុដិដែលតែងតែសំរាក ៗ នៅពេលអង្គុយ តែងព្យាយាមគិតដល់ធម៌ណាមួយ យកមកពិចារណា ៗ លុះដល់មានពន្លឺប្រាក់មាសចែងចាំងចេញអំពីមេឃមកពីខាងបូព៌ាទិស បរិយាកាសក្នុងវត្តអារាមក៏ចាប់ផ្ដើមមានសំឡេងភ្ញូអរ ដោយសំឡេងសត្វចាប ក្អែក ដែលភ្ញាក់ពីដេក ស្រែកប្រកួកហៅគ្នាចេញរកស៊ី ទើបអាត្មាចូលក្នុងបន្ទប់ រៀបចំរបស់របរដាក់ឲ្យមានរបៀបរៀបរយ ជូតក្ដារក្នុងបន្ទប់ និងបរិវេណកុដិឲ្យស្អាត ៗ

ក្រោយអំពីនោះមក ប្រសិនជាអាកាសធាតុក្ដៅ ក៏ទៅស្រង់ទឹកជំរះកាយ ពេលបានត្រជាក់ខ្លួនស្រួល ស្រឡះមុខមាត់ហើយ ក៏គ្រងចីពរ ពាក់សង្ឃាដី ចាប់យកបាត្រមកស្ពាយ ហើយចេញដើរទៅបិណ្ឌបាតតាមភូមិអ្នកស្រុក ដែលនៅជិតៗវត្តនាទិសខាងកើត ។ នៅពេលបានចង្ហាន់គ្រប់ល្មមហើយ ក៏វិលត្រឡប់មកវត្តវិញ អង្គុយសំរកល្មមបាត់ហត់ ទើបចាប់ផ្ដើមឆាន់ ដោយបើកគញ្ចប់ម្ហូបផ្សេងៗចាក់ចូលទៅក្នុងបាត្រ ហើយសង្រួមចិត្តគិតថា យើងនឹងបរិភោគអាហារនេះ គ្រាន់តែទ្រទ្រង់ជីវិតឲ្យបានរស់នៅហើយរស់នៅដើម្បីធ្វើនូវអំពើល្អ ដល់ខ្លួនឯងនិងអ្នកដទៃ មិនមែនបរិភោគដើម្បីឆ្ងាញ់ ដើម្បីសប្បាយ ឬឲ្យរូបរាងកាយស្រស់ស្អាត គឺបរិភោគដើម្បីកែរោគឃ្លាន ដូចជាមនុស្សដែលឈឺត្រូវលេបថ្នាំ នៅពេលពិចារណារួចហើយទើបចាប់ផ្ដើមឆាន់ដោយការសង្រួម ។ ពេលឆាន់រួចហើយទើបយកកាកសំណល់ទៅចាក់ឲ្យឆ្កែ ២ ក្បាល ដែលមកអង្គុយចាំទទួលអាហារ សេសសល់ជារៀងរាល់ៗថ្ងៃនៅពេលព្រឹកៗ ។ លុះលាងបាត្ររួចហើយជូត យកកន្តោរទៅចាក់ហើយលាង ព្រមទាំងកែវទឹក សម ស្លាបព្រាជូត ហើយទុកដាក់ចូលតាមកន្លែងរៀបរយ ទើបអង្គុយសង្រួមចិត្តនឹកឧទ្ទិសចំណែកផលបុណ្យនេះ ជូនដល់ម្ចាស់ទានសូមឲ្យគេបានសេចក្ដីសុខកាយសប្បាយចិត្ត ប្រាសចាកនូវរោគាព្យាធិ ទាំងពួង ។ ទម្រាំតែនឹងចប់សព្វគ្រប់ម៉ោងឈានចូលដល់ ១០ ទៅហើយ នៅពេលក្រោយនេះទើបចាប់យក

សៀវភៅធម៌ខ្លះ វិទ្យាសាស្ត្រខ្លះ និងសារព័ត៌មានផ្លូវលោកខ្លះៗ ដើម្បីឲ្យយល់រហូតដល់ម៉ោង ១ រសៀល ទើបឈប់សំរាក មុននឹងចូលសំរាកតែងកំណត់ក្នុងចិត្តថា នឹងតើនឡើងក្នុងវេលា ១ ម៉ោង ។ លុះដល់ម៉ោង ២ រសៀល ក៏តើនឡើងលាងមុខ មាត់ហើយទើបទៅអង្គុយលើគ្រែឫស្សីនៅក្រោមដើមឈើក្បែរមាត់អាងទឹកអានសៀវភៅខ្លះ ពិចារ - ណាក្នុងធម៌ខ្លះ សរសេរទុកនូវការគិតថ្មីៗដែលកើតពីការពិចារណាក្នុងធម៌ខ្លះ សរសេរទុកក្នុងសៀវភៅផ្ទាល់ខ្លួនខ្លះ ទៅសន្ទនាជាមួយភ្ញៀវដែលគេមកជួបខ្លះ ។ ក្រោយពីនោះមក លុះដល់ម៉ោង ៥ ល្ងាច អាត្មាក៏ត្រឡប់ទៅកុដិតូចនោះវិញ បោសសំអាតក្នុងបរិវេណកុដិ ជូតជុសក្តារក្នុងកុដិ ដងទឹកសំរាប់ឆាន់និងដាក់ពាង ហើយស្រង់ទឹកជំរះកាយ ។ លុះដល់ម៉ោង ៧ យប់ ទើបគ្រងចីពរទៅសន្ទនាធម៌ជាមួយភិក្ខុជាមិត្តនៅកុដិផ្សេងៗ ។ លុះដល់ម៉ោង ៨ យប់ ទើបត្រឡប់មកកុដិវិញ ហើយដើរចង្ក្រមប្រហែល ៣០ ឬ ៤០ នាទី ទើបអង្គុយសំរាកនៅរានហាលមុខកុដិ ពេលបាត់ហត់ហើយក៏ចូលទៅក្នុងកុដិបិទទ្វារ ហើយអង្គុយនៅកន្លែងធ្វើសមាធិកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ។ លុះដល់ម៉ោង ៩ យប់ ទើបថ្វាយបង្គំព្រះពេលល្ងាច រួចហើយសង្រួមចិត្តត្រួតមើលនូវការបដិបត្តិរបស់ខ្លួន តាំងតែពីព្រឹកព្រលឹមរហូតមកដល់ពេលនេះ តើមានអ្វីខុសឆ្គងមិនសមខ្លះដែរឬទេ ? ព្រមទាំងការបដិបត្តិរាល់ថ្ងៃ ក្នុងព្រះវិន័យនិងផ្លូវចិត្ត ។ នៅពេលឃើញថាមានការខុសឆ្គង មិនសម

បន្តិចបន្តួច ត្រូវតាំងចិត្តសារជាថ្មីថានឹងធ្វើឲ្យបានល្អឡើងវិញនូវថ្ងៃតទៅមុខ ។ បើឃើញថាខ្លួនឯងបានបដិបត្តិល្អសមគួរហើយ ក៏កើតមានបីតិពេញចិត្ត ផ្សាយបុណ្យឧទ្ទិសកុសលដែលកើតអំពីអំពើល្អនោះដល់ មាតា បិតា គ្រូបាធ្យាយ និងសត្តនិករគ្រប់ទិសទី ហើយក៏ប្រាសខ្លួនសឹងទៅ ដោយការតាំងចិត្តថានឹងភ្ញាក់នៅវេលាម៉ោង ៤ ភ្លឺ ។

អាត្មាបដិបត្តិយ៉ាងនេះរាល់ៗថ្ងៃ ឃើញថាមានសេចក្តីសុខស្ងប់ទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ផ្នែករាងកាយក៏គ្មានរោគាព្យាធិមកបៀតបៀន ចំណែកផ្នែកចិត្តក៏សុខស្ងប់ឡើងបានច្រើន គឺជាសេចក្តីស្ងប់ សុខត្រជាក់ជាទីបំផុតហើយដែលកាលពីមុនមក មិនដែលបានជួបប្រទះក្នុងជីវិតនេះ ប្រហែលសេចក្តីសុខនេះហើយដែលជានិរាមិសសុខដែលព្រះអរិយបុគ្គលលោកទ្រង់ត្រាស់សរសើរ ។

ក្នុងផ្នែកការបង្រៀនដល់អ្នកដទៃនោះ អាត្មាក៏ធ្វើទៅតាមពេលវេលាដែលផ្តល់ឲ្យ ដូចជាមានពេលមួយនោះអាត្មាកំពុងតែអានសៀវភៅនៅលើគ្រែនាមាត់ស្រះទឹក មានប្រុសស្រីក្មេងៗមួយគូ ដើរចូលមករកអាត្មា ។ ទាំងពីរនាក់ពាក់អាវដៃវែងមានឆ្នូតក្រឡាមិនគួរមើលទេ ស្លៀកខោវែងតឹងសឹងតែអង្គុយបត់ជើងមិនកើត ។ ចំណែកប្រុសវិញទុកសក់វែង ឯស្រីកាត់សក់ខ្លី សឹងតែមើលមិនស្គាល់ថាតើណាមួយជាប្រុសណាមួយជាស្រី ។ អាត្មាមិនបានដាក់ចិត្តទុកដាក់ប៉ុន្មានទេ ចំពោះសំលៀកបំពាក់របស់គេនោះ គ្រាន់តែគិតក្នុងចិត្តថា ការតែងខ្លួនរបស់មនុស្ស តែងតែ

ផ្លាស់ប្ដូរទៅតាមគ្រតែរៃនៃលោកដោយការចម្លង មានតែសំលៀកបំពាក់របស់ព្រះសង្ឃប៉ុណ្ណោះទេ ទើបមិនមានតែប្រែប្រួលមកដល់២៥០០ ឆ្នាំមកហើយ ។

- ព្រះតេជព្រះគុណ តើមានរបស់ល្អសំរាប់ការពារខ្លួនដែរឬទេ ? ប្រុសកំលោះសួរឡើង ក្រោយពីបានអង្គុយហើយ លើកដៃសំពះ

- មាន ! អាត្មាតបដោយពាក្យយ៉ាងខ្លី

- មេត្តាឲ្យខ្ញុំកូណា និងមិត្តរបស់ខ្ញុំសូមទុកគោរពខ្លះបានឬទេទាន ? គេនិយាយហើយងាកសំឡឹងទៅមិត្តស្រីដែលអង្គុយបត់ជើងប្រែចុះប្រែឡើងដោយពិបាក

- ឲ្យក៏បាន ! ប៉ុន្តែខ្លាចក្រែងតែញោមមិនទទួល, អាត្មាឆ្លើយតប ប្រើពាក្យជំនួសឈ្មោះថា « ញោម » ដូចជាស្ដាប់ទៅមិនសូវចូលត្រចៀក នៅពេលយកមកប្រើជាមួយក្មេងកំលោះដូច្នេះ ប៉ុន្តែអាត្មាបានប្រើពាក្យថា « ញោម » ជាមួយមនុស្សគ្រប់វ័យមកយូរឆ្នាំមកហើយ ចាំបានថាគឺតាំងតែពីថ្ងៃដំបូងដែលបានបួសមកម្ល៉េះ ទើបមិនមានការប្ដូរយ៉ាងណាឡើយ

- ខ្ញុំកូណាទទួល ! មិនទទួលដូចម្ដេចបាន បើព្រះអង្គប្រទានឲ្យហើយ ! គេឆ្លើយដោយសំនឹបង្ហាញឲ្យឃើញថា នៅមានការសង្ស័យខ្លះៗ ។

- ប៉ុន្តែញោមនៅមិនទាន់ដឹងថា តើរបស់ល្អដែលអាត្មានឹងឲ្យសំរាប់ការពារខ្លួននេះតើជាអ្វី ? បើដឹងវិញនោះ

ប្រហែលជាញោមមិនចង់បានទេ ! អាត្មានឹងប្រាប់ក៏បានដែរ ថា របស់ដែលអាត្មាប្រើការពារខ្លួនជាអ្វី គឺរបស់នេះឯង, អាត្មាក៏លើកយកជាយចីពរមកឲ្យគេមើល, កំលោះនិងនាងក្រមុំនោះសើចឡើងឃឹកៗព្រមៗគ្នា, ញោមអាចថាអាត្មាចូលចិត្តនិយាយលេងក៏បាន ប៉ុន្តែអាត្មាមិនចេះនិយាយលេងទេ គឺរបស់នេះហើយដែលជារបស់ការពារខ្លួនដែលល្អជាទីបំផុតក្នុងលោក មិនមែនជាអាវដែកធម្មតាទេ តែជាអាវដែកដែលព្រះសម្មាសម្ពុទ្ធ ព្រះអង្គប្រទានទុកឲ្យមកជាង ២៥០០ ឆ្នាំមកហើយ ជនណាប្រើអាវដែកនេះការពារខ្លួន អ្នកនោះមិនត្រឹមតែផុតពីគ្រោះថ្នាក់ដោយគ្រាប់កាំភ្លើង និងគ្រឿងសស្ត្រាវុធមានដាវ កាំបិតតែប៉ុណ្ណោះទេ នឹងអាចបានទទួលនូវការគោរពរាប់អានពីប្រជាជនទៀតផង ប្រសិនជាញោមពាក់អាវដែកមែនទែននោះ ពេលដើរចូលទៅទីក្រុង នៅពេលប្រជាជនឃើញអាចនឹងមានការភ្ញាក់ផ្អើលខ្លាច អ្នកខ្លះទៀតគេអាចស្អប់ អ្នកខ្លះទៀតគេចង់សើច ប៉ុន្តែបើពាក់អាវដែករបស់ព្រះពុទ្ធវិញ នៅពេលគ្រប់គ្នាបានឃើញហើយគេនឹងយល់បានភ្លាមថា នេះជាទង់នៃព្រះអរិយបុគ្គល ជាសញ្ញានៃសេចក្តីស្ងប់សុខ សេចក្តីបរិសុទ្ធស្អាតជាប្រក្រតី គេនឹងកើតសេចក្តីគោរពរាប់អាន នៅពេលគេពិបាកចិត្ត គេនឹងមានសេចក្តីធូរស្បើយក្នុងចិត្តនៅពេលបានជួបបានឃើញ ប៉ុន្តែប្រសិនជាញោមពាក់អាវដែកមែនទែននោះ ញោមអាចទៅរកទិញម្ហូបអាហារដោយខ្លួនឯង ប៉ុន្តែប្រសិនជាញោមពាក់អាវដែករបស់ព្រះ

ពុទ្ធអង្គនេះវិញ នឹងមានមនុស្សនាំយកម្ហូបអាហារមកប្រគេន ថែមទាំងលើកដៃសំពះទៀតផង តើញោមយល់ឃើញថាអាវដែកនេះមានឥទ្ធិពលដ៏ល្អយ៉ាងណា ?

- ឃើញហើយព្រះអង្គ, ប្រុសកំលោះនោះឆ្លើយតបដោយញញឹម, ប៉ុន្តែខ្ញុំកូណាមិនអាចទទួលបានទេទាន ព្រោះខ្ញុំកូណាមិនទាន់ចង់បួស តើរបស់ការពារខ្លួនផ្សេងទៀតដូចជាព្រះអង្គទ្រង់គ្រឿង តើព្រះអង្គមានខ្លះដែរឬទេ ? ខ្ញុំកូណាចង់បានបែបនោះច្រើនជាង

- ព្រះគ្រឿងមិនពិតអាត្មាគ្មានទេ ប៉ុន្តែដែលអាត្មាមាននោះ គឺជាព្រះពិត មិនមែនជាព្រះក្លែងក្លាយទេ បើញោមត្រូវការព្រះពិត អាត្មាអាចឲ្យបាន ប៉ុន្តែបើញោមចង់បានព្រះក្លែងក្លាយត្រូវទៅរកនៅកន្លែងផ្សេងហើយ

- ខ្ញុំកូណាសូមព្រះពិត, នាងស្រីក៏ឆ្លើយឡើងខ្លះៗ ក្រោយពេលដែលបាននៅស្ងៀមមកយូរហើយ

- ព្រះការឡៃ ព្រះមិនពិតតើយកមកធ្វើអ្វី ? នាងស្រីបានសំដែងការមិនពេញចិត្ត នូវការនិយាយលេងរបស់អាត្មា

- កូណាទាន! ប្រុសកំលោះឆ្លើយឡើង, យើងចង់បានព្រះពិតទាន

- អាត្មាសួរសាកមើល ដើម្បីសេចក្តីប្រាកដក្នុងចិត្ត ពីព្រោះ មានមនុស្សជាច្រើនដែលមករកអាត្មា ដើម្បីសុំតែព្រះអង្គការឡៃគឺមិនពិត នៅពេលដែលអាត្មាឲ្យព្រះអង្គ

ពិត គេមិនពេញចិត្ត សុំដូរយកព្រះគាថាឡើងមិនពិតទៅវិញ

លុះមកដល់ពេលនេះ អាត្មាសង្កេតឃើញថា ក្មេងកំលោះនិងនាងក្រមុំនេះសំឡឹងមុខគ្នា និងសំដែងនូវប្លែកពារស្អែកក្នុងចិត្តហើយ ប្រុសកំលោះបាននិយាយឡើង៖

- ខ្ញុំព្រះករុណាយល់ថា ពាក្យពោលរបស់ព្រះអង្គនេះពោរពេញទៅដោយន័យ ខ្លួនខ្ញុំក៏មិនទាន់ប្រាកដក្នុងចិត្តថា ព្រះអង្គនឹងចេញមកផ្លូវណា ជួនកាលអាចត្រូវព្រះអង្គបញ្ឆោតដូចរឿងចំពារ នៅពេលមុននោះក៏អាចបាន

- អាត្មាមានការមិនពេញចិត្តបន្តិចបន្តួច ដែលគេថាអាត្មានិយាយពាក្យបញ្ឆោត ប៉ុន្តែតាមធម្មតាសង្កេតមើលចិត្តរបស់ខ្លួនជានិច្ច ដោយចិត្តានុបស្សនាកម្មដ្ឋាន ទើបរំងាប់នូវការមិនពេញចិត្តនេះបាន សង្កត់ចិត្តហើយផ្សាយមេត្តាចំពោះទៅកំលោះនោះ ហើយនិយាយតបទៅយឺតៗថា៖

- អាត្មានៅក្នុងព្រៃនេះមកយូរហើយ ល្មមនឹងបានទទួលបទរៀនពីដើមឈើ សូមឲ្យញោមមើលទៅស្លឹកឈើទាំងអស់នេះចុះ វានឹងមិនជ្រុះធ្លាក់មកដោយងាយនោះសោះឡើយ លើកលែងតែវាទុំល្មមទើបធ្លាក់ចុះមកបាន ពាក្យនិយាយរបស់អាត្មាក៏ដូច្នោះដែរ នឹងមិនមានពាក្យណាចេញមកពីមាត់ លើកលែងតែពាក្យណាពិត អាត្មាឈប់និយាយពាក្យមិនពិត ពាក្យបញ្ឆោតមកតាំងតែពីថ្ងៃដំបូងដែលអាត្មាចូលមកបួសគឺ ៨ ឆ្នាំហើយ

- ខ្ញុំករុណាសូមអភ័យទោសទាន ដោយខ្ញុំករុណាប្រើពាក្យមិនសមគួរហួសទៅ, ក្មេងប្រុសនោះនិយាយដោយទឹកមុខភ័យភិត ហើយលើកដៃសំពះ ដើម្បីមិនឲ្យមានបញ្ហាផ្សេងៗ, ខ្ញុំករុណាសុំទូលព្រះអង្គត្រង់ៗថា ខ្ញុំចង់បានព្រះអង្គទ្រង់គ្រឿង ដែលគេតែងយកមកព្យួរកគ្រប់ៗគ្នានោះ ព្រះអង្គប្រហែលជាស្គាល់ហើយ

- ញោមធ្លាប់ឮពាក្យថា "**ព្រះបដិមា**" ឬទេ? អាត្មាសួរ

- ករុណាធ្លាប់! គេឆ្លើយដោយជ្រួញចិញ្ចើមបន្តិច

- តើញោមបានយល់ឬទេ ពាក្យថា "**ព្រះបដិមា**" តើប្រែថាដូចម្ដេចដែរ? អាត្មាសួរថែមទៀត

- ករុណាមិនដឹងទេទាន!

- ពាក្យថា "**បដិមា**" ជាភាសាបាលី ប្រែថា គំរូ ឬបន្លំមិនពិតប្រាកដទេ "**ព្រះបដិមា**" គឺព្រះមិនពិត ព្រះគំរូ ព្រះអង្គតូច ធំ ដែលគេកសាងដោយលោហធាតុផ្សេងៗ ដូចជា មាស ស្ពាន់ ទង់ដែង សំរិទ្ធ ឬកសាងដោយស៊ីម៉ង់ត៍និងគេសរផ្ការផ្សេងៗ ទាំងនេះគឺជា "**បដិមា**" គំរូមិនពិតទាំងអស់ គេកសាងឡើងដើម្បីជាអនុស្សាវរីយ៍ដាស់តឿនចិត្តឲ្យអ្នកទៅក្រាបសំពះនោះ រឭកដល់អង្គព្រះសម្មាសម្ពុទ្ធបរមសាស្ដាតែប៉ុណ្ណោះ ព្រះគំរូ ព្រះមិនពិតទាំងអស់នេះ មិនអាចនឹងជួយការពារអ្នកដែលប្រព្រឹត្តអាក្រក់នោះបានទេ សូម្បីឮតែយ៉ាងណាក៏ដោយក៏មិនរួចអំពីទុក្ខគ្រោះភ័យនោះបានដែរ ញោមប្រហែលធ្លាប់បានឮដំណើង

ថា មានខ្លា[១]នេះខ្លានោះ ត្រូវពួកប៉ូលីសបាញ់ស្លាប់ជាញឹកញយ ខ្លាទាំងអស់នោះសុទ្ធតែមានព្រះពុទ្ធរូបព្យួរពេញកទាំងអស់ ប៉ុន្តែនៅទីបំផុតត្រូវស្លាប់ដោយគ្រាប់កាំភ្លើងទាំងអស់ ៗ ព្រោះដូច្នេះហើយទើបអាត្មាមិនឲ្យព្រះគាថាដល់អ្នកណាឡើយ

- តើព្រះអង្គនឹងឲ្យព្រះអ្វីដល់ខ្ញុំកូណា? ក្មេងកំលោះនោះសួរហើយដកដង្ហើមធំ

- អាត្មាបានប្រាប់ហើយថានឹងឲ្យព្រះអង្គពិត គឺព្រះអង្គពិតហើយ!

- ព្រះអង្គពិតនោះ គឺខ្លួនព្រះតេជព្រះគុណនេះឬ តើមែនឬមិនមែន? នាងស្រីនិយាយហើយសើច ដោយការពេញចិត្តដែលខ្លួនឯងយល់ច្បាស់ថា អាត្មានឹងឲ្យអ្វី

- មិនមែនទេ រូបអាត្មាមិនមែនព្រះអង្គពិតនោះទេ គឺគ្រាន់តែជាសម្មតិសង្ឃ ឬជាព្រះសង្ឃដោយការសន្មតប៉ុណ្ណោះ

- បើដូច្នោះ តើព្រះពិតនោះគឺជាអ្វីដែរ? សូមព្រះអង្គមេត្តាឲ្យទានឆាប់ៗមក, ក្មេងកំលោះនោះពោលឡើងដោយរំខានខ្លាំងពេក

អាត្មាសង្កត់ចិត្ត ហើយផ្សាយមេត្តាដល់ពួកគេទាំងពីរនាក់ ហើយក៏និយាយឡើងយឺតៗ មួយៗច្បាស់ៗថា៖

(១) ឈ្មោះ "ខ្លា" គឺជាមេចោរធំៗ ។

- ព្រះដែលពិតនោះមាន ៣ ព្រះអង្គគឺ៖ ព្រះវិសុទ្ធ-គុណ ១, បញ្ញាគុណ ១ និងព្រះមហាករុណាគុណ ១ អាត្មាសូមប្រគល់ព្រះទាំង ៣ ព្រះអង្គនេះជូនដល់ញោម

- តើខ្ញុំកូណាអាចទទួលបានដោយរបៀបណា? ក្មេងប្រុសសួរដោយជឿងឆ្ងល់

- ព្រះអង្គពិតប្រាកដទាំង ៣ ព្រះអង្គនេះ ញោមយកទៅព្យួរកស្មៀមៗមិនបានទេ គឺត្រូវយកទុកនៅក្នុងខ្លួនតែម្តង គឺញោមត្រូវធ្វើខ្លួនឲ្យបានបរិសុទ្ធ លះបង់នូវអំពើអាក្រក់តាមផ្លូវកាយ ផ្លូវវាចា និងតាមផ្លូវចិត្ត បើញោមធ្វើបានដូច្នេះហើយ ញោមនឹងមានព្រះវិសុទ្ធិគុណ នេះគឺព្រះអង្គដំបូងនៅក្នុងខ្លួន គឺញោមស្វែងរកការចេះដឹងដោយការសិក្សារៀនសូត្រ ការស្តាប់ការអាន ការចូលទៅជិតអ្នកប្រាជ្ញ ដោយការសន្ទនាជាមួយនឹងលោក-អ្នកចេះដឹងមានបញ្ញា ជាអ្នកមានសីលបរិសុទ្ធ បើញោមធ្វើបានយ៉ាងនេះហើយ ញោមនឹងមានព្រះអង្គទីពីរទៀត គឺព្រះបញ្ញាគុណនៅក្នុងខ្លួន ញោមត្រូវមានសេចក្តីករុណាជានិច្ចនៅក្នុងចិត្ត គឺត្រូវមានចិត្តអាណិតអាសូរ ជួយសង្គ្រោះមិត្តមនុស្សគ្រប់ពេលវេលាដែលអាចជួយបាន ប្រសិនញោមធ្វើបានយ៉ាងនេះហើយ នោះបានឈ្មោះថា ញោមមានព្រះអង្គទី ៣ គឺព្រះមហាករុណាទិគុណនៅក្នុងខ្លួន

ក្មេងកំលោះ ក្រមុំទាំងពីរនាក់អង្គុយស្មៀម សំឡឹងមុខគ្នាមួយសន្ទុះហើយ ក្មេងប្រុសក៏និយាយឡើងព្រមទាំងសើច៖

- តើព្រះអង្គពិតទាំង ៣ ព្រះអង្គរបស់ព្រះអង្គនេះ តើលោកអាចជួយការពារដល់ខ្ញុំកូណា គឺគេបាញ់មិនត្រូវ កាំបិតចាក់ មិនមុត បានដូចម្ដេចទៅលោកម្ចាស់ ?

- អាត្មាសុំធានាថា ប្រសិនជាញោមមានព្រះអង្គពិតទាំង ៣ ព្រះអង្គនេះបរិបូណ៌នៅក្នុងខ្លួននោះហើយ សូម្បីកុំថាឡើយគេបាញ់មិនត្រូវ តែមទាំងគ្មាននរណាមកបាញ់ញោមទៀតផង កុំថាឡើយគេចាក់មិនមុត គឺគ្មាននរណាមកចាក់ញោមផង

- សូមថ្វាយបង្គំលាហើយ, ក្មេងប្រុសពោលឡើងបែបមិនសូវសប្បាយចិត្ត ហើយក៏ឱនក្រាបម្ដង ទាំងពីរនាក់ក៏ក្រោកដើរចេញទៅ ទាំងមិនងាកក្រោយ

អាត្មាតាមមើលគេ លុះត្រាផុតដើមឈើ ក៏នឹកពោលម្នាក់ឯងតិចៗថា ៖

- ឱ ! មនុស្សយើងនៅក្នុងលោកនេះ ភាគច្រើនគេមិនត្រូវការព្រះអង្គពិតប្រាកដទេ គេត្រូវការតែព្រះតាំឡ

ហើយក៏ងាកទៅមើលទឹករលកដែលនៅក្នុងអាងធំនោះ តែងនាំយករលកតូចៗរសាត់ចូលទៅប៉ះទន្លិចជ្រាំង ហើយក៏បាត់ទៅ...

# ៣. សាសនា ជាថ្នាំកែរោគទុក្ខ

**នៅ**ទីបំផុត រដូវក្ដៅក៏បានខិតចូលមក ស្លឹកឈើនៅក្នុងអារាមចាប់ផ្ដើមប្រែទៅជាពណ៌លឿង ហើយជ្រុះធ្លាក់មកលើដីជារឿយៗបន្តគ្នា នៅពេលមានខ្យល់បក់មកត្រូវម្ដងៗ ទឹកដែលនៅក្នុងអាង ក៏ស្រកចុះទៅជាច្រើនធ្វើឲ្យរយៈផ្លូវដើរពីគ្រែឫស្សី ដែលអាត្មាតែងតែទៅអង្គុយពិចារណាធម៌នោះ នៅកាន់តែឆ្ងាយឡើងៗអំពីមាត់ទឹក ស្ទើរតែមើលមិនឃើញរលកទឹករត់មកប៉ះនឹងមាត់ច្រាំង គឺឃ្លាតឆ្ងាយពីគ្នាយ៉ាងច្រើន ប៉ុន្តែអាត្មាវិលមកពិចារណានូវស្លឹកឈើដែលជ្រុះលើដីជំនួសវិញ គឺជាអារម្មណ៍នៃកម្មដ្ឋានបានល្អដែរ ដូចគ្នានឹងការពិចារណានូវទឹករលក គឺស្លឹកឈើប្រៀបបាននឹងជីវិតរបស់សត្វលោក ឯចំណែកស្លឹកឈើដែលក្លាយទៅជាពណ៌លឿងប្រៀបបីដូចជាមនុស្សជរា ចំណែកខ្យល់ដែលបក់ផាត់មកធ្វើឲ្យស្លឹកឈើជ្រុះធ្លាក់ចាកមែក គឺប្រៀបដូចជាសេចក្ដីស្លាប់ ក៏បានយល់ថា ធម្មជាតិអាចធ្វើជាមេរៀនដ៏មានតម្លៃដល់មនុស្សមាននៅគ្រប់យ៉ាង គ្រប់ទីកន្លែងទាំងអស់ ។

ធាតុអាកាសចាប់ផ្ដើមក្ដៅឡើងៗ រៀងរាល់ថ្ងៃ ប៉ុន្តែក្ដៅចំពោះតែនៅពេលថ្ងៃប៉ុណ្ណោះ នៅពេលដែលព្រះអាទិត្យលិចបាត់ទៅធាតុអាកាសក៏ចាប់ផ្ដើមត្រជាក់នៅពេលយប់រងា អាត្មាត្រូវលាតសន្ថារដី (សង់ឃ្លី) យកមក

ផ្លាប់រាល់ៗយប់ ។ នៅពេលព្រឹកធាតុអាកាសត្រជាក់ល្មម គួរឲ្យសប្បាយជាទីបំផុតហើយត្រជាក់រហូតដល់ថ្ងៃរសៀល បើសិនជាប្រៀបធៀបទៅនឹងខេត្តផ្សេងៗក្នុងប្រទេសថៃនេះ ធាតុអាកាសនៅឈៀងម៉ៃគឺល្អជាទីបំផុត ទោះជាយ៉ាងណាក៏ដោយ ក្នុងធាតុអាកាសនៃរដូវក្តៅមានប្រាកដគ្រប់ទីកន្លែង ។ ឯនាយជើងមេឃក្លាយទៅជាពណ៌ក្រហមស្លុងៗ ជួនកាលមានថ្ងៃខ្លះមើលមិនឃើញភ្នំផង អាកាសធាតុស្ទះស្ទាប់ទៅដោយផ្សែងឆេះព្រៃនៅពេលយប់ មានថ្ងៃខ្លះ អាត្មាបានឈរនៅលើផ្លូវចង្រ្កម អាចមើលទៅឃើញផ្សែងជាជួរៗផង ។ នៅលើភ្នំឃើញភ្នំ និងជើងមេឃពណ៌ខ្មៅ ជាប់គ្នាជាសាច់មួយ ហើយធ្វើឲ្យឃើញដូចជាភ្លើងកំពុងឆេះជើងមេឃ . . . សូម្បីរដូវក្តៅដែលកំពុងក្តៅហែងស្ងួតក៏ដោយ ក៏មិនអាចលះបង់ចោលនូវរបស់ដែលគួរឲ្យរីករាយទាំងអស់ទៅតែម្តងនោះឡើយ ពីព្រោះនៅកណ្តាលនៃភាពស្ងួតហួតហែងនោះ មានដើមផាយមយ៉ាងច្រើននៅក្នុងវត្តអារាម បានបញ្ចេញផ្កាមកស្គុះស្គាយមានពណ៌សជាចង្កោមៗធ្លាក់ចុះមក ជ្រុះគ្រាលលើដីជាខ្សែៗ នៅពេលមានខ្យល់បក់មក បានបញ្ចេញក្លិនយ៉ាងក្រអូបត្រជាក់ពាសពេញក្នុងវត្ត នៅពេលជាមួយគ្នានោះ មានដើមក្រាយចេញផ្កាមានពណ៌ក្រហម មើលទៅល្អស្រស់ពេញដើម ហើយមានដើមកល្បព្រឹក្សចេញផ្កាពណ៌ស៊ីជម្ពូជាកញ្ចុំៗ ធ្វើឲ្យវត្តអារាមមើលទៅដូចជាផែនដីឧចឹយដែលមានផ្កា (សាគុរៈ) រីកស្រស់ សម្រស់នៃផ្កាធ្វើឲ្យអាត្មាសឹងតែ

ភ្លេចនូវឆាគុ មិនមែនជាអាកាសក្ដៅនិងការស្ងួតរាំងរបស់រដូវក្ដៅតែម្ដង ៗ ចំណែកខាងសត្វវិញ គេក៏ដូចជារីករាយរាល់ពេល ជាមួយនឹងអាត្មាដែរ ពីព្រោះគេនាំគ្នាច្រៀងមានសម្លេងយ៉ាងខ្លាំងឮសូររំពងពេញក្នុងវិត្ត តាំងតែពីព្រឹកព្រលឹមរហូតដល់ពេលល្ងាច ដោយគ្មានការហត់នឿយអ្វីសោះ ៗ សូម្បីដូច្នោះក្ដី ក៏មិនមានធ្វើឲ្យរំខានដល់ត្រចៀក ឬដល់សមាធិចិត្តរបស់អាត្មាឡើយ ផ្ទុយទៅវិញទៅជាល្អបានជួយទៅវិញ ពីព្រោះវាស្រែកដោយទំនងដូចគ្នា ក្នុងចង្វាក់ស្មើគ្នា លាយចូលគ្នាជាមួយធម្មជាតិផ្សេងៗ អាត្មាចូលចិត្តរដូវក្ដៅ ចូលចិត្តផ្កាក្នុងរដូវក្ដៅ ចូលចិត្តស្ដាប់សម្លេងរៃយំ ហើយមិនមានពេលណា ដែលសប្បាយស្ងប់ជាងនៅពេលដែលដើរចង្ក្រមទៅមកៗ នៅកណ្ដាលក្លិនក្រអូបត្រជាក់នៃផ្កាផាយម និងសម្លេងភ្លេងនៃសត្វរៃជូនកាលស្មើរតែភ្លេចខ្លួន នឹកស្មានថាខ្លួនឯងជាសត្វរៃមួយដែរ !!!

នៅពេលរដូវក្ដៅគេសង្កេតឃើញថា មានមនុស្សមកនាំគ្នាដើរលេងនៅក្នុងវិត្តជាច្រើន មានអ្នកខ្លះចូលមកសន្ទនាជាមួយអាត្មា ប៉ុន្តែភាគច្រើនឈប់ហើយឈរមើលអំពីចម្ងាយ មួយសន្ទុះក្រោយមកក៏នាំគ្នាដើរហួសទៅ ៗ មានមួយពួកទៀត ចូលមកសន្ទនាជាមួយអាត្មាដោយរឿងដែលមានសារៈ ដែលគួរនាំមកនិទានឲ្យទាំងអស់គ្នាបានស្ដាប់ ៗ អ្នកដើរលេងដែលគួរយកមកនិទាននោះគឺ មានគំលោះ ៣ នាក់ មានម្នាក់ជាអ្នកសិក្សាមកពីទីក្រុងបាងកក

ដើម្បីមកលេងផ្ទះស្រុកកំណើត នៅពេលមហាវិទ្យាល័យ បិទឈប់សម្រាក និពីរនាក់ទៀតជាមិត្តភក្តិរបស់គេ ដែលជួយឱ្យពុកលក់នូវនៅស្មៀនម៉ែ ។

- ព្រះតេជព្រះគុណ សូមទានមេត្តានិមន្តទេសនាឲ្យមិត្តរបស់ខ្ញុំកូណាម្នាក់នេះស្តាប់ផង, គេទាគមករកកំណោះអ្នកសិក្សា, គេជានិស្សិតពេទ្យឆ្នាំទី ២ ទើបមកពីបារាំងកក គេបានប្រាប់ថា គេមិនគោរពសាសនាទេ ខ្ញុំករុណាបានប្រកែកជាមួយគេជាញឹកញាប់ ប៉ុន្តែចាញ់គេរាល់ៗពេល, គេនិយាយកំប្លែងបន្តិចបន្តួច

អាត្មានៅមិនទាន់ទុកចិត្តថា គេនិយាយលេងឬនិយាយការពិតទេជាដំបូង អាត្មាបានសង្រួមចិត្តផ្សាយមេត្តាដល់កំណោះអ្នកសិក្សាជាមុនហើយសួរថា៖

- តើជាការពិតឬទេដែលគេនិយាយនោះ ?

- បាទពិតមែន! ក្មេងកំណោះអ្នកសិក្សានោះបានឆ្លើយតបពាក្យខ្លីៗ ដោយសម្លេងច្បាស់ក្នុងចិត្ត

អាត្មាមិនមានការប្លែកក្នុងចិត្តអ្វីទាល់តែសោះ ព្រោះធ្លាប់បានជួបមនុស្សមិនមានសាសនា កាលពីមុនមកហើយ កាលមុនពេលអាត្មាមកបួស អាត្មាបានប្រកាសខ្លួនថាជាមនុស្សមិនមានសាសនាដូចគ្នា អាត្មាទើបតែបានទាគមកពេញចិត្តក្នុងព្រះពុទ្ធសាសនាយ៉ាងពិតប្រាកដ ដោយហេតុចៃដន្យគឺនៅពេលកំពុងសិក្សានៅក្នុងមហាវិទ្យាល័យឡូន - ដុនពីកាល ៨ ឆ្នាំមុនមក ហើយរឿងរ៉ាវរបស់អាត្មាជារឿងវែងឆ្ងាយ បើមានពេលនឹងនាំមកនិទានឲ្យស្តាប់នៅពេល

ក្រោយ នៅពេលនេះ សូមនិយាយតែអំពីរឿងរបស់អ្នកសិក្សាម្នាក់នេះជាមុនសិន ...

- អាត្មានៅមានការសង្ស័យ ពេលញោមប្រាប់ថាញោមមិនបានកាន់សាសនាមួយណាឡើយ ពីព្រោះអាត្មាមិនដែលឃើញអ្នកណាដែលមិនមានសាសនាទេ, អាត្មានិយាយឡើង ដើម្បីកន្លងនូវការពិសោធន៍នៃពាក្យរបស់គេ

- ខ្ញុំម្ចាស់នេះហើយដែលមិនមានសាសនា ! គេនិយាយមកយ៉ាងច្បាស់ពិតប្រាកដ, បើព្រះអង្គមិនធ្លាប់ជួបឃើញពីដើមមក គឺមើលខ្ញុំករុណានេះហើយ ដែលជាមនុស្សមិនមានសាសនា ជាដំបូងដែលព្រះអង្គបានជួប

- កុំអាល ! ញោមមិនមែនជាអ្នកដំបូងទេ ពីព្រោះអាត្មាជឿជាក់ថា ញោមនៅគោរពសាសនានៅឡើយ ជួនកាលក្នុងមួយជាតិនេះ អាត្មាមិនបានជួបជនដែលឥតសាសនារហូតក៏សឹងបាន

ពាក្យរបស់អាត្មា ហាក់បីដូចជាចាក់ត្រូវចំណុចខ្សោយកំលោះអ្នកសិក្សានេះ ដោយអាត្មាមិនបានតាំងចិត្ត ។ គេលើកដៃអេះក្បាល ហើយពោលចេញមកដោយឫកពារប្លែកៗថា ៖

- បើព្រះអង្គនៅតែមិនព្រមជឿខ្ញុំករុណាទៀត ខ្ញុំមិនដឹងឲ្យការពិសោធន៍ដល់ព្រះអង្គឲ្យឃើញបានដូចម្ដេចទេ !

- គេមិនមានសាសនាពិតប្រាកដមែនព្រះអង្គ ! មិត្តរបស់គេម្នាក់ទៀតឧទានបន្ថែម, គេមិនដែលទៅវត្តធ្វើ

បុណ្យសោះ មិនសំពះលោក មិនសូត្រមន្ត ហើយមិនជឿពីរឿងបុណ្យរឿងបាបទេ

- គ្រាន់តែប៉ុណ្ណឹង មិនអាចថាគ្មានសាសនានោះបានទេ ! អាត្មាពោលឡើង, មានមនុស្សគោរពជឿព្រះពុទ្ធសាសនាជាច្រើន ដែលមិនបានធ្វើបុណ្យទាន មិនដែលសំពះលោក សូត្រធម៌វត្តអារាម និងព្រះសង្ឃ គឺគ្រាន់តែជាស្ថាប័នសាសនា ការធ្វើបុណ្យឲ្យទាន សូត្រធម៌គឺគ្រាន់តែជាពិធីកម្ម ទាំងពីរយ៉ាងនេះគ្រាន់តែជាសំបកខាងក្រៅរបស់សាសនាតែប៉ុណ្ណោះ សន្លឹមសាររបស់សាសនានៅមានច្រើនទៀត

នៅពេលអាត្មានិយាយមកដល់ចំណុចនេះ កំលោះទាំងបីនាក់ក៏នាំគ្នាអង្គុយឈ្ងោកមុខគិត៖

- តើខ្លឹមសាររបស់ព្រះពុទ្ធសាសនា គឺអ្វីទៅព្រះអង្គ? កំលោះអ្នកសិក្សាសួរ

- ខ្លឹមសាររបស់ព្រះពុទ្ធសាសនានៅមានច្រើន អ្នកខ្លះអាចមិនរាប់អាននូវស្ថាប័នសាសនា អ្នកខ្លះអាចមិនរាប់អានពិធីកម្ម ប៉ុន្តែគ្រប់ៗគ្នាត្រូវតែរាប់អានខ្លឹមពិតប្រាកដរបស់សាសនា មិនថាគេដឹងខ្លួន ឬមិនដឹងក៏ដោយ

- ហ្ន៎ ! ប៉ុន្តែខ្ញុំបានដឹងមកថា ពួកកុម្មុយនីស្តមិនមានសាសនាទេ តើពិតមែនដែរឬទេព្រះអង្គ ? ក្មេងប្រុសអ្នកជំនួញទីមួយសួរឡើង

- ផ្ទុយគ្នាស្រឡះ កុម្មុយនីស្តនេះហើយគឺជាអ្នកដែល

ពិតប្រាកដបំផុតខាងសាសនា

- តើសាសនាអ្វីទៅព្រះអង្គ? ទាំងបីនាក់សួរឡើងសឹង ទៅជាសម្លេងមួយ

- ក៏ជាសាសនាកុម្មុយនីស្តនោះអី! អាត្មាឆ្លើយធ្វើឲ្យ កំលោះទាំងបីសើចគឹលព្រមគ្នាឡើង, ដើម្បីឲ្យញោមយល់ ចូលចិត្តនូវខ្លឹមសារនៃសាសនាឲ្យកាន់តែច្បាស់ឡើង អាត្មា សូមសួរបន្តិចចុះថា ក្នុងអាយុម្ភៃឆ្នាំជាងរបស់ញោមនេះ តើ មានធ្លាប់ជួបប្រទះនូវទុក្ខធ្ងន់ៗខ្លះដែរឬទេ?

- ច្រើនដងហើយព្រះអង្គ!!! គេឆ្លើយដោយទឹកមុខ ស្ងួលៗ, តើដូចម្តេចទៅលោកម្ចាស់?

- ហើយញោម បានគេចផុតអំពីទុក្ខទោសទាំងអស់ នោះ តើបានដោយយ៉ាងណាដែរ? អាត្មាសួរតបទៅវិញ ដោយមិនតបនូវពាក្យសំណួររបស់គេ

- ខ្ញុំករុណា អាចគេចខ្លួនផុតបានគ្រប់ពេល បើជារឿង មាសប្រាក់ឪពុកម្តាយជាអ្នកជួយដោះស្រាយបញ្ហាឲ្យ បើ សិនជារឿងការងារ មិត្តភក្តិជាអ្នកជួយ បើសិនជារឿងជម្ងឺ មានគ្រូពេទ្យជាអ្នកជួយសម្រាលទុក្ខ

- ញោម នៅមិនទាន់បានជួបប្រទះនូវសេចក្តីទុក្ខមែន ទែន ជួបប្រទះតែទុក្ខតូចៗ ដែលអាចមានគេជួយសម្រួល បានដោយស្រួល, អាត្មាពោលមិនទាន់ផុតពាក្យផង មិត្ត របស់គេម្នាក់សើចឃឹកឡើង ហើយខ្ទឹបដាក់ត្រចៀករបស់ គេតិចៗ ធ្វើឲ្យគេមុខក្រហមហើយញញឹមស្ងួត ៗ

- *អឺ !!! គេពោលឡើងថើងៗ, កូណាស្លាប់ ទុក្ខធ្ងន់ៗ ដែលមិនមាននរណាជួយបានក៏ធ្លាប់មានដែរ នោះគឺជារឿងទាក់ទងជាមួយបេះដូងបន្តិចបន្តួច ប៉ុន្តែខ្ញុំពេញចិត្ត ដែលបានដោះស្រាយបញ្ហានោះចេញរួចមក*

- *ល្អណាស់ !!! នៅពេលអាត្មាសួរថា តើធ្លាប់ជួបនឹងទុក្ខធ្ងន់ៗ ឬទេអាត្មាសំដៅដល់ទុក្ខរបៀបនេះឯង ហើយតើញោមដោះស្រាយនូវទុក្ខដ៏ធ្ងន់នៅពេលនោះដោយវិធីណា? មេត្តានិយាយរឿងលំអិតឲ្យស្តាប់ ដោយយកចំពោះតែវិធីដោះស្រាយរបស់ញោមតែប៉ុណ្ណោះ*

- *គឺមិនមានអ្វីទេ ... គេឈ្ងោកមុខឆ្លើយ នៅពេលដែលមិត្តទាំងពីរសម្លឹងមកដោយទឹកមុខញញឹម, នៅពេលឳពុកម្តាយ មិត្តភក្តិ មាសប្រាក់ ការចេះដឹងជួយមិនរួចហើយ ខ្ញុំព្រះករុណា ប្រើវិធីអត់ធន់ ខ្ទិនមុខតស៊ូជាមួយទុក្ខនោះ យប់ថ្ងៃចេះតែកន្លងទៅៗបានដឹងថា សេចក្តីទុក្ខព្រួយ វាចុះបាត់ទៅដោយខ្លួនឯង នៅទីបំផុតបានសប្បាយចិត្តដូចពីមុនដូចជាមិនមានអ្វីកើតឡើង លុះមកដល់ពេលនេះ ខ្ញុំបាទអាចសើចចំអកនូវហេតុការណ៍នៅពេលនោះយ៉ាងសប្បាយ*

- *តើពិតមែនឬ? មិត្តម្នាក់ទៀតសួរបន្ទសសម្លេងទំនងដូចជាលលេង*

- *មែន !!! គេឆ្លើយបញ្ជាក់យ៉ាងច្បាស់*

- *ល្អហើយចុះ ! អាត្មាគាត់នូវពាក្យឡើង, អាត្មាជឿ*

ញោមហើយ បានសេចក្ដីថាញោមបានប្រើជីវិតអស់ទ្រាំក្នុងភាវនិស្សរណៈស្រាយតែនូវសេចក្ដីទុក្ខព្រួយ បានផលប្រសើរណាស់ បើសិនជាញោមបានជួបប្រទះនូវទុក្ខធ្ងន់ៗម្ដងទៀត ញោមអាចប្រើវិធីនេះទៀត បើមានមិត្តភក្ដិណាជួបប្រទះនូវទុក្ខវិបត្តិដ៏ធ្ងន់យ៉ាងនេះ ហើយមកសូមឲ្យជួយពន្យល់ ញោមអាចប្រើវិធីនេះទៀត, **គឺឲ្យអស់ឆន់មែនទេ?**

- កូណាមែន! ខ្ញុំម្ចាស់បានពន្យល់មកច្រើនគ្នាហើយ ហើយរាល់ៗពេលដែលគេបានជឿខ្ញុំម្ចាស់គេបានសប្បាយចិត្តគ្រប់ៗគ្នា មានតែម្នាក់ទេដែលគេមិនព្រមជឿ នៅទីបំផុតគេបាញ់ខ្លួនគេស្លាប់ទៅ ខ្ញុំម្ចាស់គិតថា វាឆ្កួតពិតៗ

- ឃើញហើយឬនៅ, អាត្មានិយាយដោយបានប្រៀប ប៉ុន្តែនៅពេលសួរនេះ ម្ចាស់សំណួរមានៈកំពុងតែកើតឡើងនៅក្នុងចិត្ត ដូច្នេះទើបប្រញាប់រម្ងាប់វាចេញ ទើបផ្ដើមនិយាយតទៅទៀតដោយសម្លេងធម្មតា, អាត្មាបាននិយាយកាលពីមុនមកហើយតើថា ញោមជាអ្នកមានសាសនាពិតមែន ដូចអាត្មាថា មិនត្រឹមតែមានហើយនៅស្ងៀមៗទេ ថែមទាំងបានប្រកាសផ្សាយចេញតទៅទៀតផង

- លោកម្ចាស់មានន័យថាដូចម្ដេច? អ្នកកំលោះធ្វើជិន្ទញទីពីរសួរឡើង

- សាសនា គ្រប់សាសនាកើតមានឡើង ពីព្រោះជីវិតពេញទៅដោយទុក្ខ បើសិនជាមិនមានទុក្ខទេ សាសនាក៏នឹងមិនកើតឡើងដែរ សាសនាគ្រប់សាសនា បើនិយាយ

ដោយការពិតហើយ មិនមានអ្វីប្លែកទេគឺជាវិធីកែដោះស្រាយនូវទុក្ខនោះឯង បើមានទុក្ខធ្ងន់ៗហើយមិនមានវិធីណាអាចជួយកែបានទេនោះ, ដូចជាញោមបានជួបប្រទះនោះ ប៉ុន្តែញោមមានវិធីដោះស្រាយកែទុក្ខបានយ៉ាងល្អនេះហើយគឺសាសនា

- ក៏ប៉ុន្តែនេះជាវិធីកែដំណោះស្រាយ នូវទុក្ខផ្ទាល់ខ្លួនរបស់ខ្ញុំម្នាក់ទេតើ ! នឹងហៅថាជាសាសនាបានដូចម្ដេចកើត? ក្មេងកំលោះអ្នកសិក្សាឆ្លើយឡើង

- សូមកុំភ្លេចថា, អាត្មាឆ្លើយតប, សាសនាធំៗនៅក្នុងលោកនេះ ចាប់ផ្ដើមជាវិធីកែនូវទុក្ខរបស់មនុស្សម្នាក់ឯងដូចគ្នាដែរ គឺដូចជាព្រះពុទ្ធសាសនា ក៏ជាវិធីកែដោះស្រាយនូវទុក្ខរបស់ព្រះពុទ្ធអង្គ គ្រិស្តសាសនា ក៏ជាវិធីកែនូវទុក្ខរបស់ព្រះយេស៊ូគ្រិស្ត លោកទាំងអស់នោះ នៅពេលរកឃើញរបៀបកែដំណោះស្រាយ ឬរំលត់នូវទុក្ខ បានរំលត់ទុក្ខរបស់ខ្លួនឯងហើយ ទើបលោកនឹកអាណិតដល់ជនដទៃដែលធ្លាក់ចុះទៅក្នុងគំនរភ្លើងទុក្ខនោះ ទើបលោកប្រាប់នូវរបៀបរំលត់ទុក្ខ នៅពេលមានអ្នកជ្រះថ្លាជឿ ក៏នាំយកវិធីកែដំណោះស្រាយនូវទុក្ខរបស់ព្រះអង្គ យកទៅប្រើច្រើនឡើងៗ នៅទីបំផុតក៏បានក្លាយទៅជាពុទ្ធសាសនា ឬជាគ្រិស្តសាសនានោះទៅ សូម្បីវិធីរបស់ញោម ដែលញោមបានប្រើមកហើយ ឃើញថាបានផលល្អហើយ ទើបយកមកពន្យល់ឲ្យមិត្តភក្តិនាំគ្នាយកទៅធ្វើតាម នឹងអាចក្លាយទៅជាសាសនាក៏អាចបាន បើកាលណាមានមនុស្សគេចូល

ចិត្តច្រើន គេអាចនាំយកទៅធ្វើតាមតាន់តែច្រើនឡើងៗ ។

កំលោះទាំងបី មិនបានឆ្លើយអ្វីទាំងអស់ គ្រាន់តែងក់ក្បាលតិចៗសម្តែងឲ្យឃើញថា យល់ស្របតាមពាក្យពន្យល់របស់អាត្មា ។

- មនុស្សទាំងអស់តែងមានសេចក្តីទុក្ខ សូម្បីជាមហាសេដ្ឋីមានទ្រព្យសម្បត្តិទាំងកោដិ លាន ក៏នៅតែមិនផុតពីសេចក្តីទុក្ខ ហើយទាំងអស់គ្នាតែងមានវិធីកែដោះស្រាយនូវទុក្ខបែបណាមួយរៀងៗខ្លួន អាចជារបៀបផ្ទាល់ខ្លួនរបស់គេម្នាក់ៗ ភាគច្រើនដែលគេនិយមចូលចិត្តប្រើជានិច្ចនោះហើយគឺជាសាសនារបស់គេ ដូច្នេះទើបអាត្មាហ៊ាននិយាយតាំងតែពីដំបូងមកថា គ្រប់ៗគ្នាត្រូវតែមានសាសនា

- តើលោកម្ចាស់វិញ មានវិធីកែដោះស្រាយនូវទុក្ខផ្ទាល់ខ្លួនដែរឬទេ ? បើមាន មេត្តាបង្រៀនខ្ញុំកូណាផងដើម្បីយកទៅប្រើ, កំលោះអ្នកជំនួញទីមួយបានពោលឡើង

- អាត្មាមិនមានផ្ទាល់ខ្លួនទេ មានតែការជ្រើសរើសក្នុងពុទ្ធវិធី ដែលកែដោះស្រាយនូវទុក្ខ ទើបព្រមទទួលយកមកប្រើ អាត្មាបានពិចារណាមើលមក ឃើញប្រាកដច្បាស់ហើយថា មិនមានសាស្តាអង្គណា បានពិចារណានូវរឿងទុក្ខនិងបានស្គាល់នូវទុក្ខឲ្យច្បាស់ជាងព្រះពុទ្ធអង្គនោះទេ ហើយមិនមានវិធីណា ដែលអាចរំងាប់នូវទុក្ខផ្សេងៗក្នុងលោកដែលបាននូវផលច្បាស់ស្មើ ឬប្រហែលនិងពុទ្ធវិធីនេះទេ ប៉ុន្តែថ្ងៃនេះ ដល់ពេលវេលាដែលអាត្មានឹងត្រូវបដិបត្តិនូវកិច្ចវត្ត កែដោះស្រាយនូវទុក្ខហើយ ចាំពេលក្រោយបើមាន

*ពេលមកសន្ទនាគ្នាទៀត អាត្មានឹងអធិប្បាយនូវវិធីដើម្បីកែដោះស្រាយនូវទុក្ខឲ្យស្លាប់តទៅទៀត ។*

*គំលោះទាំងបីនាក់ បាននិមនចុះក្រាបអាត្មាយ៉ាងមិន លំទោន ជាពិសេសព្រមទទួលពាក្យថា នឹងមកសន្ទនាម្តងទៀត ហើយក៏លាចេញទៅ ចំណែកអាត្មាវិញ ក៏ត្រឡប់ទៅដើរចង្រ្កម ដើម្បីដកនូវឫសគល់នៃកិលេសតទៅ ។*

# សាសនាឯឱសថ

**ពាក្យប្រាំពីរ**

***សាសនាជាថ្នាំផ្សាំផ្សះចិត្ត ទុក្ខភ័យវិបត្តិផងនានា***
***កើតពីកិលេសនិងតណ្ហា នៃសព្វសត្តាក្នុងលោកិយ ។***
***ដូច្នេះត្រូវខំរៀនសិក្សា ត្រិះរិះពិចារណាបានប្រពៃ***
***យល់ច្បាស់ហេតុផលអស់សង្ស័យ បានជាបច្ច័យការបដិបត្តិ ។***
***កុំកាន់សាសនាថាតែមាត់ សាងសាលាវត្តមិនរៀនហាត់***
***កាយវាចាចិត្តឥតដុះខាត់ ខាតគុណសម្បត្តិបង់វេលា ។***
***ត្រូវខំរៀនយល់ស្គាល់គុណព្រះ ព្រះធម៌ចែងច្បាស់ពុទ្ធដីកា***
***ព្រមទាំងព្រះសង្ឃអង្គរតនា ញុំាងចិត្តជ្រះថ្លាក្នុងព្រះគុណ ។***
***មាន សីល សមាធិ បញ្ញា ចាត់ជាមាគ៌ាបង្កើតបុណ្យ***
***បដិបត្តិបូជាជាទ្រព្យធន បានឱសថគុណព្យាបាលចិត្ត ៕***

ដោយឧបាសក មុិញ សារ៉ាង

# ៥. ចិត្តានុភាព

**នៅ**ពេលនេះ ជាពេលជិតឈានមកដល់នូវបុណ្យចូលឆ្នាំថ្មីហើយ មានប្រជាជនមកពីបាងកក និងស្រុកខេត្តផ្សេងៗ ចាប់ផ្ដើមសោត់ហូរចូលមកដល់ស្រុកឆៀងម៉ៃ ដើម្បីមកចូលរួមនូវមហាសង្ក្រាន្ត ដែលល្បីឈ្មោះនៃប្រជាជននៅស្រុកឆៀងម៉ៃ ភាគច្រើនជាកំលោះៗដែលប្រាថ្នាមកលេងដើម្បីមកមើលស្រីស្អាតៗ ក្នុងភាគខាងត្បូង ចំណែកមនុស្សចាស់ៗវិញ ប្រាថ្នាមកមើលភូមិភាគនៃស្រុកភូមិ ដី និងអរិយធម៌ប្រពៃណី ទំនៀមទំលាប់ដ៏ល្អរបស់ស្រុកនេះ ប៉ុន្តែអាចមានមនុស្សចាស់មិនតិចដែរ ដែលមកមានបំណងតែម៉្យាង គឺដូចជាក្មេងៗកំលោះៗនោះដែរ ពីព្រោះមនុស្សបុថុជ្ជន ដែលនៅមានចិត្តពោរពេញទៅដោយកិលេស មិនថានៅក្នុងភេទ ឬចំណាស់ណាក៏ដោយ តែងតែនៅពេញចិត្តក្នុងរូប សម្លេង ក្លិន រស សម្ផស្ស ធម្មារម្មណ៍ ដ៏ផ្អែកល្អទាំងអស់ ។

មនុស្សមកពីស្រុក ខេត្តក្រៅផ្សេងៗទាំងនេះ នាំគ្នាដើរលេងជាក្រុមៗ ហើយដើរមើលគ្រប់ទីកន្លែង ដូចជាមិនឲ្យមានកន្លែងអាថ៌កំបាំងផ្សេងៗ នៅក្នុងឆៀងម៉ៃនៅសល់សោះឡើយ ។

នៅក្នុងវិត្តជើងភ្នំឌយសុថេប ដែលអាត្មាគង់នៅមានមនុស្សចូលមកលេងថែមច្រើនឡើងៗរាល់ៗថ្ងៃលុះត្រា

មើលទៅពាសពេញក្នុងបរិវេណវត្ត ហើយមានសម្លេងអឺងកង អ៊ូអរ ដូចជាមានបុណ្យធំនៅក្នុងវត្តតែម្តង អាត្មាពិចារណាឃើញថា សភាវៈការរបៀបនេះមិនសមគួរជាកន្លែងសម្រាប់បំពេញធម៌អាថ៌ទេ ដើម្បីរកការវិវេកនិងបដិបត្តិសមាធិ ទើបរៀបចំបរិក្ខារដើម្បីនឹងធ្វើដំណើរចេញទៅសម្រាក និងបំពេញព្យាយាមក្នុងធម៌នៅលើព្រះធាតុដោយស្ងប់ បណ្តោះអាសន្នមួយរយៈពេលសិន ។ ដូច្នេះក្នុងព្រឹកថ្ងៃមួយ ក្រោយពេលឆាន់ព្រឹករួចហើយ អាត្មាបានស្ពាយបាត្រ និងស្ពាយក្រុតចេញដើរផ្លូវ ទម្រាំឡើងទៅដល់ព្រះធាតុជិតម៉ោង ៤ រសៀល ។

ព្រះមហាថេរៈ ដែលលោកមើលការខុសត្រូវនៅក្នុងវត្តអារាមនេះ លោកបានជួយរៀបចំឲ្យអាត្មាមកនៅសម្រាកក្នុងកុដិមួយតូច ដែលស្ថិតនៅខាងៗភ្នំផ្នែកខាងកើតឆៀងទៅខាងត្បូងនៃអន្លង់ព្រះធាតុ ។ នៅជិតៗកុដិមានដើមឈើច្រើនយ៉ាងកំពុងបញ្ចេញផ្ការីកស្គុះស្គាយ ឲ្យក្លិនក្រអូបត្រដាក់រហូត សូម្បីមានប្រជាជនមកថ្វាយបង្គំព្រះធាតុមួយថ្ងៃៗជាច្រើននាក់ក៏ដោយ ក៏ឥតមានរំខានដល់ការបដិបត្តិធម៌របស់អាត្មាសោះឡើយ ពីព្រោះកុដិដែលអាត្មានៅនោះចុះទាបទៅច្រើន មិនអាចចុះទៅដើរលេងរហោតរហូតបានទេ សូម្បីតែសម្លេងមនុស្សនិយាយគ្នាក៏មិនអាចឮទៅដល់ មានតែសម្លេងរគាំងប៉ុណ្ណោះដែលឮស្សូរមួយដងមួយកាល

រាល់ពេលរសៀល ព្រះអាទិត្យគោចរលិចផុតទៅអន្លង់ព្រះធាតុទៅទិសខាងលិច នៅពេលប្រជាជនចុះមកអំពី

ព្រះធាតុ ទៅដល់ទីខេត្តអស់ហើយ ។ អាត្មាចូលចិត្តទៅអង្គុយលើជើងម៉ា ដែលគេតាំងនៅទីវាលជិតមាត់ទឹកផ្នែកទិសខាងត្បូងនៃអង្គព្រះធាតុ ហើយមើលទៅរូបចម្លាក់ផ្សេងៗ ដែលគេដាក់តម្រៀបគ្នានៅខាងមុខ ។

នៅស្រុកធៀងម៉ៃទាំងមូល ពេលសម្លឹងមើលពីលើភ្នំសុថេបមក ឃើញដូចកំទេចកញ្ចក់តូចៗ ពេញដំបូលនៃគេហដ្ឋាននិងឃើញដើមឈើព័ណ៌បៃតង ខ្ចី មានចុងយ៉ាងស្រួចនៃព្រះចេតិយសៀតឡើងមកលើដោយចន្លោះៗ ខាងផ្នែកឆ្វេងនិងខាងស្តាំ ឃើញមានដើមឈើ ព័ណ៌បៃតងជាជួរៗចេញមកពីភ្នំ តាមផ្លូវចូលមកក្នុងស្រុកនោះ គឺជាផ្លូវឈ្មោះហួយកែវនិងផ្លូវសុថេប ។ រវាងផ្លូវទាំងពីរនោះ មានវាលទំនេរពណ៌លឿង ហើយបានឃើញវាលស្រែពណ៌បៃតង ជាប់ពីស្រុកចេញទៅបន្តិចបន្តួច ឃើញព្រះចេតិយមានពណ៌មាស គឺក្នុងវិត្តភ្នំមានសួនច្បារលើបចេញមកក្នុងជួរនៃដើមឈើនោះ នៅពេលប៉ះត្រូវជាមួយពន្លឺថ្ងៃក្នុងពេលល្ងាច គឺចេញពន្លឺស្អាតគួរឲ្យជាប់ចិត្ត ។ នៅឆ្ងាយបន្តិចខាងស្តាំដៃ ឃើញមានផ្លូវមួយកាត់តាមវាលស្រែ ចុះទៅទិសខាងលិចមានរថយន្តយ៉ាងច្រើន កំពុងបើកបរនៅលើផ្លូវ មើលពីលើទៅឃើញដូចជាសត្វស្រមោច ដែលកំពុងវារនៅតាមផ្លូវឃឹតៗ ។ ឆ្ងាយទៅៗ ចេញទៅតាមទិសខាងកើតឆ្ពោះទៅទិសខាងលិច នៅឈរក្នុងផ្សែងនៃពពកនាពេលតិម្ភរដូវ របស់គ្រប់យ៉ាងពេលដាក់បញ្ចូលគ្នាទៅក៏ឃើញជាជួរៗយ៉ាងស្អាត ដែលមិនងាយបានជួបប្រទះ

នៅក្នុងប្រទេស ។ អាត្មាចូលចិត្តទៅអង្គុយមើលហើយសរសើរនូវចំណុចនេះណាស់ ហើយតែងតែយកមកគិតប្រៀបធៀបនៅក្នុងផ្លូវធម៌របស់ព្រះបរមសាស្ដា ។ អំពីទីខ្ពស់ដូច្នេះ គ្រប់យ៉ាងទាំងអស់មើលទៅឃើញតូចៗលុះត្រាតែគ្មានន័យនិងតម្លៃអ្វីសោះឡើយ សេចក្ដីខ្ពស់នេះបានជួយឲ្យឃើញមនុស្សក្លាយទៅជាសត្វលោកមានខ្លួនតូចៗ តោងនៅតាមផែនដី ហើយឃើញសម្បត្តិទ្រព្យទាំងឡាយទាំងពួង គ្រាន់តែជាគ្រឿងល្បែងលេងរបស់មនុស្ស ។

ធាតុអាកាសដែលត្រជាក់ សប្បាយនឹងសេចក្ដីស្ងប់ស្ងាត់នៅលើកំពូលភ្នំនេះ ជួយឲ្យការបដិបត្តិដើម្បីដកនូវឫសនៃទុក្ខរបស់អាត្មាឲ្យវាប្រព្រឹត្តទៅបានលឿនឆាប់ ផ្លូវបដិបត្តិរបស់អាត្មា គឺទៅតាមគោលនៃសតិបដ្ឋាន ៤[១] គឺការតាំងសតិ សេចក្ដីភ្ញាក់ខ្លួន និងសម្បជញ្ញ សេចក្ដីដឹងខ្លួននៅក្នុងកាយ នៅពេលកាយស្ថិតនៅក្នុងឥរិយាបថឈរ ដើរ អង្គុយ ដេក គឺឲ្យដឹងទាន់ថាកំពុងឈរ ដើរ អង្គុយ ដេក នៅពេលរាងកាយធ្វើនូវអាការៈបរិភោគ ផឹក ធ្វើកិច្ចការ និងនិយាយ ក៏ឲ្យដឹងថាខ្លួនកំពុងបរិភោគ ផឹក ធ្វើកិច្ចការ និយាយនៅពេលដកដង្ហើមចូលដើមទ្រូងរីក ក៏ឲ្យដឹងទាន់ថាកំពុងដកដង្ហើមចូល ហើយដើមទ្រូងរីក នៅពេលដកដង្ហើមចេញ ដើមទ្រូងផតក៏ឲ្យដឹង ។ នៅពេល

(១) **សតិបដ្ឋាន ៤** ៖ ១. កាយានុបស្សនា, ២. វេទនានុបស្សនា, ៣. ចិត្តានុបស្សនា, ៤. ធម្មានុបស្សនា ។

បត់ជើងតូច-ធំ ក៏ត្រូវឲ្យដឹង សរុបសេចក្តីទៅគឺថា មិនព្រមឲ្យការកម្រើកគ្រប់យ៉ាងនៃកាយ សូម្បីតែមួយពព្រិចភ្នែក គឺមិនឲ្យចន្លោះពីការកំណត់ដឹងផ្សេងៗ ក្នុងរាងកាយឲ្យមានសតិនិងសម្បជញ្ញៈជានិច្ច ។

ប្រការទីពីរ តាំងសតិសម្បជញ្ញៈនៅក្នុងចិត្ត ចាំសង្កេតមើលនូវការកម្រើករបស់ចិត្តគ្រប់វិនាទី នៅពេលចិត្តគិត ក៏ឲ្យដឹងថាកំពុងគិត បើចិត្តនៅស្ងៀម ក៏ឲ្យដឹងថានៅស្ងៀម បើសេចក្តីលោភកើតឡើង ក៏ឲ្យដឹងថាសេចក្តីលោភកំពុងកើតឡើងហើយ ។ នៅពេលសេចក្តីក្រោធ សេចក្តីវង្វេង សេចក្តីច្រណែន ពេលរីករាយ ពេលអផ្សុក ពេលខ្លាច ។ល។ កើតឡើង ក៏ត្រូវឲ្យដឹងថាកិលេសរបៀបនោះៗ កំពុងកើតឡើងហើយដែរ ។

ប្រការទីបី គឺតាំងសតិសម្បជញ្ញៈទុកក្នុងវេទនា គឺសេចក្តីដឹងផ្សេងៗ ។ នៅពេលសេចក្តីដឹងជាសុខកើតឡើង ក៏ឲ្យដឹងថាសុខកំពុងកើតឡើង នៅពេលទុក្ខកើតឡើង ក៏ឲ្យដឹងថាទុក្ខកំពុងកើតឡើង ពេលនៅស្ងៀមៗ មិនមានសុខ មិនមានទុក្ខ ក៏ឲ្យដឹងថាកំពុងនៅស្ងៀមៗ ។

ប្រការទីបួន ទាញនូវសតិសម្បជញ្ញៈទុកក្នុងធម្មៈ គឺនៅពេលដែលបំពេញព្យាយាមនោះ បើបញ្ញាកើតសេចក្តីយល់ដឹងច្បាស់ក្នុងធម្មៈ "១" ណាមួយឡើងនោះ ក៏ឲ្យដឹងនូវធម្មៈនោះៗ កំពុងកើតឡើង ។

ការប្រតិបត្តិយ៉ាងម៉ត់ចត់នៅក្នុងសតិបដ្ឋានបួន ចាំសង្កេតមើលនូវកាយ ចិត្ត វេទនា និងធម៌ ដូចជាអ្នកនៅ

យាមទ្វារ ប្រកបដោយការរក្សាសីលឲ្យបានបរិសុទ្ធដោយការសង្រួមភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត និយាយឲ្យបានតិចបំផុត បរិភោគ ដេកឲ្យល្មម ធ្វើយ៉ាងនេះចិត្តរបស់អាត្មា ចាប់ផ្ដើមតាំងមាំនៅក្នុងសមាធិ ព្រមទៅដោយចិត្តជាសមាធិនេះឯង ហើយបានដឹងថា ត្បូបញ្ញាបានទទួលនូវការផុសខាត់បានស្រួចមុត ល្អិតប្រណីតឡើង អាចមើលឃើញរបស់ដែលមិនដែលឃើញ កាលពីមុនមកក្នុងជីវិតនេះ ។ លើកឧទាហរណ៍ដូចជាការលើកជើង ឈានជើង ដែលគ្រប់គ្នាតែងធ្វើជានិច្ចនោះ បើឃើងមើលដោយបញ្ញាដែលគ្រោតគ្រាត នឹងឃើញត្រឹមតែមួយរយៈប៉ុណ្ណោះ គឺឈានជើងនីមួយៗ ការលើកជើងឡើងនិងពេលដាក់ជើងចុះ ប៉ុន្តែបើមើលដោយបញ្ញាដ៏ល្អិតដែលសមាធិអប់រំបានហើយ នឹងឃើញថាការលើកជើងឈានជើងនោះ ជាការដើរដែលតម្រូតគ្នានូវការ ប្រកបដោយរយៈផ្សេងៗច្រើនណាស់ គឺមានការបញ្ចេញកម្លាំងនៅពេលលើកជើងឡើង ពេលជើងផុតអំពីដី ដឹងថាមានសម្ពស្សត្រជាក់នៅត្រង់បាតជើងហើយមានការបញ្ចេញកម្លាំងទៀត ដើម្បីជម្រុញជើងឲ្យទៅខាងមុខ ។ នៅពេលដែលជើងរុញប៉ះខ្យល់នៅខាងមុខ មានសម្ពស្សត្រជាក់ពេញជើង មានការបញ្ចេញកម្លាំងដើម្បីនឹងដាក់ជើងចុះ ដឹងថាមានការសង្កត់នូវខ្យល់ដល់បាតជើងនៅពេលជើងដល់ដី បានដឹងថាមានការណែនហើយឈឺតិចៗនៅបាតជើង ។ ចិត្តដែលជាសមាធិ មានបញ្ញាយ៉ាងស្រួចមុតកើតឡើងហើយអាចតាមមើលផ្នែកល្អិតនៃ

ភេរៈផ្លូវទាំងនោះយ៉ាងច្បាស់ ។ ព្រោះហេតុនោះបញ្ញាដែលកើតពីសមាធិទើបអាចធ្វើឲ្យដឹងការពិតបានយ៉ាងល្អិតច្បាស់ជាងចិត្តរបស់មនុស្សយើងធម្មតារប់រយដង ប្រៀបដូចការមើលរបស់ដោយកែវឆ្លុះ និងការមើលដោយភ្នែកធម្មតា ។

មុនពេលចូលមកបួស លោកគ្រូបានបង្រៀនអាត្មាថា ៖

- ទឹកដែលនឹងស្ងប់ សម្រាមផ្សេងៗដែលនៅលើទឹកតែងតែធ្លាក់ចុះទៅដេកនៅបាតពាងធ្វើឲ្យទឹកនោះថ្លា នៅពេលទឹកនោះថ្លាតែងមានលក្ខណៈដូចជាកញ្ចក់ យើងអាចឆ្លុះមើលមុខរបស់យើងបានជំនួសកញ្ចក់ យ៉ាងណាមិញចិត្តដែលស្ងប់នៅនឹងជាសមាធិហើយ កិលេសផ្សេងៗក៏ធ្លាក់ចុះទៅបាតដែរ ធ្វើឲ្យចិត្តបានថ្លាស្អាតអាចឆ្លុះមើលនូវរបស់ផ្សេងៗបានច្បាស់ល្អ ។

មនុស្សដែលកំពុងដើរប្រញាប់ ឬអ្នកដែលអង្គុយនៅលើឡានដែលកំពុងបើកបរ តែងមើលទៅរបស់អ្វីៗមិនសូវច្បាស់ទេ បើចង់មើលឲ្យឃើញច្បាស់នោះ គឺត្រូវឈប់សិន ។ ឯចិត្តរបស់មនុស្សយើងក៏ដូចគ្នាដែរ នៅពេលយើងក្រោកពីដេក ចិត្តតែងចាប់ផ្តើមរត់ពីអារម្មណ៍នេះទៅរកអារម្មណ៍នោះ មិនសូវបានឈប់សម្រាកសោះឡើយ ទើបឃើញនូវរបស់ផ្សេងៗហៀបអណ្តែតអណ្តូង បើចង់ឲ្យឃើញច្បាស់ត្រូវធ្វើចិត្តឲ្យឈប់ជាសមាធិ ។

ពេលាមនុស្សដែលនឹងបាញ់កាំភ្លើង គេត្រូវបិទភ្នែក

ម្ជាង ហើយគេផ្ទុំងតម្រង់នូវភ្នែកម្ជាង ។ នៅពេលយើងពិចារណានូវរបស់ណាមួយឲ្យបានច្បាស់នោះ យើងត្រូវបិទនូវទ្វារអារម្មណ៍ផ្សេងៗ ដូចជាភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ជាមុនសិន នៅសល់តែទ្វារមួយគឺមនោទ្វារ ដែលមានសមាធិការពារយ៉ាងម៉ត់ចត់ ។

រាងកាយតែងតែកម្រើកជានិច្ចទើបមានកម្លាំង ប៉ុន្តែខាងផ្លូវចិត្តវិញត្រូវឈប់នៅស្ងៀមទើបមានកម្លាំង ។ ប្រសិនណាឲ្យចិត្តបែកខ្ចាត់ខ្ចាយទៅគ្រប់ទីកន្លែង នឹងមានកម្លាំងតិច ។ ដូចជាយើងយកកញ្ចក់ទៅដាក់នៅកណ្តាលថ្ងៃមានពន្លឺខ្លាំង ក្តៅខ្លាំងអាចដុតបំផ្លាញនូវរបស់ផ្សេងៗបាន ឯចិត្តរបស់យើងក៏ដូចគ្នាដែរ ប្រសិនជារួមគ្នានៅក្នុងចំណុចតែមួយដោយសមាធិនឹងមានពន្លឺ គឺបញ្ញាច្រើនអាចដុតបំផ្លាញនូវអវិជ្ជា តណ្ហាឲ្យអស់ទៅបានដោយគ្មានសេសសល់ ។

ពាក្យប្រៀនប្រដៅដោយការប្រៀបធៀប ដែលគួរឲ្យស្តាប់ ដែលបានពោលមកខាងលើនេះ អាត្មាយល់ស្របតាមលោកគ្រូ គឺជាសេចក្តីពិតមួយរយភាគរយ ពីព្រោះអាស្រ័យនៅការជួបប្រទះតាមផ្លូវចិត្តរបស់ខ្លួនឯងជាការពិតជាសាក្សីស្រាប់ ។

ចំណែកផលខាងផ្លូវចិត្តនោះ អាត្មាបានយល់ថាមានចិត្តស្ងប់ សុខត្រជាក់ ស្អួត ដោយមិនដែលបានជួបប្រទះកាលពីមុនមកសោះក្នុងមួយជីវិតនេះ ដែលជាសេចក្តីសុខខាងលោកិយវិស័យ ។ កាលនៅជាគ្រហស្ថក៏ធ្លាប់បានទទួលនូវរបស់គ្រប់យ៉ាង ដូចជាសេចក្តីសុខដែលកើតអំពី

ការមានទ្រព្យ សុខបានអំពីបានចាយនូវប្រាក់ សុខកើតអំពីបានទិញនូវរបស់ល្អហ៊ឺហា ពេញចិត្តនូវរូប សម្លេង ក្លិន រស សម្ផស្ស យកមកបម្រើនូវជីវិត សុខកើតអំពីស្នេហា សុខកើតអំពីការបានសម្រេចក្នុងកិច្ចការ និងការរៀនសូត្រជាដើម ៗ សេចក្តីសុខទាំងអស់នេះរួមគ្នាទៅហើយ ក៏មិនទាន់ស្មើមួយចំណិតនៃសេចក្តីសុខក្នុងធម៌ ដែលបានទទួលនូវពេលដែលបានពិចារណាមើលឲ្យល្អិត ហើយឃើញថាមនុស្សឃើងខំរត់រកទ្រព្យសម្បត្តិ ដោយសេចក្តីនឿយហត់ គឺដើម្បីឲ្យកើតនូវសេចក្តីសប្បាយរីករាយ តែងគិតថាខ្លួនមានទ្រព្យសម្បត្តិច្រើនហើយ មានស្មើនឹងគេហើយ មិនភ័យនឹងការអត់ឃ្លានទៀតទេ ៗ ចំណែកអ្នកដែលស្វែងរកគូស្នេហា គឺដើម្បីឲ្យកើតនូវសេចក្តីស្ងប់ចិត្ត ដោយបាននឹង ថាខ្លួនមានគូស្នេហាហើយៗ សេចក្តីសុខខាងផ្លូវភេទក៏បានទទួលដូចប្រាថ្នាដែរ ៗ ការដែលមនុស្សឃើងខំស្វែងរកនូវរបស់ផ្សេងៗ ក៏ពីព្រោះតែឲ្យចិត្តបានស្ងប់តែប៉ុណ្ណោះ គិតថាខ្លួនមិនចាញ់ប្រៀបអ្នកដទៃទេ បានស្មើនឹងគេដែរ ៗ ទើបអាចសរុបបានថា សេចក្តីសុខដែលពិតប្រាកដនោះមានតែមួយទេគឺ **សេចក្តីស្ងប់ផ្លូវចិត្ត** ដូចដែលព្រះបរមសាស្តាទ្រង់ត្រាស់ថា៖

**នត្ថិ សន្តិ បរំ សុខំ**

ពុំមានសេចក្តីសុខដទៃក្រៅពីសេចក្តីស្ងប់ឡើយ ៗ

គ្រាន់តែខុសគ្នា គឺសេចក្តីស្ងប់ខាងផ្លូវលោកត្រូវ

*អាស្រ័យនូវវត្ថុផ្សេងៗ ប៉ុន្តែសេចក្តីស្ងប់ក្នុងព្រះធម៌វិញ ជាសេចក្តីស្ងប់ដែលគេឃើញបាន អំពីចិត្តដោយស្មោះត្រង់ មិនបាច់ពឹងទៅលើវត្ថុ ដោយសេចក្តីស្ងប់ខាងផ្លូវលោក ត្រូវពឹងទៅលើវត្ថុដែលជារបស់មិនទៀងទាត់ ដូច្នេះសុខផ្លូវលោកទៅជាមិនទៀងទាត់ទៅវិញដែរ ចំណែកស្ងប់ខាងផ្លូវធម៌វិញ ជាសេចក្តីសុខស្ងប់ស៊ីបរិសុទ្ធ មិនបាច់ពឹងទៅលើវត្ថុ ទើបជាសុខយ៉ាងយូរអង្វែង ហើយល្អិតប្រាកដជាង ។*

*អាត្មាបានបំពេញព្យាយាមតទៅជានិច្ច ទាំងពេលថ្ងៃ និងពេលយប់ ដោយមិនព្រមឲ្យពេលវេលាហួសទៅ ដោយឥតប្រយោជន៍ក្នុងផ្នែកចិត្តនោះឡើយ ។ ក្រៅពីបាន ទទួលនូវសេចក្តីស្ងប់ត្រជាក់យ៉ាងជ្រៅជ្រះហើយ ទើបនឹងថាចិត្តថ្លាស្អាត ប្រៀបបាននឹងវង់ព្រះចន្ទនូវថ្ងៃពេញបូណ៌មី អណ្តែតចេញមកនៅក្នុងផ្ទៃអាកាសលើមេឃ ធ្វើឲ្យគិតទៅដល់ពាក្យប្រៀនប្រដៅរបស់លោកគ្រូដែលថា៖*

*- ចិត្តរបស់មនុស្សយើង នៅពេលដែលចិត្តបាន ស្ងប់នឹងទៅជាសមាធិយ៉ាងពិតប្រាកដហើយ របស់ឬធូលីផ្សេងៗដែលធ្វើឲ្យចិត្តកករល្អក់ខូចគុណភាព តែងតែធ្លាក់ចុះទៅបាតរបស់ចិត្ត ធ្វើឲ្យចិត្តថ្លាស្អាត ។ សំរាមរបស់ចិត្ត មាន ៥ យ៉ាង ដែលហៅថា នីវរណៈ ៥ ប្រែថាកិលេសដែលជាគ្រឿងរារាំងនូវសេចក្តីចម្រើនខាងផ្លូវចិត្តទាំង ៥ យ៉ាងនេះគឺ៖*

- **កាមឆន្ទ** *សេចក្តីពេញចិត្ត ត្រេកអរនៅក្នុងរូប សម្លេង ក្លិន រស សម្ផស្ស ធម្មារម្មណ៍ផ្នែកល្អ នៅពេល*

ចិត្តត្រូវកាមឆន្ទៈគ្របសង្កត់ហើយ ចិត្តក៏នឹងទៅជាវិករាយ ភ្លើតភ្លើន ធ្វើឲ្យខូចគុណភាពនោះទៅ ;

- **ព្យាបាទ** សេចក្តីគុំគួន ខឹងខ្នាញ់ មិនពេញចិត្ត នៅពេលបានជួបនឹង រូប សម្លេង ក្លិន រស សម្ផស្ស ធម្មារម្មណ៍ផ្អែកខាងអាក្រក់ ;
- **ថីនមិទ្ធ** ការប្រអូសក្ញុញទ្រាន់ និងការងងុយដេក គិតអ្វីមិនសូវឃើញ ភ្លេចភ្លាំងដោយការងោកងក់ មកពីការទទួលទានអាហារច្រើនពេកធ្វើឲ្យទន់ខ្សោយ ;
- **ឧទ្ធច្ចកុក្កុច្ច** សេចក្តីរាយមាយ និងសេចក្តីរសាប់-រសល់ឬក្តៅក្រហាយក្នុងចិត្ត រវើរវាយរំខានចិត្តអណ្តែតអណ្តូង ;
- **វិចិកិច្ឆា** សេចក្តីសន្ទិះសង្ស័យ មិនដាច់ស្រេច ក្នុងចិត្តគាត់ចិត្តមិនដាច់ស្រេច លេបមិនចូលខ្ជាក់មិនចេញ ប្រាប់មិនត្រូវ តាមធម្មតា ដូចជាមានបន្លាមកខ្ទាស់នៅក្នុងចិត្តទាំង ៥ យ៉ាងនេះ តែងតែមានកង្វល់ខ្វល់ខ្វាយនៅក្នុងចិត្តរបស់មនុស្សយើងជាធម្មតា ជាសាមញ្ញគ្រប់ៗគ្នានៅក្នុងជីវិតប្រចាំថ្ងៃ ប្រកបទៅដោយធម៌ទាំង ៥ នេះឯង តែងតែធ្វើការផ្លាស់ប្តូរវេនគ្នា ចូលមកបំផ្លាញនូវគុណភាពរបស់ចិត្តថ្លើមនៃមនុស្សយើងគ្រប់វេលា គឺតាំងតែពីពេលភ្ញាក់ឡើងរហូតដល់ពេលចូលដេកវិញ ប្រសិនជាមានគេនៅចាំសង្កេតមើលនូវទឹកមុខរបស់មនុស្សម្នាក់ៗ ដែលកំពុងធ្វើការងារចិញ្ចឹមជីវិតរាល់ថ្ងៃ ៗ យើងអាចសង្កេតឃើញថា នៅពេលខ្លះមុខគេមាំដោយការមិនពេញចិត្ត មានពេលខ្លះ

ទៀតគេស្រែកទាំងកំបុតកំបុយ ពេលខ្លះទៀតគេសើចសុយ គឺផ្លាស់ប្តូរផងគ្នា តាំងពីព្រឹកព្រលឹមរហូតដល់យប់ ។ នេះហើយដែលធ្វើឲ្យចិត្តខូចគុណភាព មិនមានសេចក្តីស្ងប់សុខត្រង់ណាសោះឡើយ គិតតែរវើរវាយ ការយល់ក៏រវើរវាយ ការចងចាំក៏ដោយក៏ជាការរវើរវាយ អ្វីគ្រប់យ៉ាងទាំងអស់មានការអណ្តែតអណ្តូង ការរស់នៅ ការធ្វើកិច្ចការអ្វីៗ មួយថ្ងៃៗ គឺដូចជានៅក្នុងការយល់សប្តិ ដូច្នេះពាក្យរបស់អ្នកប្រាជ្ញបានពោលទុកថា «**ជីវិតគឺជាការយល់សប្តិ**» នេះជាសេចក្តីពិតណាស់ ចំពោះអ្នកមានចិត្តងងឹតងងល់ ដោយមានបន្លាមកខ្ទាស់ជាប់នៅក្នុងចិត្តទាំង ៥ ដែលបានពោលមកហើយនេះ ។

ប៉ុន្តែនៅពេលចិត្តបានតាំងមាំជាសមាធិហើយ ងសំរាមផ្សេងៗនៃចិត្ត ក៏បានធ្លាក់ចុះបាត់អស់ទៅហើយ ទើបបានដឹងថាចិត្តថ្លាស្អាតអាចធ្វើការ ឬមើលទៅទីផ្សេងៗបានយ៉ាងច្បាស់ប្រសើរ និងនាំចិត្តទៅរំឭកដល់ហេតុការណ៍អ្វីមួយ ឬអាចនឹកឃើញឡើងវិញដែលយើងធ្លាប់បានរៀនចេះចាំកាលពីមុនមកអាចនឹកឃើញបានយ៉ាងច្បាស់ ហើយអាចគិតឃើញរឿងរ៉ាវផ្សេងៗ ដែលកាលពីដើមយើងនឹកមិនឃើញ គិតអ្វីៗឃើញធ្លុះធ្លាយច្បាស់ស្រឡះគ្មានទាក់ទើ ហើយបើមានបញ្ហាផ្នែកវិជ្ជាផ្សេងៗ ដែលពិបាកស្មុគស្មាញគិតមិនចេញ ស្រាប់តែនឹកឃើញ គិតចេញមកនៅពេលដែលចិត្តជាសមាធិ ។

អាត្មានឹកស្តាយនូវពេលវេលា ដែលបានកន្លងហួស

*ទៅក្នុងអតីតៈនៅពេលដែលកំពុងសិក្សា មិនបានដឹងនូវសេចក្តីដ៏អស្ចារ្យនៃចិត្តនេះសោះ ហើយមិនបានអប់រំចិត្តទៅតាមផ្លូវព្រះពុទ្ធសាសនា ទើបក្នុងការសិក្សាដូចជាការយល់សប្តិ សូម្បីបានប្រឡងជាប់ហើយបានលេខល្អជានិច្ចក៏ដោយ គឺមកពីសេចក្តីមានះ ការព្យាយាមជិតស្លាប់ ប្រសិនជាអ្នកសិក្សាបានអប់រំចិត្ត ទៅតាមគោលនៃសមាធិវិញ និងបានជាប្រយោជន៍យ៉ាងធំក្នុងការសិក្សារៀនសូត្រនេះ ...*

# បន្លាចិត្ត

**ពាក្យប្រាំពីរ**

| | |
|---|---|
| ***បើបន្លាមុតត្រូវដោះចេញ*** | ***កុំទុកទោម្មេញឈើពើតផ្សា*** |
| ***ឯនីវរណៈប្រាំប្រការ*** | ***ទុកដូចបន្លាចាក់ដោតចិត្ត ។*** |
| ***ត្រូវព្យាយាមដោះដោយបញ្ញា*** | ***រួមដោយសមាធិដោយពិត*** |
| ***ដកហូតបន្លាចេញពីចិត្ត*** | ***ទើបឃើញធម៌ពិតចិត្តសុខសាន្ត ៕*** |

ដោយឧបាសក ម៉ិញ សារ៉ាង

# ឧបាទាន

**ពាក្យប្រាំពីរ**

*ឧបាទានមានខន្ធជាប្រភព សត្វវង្វេងជ្រប់ដោយ អវិជ្ជា*
*សម្គាល់ខន្ធប្រាំថា អត្តា ដូចជាសត្វស្វាគូទជាប់ជ័រ ។*
*ចង់រើទៅណាក៏មិនបាន ប្រកាន់កាយប្រាណចិត្តអន់អរ*
*មោហ៍បាំងឥតយល់ថាជាធម៌ ទុក្ខសោកមានមកក្នុងលោកិយ ។*
*តែងតែអន្ទោលទៅក្នុងភព ទោះទាំងថ្ងៃយប់តក់ស្លុតភ័យ*
*ខំរៃរកខំពុនធ្វន់ក្រាស់ក្រៃ ក្មេងចាស់ប្រុសស្រីដឹងមិនដល់ ។*
*ត្រូវខំសន្សំនូវ បញ្ញា ឃើញត្រៃលក្ខណាអស់ចម្ងល់*
*វិបស្សនាញាណបានដឹងយល់ សម្គាល់ខន្ធប្រាំ អនត្តា ។*
*ដកចិត្តចេញពីឧបាទាន ដោយមានពន្លឺគឺ បញ្ញា*
*ឃើញច្បាស់ខន្ធប្រាំថាជាមារ ខ្ពើមលះដាក់លាលែងអាល័យ ៕*

ដោយឧបាសក មុិញ សារ៉ាំង

# ៥. ញ្ញាះទៅកាន់ផែនដីវិញ

កិច្ចវិត្តប្រចាំថ្ងៃរបស់អាត្មានៅលើព្រះធាតុ លើភ្នំសុមេរុ ក៏នៅមាននិរន្តរភាពដូចអំពីមុនៗ ដូចកាលនៅក្នុងវិត្តលើងភ្នំដែរ គឺគ្រាន់តែមានការខុសគ្នានៅទីកន្លែងប៉ុណ្ណោះ និងក្នុងបរិវេណគុនិចឆ្ងាតដាងបន្តិច ទើបប្រើពេលវេលាក្នុងការបោសជូតតិចជាង ហើយជំនួសនូវការពិចារណានៃទឹកហេតដក់ទៅតាមមាត់ច្រាំង ដែលនៅក្នុងអាងទឹកនោះ ។ ឥឡូវនេះទៅអង្គុយនៅលើកៅអីថ្ម ហើយពិចារណាទេសភាពនៅខាងក្រោមជំនួសវិញ ប៉ុន្តែបានផលផ្នែកផ្លូវចិត្តប្រហែលគ្នា ពីព្រោះពេលនៅលើកំពូលភ្នំនេះមើលឃើញអាគារ ផ្ទះសម្បែង និងវាលស្រែចំការទៅជារបស់តូចៗ ឥតមានតម្លៃអ្វីទាល់តែសោះ ធ្វើឲ្យឃើងដកចិត្តចេញពីឧបាទាន សេចក្តីហួងហែងក្នុងរបស់ទាំងអស់នោះ ហើយឃើញមនុស្សដូចជាចំណុចមួយតូចៗគោងនៅលើផែនដី ធ្វើឲ្យឃើញមនុស្សដូចជាសត្វមួយតូចៗ ដូចគ្នានិងសត្វផ្សេងៗ ។ ការបានឃើញដូច្នេះ អាចជួយសម្រាលនូវ អហង្ការមមង្ការ[១] បានយ៉ាងល្អប្រពៃ ។

ចំណែកការបិណ្ឌបាតវិញ នៅលើព្រះធាតុឯយសុ -

---

(១) អហង្ការមមង្ការ ឬ អហំមមំការ : សេចក្តីប្រកាន់ថាអញ ថារបស់អញ; មានះក្រៃពេក : មានអហង្ការមមង្ការតែរៀងរាល់ខ្លួន ឥតអ្នកណាស្តាប់អ្នកណា; ពួករេហ៍ពលទាំងពីរខាង សុទ្ធតែមានអហំមមំការដូចៗគ្នា (ម. ព. មមង្ការ ផង)។ អហំការ

ថេរ មានការពិបាកជាងនៅខាងក្រោម ពីព្រោះត្រូវដើរចុះមកខាងក្រោម ហើយដើរបិណ្ឌបាតទៅតាមរានដែលគេលក់អីវ៉ាន់ នៅតាមផ្លូវកន្លែងគេចតឡានខាងក្រោមជណ្តើរនាគ រួចហើយត្រូវដើរឡើងជណ្តើរទៅវិញ ប្រហែលជា ៣០០ កាំ ទើបត្រឡប់មកដល់កុដិនៅលើកំពូលភ្នំវិញ ។

ពេលនោះមានព្រះភិក្ខុមួយអង្គ ដែលនៅជិតគ្នានោះដែរ ប្រហែលជាលោកបានឃើញនូវការលំបាករបស់អាត្មា ទើបលោកឲ្យយោបល់ថា ៖

- លោកមិនបាច់និមន្តចុះទៅបិណ្ឌបាតទេ នៅក្នុងវិត្តនេះមានផ្ទះបាយ ហើយគេបានធ្វើចង្ហាន់ប្រគេនលោកនេន

- អាត្មាសូមអរគុណចំពោះលោកហើយ ដែលមានចេតនាល្អ, អាត្មាបានឆ្លើយតបទៅលោកវិញ, អាត្មាត្រូវតែទៅបិណ្ឌបាត ពីព្រោះបានតាំងសច្ចាធិដ្ឋានតាំងពីថ្ងៃចូលបួសថា នឹងដើរបិណ្ឌបាតជាវិត្តលោកគ្រូរបស់អាត្មាបានបង្រៀនមកថា ការដើរបិណ្ឌបាតជាប្រពៃណី សូម្បីព្រះសម្មាសម្ពុទ្ធ ព្រះអង្គក៏មិនបានលះបង់ដែរ ការដើរយកខ្យល់អាកាសដ៏បរិសុទ្ធនៅពេលព្រឹកព្រលឹមនោះ ជាការហាត់ប្រាណយ៉ាងប្រសើរបំផុត សម្រាប់ភិក្ខុដែលមិនមានពេលធ្វើកីឡាផ្សេងៗ ហើយជាពិសេសទៅទៀតការដើរបិណ្ឌបាត ជាការជួយដល់ញាតិញោមដែលមានទ្រព្យធនធានតិចតួចប៉ុន្តែមានភារៈកិច្ចច្រើន ដែលមិនអាចទៅធ្វើបុណ្យនៅវិត្ត ហើយគាត់បានធ្វើបុណ្យជាមួយព្រះសង្ឃ

នៅមុខទ្វារផ្ទះរបស់ខ្លួន ទៅតាមឆន្ទៈដែលខ្លួនមាន នេះហើយដែលជាការអនុគ្រោះដល់មនុស្សគ្រប់ជាន់ថ្នាក់ ជាការបានចូលមកក្រោមប្រជាជន ពីព្រោះអ្នកស្រុកភាគច្រើនតែងតែមានភារៈកិច្ចច្រើនដើម្បីចិញ្ចឹមជីវិត មិនអាចទៅធ្វើបុណ្យនៅវត្តបានរាល់ថ្ងៃទេ ។ បើសិនជាព្រះសង្ឃឈប់និមន្តបិណ្ឌបាតទៅ គេក៏មិនអាចមានឱកាសបានធ្វើបុណ្យដែរ ហើយការទាក់ទងរវាងអ្នកស្រុកនឹងព្រះសង្ឃក៏ឃ្លាតឆ្ងាយពីគ្នា ។ ដូច្នេះអ្នកស្រុកនឹងព្រះពុទ្ធ ព្រះធម៌ នៅឆ្ងាយពីគ្នា នៅទីបំផុតគេក៏ក្លាយទៅជាមនុស្សគ្មានសាសនា ហើយនៅពេលមានសាសនាផ្សេងៗទៀតគេមកពន្យល់ទាក់ទងជារឿយៗ ញឹកញយទៅ អ្នកស្រុកនោះអាចទៅជឿ គោរពនូវសាសនាថ្មីនោះទៅ ។ ព្រះពុទ្ធសាសនាដែលនៅគង់វង្សមកបាន ក៏ពីព្រោះព្រះសង្ឃមានការទាក់ទងជានិច្ចជាមួយអ្នកស្រុកដោយការដើរបិណ្ឌបាតនេះឯង ។

ពាក្យចម្លើយរបស់អាត្មានេះ បានទៅប៉ះទង្គិចត្រូវនូវចំណុចសំខាន់នៃចិត្តរបស់ភិក្ខុនេះដោយចៃដន្យ ។

នៅពេលព្រឹកឡើង អាត្មាបានឃើញលោកនិមន្តចេញទៅបិណ្ឌបាតដូចអាត្មាដែរ ។ នៅពេលក្រោយមកលោកបានចូលមកជួបអាត្មា ហើយបានពោលរៀបរាប់អំពីអានិសង្សនៃការដើរបិណ្ឌបាតនោះឲ្យស្ដាប់ថា បានធ្វើឲ្យលោកជាសះស្បើយពីការឈឺនូវសន្លាក់ជើង ដែលបានឈឺជាងមួយឆ្នាំមកហើយ ម្យ៉ាងទៀតធ្វើឲ្យលោកបានស្គាល់ញាតិញោមកាន់តែជិតស្និទ្ធស្នាលឡើងទៀត លុះគ្រាអ្នក

ស្រុកកើតនូវការរាប់អាន ។ នៅពេលមានបញ្ហាជីវិត អាច ទៅពិភាក្សាសួមសួរយោបល់អំពីគាត់ ជាហេតុឲ្យលោក បានផ្សព្វផ្សាយនូវធម៌ដើម្បីបំបាត់នូវទុក្ខ ហើយចម្រើននូវ សេចក្តីសុខដល់អ្នកស្រុក ធ្វើឲ្យគាត់បានយល់ឃើញនូវ តម្លៃរបស់ព្រះសង្ឃនៃព្រះពុទ្ធសាសនា ។

ផ្នែកការបដិបត្តិផ្លូវចិត្តក៏បានផលល្អ ហេតុដែលឲ្យ អាត្មាអាចនិយាយថាបានផលល្អ ពីព្រោះរាល់យប់ដែល អាត្មាអង្គុយនៅក្នុងកន្លែងតាំងសមាធិ មិនថាបរិកម្មពាក្យ «ពុទ្ធោ» ឬកំណត់មើលខ្យល់ដកដង្ហើមចេញចូល ឬសម្លឹង មើលកសិណ ចិត្តតែងស្ងប់រម្ងាប់ដល់អប្បនាសមាធិយ៉ាង ឆាប់រហ័ស ។ នៅពេលចិត្តបានស្ងប់ច្បាស់ហើយ នីវរណៈ ទាំង ៥ ដែលជាបន្លា តែងធ្វើឲ្យចិត្តប្រាសចាកនូវគុណធម៌ក៏ បានរម្ងាប់អស់ទៅ នៅសល់តែចិត្តដែលភ្លឺថ្លាស្អាតនិងបរិសុទ្ធ ដូចជាព្រះចន្ទពេញវង់អណ្តែតនៅចំពោះមុខ ហើយរបស់ ដែលនៅសល់ក្នុងចិត្តដ៏សែនសុខត្រជាក់នោះគឺ អារម្មណ៍ ខ្លះដែលចិត្តនឹកគិត ឬបង្កើតឡើងមកការត្រិះរិះពិចារណានូវ អារម្មណ៍នោះ សេចក្តីឆ្អែតសុខនៅក្នុងចិត្ត សេចក្តីស្ងប់នៃ ចិត្តយ៉ាងវិសេសនិងសេចក្តីភ្ញាក់ខ្លួន ដែលចាំការពារនូវ លក្ខណៈនៃចិត្តផ្សេងៗនោះតែប៉ុណ្ណោះ ។ ថ្ងៃខ្លះអាត្មា សប្បាយនៅក្នុងសេចក្តីស្ងប់យ៉ាងពិតប្រាកដនោះ លុះដល់ ភ្លឺដោយមិនបានដឹងខ្លួន យល់ថាមានពេលមួយយប់ សម្រាប់សេចក្តីសុខដ៏បរិសុទ្ធស្អាត ។ ដូច្នេះពេលវេលាខ្លី ណាស់បើនឹងប្រៀបនូវចិត្តរបស់អាត្មា ក្នុងពេលដែលកំពុង

ចុះស៊ុបក្នុងសមាធិនោះ ដូចជាបុរសដែលឃ្លានឬអត់អាហារ មកជាច្រើនថ្ងៃហើយ ស្រាប់តែបានមកជួបនូវអាហារ ៥ មុខ ដែលមានរសជាតិប្លែកៗគ្នាគឺល្វីង ជូរ ហឹរ ផ្អែម ខ្ទិះ ហើយតាំងឈ្លោកមុខបរិភោគដោយសេចក្តីស្រេកឃ្លាន ។

ច្រើនថ្ងៃផុតទៅ ពេលជឿជាក់ថាខ្លួនឯងមានការ ជំនាញនៅក្នុងសមាធិថ្នាក់នេះបានល្អហើយ អាត្មាបាន បញ្ឈានូវសតិ ដកចិត្តពីអារម្មណ៍ហើយការគិតចង់សាក ល្បងមើលអារម្មណ៍ នៅពេលនោះឯងមិនយូរប៉ុន្មានក៏ បានឃើញច្បាស់ថាអារម្មណ៍របស់ចិត្តបានរម្ងាប់ទៅហើយ ការពិចារណាទៅតាមអារម្មណ៍របស់ចិត្តក៏រលត់ទៅ ធ្វើឲ្យ ចិត្តបានស្ងប់ច្បាស់ថ្លាស្អាតបរិសុទ្ធខ្លាំងឡើងៗ របស់ដែល នៅសល់ក្នុងដួងចិត្តនោះគឺសេចក្តីស្ងប់ ផ្អែត ត្រជាក់ចិត្ត សេចក្តីសុខស្ងប់និងសេចក្តីមុតមាំពិតប្រាកដប៉ុណ្ណោះ ។ អាត្មាអាចពោលបានថា នៅពេលនេះទាំងសាច់ទាំងខ្លួន មិនមានអ្វីសោះឡើយ ក្រៅតែអំពីការសុខស្ងប់និងសេចក្តី ពេញចិត្តផ្អែតចិត្តដ៏បរិសុទ្ធតែប៉ុណ្ណោះ បើនឹងប្រៀបទៅនឹង ចិត្តរបស់អាត្មា ជាមួយបុរសដែលឃ្លានម្តងទៀត ដូចជាគេ បានទទួលទាននូវរសជាតិល្វីងនិងជាតិជូរអស់ហើយ គឺនៅ សល់តែជាតិហឹរ ផ្អែម និងខ្ទិះតែប៉ុណ្ណោះ អាត្មាសប្បាយ នៅក្នុងសេចក្តីសុខដ៏បរិសុទ្ធនេះ អស់ពេលយូរថ្ងៃមក ហើយមិនស្ងប់ពិតប្រាកដនោះដែរ ។ នៅពេលព្យាយាម មួយរយៈ សេចក្តីសុខក៏ស្ងប់ទៅ នៅសល់តែសេចក្តីនឹង ធឹងយ៉ាងមាំទាំ ផុតពីរបស់ដែលមករំខានផ្សេងៗសូម្បី

*បន្តិចបន្តួចឡើយ សឹងតែអាចពោលបានថា មិនមានរបស់អ្វីសល់នៅក្នុងចិត្តសោះឡើយ ក្រៅពីសេចក្តីស្ងប់យ៉ាងពិតប្រាកដយ៉ាងច្បាស់ជាទីបំផុត សេចក្តីជាកណ្តាលមិនជាប់ជំពាក់ មិនរវល់ ឬផ្អៀងទៅខាងណា ក្នុងទិសណាក៏មានពន្លឺភ្លឺស្វាងសឹបរិសុទ្ធស្រឡះជាក់ ហើយនៅសល់តែសតិដែលនៅចាំមើលការពារជានិច្ចតែប៉ុណ្ណោះ បើនឹងប្រៀបធៀបនឹងបុរសដែលស្រេកឃ្លាន នៅពេលនេះក៏ប្រៀបដូចជាគេបានបរិភោគអាហារគ្រប់រសជាតិអស់ហើយ មិនមានអ្វីនៅសល់ទៀតទេ លើកលែងតែសេចក្តីឆ្អែតតែប៉ុណ្ណោះ ។ អាត្មាសង្កេតឃើញថា លក្ខណៈរបស់ចិត្តក្នុងសមាធិថ្នាក់នេះ ដូចជាចិត្តរបស់មនុស្សដែលកំពុងដេកលក់យ៉ាងស៊ុបប្រសាទទាំង ៥ មិនមានការទាក់ទងជាមួយខាងផ្លូវលោកខាងក្រៅ ប៉ុន្តែនៅមានសតិជាអ្នកមើលការខុសត្រូវរបស់ចិត្ត ដែលកំពុងដេកលក់ស៊ុបនេះ ប្រៀបដូចជាមាតាកំពុងនៅចាំមើលកូនរបស់ខ្លួន ដែលកំពុងដេកលក់យ៉ាងស៊ុបនៅពីមុខ ។*

*នៅពេលចិត្តឡើងដល់សមាធិថ្នាក់នេះហើយ អាត្មាក៏បានថយត្រឡប់មកវិញនៅថ្នាក់ទី ៣ ដោយប្រើសតិហៅយកសេចក្តីត្រឡប់មកវិញ ក្រោយពីនោះមក ក៏ដើរថយត្រឡប់មកថ្នាក់ទី ២ នៅមួយខណៈ ហើយក៏ប្រមូលនៅអារម្មណ៍ឡើង យកសតិមកពិនិត្យមើលអារម្មណ៍នេះហើយប្រែទៅជាថ្នាក់ទី ១ ក្រៅអំពីនោះ ក៏បើកទ្វារទទួលនូវអារម្មណ៍ខាងផ្លូវលោក ដោយបើកត្រចៀកឲ្យបានឮ*

សម្លេងមុន ហើយទើបបើកភ្នែកឡើងឃើញរូបដែលនៅពីមុខ មាននិ័យថាចេញពីសមាធិនៅក្នុងការនឹងគិតដូចមនុស្សធម្មតា បាននឹងថាមានការស្រឡះមុខមាត់ ត្រជាក់ចិត្តដូចជាមនុស្ស ដែលទើបតែនឹងក្រោកភ្ញាក់ពីការដេកលក់យ៉ាងសុខស្ងប់ ចិត្តនៅស្ងប់សុខត្រជាក់នៅឡើយ ចិត្តរីករាយសប្បាយការគិត ការអាន យល់បានងាយរហ័ស ការចងចាំបានល្អឡើង ចិត្តមានកម្លាំងឡើងច្រើន កិលេសផ្សេងៗចុះស្រាលស្ដើងអស់យ៉ាងច្រើន ។

យប់ថ្ងៃកន្លងផុតទៅ អាត្មានៅខំព្យាយាមប្រតិបត្តិនៅលើព្រះធាតុដយសុចេប ដោយមិនបានរាថែថយទេ ប៉ុន្តែមានរបស់មួយដែលគួរឲ្យប្លែកក្នុងចិត្តខ្លះ គឺអាត្មាអាចចូលសមាធិបានដល់ត្រឹមថ្នាក់ទី ៤ ដូចបានពោលមកហើយនោះប៉ុណ្ណោះឯង ។ ប៉ុន្តែព្យាយាមខំរៀននូវការហាត់ពេលចូល ពេលចេញឲ្យស្ទាត់ ឲ្យរហ័សជំនាញខ្លាំងថែមឡើងទៀត លុះត្រាអាចចូលសមាធិថ្នាក់ណាមួយបានយ៉ាងរហ័សទាំងទៅតាមលំដាប់ ឬរំលងថ្នាក់ ទាំងក្នុងឥរិយាបថអង្គុយនិងឥរិយាបថដេក ទាំងក្នុងវេលាយប់អធ្រាត្រនិងពេលថ្ងៃនៅពេលមានការស្ទាត់ជំនាញខ្លាំងឡើង លុះអាចចូលដល់សមាធិថ្នាក់ណាមួយបានយ៉ាងរហ័ស ទាំងតាមលំដាប់ថ្នាក់និងផ្លោះថ្នាក់ ទាំងក្នុងឥរិយាបថអង្គុយនិងឥរិយាបថដេក ទាំងក្នុងវេលាយប់អធ្រាត្រនិងពេលថ្ងៃ ។ នៅពេលមានការស្ទាត់ជំនាញច្រើនឡើង អំណាចពិសេសផ្សេងៗ ក៏កើតមានមកតាមដែរ ដូចជាមានពេលខ្លះអាត្មាបានសាកល្បង

ចូលសម្រាកនៅក្នុងសមាធិក្នុងថ្នាក់ទី ៤ តាំងតែពីព្រលប់ រហូតដល់ភ្លឺ រហូតជាប់គ្នាដល់ទៅ ៤ ថ្ងៃ ដោយមិនបាន សឹងសម្រាកដូចធម្មតានោះសោះ សូម្បីដល់ថ្នាក់នោះហើយ ក៏ដោយ រាងកាយនិងចិត្តក៏នៅស្រួលជាប្រក្រតីធម្មតា មិន មានអាការៈងងុយដេក ទន់ខ្សោយ ហត់ហេវសូម្បីបន្តិច បន្តួចឡើយ ៗ លើសពីនេះទៀត នៅមានការស្រស់បស់ ត្រជាក់រីករាយ ស្រួលខ្លួនជាងពេលធម្មតាទៅទៀត ពីព្រោះ សមាធិថ្នាក់ទី ៤ នេះ ចិត្តនិងរាងកាយបានទទួលនៅការ សម្រាកយ៉ាងពិសេសជាប់ៗគ្នារហូតពេញមួយយប់ មិន មានការយល់សប្តិ ឬការភ្ញាក់ឆ្លើលអ្វីមួយមករំខានរហូត ពេញមួយយប់ ៗ ចាប់តាំងតែពីនោះមកអាត្មាទើបចូលចិត្ត ចូលសមាធិថ្នាក់ទី ៤ ជំនួសការសឹងលក់បែបធម្មតា ៗ

ពេលយប់មួយ នៅពេលដែលអាត្មាចូលក្នុងសមាធិ កម្រិតទី ៤ ហើយថយចេញមកសម្រាកនៅក្នុងសមាធិថ្នាក់ទី ១ នោះ មានហេតុការណ៍ប្លែកខុសវិស័យពីមនុស្សធម្មតា កើតឡើង ៗ ជាហេតុការណ៍ដំបូងដែលធ្វើឲ្យអាត្មាកើត សេចក្តីជឿច្បាស់ថាក្នុងលោកនៃឧប្បត្តិកសត្វ ដូចជាទេវតា និងភូតខ្មោចបិសាច ជារបស់មានពិតនៅក្នុងហេតុការណ៍ អាត្មានឹងពោលរៀបរាប់លំអិត ដូចនិទានតទៅនេះ ៖

នៅពេលដែលអាត្មាកំពុងពិចារណា ក្នុងអារម្មណ៍ នៅក្នុងសមាធិថ្នាក់ទី ១ នៅយប់ដែលបានពោលមក ឃើញ មានពន្លឺដូចនៅពេលថ្ងៃកើតឡើង ធ្វើឲ្យមើលឃើញរបស់ ផ្សេងៗដែលនៅជុំវិញខ្លួនប្រៀបដូចជាពេលថ្ងៃធម្មតា គ្រាន់

តែខុសគ្នាត្រង់ថា នៅពេលថ្ងៃនេះជាថ្ងៃដែលស្ងប់ស្ងាត់ មិនមានសម្លេងដទៃមករំខានសូម្បីបន្តិចបន្តួច មានពន្លឺចេញមកនោះគឺ មានការខុសប្លែកពីពន្លឺថ្ងៃធម្មតា ជាពន្លឺភ្លឺពណ៌ស៊ីនួនត្រជាក់ភ្នែក ភ្លឺស្មើគ្នានៅគ្រប់ទីកន្លែង មិនមានស្រមោលបាំងនៅទីដែលគួរនឹងមាន ៗ ហេតុការណ៍ដែលកើតឡើងនោះ មិនមែនជាការយល់សប្តិយ៉ាងពិតប្រាកដពីព្រោះអាត្មាមិនមែនសឹងលក់ សូម្បីនឹងនៅក្នុងសមាធិ ក៏នៅមានសតិដួយមើលចិត្តយ៉ាងពេញទំហឹងដែរ សភាពការណ៍ដែលឃើញចំពោះមុខ ក៏មិនមែនភាពបន្លំដែលកើតឡើង ដូចជាអណ្តែតអណ្តូងដូចជាការយល់សប្តិនោះក៏មិនមែន ប៉ុន្តែជារបស់ផ្សេងមួយទៀតដែលអាត្មាបានឃើញនៅក្នុងថ្ងៃនេះឯង ដូចជាបរិក្ខារផ្សេងៗដែលនៅក្នុងកុដិ ក៏នៅក្នុងកន្លែងដដែល ជារបៀបរៀបរយដូចដើម ៗ ឯដើមឈើដែលនៅពីមុខកុដិ ក៏ឃើញនៅដដែល មើលទៅមែកធាងរបស់វាក៏នៅដូចកាលពីដើមទាំងអស់ មើលទៅរបស់គ្រប់យ៉ាងនៅដូចពេលមុនគ្រប់យ៉ាង ដូច្នេះសន្មតថាមិនមែនជាការយល់សប្តិយ៉ាងពិតប្រាកដ ៗ

នៅពេលដែលអាត្មា កំពុងអង្គុយត្រួតពិនិត្យមើលនូវរបស់ផ្សេងៗនោះ គឺបានឃើញបុរសចាស់ម្នាក់ ដើរកាន់ឈើច្រត់តម្រង់ចូលមក រូបរាងរបស់គាត់ស្គម សាច់ស្បែកជ្រួញជ្រីវ មានសក់ពណ៌ស ក្របួចចងដាក់ទៅខាងលើ សង្កេតឃើញសំលៀកបំពាក់របស់គាត់ជាធម្មតា ប៉ុន្តែជាស្បែកខ្លាធំ ដោយមានឆ្នូតចេញមកឲ្យឃើញច្បាស់ ៗ

តាមការស្មានមើលទៅគាត់អាយុប្រហែល ៧០ ឆ្នាំយ៉ាងតិច គាត់បានមកអង្គុយនៅខាងមុខអាត្មា លើកដៃសំពះ ហើយនិយាយឡើងថា៖

- ខ្ញុំករុណាជាសុចេរិតសី ជាអ្នកនៅរក្សាព្រះធាតុឯយសុធេប ខ្ញុំម្ចាស់រីករាយណាស់ដោយបានឃើញលោកបដិបត្តិ លុះត្រាអាចលើកនូវកំពស់ចិត្តឡើងបានប្រហែលនឹងកំពស់ចិត្តរបស់យើង ទើបមកសន្ទនាជាមួយ

អាត្មា សម្លឹងមើលនូវអាកប្បកិរិយារបស់តសីចាស់ដោយមានសេចក្ដីពេញចិត្ត ហើយបានឆ្លើយថា៖

- អាត្មាត្រេកអរណាស់ ដែលបានមកសន្ទនាជាមួយលោកដែលជាអ្នកមានសីល បើសិនជាលោកមានបញ្ហាអ្វីផ្សេងៗដែលនឹងចង់សួរ សូមអញ្ជើញសួរបានតាមអធ្យាស្រ័យមកចុះ

មានចំណុចមួយដែលគួរឲ្យស្រេង្គតនោះគឺ ការនិយាយរបស់អាត្មាមិនមែននិយាយមាត់បែបធម្មតានោះទេ ប៉ុន្តែជាការនិយាយដោយចិត្ត គ្រាន់តែនឹកនិយាយដោយចិត្តប៉ុណ្ណោះ ក៏កើតទៅជាសម្លេងដែលឲ្យឮច្បាស់ទាំងអាត្មាខ្លួនឯង និងគូសន្ទនា

- ខ្ញុំម្ចាស់នៅលើភ្នំនេះអស់រយៈពេល ៦០០ ឆ្នាំជាងមកហើយ, សុចេរិតសីពោលឡើង, នៅពេលជាមនុស្ស ខ្ញុំព្រះករុណាបានបដិបត្តិដល់ឈានទី ៤ ប៉ុន្តែខ្ញុំម្ចាស់មិនបានចូលឈានរំលត់ខន្ធ ទើបមិនបានទៅកើតក្នុងព្រហ្មលោក បានត្រឹមតែជាអារុក្ខទេវតានៅលើភ្នំនេះ ៗ តមកក្នុងព.ស.

១៤២៧ ព្រះចៅគឺអណាភាឆម្មិរាជនៃនគរឆៀងម៉ៃ បានកសាង ចេតិយស្ថានក្នុងទីនេះឡើង ដើម្បីបញ្ចុះព្រះបរមធាតុនិងព្រះអង្គបានមកពីក្រុងសុខោទ័យ ហើយបានធ្វើពិធីបួងសួង ឲ្យខ្ញុំព្រះករុណាជាអ្នកនៅចាំថែរក្សា ខ្ញុំម្ចាស់ក៏សម្រេចចិត្តទទួលព្រះបញ្ជាតមក

អាត្មានឹកប្លែកក្នុងចិត្ត នៅពេលបានស្តាប់ប្រវត្តិនៃព្រះធាតុពីនគសីដោយមិនដែលបានឮ បានស្តាប់ពីមុនមកសោះ ដើម្បីពិសោធថា តើពាក្យដែលនគសីនេះនិយាយប្រាប់ ជាការពិតមែនឬទេ ? ៗ នៅថ្ងៃបន្ទាប់មកអាត្មាបានទៅរកស្មៀនតៅប្រវត្តិនៃព្រះធាតុ នៅភ្នំសុថេបយកមកអានប្រាកដឃើញថា ពាក្យនិយាយរបស់គាត់ទាំងប៉ុន្មានគឺជាការពិតទាំងអស់

- ការលះបង់នូវពេលវេលារាប់រយឆ្នាំ នៅថែរក្សាបូជនីយស្ថានដើម្បីហិតានុហិតប្រយោជន៍ ពពួកជនទាំងឡាយ នេះក៏ជាមហាកុសល អាត្មាសូមអនុមោទនាផង, អាត្មាបានឆ្លើយទៅសុថេវិនគសីៗ គាត់ញញឹមដោយសេចក្តីពេញចិត្ត ប៉ុន្តែនៅពេលក្រោយមក គាត់ក៏មានទឹកមុខស្រងូតស្រពោនវិញ

- ប៉ុន្តែខ្ញុំម្ចាស់តាំងចិត្តជានិច្ចថា នៅពេលមួយបើព្រះបរមធាតុ មានអ្នកមើលថែដែលសមគួរមកជំនួសហើយ នឹងច្យុតទៅកើតជាមនុស្សដើម្បីបំពេញបារមីតទៅទៀត

- អស់ពេលវេលា៦០០ឆ្នាំ យ៉ាងពិតឆ្ងាយនេះលោកមិនដែលធ្លាប់បានទៅកើតសោះទេឬ ?

- ឆ្លាប់! ព្រះនសីឆ្លើយតប, ប៉ុន្តែកម្លាំងអធិដ្ឋានរបស់ព្រះរាជានៃព្រះអង្គនោះ មិនព្រមឲ្យខ្ញុំម្ចាស់ទៅកើតក្នុងកំណើតខ្ពស់ជាងតិរច្ឆាននោះទេ ទើបខ្ញុំម្ចាស់យកកំណើតជាសត្វវិលវល់នៅជិតៗព្រះធាតុនេះ ៣-៤ ដងហើយ ។ នៅពេលចុងក្រោយ ខ្ញុំម្ចាស់កើតជាមាន់ នៅចាំមើលព្រះធាតុលុះដល់អាយុខ័យ តមកក៏មិនបានទៅកើតទៀតទេ

ដើម្បីជាការពិសោធន៍នូវពាក្យសំដីរបស់នសី នៅពេលព្រឹកឡើងអាត្មាបានសួរមិត្តមួយអង្គចង់ដឹងថាតើ ឆ្លាប់មានមាន់មកនៅក្នុងបរិវេណព្រះធាតុនេះដែរឬទេ ? លោកឆ្លើយថាធ្លាប់មាន ហើយមាន់នោះដេញចឹកគេគ្រប់គ្នា ដែលអ្នកណាឡើងមកលើបរិវេណព្រះធាតុ ដោយមិនបានដោះស្បែកជើង

- នៅពេលនោះ ខ្ញុំម្ចាស់ឃើញថាដល់ពេលវេលាដែលនឹងច្យុតទៅកើតក្នុងកំណើតមនុស្សហើយ,នសីពោលតទៅទៀតថា ពីព្រោះពេលនេះវត្តអារាមក៏បានប្រគល់ឋានៈជារបស់ស្តេចទៅហើយ គឺនៅក្នុងមើលការខុសត្រូវរបស់ស្តេច ។ លោកបានព្រះរាជទានទ្រព្យសម្បត្តិឧបត្ថម្ភ ខ្ញុំម្ចាស់ទើបអស់មាននាទីទៀតហើយ ប៉ុន្តែមុនពេលដែលច្យុតទៅ ខ្ញុំម្ចាស់នៅមានការហួងហែងនូវសម្បត្តិពីដើមខ្លះដែល ខ្ញុំម្ចាស់បានកប់ទុកតាំងតែពីគាលកើតជាមនុស្ស ខ្ញុំម្ចាស់មិនអាចទៅកើតទៀតបានទេ កាលណាមិនទាន់បានប្រគល់ទ្រព្យសម្បត្តិនេះ ឲ្យទៅអ្នកណាម្នាក់ដែលសមគួរនឹងប្រគល់ឲ្យ ហើយនៅពេលនេះ ខ្ញុំម្ចាស់បានជួបនៅ

*បុគ្គលដែលគ្នាប្រគល់ឲ្យហើយ គឺជាព្រះតេជព្រះគុណនេះ ឯង ...*

# *ទុក្ខព្រោះកង្វះ*

**ពាក្យប្រាំពីរ**

**អ្នកក្រទុក្ខព្រោះការស្រេកឃ្លាន អ្នកមានទុក្ខព្រួយខ្លាចបាត់ទ្រព្យ**
**អ្នកខ្វះបុណ្យព្រេងវេរងអភ័ព្វ រស់នៅមិនគាប់ច្រើនទុក្ខា ។**
**អ្នកស៊ីម្នាក់ឯងគ្មានបានសុខ អ្នកខ្ជិលសំកុកឥតធ្វើការ**
**អ្នកឥតបានធ្វើចាំតែថា អ្នកល្មោភចិន្តាមិនចេះល្មម ។**
**ទាំងនេះសុទ្ធតែជាប្រមុខ បង្កនាំទុក្ខត្រូវប្រឈម**
**ខិតខំរៀនយល់ស្គាល់ហេតុព្រម កុំល្មោភចេះល្មមបានសុខា ៕**

ដោយឧបាសក ម៉ិញ សារ៉ាង

# អន្ទាក់ចិត្ត

**ពាក្យប្រាំបួន**

**ចិត្តជំពាក់ ជាអន្ទាក់ ដាក់ខ្លួនឯង**
**ឲ្យចំបែង ង៉ែងសោកសៅ ក្ដៅក្រហាយ**
**រឹងចង្អៀត សៀតចង្អល់ អំពល់ខ្វាយ**
**ចងចិត្តកាយ ចេញមិនឆ្ងាយ ក្លាយទុក្ខា ។**
**ត្រូវខំកាត់ ផ្ដាច់ចំណង ផងទាំងឡាយ**
**ឲ្យរសាយ រារាតឆ្ងាយ កាយចិន្ដា**
**កំចាត់បាន ឧបាទាន និងតណ្ហា**
**មោហ៍អវិជ្ជា វិនាសបាត់ រសាត់បង់ ៕**

ដោយឧបាសក ម៉ិញ សារ៉ាំង

# ៦. លោភានុភាព

បើជាគ្រហស្ថនៅគ្រប់គ្រងផ្ទះ នៅមានសេចក្ដីលោភក្នុងទ្រព្យសម្បត្តិ ហើយនៅមានការប្រើប្រាស់ក្នុងទ្រព្យសម្បត្តិនោះ បើមានអ្នកមកសូមប្រគល់នូវទ្រព្យសម្បត្តិឲ្យដូច្នេះ អាត្មាប្រហែលជាភ្ញាក់ផ្អើលសប្បាយចិត្តមិនតិចទេ ប៉ុន្តែក្នុងឋានៈជាបព្វជិត ដែលបានលះនូវសម្បត្តិទាំងពួងចេញមកកាន់ភេទសមណៈ ដែលកើតពីសេចក្ដីស្រឡាញ់និងផាសុកភាព ពីព្រោះបានទម្លាក់នូវរបស់ធ្ងន់ផ្សេងៗចេញអស់ហើយ នៅពេលឥសីចាស់មកសូមប្រគល់នូវមហាសម្បត្តិនេះ អាត្មាយល់ថាដូចជាមានមនុស្សលើកភារៈមួយយ៉ាងធ្ងន់មកដាក់លើស្មាទៀត ទើបឆ្លើយជាមួយព្រាហ្មណ៍ចាស់នេះថា៖

- បើលោកយល់ថា អាត្មាជាអ្នកដែលសមល្មមនូវការទទួលនូវសម្បត្តិរបស់លោក គឺលោកបានយល់ខុសហើយ ពីព្រោះអាត្មាមិនត្រូវការទ្រព្យសម្បត្តិរបស់លោកទេ ហើយជីវិតបព្វជិតរបស់អាត្មា ក៏មិនមានការចាំបាច់ដោយទ្រព្យផ្សេងៗ ក្រៅពីបាត្រនិងចីវរដែរ

- ពីព្រោះឃើញថាលោកមិនត្រូវការសម្បត្តិនេះហើយ ទើបខ្ញុំករុណាឃើញថាជាការសមគួរ ប្រសិនជាព្រះអង្គនៅចង់បានសម្បត្តិ នៅពេលបានទទួលយកនូវសម្បត្តិរបស់ខ្ញុំព្រះករុណានេះទៅគាលណាហើយ ព្រះអង្គក៏អាច

នឹងនាំយកទៅចាយប្រើជាប្រយោជន៍តែមួយអង្គឯង ប៉ុន្តែនេះព្រះអង្គមិនត្រូវការនូវទ្រព្យសម្បត្តិរបស់ខ្ញុំកូណា ទើបខ្ញុំកូណាជឿជាក់បានថាទ្រព្យសម្បត្តិរបស់ខ្ញុំនេះ នឹងបានជាប្រយោជន៍ដល់ជនឯទៀតជាមិនខានតើព្រះអង្គទទួលឬទេ?

ពាក្យសួរបៀបធ្វើឲ្យរំខានរបស់លោកឥសី ធ្វើឲ្យអាត្មាកើតសេចក្ដីរំភើបចិត្តឡើងមកភ្លាម ។ ឥសីចាស់ជរានោះមើលទៅលោកអាចយល់ចិត្តរបស់អាត្មាជាមុន ទើបនិយាយជាពាក្យទំនងបោះឆ្នាក់តទៅទៀតថា ៖

- បើព្រះអង្គទទួល លោកអាចមានឈ្មោះថាបានធ្វើបុណ្យមហាកុសលធំ ប្រការដំបូងនឹងបានឈ្មោះថា បានធ្វើមហាកុសល ដូចជាដោះលែងឲ្យខ្ញុំម្ចាស់បានរួច ឲ្យមានសេរីភាព ខ្ញុំម្ចាស់នឹងអាចបានទៅកើតដើម្បីបំពេញបារមីតទៅ ។ ប្រការទីពីរ ទ្រព្យសម្បត្តិរបស់ខ្ញុំម្ចាស់នឹងបានជាប្រយោជន៍ដល់ទៅអ្នកដទៃឯទៀត ប្រសើរជាងដែលយកមកកប់ទុកចោលក្នុងដីឥតប្រយោជន៍យ៉ាងនេះ

អាត្មានឹកអាណិតដល់ឥសីចាស់ជរា ដែលស្រេកឃ្លានចង់ទៅកើតទៀត ប៉ុន្តែខ្លាចក្រែងមានការពិបាកក្នុងរបស់ទាំងនោះ ដែលកើតអំពីទ្រព្យសម្បត្តិទាំងអស់នេះ ។ នៅខណៈដែលមិនអាចកាត់សេចក្ដីនេះឲ្យបានដាច់ស្រេចទេនោះ ទើបសូមពន្យារពេលតទៅទៀតបានបន្តិចសិនទើបនិយាយប្រាប់គាត់ថា ៖

- រឿងនេះជារឿងសំខាន់សម្រាប់ខ្លួនអាត្មា ប្រសិនជាលោកមិនប្រញាប់ពេកទេ អាត្មាសូមយករឿងនេះមក

គិតពិចារណាមើលសិនប្រហែលមួយថ្ងៃទៀត គឺសូម លោកមកជួបអាត្មានូវថ្ងៃស្អែកនេះទៀត អាត្មានឹងប្រាប់នូវ សេចក្តីសម្រេចរបស់អាត្មាឲ្យបានជ្រាប ។

- ខ្ញុំព្រះករុណាមិនប្រញាប់ពេកទេ ពីព្រោះខ្ញុំម្ចាស់ បានចាំនូវឱកាសនេះមករាប់រយឆ្នាំមកហើយ ក្នុងការរង់ចាំ តទៅទៀតពីរថ្ងៃនោះមិនជាការពិបាកអ្វីទេ ប៉ុន្តែនៅថ្ងៃ ស្អែកនេះ ខ្ញុំព្រះករុណានឹងទៅសួរមិត្តឥសីមួយអង្គទៀត នៅឯភ្នំធៀងផារ ហើយនឹងត្រឡប់មកវិញនៅថ្ងៃស្អែក ខ្ញុំ ករុណានឹងមកជួបព្រះអង្គទៀតនៅថ្ងៃខានស្អែកនោះ

នៅពេលដែលលោកឥសី កំពុងនឹងក្រាបលាទៅ នោះ អាត្មាក៏ចាប់នឹកក្នុងគិតឃើញថា ប្រសិនជាទ្រព្យ សម្បត្តិរបស់លោកឥសីមិនជាច្រើនទេនោះ ក៏សម្រេចចិត្ត ថាទទួលយកតែម្តងទៅចុះ ។ ទើបសួរគាត់ថា៖

- តែបើមិនយល់ទាស់ទេ អាត្មាចង់ដឹងនូវទ្រព្យសម្បត្តិ របស់លោកតើមានអ្វីខ្លះ ? ហើយនៅកន្លែងណា ?

- សម្បត្តិរបស់ខ្ញុំកូណាភាគច្រើនជាគ្រឿង ពេជ្រ និល ត្បូងដែលមហាក្សត្រិយ៍ក្នុងអាណាចក្រថៃ អាណាចក្រ ភៈយ៉ៅ និងអាណាចក្រសុខោទ័យក្នុងអតីត បាននាំយក មកធ្វើសក្ការបូជា ។ គ្រឿងពេជ្រទាំងអស់នេះមានប្រមាណ ជា ៥ ពាងខ្នាតកណ្តាល, ក្រៅពីនោះមានទេវរូបមាសខ្នាត កណ្តាល ៣ អង្គ, សៀវភៅតម្រាថ្នាំ ព្រមទាំងថ្នាំ ដែលខ្ញុំ ម្ចាស់បានទុកប្រមូលទាំងអស់មានច្រើនកញ្ចប់ទៀត, មាន ដើមឈើជាប្រាក់ និងដើមឈើជាមាសប្រហែល ១០ ដើម

ដែលស្ដេចពីដំនាន់បូរាណបាននាំមកបូជាអន្លុំព្រះធាតុ តែខ្ញុំម្ចាស់យល់ឃើញថា នឹងមិនផុតពីភ័យអន្តរាយទើបប្រមូលមកទុកជុំគ្នានៅទីកន្លែងតែមួយ

ខ្ញុំករុណាទុកសម្បត្តិទាំងអស់នេះ នៅក្នុងល្អាងមួយដែលនៅជិតៗភ្នំឆ្ងាយពីអន្លុំព្រះធាតុចុះទៅខាងទិស ... មិនឆ្ងាយទេ ត្រង់មាត់ល្អាងមានថ្មមួយយ៉ាងធំ ខ្ពស់ប្រហែលកម្ពស់ក្បាលមនុស្សបិទទុក ថ្មដែលបានពោលមកនេះឋិតនៅត្រង់កណ្ដាលរវាងដើមឈើមួយដើម .... ខ្នាតធំប្រហែលគុម្ពឫស្សីមួយគុម្ព, ថ្មនោះសូម្បីមើលទៅឃើញធំ តែបើឡើងទៅឈរនៅខាងលើថ្មនោះហើយៗ យកឈើធំល្មមស៊ក ថ្មនោះនឹងរបើកហើយលោកនឹងបានឃើញនៅមាត់ល្អាងមានថ្មតូចៗ ដែលអាចវារចូលទៅបានបើព្រះអង្គវារចូលទៅតាមផ្លូវប្រហែល ៣ ជំហាន លោកនឹងបានឃើញមានផ្លូវបែកជាពីរនៅខាងមុខ សូមឲ្យព្រះអង្គវារទៅតាមផ្លូវខាងស្ដាំ កុំទៅខាងឆ្វេងនៃជាដាច់ខាតពីព្រោះជាផ្លូវខ្វាត់ខ្វែងហើយជ្រៅទៅឆ្ងាយ អាចធ្វើឲ្យវង្វេងបាន បើព្រះអង្គទៅតាមផ្លូវខាងស្ដាំនៃ លោកនឹងជួបផ្លូវដើរស្រួល ទូលាយហើយខ្ពស់ឡើងៗ លុះត្រាអាចដើរបានយ៉ាងសប្បាយ ៗ នៅពេលលោកដើរតាមផ្លូវនោះតទៅប្រហែល ៥ ឬ ៦ ព្យាម លោកនឹងជួបល្អាងមួយធំល្មមគួរសម ខ្ញុំម្ចាស់បានទុករបស់ទ្រព្យទាំងអស់នោះនៅក្នុងបន្ទប់នោះឯង

អាត្មាបានពោលពាក្យអរគុណដល់សុចេរិតសី ដែល

ករុណាប្រាប់ចំនួនទ្រព្យ ហើយនិងទីកន្លែងដែលបានលាក់ទុកយ៉ាងល្អិតល្អន់ ។ បន្ទាប់មកឥសីជរានោះក៏លាចេញទៅ ។

ថ្ងៃស្អែកឡើង ពេលឆាន់ព្រឹករួចហើយ អាត្មាយកពេលវេលា ទៅពិនិត្យមើលនៅមាត់ថ្លុកដែលចូលទៅកន្លែងកំណប់មហាសម្បត្តិ តាមពាក្យពន្យល់របស់ឥសី ។ ដើរចុះពីអន្លង់ព្រះធាតុទៅមិនយូរ ក៏មកដល់មុខល្អាងខ្ពស់ល្មមសមគួរនៅកន្លែងមួយនៅជើងល្អាងនោះជាវាលដីរាបធំទូលាយមានដើមឈើម្លប់ត្រជាក់ជាប់ៗគ្នា នៅខាងមុខមានដុំថ្មធំនៅរវាងដើមឈើធំនិងគុម្ពឫស្សី ដូចពាក្យឥសីបាននិយាយប្រាប់មែន ។ សង្កេតត្រួតមើលនូវបរិវេណទីកន្លែងគ្រប់អស់ហើយ អាត្មាក៏វិលត្រឡប់មកកុដិវិញ ។ នៅពេលមកដល់កុដិ អាត្មាក៏ចាប់ផ្តើមគិតថា តើនឹងគិតចាត់ចែងយ៉ាងណាជាមួយទ្រព្យសម្បត្តិរបស់ឥសីនោះ ។ នៅពេលខ្លះសេចក្តីលោភ ដែលមិនទាន់ជីកកប់ឲ្យជ្រៅនៃបេះដូងនោះវាអាចស្ទុះឡើងមក ធ្វើឲ្យកើតសេចក្តីចង់បានទ្រព្យសម្បត្តិទាំងនោះ យកទៅប្រើប្រាស់ជាប្រយោជន៍ ផ្ទាល់ខ្លួន ប៉ុន្តែពេលមានសតិសម្បជញ្ញៈត្រឡប់មកវិញ អាត្មាក៏កំចាត់លោភៈចិត្តចេញ ដោយពិចារណាឲ្យឃើញនូវសេចក្តីពិតដែលជាចំណុចខ្ពស់បំផុតរបស់មនុស្សគ្រប់ៗគ្នា គឺសេចក្តីសុខចិត្តស្ងប់ ។ មនុស្សមិនអាចនឹងមានសេចក្តីស្ងប់សុខបានពីព្រោះតណ្ហា គឺសេចក្តីចង់បានចូលគ្របចិត្ត ធ្វើឲ្យចិត្តរសាប់រសល់ ស្ទុះស្ទាចង់បានយកមកមិនមានទីបញ្ចប់ ។

មនុស្សយើង មានផ្លូវតែមួយគត់ដែលធ្វើឲ្យស្ងប់សុខបាន នោះគឺ រករបស់ផ្សេងៗមកជំនួសសេចក្ដីចង់ នៅពេលបានដូចប្រាថ្នាចង់បានហើយ ក៏កើតសេចក្ដីស្ងប់សុខចិត្តមួយរយៈពេល មិនយូរប៉ុន្មានក៏កើតសេចក្ដីចង់បាននូវរបស់ផ្សេងៗទៀត ។ មនុស្សដែលធ្លាក់ចុះជាខ្ញុំកញ្ជះរបស់តណ្ហា ក៏តែងតែរត់ប្រដេញតាមរហូតទៅរកចំណីមកចិញ្ចឹមតណ្ហាតទៅលុះត្រាតែជីវិតរលត់ផុត ។ សុខបែបមនុស្សលោកគឺជាសុខមួយរយៈពេល ហើយមានបន្តិចបន្តួច ប៉ុន្តែត្រូវចុះដើមទុន ចុះកម្លាំងច្រើនហើយលាយទៅដោយទុក្ខ ។ ការអាស្រ័យសម្បត្តិរកនៅសេចក្ដីសុខ ប្រៀបដូចអង្គុយលើទូកដែលធ្លុះធ្លុងទៅច្រាំងម្ខាង អ្នកដែលជិះទូកនោះ ត្រូវខាតពេលវេលា ដោយរវល់ទៅជួយបិទប្រហោងទូកដែលធ្លុះដើម្បីមិនឲ្យទូកលិច ប៉ុន្តែទូកនោះត្រូវតែលិចចូលក្នុងទឹកមុនទៅដល់ច្រាំងជានិច្ច ។ មនុស្សលោកដែលខំរកសេចក្ដីសុខអំពីទ្រព្យសម្បត្តិ តែងតែខាតពេលវេលាភាគច្រើនទៅក្នុងការស្វែងរក និងការថែរក្សានូវទ្រព្យ លុះតែមិនមានវេលាដែលជួយឲ្យមានសេចក្ដីសុខស្ងប់ចិត្ត ។ ចំណែកសុខខាងផ្លូវធម៌មានការផ្ទុយគ្នានិងសុខផ្លូវលោក គឺមិនគិតទៅការខិតខំការស្វែងរកកាមគុណទាំង ៥ យកមកទំនុកបម្រុងចិញ្ចឹមតណ្ហាទេ ត្រឡប់ទៅជាព្យាយាមបំផ្លាញតួតណ្ហាដែល ជាហេតុឲ្យចិត្តខ្វល់ខ្វាយអន្ទះអន្ទែងនោះចេញ ។ នៅពេលបំផ្លាញតណ្ហាបានហើយ ចិត្តក៏បានទទួលនូវសេចក្ដីស្ងប់សុខរហូតតទៅ ដែលជាសុខដោយមិនបាច់

អស់ដើមទុនអ៊ីចឹងទៅ គឺបានសុខរហូតទៅ គឺមានតែសេចក្ដីតាំងចិត្តយ៉ាងមុតមាំដើម្បី បង្ក្រាបនូវតណ្ហាប៉ុណ្ណោះឯង នៅពេលអាត្មាបានចាប់សត្រូវរបស់អាត្មាគឺតណ្ហា ចងវាជាប់ហើយដោយសមាធិយ៉ាងមាំទាំ ។ នៅពេលតណ្ហាគម្រើកខ្លួនបន្តិចបន្តួច ពីព្រោះឃើញរបស់ដែលល្អលោភលន់ ជ្រូកគឺទ្រព្យរបស់គសិនោះ ប្រសិនព្រមស្រាយដោយឲ្យវាមានសេរីភាព វានឹងមកជិះកឃើងតទៅនៅក្នុងវិដ្ដៈគ្មានទីបំផុតទៀតឬ ? អាត្មាគិតឡើងបានដូច្នេះ ក៏ព្យាយាមរំងាប់នូវសេចក្ដីចំណង់ដែលស្ទុះឡើងចេញមកឲ្យបានស្ងប់រំងាប់ទៅវិញ ។

សូម្បីតែមិនទាន់បានបញ្ចេញពាក្យថា ទទួលនូវទ្រព្យសម្បត្តិរបស់គសិសុចេរិៈ អាត្មាក៏មានការរើលពិបាកដល់ថ្នាក់នេះទៅហើយ ចុះប្រសិនជាព្រមទទួលយកមកចាត់ការផ្សេងៗពិតមែននោះតើនឹងមានការពិបាកយ៉ាងណាទៅហ្ន៎? នៅពេលបានគិតដល់ត្រង់នេះហើយ អាត្មាចង់តែឈប់ទទួល គឺសូមបដិសេធមិនទទួលនូវទ្រព្យសម្បត្តិទាំងអស់នោះរបស់គសិជិភឡើយ ប៉ុន្តែនៅពេលជាមួយគ្នានោះក៏មានចិត្តគិតចង់ជួយឲ្យគាត់បានទៅកើតតទៅ ។ នៅក្នុងពេលដែល អាត្មាកំពុងគិតរកមធ្យោបាយដោះស្រាយរឿងហ្នឹង មានបុរសម្នាក់ឈ្មោះ " ប៉ាន់ " ដែលអាស្រ័យនៅផ្ទះថែរក្សាដើងជាណ្ដើរនាគ ក៏មកជួបអាត្មានៅទីកុដិ ។ លោក " ប៉ាន់ " នេះមានអាយុប្រហែលជា ៤០ ហើយ មានកូន ៦ នាក់ ។ បងៗ ៣ នាក់ទៅរៀនក្នុងសាលារដ្ឋនៅក្នុងខេត្ត

ភ្ញៀវ ដោយទៅនៅជាមួយញាតិរបស់គាត់ ចំណែកឯ ៣ នាក់ ក្រោយៗទៀតនៅតូចៗ ដើរលក់ផ្កា ធូប ទៀន ឲ្យអ្នកដែលគេមកថ្វាយបង្គំព្រះធាតុ បានចំណេញបន្តិចបន្តួចដើម្បីជួយផ្គត់ផ្គង់គ្រួសារ ។ ចំណែកលោក " ប៉ាន់ " និងភរិយាវិញ លក់កាហ្វេ និងគុយទាវ បានសល់ខ្លះផ្ញើទៅឲ្យកូនរៀន ។ សូម្បីធ្វើការហត់នឿយច្រើនយ៉ាងណា ក៏បានត្រឹមតែគ្រប់ចាយនិងចំណាយប៉ុណ្ណោះ ទើបជីវិតភាពរបស់គាត់នៅតែក្រលំបាកគោកយ៉ាកខ្វះខាតជានិច្ច ។ សូម្បីក្រលំបាកយ៉ាងនេះក៏ដោយ នាយ " ប៉ាន់ " នៅតែមានសទ្ធាធ្វើបុណ្យបានទៀតជឿព្រះពុទ្ធសាសនា ដាក់បាត្រឲ្យអាត្មាជានិច្ចរាល់ព្រឹកមិនដែលខានទេ ។ ក្រោយពីសួរសុខទុក្ខតាមទំនៀមទម្លាប់រួចហើយ លោក " ប៉ាន់ " ចាប់ផ្ដើមនិយាយឡើង ក្នុងបំណងដែលមកជួបអាត្មានេះ ៖

- ខ្ញុំកូណាចង់ផ្លាស់ប្ដូរមុខរបរម្ដង ពីព្រោះការលក់កាហ្វេនៅជើងភ្នំនេះ មិនមានការរីកចម្រើនទៅមុខសោះ ការចំណូលគឺអាស្រ័យនៅលើអ្នកដែលគេមកថ្វាយបង្គំព្រះធាតុ ។ នៅក្នុងរដូវក្ដៅអាចមានចំនួនគ្រាន់ខ្លះ ប៉ុន្តែនៅក្នុងរដូវភ្លៀងវិញ បើមិនមានមនុស្សម្នាគេឡើងមកទេនោះត្រូវចូលដើមហើយ ខ្ញុំកូណាបានពិគ្រោះជាមួយនឹងភរិយាថា នឹងរកទិញរ៉ឺម៉កកង់បីដែលគេហៅថា " តុកៗ " បានមួយគ្រឿង ដើម្បីទទួលមនុស្សដែលគេមកថ្វាយបង្គំព្រះធាតុនោះ ចំណែកភរិយាក៏អាចនៅលក់កាហ្វេដូចដើមតទៅទៀត ។ មានមិត្តម្នាក់ គេនិយាយលក់រ៉ឺម៉កកង់បីរបស់គេ

ក្នុងតម្លៃថោកគួរសមគឺ ៦០០០ បាទ នៅពេលនេះខ្ញុំករុណាមានតែ ២០០០ បាទប៉ុណ្ណោះ សូមសេចក្ដីមេត្តាករុណាព្រះអង្គជួយបន្ថែម ៤០០០ បាទទាន !

- ញោមបាននឹងហើយថា អាត្មាជាព្រះសង្ឃអាគន្តុក ហើយមកនៅអាស្រ័យក្នុងទីវត្តនេះ មិនបានយូរប៉ុន្មានផង តើនឹងបានប្រាក់ពីណាច្រើនយ៉ាងនេះមកជួយញោម ?

- ខ្ញុំករុណាបានយល់នូវចំណុចនេះហើយ ខ្ញុំករុណាមិនមែនតាំងចិត្តមកសុំប្រាក់ពីគេជាគុណនោះទេ ប៉ុន្តែសូមឲ្យព្រះអង្គជួយខ្ចីលោកគ្រូធំឲ្យខ្ញុំករុណាផងទាន ពីព្រោះប្រាក់របស់វត្តមានច្រើន ខ្ញុំករុណានឹងសងវិញក្នុងមួយខែ ៣០០ បាទ ហើយចំណែកការប្រាក់វិញ ខាងវត្តយកប៉ុន្មានខ្ញុំករុណាព្រមទាំងអស់

នៅពេលបានស្ដាប់នូវបញ្ហានិពិបាករបស់នាយ ប៉ាន់រួចហើយ អាត្មាមានការពិបាកតឹងទ្រូងដើមទ្រូងភ្លាម ៗ រឿងរបស់តសីនៅមិនទាន់សម្រេចផង ស្រាប់តែមានរឿងរបស់ញោម ដែលធ្លាប់មានឧបការគុណចូលមកថែមមួយទៀត ចូលមកព្រមគ្នាទាំង ២ នាក់ គឺសុទ្ធតែជារឿងទាក់ទងជាមួយទ្រព្យសម្បត្តិ ដែលអាត្មាបានលះបង់រួចហើយ ថានឹងមិនវិលវល់តទៅទៀតទេ ប៉ុន្តែគិតទៅគិតមកក៏មានសេចក្ដីអាណិតញាតិញោម ដែលកំពុងតែជួបប្រទះសេចក្ដីក្ដៅក្រហាយហើយថែមទាំងឈ្លោកមុខមកសុំការជួយសង្គ្រោះទៀត បើបដិសេធនូវសំណូមពរនេះដូចជាចិត្តដាច់ពេក ហើយគាត់ជាអ្នកមានឧបការគុណទៀតផង ជាការមិនសម

គ្រួសោះ សូម្បីគាលមានព្រាហ្មណ៍ម្នាក់ចូលទៅសូមបួស គាត់គ្មានញាតិសោះ ព្រះសារីបុត្រ បានទទួលជាម្ចាស់ជួយចាត់ចែងឲ្យ ពីព្រោះលោកចាំបានថា ព្រាហ្មណ៍នេះធ្លាប់ប្រគេនបាយដល់លោកមួយវែកដែរ ឯលោក “ ប៉ាន់ ” ជាត់បានឲ្យអាត្មាជារៀងរាល់ៗថ្ងៃ នៅពេលគាត់មានការក្តៅក្រហាយមកសូមឲ្យអាត្មាជួយតើអាត្មាបដិសេធបានដែរឬ ? ក្រោយពីបានគិតយ៉ាងល្អិតល្អន់យ៉ាងនេះហើយ អាត្មាបានសម្រេចចិត្តជួយលោក “ ប៉ាន់ ” ហើយការជួយដែលប្រសើរបំផុតនោះគឺ លើកទ្រព្យសម្បត្តិរបស់លោកតាឥសីចាស់នោះប្រគល់ទៅឲ្យគែម្តងទៅ ពីព្រោះគាត់មានការក្តៅក្រហាយជាមួយនឹងទ្រព្យសម្បត្តិនោះ ហើយគាត់ក៏មានចិត្តសទ្ធាក្នុងព្រះពុទ្ធសាសនា, នៅពេលបានសម្រេចចិត្តដូច្នេះហើយ អាត្មាបានប្រាប់គេថា៖

- អាត្មាពេញចិត្តនឹងជួយញោម !

គេក៏ឱនក្រាបទៀបជើងអាត្មា ដោយសេចក្តីត្រេកអរយ៉ាងខ្លាំងក្លា ហើយពោលពាក្យអរគុណយ៉ាងច្រើន ៗ

- ប៉ុន្តែអាត្មាមិនបានសុំខ្ចីអំពីវិត្តនោះទេ ពីព្រោះអាត្មាជាព្រះសង្ឃអាគន្តុកៈ ដែលមកសុំស្នាក់នៅបណ្តោះអាសន្នប្រហែលជាលោកមិនទុកចិត្ត ដល់ទៅឲ្យអាត្មាខ្ចីប្រាក់យ៉ាងច្រើនដូច្នេះទេណ៎ា

- ដោយវិធីណាក៏បានដែរ ស្រេចតែព្រះអង្គមេត្តាទៅចុះ !, លោក ប៉ាន់ និយាយដោយពាក្យរីករាយ

- មានកន្លែងមួយនៅមិនឆ្ងាយពីទីនេះប៉ុន្មានទេ មានកំណប់យ៉ាងច្រើនរបស់ " សុចេរិតសី " នៅក្នុងល្អាងភ្នំមួយ, អាត្មាចាប់ផ្ដើមនិយាយប្រាប់លោក " ប៉ាន់ ", សុចេរិតសីបានស្នើសុំប្រគល់ទ្រព្យសម្បត្តិនោះដល់អាត្មា ក៏ប៉ុន្តែអាត្មានៅមិនទាន់ឆ្លើយថាទទួលនៅឡើយទេ ពីព្រោះនៅមិនទាន់ដឹងថាតើនឹងត្រូវយកទៅធ្វើអ្វីនៅឡើយ ញោមមកក្នុងថ្ងៃនេះជាការល្អហើយណាំធ្វើឲ្យអាត្មានឹកឃើញនូវមធ្យោបាយនឹងចាត់ចែងទ្រព្យសម្បត្តិនោះ ឲ្យវាផុតស្រឡះតែម្ដងទៅ !

លោក " ប៉ាន់ " សម្លឹងមើលមុខអាត្មាដូចជាមិនសូវជឿថារឿងដែលអាត្មានិយាយប្រាប់នេះ តើជាការពិតឬក្លែងក្លាយ...

- ព្រះអង្គនិយាយលេងឬនិយាយមែនហ្នឹងទាន ! គេសួរឡើងក្នុងការងឿងឆ្ងល់

- អាត្មាមិននិយាយលេងទេ, ឯចំណែកញោមវិញ ញោមជឿឬមិនជឿវាជារឿងរបស់ញោមទេ !

លោក ប៉ាន់ នៅពេលក្រោយមកគេក៏ជឿអាត្មា ប៉ុន្តែគេប្លែកក្នុងចិត្តយ៉ាងខ្លាំង ។ ដើម្បីឲ្យគេពិសោធដោយខ្លួនឯង អាត្មាបានប្រាប់ផ្លូវដើរទៅកន្លែងទុកសម្បត្តិនោះ ដែលមានដើមឈើធំនិងគុម្ពឫស្សីជាទីចំណាំ

- ញោមអាចទៅមើលផ្ទាល់ភ្នែក ដោយខ្លួនឯងក៏បានដែរ, អាត្មាបានបញ្ជាក់នូវពាក្យចុងក្រោយ, តែសុំកុំអាលទៅធ្វើអ្វីឲ្យសោះ លុះត្រាបានសម្រេចទទួលពាក្យជាមួយ

លោកនិសីនោះសិន ស្អែកនេះពេលព្រឹកសុំញោមមកជួប នឹងអាត្មាទៀតនៅកន្លែងនេះ

លោក ប៉ាន់ ទទួលពាក្យរបស់អាត្មាហើយក៏គ្រាបបង្គំលាចេញទៅ ដោយឫកពារប្រញាប់ប្រញាល់ ខ្លួនអាត្មាក៏សប្បាយចិត្តដែរ ដោយបានជួយឲ្យគេបានសេចក្ដីសុខ ហើយសប្បាយចិត្តមួយទៀត គឺបានជួយឲ្យនិសីជរនោះមានសេរីភាព ។

នៅពេលព្រឹកឡើង អាត្មាបានចេញទៅបិណ្ឌបាតតាមផ្ទះជាធម្មតានៅជិតជើងជណ្ដើរនាគតាមធម្មតា ។ នៅពេលដល់ភូមិរបស់លោក " ប៉ាន់ " មានការប្លែកបន្តិចបន្តួចពីព្រោះឃើញទ្វារផ្ទះនៅបិទ ហើយបើកតែបន្ទះភ្ជារមួយបន្ទះ ដែលរាល់ថ្ងៃធ្លាប់តែបើកស្រឡះ ជាពិសេសទៅទៀត នៅខាងក្នុងផ្ទះស្ងាត់ខុសធម្មតា ដូចជាទាំងអស់គ្នានៅដេកលក់មិនទាន់ភ្ញាក់អាត្មាយល់ថាប្រហែលជាយប់មិញគេបើកហាងនៅយូរ គេចូលដេកយប់ជ្រៅហើយមើលទៅ ទើបគេដេកជ្រុលដល់ថ្ងៃថ្មើនេះឲ្យគេខានធ្វើបុណ្យ ។ អាត្មាគិតហើយទើបគាត់ចិត្តឈរដោយចិត្តស្ងប់ នៅខាងមុខហាងរបស់គេ ចំកន្លែងពីមុខដែលបើកបន្តិច បើមានមនុស្សភ្ញាក់គេអាចនឹងឃើញអាត្មា ហើយចេញមកដាក់បាត ។ ឈរនៅមួយសន្ទុះ បានឮសម្លេងក្មេងតូចស្រែកពីក្នុងហាងថា៖

- ម៉ែ ! លោកនិមន្តមកហើយ

មិនយូរប៉ុន្មាន អាត្មាឃើញភរិយារបស់នាយ ប៉ាន់ ប្រញិបប្រញាប់បើកភ្ជារ នៅមុខភានចេញថែមមួយបន្ទះ

ទៀត ប៉ុន្តែនឹកឆ្ងល់ក្នុងចិត្តយ៉ាងខ្លាំង ដោយឃើញគាត់បើកទ្វារបណ្តើរយំបណ្តើរ ។ នៅពេលរៀបចំរួចហើយ ក៏មកអង្គុយលើកដៃសំពះអាត្មា ហើយពោលទាំងទឹកភ្នែកថា៖

- សូមព្រះតេជគុណនិមន្តមកខាងក្នុងសិនទាន!
- តើមានហេតុការណ៍អ្វីកើតឡើងឬញោម? អាត្មាសួរ
- បង "ប៉ាន់" កើតអីមិនដឹងទេទាន សូមទានមេត្តាមើលដោយព្រះអង្គឯងចុះ! គាត់ព្យាយាមរម្ងាប់នូវការភ្ញាក់ផ្អើល

អាត្មាបានដើរចូលទៅតាមភរិយារបស់គាត់ ដោយចិត្តខ្វល់ខ្វាយព្រួយខុសពីធម្មតា ។ លុះគ្រាចង់ភ្លេចខ្លួនដែរ សមណសញ្ញាផ្សេងៗទាំងអស់ សូម្បីនៅក្នុងបន្ទប់ហាងនោះងងឹតបន្តិច ប៉ុន្តែអាចមើលឃើញរបស់ផ្សេងៗបានច្បាស់ ។ ភរិយានាយ ប៉ាន់ បានយកកៅអីមួយមកឲ្យអាត្មាអង្គុយនៅជិតគ្រែដេកដែលធ្វើអំពីបន្ទះឫស្សី ហើយលើកមុងឡើងពាក់ទៅខាងលើ ភាពដែលនៅចំពោះមុខរបស់អាត្មា គឺជានាយ ប៉ាន់ ដែលដេកធ្មេចភ្នែកព្រិមៗ ដកដង្ហើមតិចៗនៅលើគ្រែ មុខមាត់របស់គេពោរពេញទៅដោយស្នាមដាច់ដាច្រើនកន្លែងសឹងតែមើលមិនស្គាល់ ។ ភរិយារបស់គាត់បានបកភួយចេញ ដើម្បីឲ្យឃើញស្នាមដាច់ផ្សេងៗទៀត ដែលមាននៅពាសពេញដើមទ្រូង ពោះនិងរហូតជើង ។

- តើគេកើតអីទៅហ្នឹង? អាត្មាសួរដោយព្យាយាម

រម្ងាប់ចិត្តឲ្យបានជាប្រក្រតី

- ខ្ញុំករុណាក៏មិនដឹងដែរ..., ភរិយានាយ "ប៉ាន់" ឆ្លើយដោយសម្លេងស្រួលៗ, នៅពេលយប់មិញគាត់បានចេញពីផ្ទះទៅប្រហែលជាម៉ោង ២ អធ្រាត្រ បានប្រាប់ថាទៅមានការ ហើយក៏ចេញបាត់ទៅ ខ្ញុំករុណានៅរង់ចាំជិតមួយយប់ ក៏មិនទាន់ឃើញត្រឡប់មកវិញ ទាល់តែម៉ោង ៤ ទៀបភ្លឺបានឮសម្លេងក្អុងក្អាំងៗនៅមុខរាន ក៏បើកទ្វារមកមើលបានឃើញគាត់ដេកនៅក្នុងថ្លុកឈាមលើដីនេះតែម្តង ទើបជួយលើកគ្រាគាត់មកឲ្យដេកនៅលើគ្រែ សួរអ្វីៗមិនដឹងទាំងអស់ ដូចដែលព្រះអង្គបានឃើញនេះឯង...

## លោភៈ

**ពាក្យប្រាំពីរ**

**លោភនាំអន្តរាយគ្រប់ប្រការ លោភនាំចិន្តាឲ្យហ្មងសៅ**
**លោភនាំភ្លេចពាក្យប្រៀនប្រដៅ លោភនាំល្ងង់ខ្លៅព្រោះវង្វេង ។**
**លោភនាំឲ្យបង់ពាក្យសច្ចៈ លោភនាំហាយនៈ[១] ឃើញជាក់ស្តែង**
**លោភផុតបំផ្លាញកាយចិត្តឯង លោភនាំឲ្យលែងខ្លាចបាបកម្ម ៕**

ដោយឧបាសក មិុញ សាវ៉ាង

(១) ហាយនៈ --យៈនៈ សំ. បា. ( ន. ) (ហាយន) ឆ្នាំ ។ សេចក្តីវិនាស, សេចក្តីសាបសូន្យ; ដំណើរទ្រុឌទ្រោម : ការប្រព្រឹត្តអាក្រក់នាំឲ្យមានហាយនៈ ។ ព. ផ្ទ. វឌ្ឍនៈ ។

# ៧. ទុក្ខលោក

រូបរាងរបស់នាយ "ប៉ាន់" ដែលពោរពេញទៅដោយស្នាមដាច់ និបៅ ស្នាមរបកស្បែកដាច់ជ្រៅមានឈាមចេញមក ធ្វើឲ្យអាត្មានឹកអាណិតស្រណោះសង្វេគក្នុងចិត្តឥតឧបមា មើលទៅភរិយានិងកូនតូចៗទាំង ៣ នាក់ដែលគេកំពុងតែយំនៅជិតខាង រឹតតែធ្វើឲ្យចិត្តអាត្មាកាន់តែស្លុតអាណិតខ្លាំងថែមទៅទៀត បានយល់បេះដូងនៅហ្នឹងថ្កល់ប្រៀបបីដូចជាត្រូវភ្នំសុមេរុទាំងមូលមកសង្កត់ ទុក្ខសម្រាប់អាត្មានៅក្នុងពេលនេះ គ្រប់ជីវិតទាំងអស់ដែលនៅជុំវិញអាត្មាគឺសុទ្ធតែជាទុក្ខ ដែលកំពុងសម្តែងបទបែបដែលពិតប្រាកដរបស់ខ្លួនយ៉ាងច្បាស់ ៗ សូម្បីខ្លួនអាត្មាក៏ដោយដែលកំពុងតែរៀនបំបាត់ទុក្ខ ក៏ទៅរួមសម្តែងបទបែបនៃសេចក្តីទុក្ខជាមួយគេដែរដោយមិនដឹងខ្លួន ៗ នៅក្នុងបន្ទប់ដ៏អាប់អួររបស់នាយប៉ាន់ក្នុងពេលនោះ ពួរងំទៅដោយសម្លេងសោកសៅ សូម្បីជាសម្លេងតិចៗក៏ដោយ ប៉ុន្តែអាចទៅកម្រើកដល់ចិត្តជាងសម្លេងផ្គរលាន់ទៅទៀត ៗ ទឹកភ្នែកដែលហូរចេញមក ដូចជាកំពុងតែស្រោចស្រពឲ្យផែនថ្កាល់ មិនជាច្រើនទេ ប៉ុន្តែមានឥទ្ធិពលទៅដល់បេះដូងច្រើនជាងមហាសមុទ្រ សូម្បីតែគេគ្រប់គ្នាមិនហើបមាត់និយាយ ប៉ុន្តែភាសានៃទុក្ខបានស្រែករំពងប្រកាសខ្លួនឯងគ្រប់ពេលវេលា ៗ

អាត្មាបានមានសតិឡើងវិញ ទើបនិយាយប្រាប់ទៅភរិយារបស់គេថា៖

- កុំយំសោកពេកញោម ប្រហែលគាត់មិនមានអ្វីខ្លាំងទេញោម ប្រញាប់ទៅស្លៀកពាក់ឲ្យហើយទៅ នៅពេលបន្តិចទៀតមានឡានគេមកពីក្រុង នឹងអាចនាំគាត់ទៅឡើងឡាននាំទៅព្យាបាលនៅមន្ទីរពេទ្យឲ្យគេបិទដំបៅឲ្យគាត់ទៅ

ភរិយារបស់នាយ "ប៉ាន់" គាត់ក៏ចេញទៅស្លៀកពាក់ភ្លាម អាត្មាក៏ចូលទៅជិតគ្រែរបស់នាយ ប៉ាន់ ហើយយកដៃទៅចាប់កដៃស្ទាបមើលជីពចរ ៗ សូម្បីបាននឹងថាត្រជាក់ហើយ ជីពចរដើរយឺតៗបន្តិចតែមិនមានអ្វីខុសពីធម្មតាដែលគួរឲ្យព្រួយបារម្ភណ៍ អាត្មាបានប្រាប់នូវអាការៈរោគនេះដល់ភរិយារបស់គាត់ជាការលើកទឹកចិត្ត ហើយបានហៅឈ្មោះនាយ ប៉ាន់ តិចៗច្រើនដង គាត់បានឆ្លើយដោយសម្លេងខ្សាវៗ "អឺៗ" ដោយមិនបានបើកភ្នែក អាត្មាព្យាយាមគិតមើលអ្វីធ្វើឲ្យគាត់ភ្ញាក់ ដើម្បីនឹងសួរនូវរឿងរ៉ាវបានស្ដាប់ ប៉ុន្តែមិនបានសម្រេច ហើយបើព្យាយាមសួរទៅទៀតគឺជាការធ្វើឲ្យរំខានដល់អ្នកជម្ងឺឥតប្រយោជន៍ ទើបអង្គុយជិតនៅស្ងៀមៗ សម្លឹងមើលដោយសេចក្ដីអាណិតសង្វេគក្នុងចិត្ត ៗ

នៅពេលព្រះអាទិត្យរះឡើងច្បាស់ហើយ អ្នកស្រុកជិតខាងផ្ទះនាយ "ប៉ាន់" ក៏នាំគ្នាចូលមកសួរអំពីមូលហេតុដែលបានកើតឡើងរបស់នាយ ប៉ាន់ អ្នកដែលបានត្រឡប់ពីការសួរសុខទុក្ខហើយ ត្រឡប់ទៅវិញក៏ទៅនិយាយប្រាប់

តៗគ្នាទៀត ដូច្នេះក៏មានមនុស្សមកមើល មកសួរគាត់តែច្រើនឡើងៗ លុះគ្រានៅក្នុងផ្ទះនាយ ប៉ាន់ ពេញណែនទៅដោយញាតិមិត្ត ដូចជាកំពុងតែធ្វើបុណ្យទានអ្វីមួយ ឮសូរសម្លេងពេញក្នុងផ្ទះនាំគ្នានិតអំពីស្នាមដាច់របស់នាយ ប៉ាន់ គឺមានយោបល់ផ្សេងៗគ្នា ខ្លះណាស៊ើបសួរពីប្រពន្ធរបស់គាត់អំពីហេតុការណ៍ទាំងនោះដើម្បីរកការពិត ប៉ុន្តែតវិយារបស់គាត់បានឆ្លើយថាហេតុការណ៍ទាំងអស់នេះ គឺគាត់មិនបានដឹងទាល់តែសោះ ។ នាយ “ អាយ ” ជាមិត្តជិតខាងបានប្រាប់ដល់ប្រពន្ធនាយ “ ប៉ាន់ ” ថា ៖ កាលពីម៉ោង ២ អាធ្រាត្រយប់មិញ ឃើញនាយ ប៉ាន់ ទៅខ្ចីភ្លើងពិលនៅផ្ទះគាត់ ហើយប្រាប់ថាយកទៅមានការបន្តិច នៅពេលបានពិលនោះហើយ នាយ “អាយ ” ក៏មិនបានយកចិត្តទុកដាក់ថាគេយកទៅណានោះទេ ពីព្រោះការខ្ចីភ្លើងពិលនេះជារឿងធម្មតាធ្លាប់ខ្ចីគ្នាទៅវិញទៅមកជានិច្ច ។ មានសម្តីជាច្រើនដែលសន្និដ្ឋានថា ប្រហែលជានាយ ប៉ាន់ ទៅធ្វើកិច្ចការៈអ្វីមួយនៅក្នុងព្រៃហើយបានជួបខ្លា ហើយត្រូវខ្លាខាំធ្វើឲ្យមានរបួសនេះ ។ ប៉ុន្តែក្រោយពីបានត្រួតមើលមុខរបួសហើយបានសន្និដ្ឋានថានោះដូចជាមិនមែន ពីព្រោះស្នាមដំបៅនៅលើខ្លួនរបស់គាត់ មិនបានបង្ហាញថាជាស្នាមក្រចករបស់ខ្លាទេ គឺជាស្នាមដំបៅជ្រៅដល់សាច់ មានឈាមហូរចេញមកហើយមានស្នាមតែខាងមុខតែប៉ុណ្ណោះ គឺមាននៅដើមទ្រូងនិងពោះ ចំណែកខាងក្រោយខ្នងមិនឃើញមានអ្វីសោះឡើយ ។ តាមដែលការសង្កេតទៅឃើញថា នាយ ប៉ាន់

ត្រូវបានគេអូសផ្ទាប់មុខទៅលើផែនដី ដោយរយៈផ្លូវឆ្ងាយគួរសមដែលតាមសង្កេតមើល អ្នកខ្លះថានាយ ប៉ាន់ ឡើងដើមឈើដោយខ្ញុំប ហើយធ្លាក់ធ្លាក់ចុះមកដែលកំពុងយកនែខ្ញុំបដើមឈើ ទើបមានស្នាមដាច់ខាងមុខដូច្នេះ ។ តាមយោបល់នេះគួរស្ដាប់បានដែរ ប៉ុន្តែគួរឲ្យឆ្ងល់ថាតើនាយ ប៉ាន់ ទៅឡើងដើមឈើធ្វើអ្វីទាំងកណ្ដាលយប់អធ្រាត្រដូច្នេះ ហើយនៅមានមតិផ្សេងៗទៀតជាច្រើន តែមិនបានការទាំងអស់ លុះត្រាតែនាយ ប៉ាន់ ទើបអាចនិយាយប្រាប់ដោយខ្លួនឯងទើបច្បាស់យកជាការបាន ។

អាត្មាបានប្រាប់ញាតិរបស់នាយ “ ប៉ាន់ ” ឲ្យនាំគាត់ទៅមន្ទីរពេទ្យហើយក៏លាញាតិញោមមកកុដិវិញ ហើយក៏រៀបចំឆាន់អាហារពេលព្រឹក ប៉ុន្តែឃើតជាងសព្វដង ។

នៅពេលកំពុងឆាន់ ចិត្តគិតទៅនាយ ប៉ាន់ ធ្វើឲ្យឆាន់បានតិចជាងសព្វមួយដង ។ នៅពេលឆាន់អាហាររួច បានលាងជូតបាត្រទុកត្រឹមត្រូវរួចអស់ហើយ រឿងរបស់នាយ “ ប៉ាន់ ” នៅមិនទាន់ផុតពីចិត្ត ការសំខាន់នោះគឺចង់ដឹងនូវហេតុការណ៍ តើអ្វីដែលកើតឡើងធ្វើឲ្យនាយ “ ប៉ាន់ ” បានទទួលរបួសប្លែកយ៉ាងនេះ ។ សេចក្ដីអន្ទះសាចង់ដឹងការពិតហៀបតែនឹងសម្រេចចិត្តថានិងទៅមើលនាយ ប៉ាន់ នៅឯមន្ទីពេទ្យ ប៉ុន្តែបានរម្ងាប់ចិត្តបាន ហើយប្រកបកិច្ចវត្តទៅតាមធម្មតា ។

នៅពេលរសៀលក្នុងថ្ងៃហ្នឹងឯង អាត្មាកំពុងសម្រាកនៅមុខកុដិ នាយ អាយ ដែលជាមិត្តរបស់នាយ ប៉ាន់ បាន

ចូលមកក្នុងវិហារគេភក្ត្រា គាត់អង្គុយចុះ ហើយលើកដៃសំពះ និយាយឡើងថា៖

- ពេលព្រឹកមិញនេះ ក្រោយពីព្រះអង្គនិមន្តចេញមក មិនយូរប៉ុន្មាន មានឡានគេឡើងមកពីភៀង យើងក៏បាន ជួយលើកនាយ " ប៉ាន់ " ឡើងឡានធាំទៅមន្ទីរពេទ្យ លោក គ្រូពេទ្យបានត្រួតពិនិត្យមើលស្នាមរបួសដាច់នោះភ្លាម រួច ហើយនាយ " ប៉ាន់ " ក៏ដេកលក់ស៊ប់ទៅ លុះដល់ជិតថ្ងៃ រសៀលទើបបានភ្ញាក់ ពេលគេបើកភ្នែកឡើង ពាក្យដំបូង ដែលគេនិយាយគឺគេចង់ជួបព្រះអង្គ ខ្ញុំកូណាព្យាយាមសួរ នូវហេតុការណ៍ដែលគេបានដាច់សាច់ចេញឈាម ប៉ុន្តែគេ មិនព្រមប្រាប់ទាល់តែសោះ គេសុំជួបតែព្រះអង្គមុនសិន លោកគ្រូពេទ្យព្យាយាមសួរគាត់ ប៉ុន្តែមិនបានចម្លើយអ្វី សោះ ហេតុដូច្នេះខ្ញុំក៏ប្រញាប់មកនិមន្តព្រះតេជគុណទៅជួប គាត់នៅឯមន្ទីរពេទ្យឥឡូវនេះផង

ភក្ត្រាភ្ញាក់ប្រហោងពោះឆ្លូងដោយបានឮថា អាការៈ របស់គេបានល្អឡើងវិញអាចនិយាយបាន ហើយមានប្លែក ក្នុងចិត្ត ដែលគេប្រាថ្នាចង់ជួបនឹងភក្ត្រាមុននរណាៗទាំង អស់ ។ ដោយមិនបង្អង់យូរភក្ត្រាក៏ក្រង់ចីពរ គាន់ចង់យាម ហើយក៏ដើរតាមក្រោយនាយ "អាយ " ចុះមកឡើងឡាននៅ ជើងជណ្តើរនោគ ។

នៅមន្ទីរពេទ្យភក្ត្រាបានជួបនាយ ប៉ាន់ ដេកនៅលើ គ្រែ ដោយប្រែរូបសឹងតែមើលមិនស្គាល់ ពីព្រោះតាមមុខ មាត់ខ្លួនប្រាណពេញទៅដោយបួស្នាកពណ៌ស មានគេយក

គៅអឹមកឲ្យអង្គុយនៅជិតក្រែរបស់គេ ។ អាត្មាអង្គុយចុះហើយសម្លឹងមើលនាយ “ ប៉ាន់ ” ដោយចិត្តពោរពេញទៅដោយការព្រួយបារម្ភណ៍និងអាណិតលាយគ្នានាយ “ ប៉ាន់ ” លើកដៃឡើងសំពះយ៉ាងលំបាក ភ្នែកទាំងពីរខាងពេញទៅដោយទឹកភ្នែក ឃើងសម្លឹងមើលគ្នាដោយអាការៈស្ងប់ស្ងាត់មួយសន្ទុះ ទើបនាយ “ ប៉ាន់ ” បាននិយាយឡើងដោយសម្លេងខ្សោយថា ៖

- ព្រះអង្គ ! ខ្ញុំកូណាបានធ្វើខុសហើយ សូមក្រាបបង្គំអភ័យទោស សូមព្រះអង្គមេត្តាអភ័យទោសឲ្យខ្ញុំកូណាផង

ពាក្យរបស់នាយ “ ប៉ាន់ ” ធ្វើឲ្យអាត្មាឆ្ងល់ ពីព្រោះមិនបានដឹងថាតើគេធ្វើខុសអ្វី ហើយដូចម្តេចទើបត្រូវមកសុំទោសអាត្មាផង ដើម្បីឲ្យច្បាស់ទើបអាត្មាសួរទៅគេថា ៖

- តើញោមបានធ្វើអ្វីខុសឬ ? អាត្មានឹកមិនឃើញទេថាតើញោមបានធ្វើអ្វីខុសមក

- ខុសខ្លាំងណាស់ ! នាយ “ ប៉ាន់” បញ្ជាក់, គេក្រឡេកមើលទៅជុំវិញក្រែ ដូចជារកសម្លឹងរកមើលអ្វីម៉្យាង ហើយក៏បានបក់ដៃហៅនាយ “អាយ” ដែលឈរនៅជិតក្រែ ឲ្យចូលមកជិតគេប្រាប់ថា ឲ្យអ្នកទាំងអស់គ្នាចេញទៅខាងក្រៅសិនគេត្រូវការនិយាយរឿងអ្វីមួយ ជាមួយព្រះអង្គផ្ទាល់ខ្លួនញាតិមិត្តទាំងអស់ធ្វើតាមពាក្យសុំដោយល្អ ប៉ុន្តែអ្នកទាំងអស់គ្នានាំគ្នាដើរចេញទៅ ដោយទឹកមុខបង្ហាញថាខុសបំណងរបស់គេ ។

- លោកម្ចាស់ ! នាយ "ប៉ាន់" និយាយឡើងនៅពេលអ្នកឯទៀតបានចេញទៅអស់, ព្រះអង្គមិនបានដឹងមែនឬថាដូចម្ដេចបានជាខ្ញុំករុណាជួបនិងគ្រោះកម្មក្នុងពេលនេះ ?

- តើឲ្យអាត្មាដឹងដូចម្ដេច បើញោមមិនទាន់បានប្រាប់អាត្មាផងនោះ ?

នាយ " ប៉ាន់ " នៅស្ងៀមមួយសន្ទុះ ហើយនិយាយឡើងថា ៖

- ខ្ញុំករុណានឹកថា ព្រះអង្គបានដឹងរឿងនេះហើយ ពីព្រោះព្រះអង្គជាអ្នកប្រាប់ខ្ញុំម្ចាស់ រឿងល្អងមហាសម្បត្តិរបស់ឥសីនោះ នៅពេលបានឮពាក្យថាល្អងមហាសម្បត្តិរបស់ឥសីអាត្មាភ្ញាក់ព្រើត ពីព្រោះមិនបានគិតដល់បន្តិចបន្តួចទាល់តែសោះ ថាគ្រោះកម្មរបស់នាយប៉ាន់ទៅទាក់ទងជាមួយនឹងល្អងមហាសម្បត្តិ ។ នៅពេលឲ្យគេនិយាយរឿងរ៉ាវទៅតាមការពិតឲ្យស្ដាប់ ទើបអាត្មាពោលថា ៖

- អាត្មាខ្លួនឯងមិនដឹងរឿងល្អងមហាសម្បត្តិនោះ ឲ្យបានច្រើនជាងដែលបាននិយាយឲ្យញោមស្ដាប់ កាលពីម្សិលម៉ិញនោះទេ តើញោមអាចនិយាយឲ្យអាត្មាស្ដាប់ថា តើ រឿងរ៉ាវទាំងនោះវាមានមកយ៉ាងណាខ្លះ ?

- កាលពីម្សិលម៉ិញ, នាយ "ប៉ាន់" ក៏ចាប់ផ្ដើមនិយាយ, ក្រោយពីបានដឹងរឿង ដែលទាក់ទងនឹងកំណប់ទ្រព្យឥសីនោះហើយ ខ្ញុំករុណាក៏លបទៅ ពិនិត្យមើលទីកន្លែងដែលព្រះតេជគុណប្រាប់នោះតែម្នាក់ឯងស្ងាត់ៗ ហើយក៏បាន

ជួបគ្រប់យ៉ាងតាមដែលព្រះអង្គបាននិយាយប្រាប់ ។ ការពិតទីកន្លែងនោះ មិនមែនជាប្លែកអ្វីទេសម្រាប់ខ្ញុំករុណា ពីព្រោះ ខ្ញុំករុណាធ្លាប់ដើរទៅមកនៅទីកន្លែងនោះពីមុនមកហើយ យ៉ាងហោចណាស់ក៏ ៣ឬ ៤ដងដែរ ប៉ុន្តែមិនដែលចាប់ភ្លឹកទាល់តែសោះ ពីព្រោះមិនដឹងថាមានមហាសម្បត្តិលាក់ទុក ។ នៅពេលពិនិត្យមើលកន្លែងដែលជាទីពេញចិត្តរួចហើយ ខ្ញុំករុណាក៏ត្រឡប់មកផ្ទះវិញ នៅពេលដើរតាមផ្លូវ ខ្ញុំករុណាគិតរហូតថា តើនឹងយករបៀបណានូវសម្បត្តិមហាសាលនោះ ខ្ញុំករុណាសប្បាយចិត្តយ៉ាងខ្លាំងរកប្រាប់មិនត្រូវ ដែលនឹងក្លាយខ្លួនទៅជាមហាសេដ្ឋីក្នុងរយៈពេលតែមួយថ្ងៃ ខ្ញុំករុណាបានធ្វើគម្រោងការនូវអនាគតទុកយ៉ាងអន្លើតអន្លោង...

លុះដល់ពេលរសៀលថ្ងៃនោះ ខ្ញុំករុណាដេកញញឹមនៅក្នុងផ្ទះដោយមិនបានធ្វើការអ្វីសោះ ។ ក្នុងពេលដែលកំពុងដេកគិតនោះឯង ខ្ញុំករុណាកើតសេចក្តីលោភ ចង់បានមហាសម្បត្តិឲ្យរហ័ស ជាទីបំផុតដើម្បីយកទ្រព្យនោះមកទុកនៅក្នុងការគ្រប់គ្រងរបស់គ្រួសារខ្ញុំករុណា ចិត្តមួយទៀតចង់ប្រញាប់ទៅជីកយកមហាសម្បត្តិនោះ ក្នុងថ្ងៃម្សិលមិញម្ល៉េះ ពីព្រោះចង់ពិសោធមើលថា ពាក្យពោលរបស់ព្រះអង្គតើជាការពិតឬទេ ? ថែមទាំងព្រួយខ្លាចក្រែងព្រះអង្គផ្លាស់ប្តូរចិត្ត លើកសម្បត្តិនោះទៅឲ្យអ្នកផ្សេងវិញទៅ ខ្ញុំករុណាព្រមទាំងកូនប្រពន្ធក៏នឹងអត់លំបាកតទៅទៀត ។ ខ្ញុំករុណាព្រួយបារម្ភណ៍ទៅរឿងផ្សេងៗ តែនៅក្នុងពេលជាមួយគ្នា

នោះក៏គិតដល់ពាក្យរបស់ព្រះអង្គ ដែលស្ដែផ្ដាំថាកុំអាលធ្វើអ្វីឲ្យសោះត្រូវរង់ចាំដល់ថ្ងៃស្អែកសិន ។ ខ្ញុំករុណាគិតគាត់ចិត្តដល់ថ្ងៃរសៀល នៅទីបំផុតផ្នែកសេចក្ដីលោភៈក៏មានជ័យជំនះ ខ្ញុំបានគាត់ចិត្តសម្រេចថានឹងទៅជីកយកមហាសម្បត្តិនៅពេលយប់ម្សិលមិញនេះហើយ ទោះក្លាយទៅជាស្អី ក៏ក្លាយទៅចុះ... ដោយជំនះនូវពាក្យបណ្ដាំរបស់ព្រះអង្គក៏ធ្វើដែរ នេះហើយទានប្រោស គឺសេចក្ដីខុសយ៉ាងធ្ងន់របស់ខ្ញុំករុណា ពីព្រោះសេចក្ដីលោភពិតៗ ខ្ញុំករុណាទើបជំនះនូវពាក្យបណ្ដាំរបស់ព្រះអង្គជាអ្នកមានគុណ នៅទីបំផុតក៏បានជួបសេចក្ដីទុក្ខ ដែលព្រះអង្គបានឃើញមកនេះ ខ្ញុំករុណាសូមក្រាបថ្វាយបង្គំ សូមអភ័យទោសពីព្រះអង្គផង, នាយ “ប៉ាន់” ធ្មេចភ្នែកនៅស្ងៀម ដូចជាឈប់សម្រាកមួយរយៈពេល

- មិនអីទេញោម! អាត្មាពេញចិត្តនឹងលើកទោសឲ្យ, អាត្មានិយាយឡើងនៅពេលដែលគេឈប់សម្រាក, តាមពិតញោមមិនបានធ្វើខុសអ្វីចំពោះអាត្មានោះទេ រហូតដល់មកសូមទោសនោះ អាត្មាបានសង្កេតមកយូរហើយ ដោយឃើញថាញោមជាមនុស្សល្អ មានសីលធម៌មានចិត្តឆ្ងន់ទៅក្នុងការបុណ្យកុសល ការដែលញោមបានធ្វើហួសនៅពាក្យពេចន៍របស់អាត្មាមកនេះ ហើយបានជួបប្រទះនូវសេចក្ដីទុក្ខក្នុងពេលនេះ ក៏ព្រោះតែអំណាចនៃសេចក្ដីលោភ បើញោមមានសេចក្ដីខុសខ្លះ នេះជាសេចក្ដីខ្សោយនៃចិត្តរបស់ញោមឯងទេ ដែលព្រមព្រៀងឲ្យសេចក្ដីលោភអាចមកគ្រប

សង្កត់នូវចិត្តបាន ព្រមឲ្យខ្លួនធ្លាក់ទៅជាកញ្ជះរបស់សេចក្តីលោភបានយ៉ាងងាយ តែបានហើយ រឿងដែលវាកើតឡើងហើយ ក៏ឲ្យហើយទៅចុះ របស់ដែលគួរទុកឲ្យនៅគឺជាមេរៀនអំពីហេតុការណ៍នោះៗ ហេតុការណ៍គ្រប់យ៉ាងដែលកើតឡើងដល់ជីវិតរបស់យើង គឺជាមេរៀនដែលយើងបានអានអំពីសៀវភៅតម្រាច្រើនឯង ដូចជានៅពេលនេះ ញោមអាចបានការចេះដឹងថា សេចក្តីលោភគឺជាគ្រូបិសាចដែលកាចសាហាវ នៅពេលដែលវាបានចូលទៅក្នុងខ្លួនរបស់ណាហើយ វានឹងធ្វើឲ្យមនុស្សនោះគិតតែយកឲ្យបានតែម្យ៉ាងប៉ុណ្ណោះ ភ្លេចច្បាប់ទម្លាប់ភ្លេចសីលធម៌អស់រលីងនៅទីបំផុតសូម្បីបានដូចសេចក្តីប្រាថ្នាហើយ ត្រឡប់ជាខុសបំណងហើយជួបនូវសេចក្តីទុក្ខថែមទៅទៀត ដូចជាពាក្យសុភាសិតបុរាណបានពោលទុកថា ៖ “ **ចចើងចង់លោភ តែងបាត់ធនទៅ** ” សូមញោមចាំទុកចុះណា៎!

នាយ “ប៉ាន់” លើកដៃឡើងសំពះ ហើយនិយាយឡើងថា ៖

- ខ្ញុំករុណានឹងចងចាំទុករហូតដល់ស្លាប់ទាន!

- ល្អហើយចុះ សុំញោមនិយាយតទៅទៀតមើល៍ តើរឿងរ៉ាវហ្នឹងវាមានហេតុគេទអ្វីខ្លះ ? អាត្មានិយាយកាត់នាយ “ ប៉ាន់ ”

- នៅពេលសម្រេចចិត្តថា នឹងទៅជីកយកនូវមហាសម្បត្តិនសីនោះហើយ គឺម្សិលមិញប្រហែលជាម៉ោង២

អាធ្រាត្រ ខ្ញុំករុណាចេញពីផ្ទះហើយចូលទៅខ្ទីពិលរបស់មិត្រ បានហើយ ក៏ដើរចេញទៅតាមផ្លូវតម្រង់កន្លែងទុកសម្បត្តិ នោះម្នាក់ឯង ៗ នៅពេលបំភ្លឺភ្លើងទៅ បានឃើញរបស់គ្រប់យ៉ាងជាធម្មតា ខ្ញុំករុណាក៏ឡើងទៅឈរនៅខាងលើនៃទ្វារល្អាង យកឈើមួយស៊កចូលត្រង់ប្រហោងថ្ម បិទទ្វារល្អាងហើយក៏ស៊ក ប៉ុន្តែឃើញថាដុំថ្មនោះមិនបានកម្រើកសោះ ខ្ញុំករុណាខំព្យាយាមគាស់លុះត្រាពេញកម្លាំង ហើយក៏អង្គុយសម្រាក ៗ នៅពេលចុងក្រោយ បានប្រមូលកម្លាំងទាំងអស់គាស់ម្ដងទៀត លើកនេះបានសម្រេច ឃើញដុំថ្មបានធ្លាក់ចុះទៅផ្អែកនៅគល់ឈើធំៗនៅខាងៗ ៗ ជាមួយគ្នានោះបានឮសម្លេងផ្ទូងៗ ដូចជាសម្លេងខ្ញុំរស្រែកនៅក្នុងល្អាងភ្នំ ខ្ញុំករុណាប្រញាប់លោតចុះមកឈរនៅខាងក្រោមសម្លឹងចាំមើលនៅមាត់ល្អាង ដែលមានទំហំអាចវារចូលទៅបាន ខ្ញុំករុណានឹកត្រេកអរជាទីបំផុត ដែលគ្រប់យ៉ាងបានគិតទុកមក ៗ

នៅពេលដែលខ្ញុំករុណាកំពុងតែត្រៀមខ្លួន នឹងលូនចូលទៅក្នុងល្អាងនោះហើយ ក៏ត្រូវឈប់ង៉ក់នៅពេលបានដឹងថាមានខ្យល់ក្ដៅឧណ្ហៗចេញមកពីល្អាង មកប៉ះផ្ទៃមុខថែមទាំងមានសម្លេងឈូៗ អ៊ូៗ នៅខាងក្នុងល្អាង ដូចជាកំពុងមានខ្យល់ព្យុះធំបក់នៅខាងក្នុងល្អាង ៗ ខ្ញុំករុណាភ័យខ្លាំង ក៏ថយចេញទៅអង្គុយខាងៗមាត់ល្អាង នៅចាំមើលថាតើនឹងមានអ្វីកើតឡើង មួយសន្ទុះក្រោយមក ខ្ញុំករុណាត្រូវលោតផ្លោះចេញពីមាត់ល្អាង ពីព្រោះឃើញច្បាស់ថា

មានទឹកធំប្រហែលនឹងមាត់ល្អាង បានបាញ់ចេញមកយ៉ាងខ្លាំង ។ ខ្ញុំកូណាសម្លឹងមើលខាងៗ ដោយបេះដូងលោតយ៉ាងខ្លាំង ដោយមានសង្ឃឹមថា មិនយូរប៉ុន្មានទឹកនឹងហូរចេញមកអស់ ហើយនឹងលូនចូលទៅយកមហាសម្បត្តិបាន ។ ប៉ុន្តែទឹកចេះតែហូរចេញមកមិនឈប់ឈរសោះ ហើយគាន់តែខ្លាំងជាងពីមុននោះទៀត នៅពេលខ្ញុំបានដឹងខ្លួន ក៏ប្រាកដឃើញថាទឹកបានជន់លិចខ្លួនខ្ញុំដល់ត្រឹមដើមទ្រូង ។ ខ្ញុំកូណាភ្ញាក់ភ្ញក បានមើលទៅជុំវិញខ្លួនក៏ប្រទះឃើញថាគ្រប់ផ្លូវគ្រប់ទីកន្លែង ពោរពេញទៅដោយទឹកទាំងអស់ ដូចជានៅកន្លែងនោះបានប្រែទៅជាទន្លេទៅហើយ ។ ដោយសេចក្ដីភ័យតក់ស្លុតខ្លាចខ្លាំងពេក ហើយដោយគិតថាយកខ្លួនឲ្យរួចផុតអំពីគ្រោះថ្នាក់នេះ ខ្ញុំកូណាបានចាប់ផ្តើមហែលទឹកទៅរកច្រាំងភ្លាមមួយរំពេច ប៉ុន្តែដែលគួរអស្ចារ្យយ៉ាងខ្លាំងនោះគឺ ខ្ញុំកូណាមើលទៅឃើញមាត់ច្រាំងនោះហើយៗ ចម្ងាយប្រហែលតែ ១០ ជំហាន ប៉ុន្តែហែលមិនដល់សោះ ខ្ញុំកូណាប្រឹងហែលលុះត្រាតែអស់សតិ ក៏លិចចុះទៅក្នុងទន្លេនោះទៅ ហើយគិតថាពេលវេលានេះគឺជាជីវិតចុងក្រោយរបស់ខ្ញុំកូណាមកដល់ហើយ ។

ប៉ុន្តែនៅទីបំផុត ខ្ញុំម្ចាស់បានដឹងខ្លួនឡើងវិញម្តងទៀតកណ្តាលយប់ជ្រៅ បានឃើញខ្លួនឯងកំពុងដេកផ្កាប់មុខនៅលើដីជិតមាត់ល្អាងនោះឯង ។ មើលទៅខាងមាត់ល្អាង ឃើញមានថ្មនៅបិទជិតដូចដើម ខ្ញុំកូណាក្រោកអង្គុយ មើលទៅជុំវិញខ្លួនមិនឃើញមានទឹកទន្លេជោរជន់

ដល់ជើងមេឃដូចគាលបានឃើញពីមុនទេ ឈ្មោគមើលទៅដី ឃើញបរិវេណជុំវិញខ្លួនក្លាយទៅជាដីទួលធំ ដើមឈើតូចៗនិងស្មៅដួលរលំលើដីជាជួរៗ នៅពេលសម្លឹងមើលហើយស្លាបទ្រូងខ្លួនឯង ប្រាកដឃើញថា ពោរពេញទៅដោយស្នាមដាច់រលាត់របកពេញដើមទ្រូង ពោះ និងខ្នងជើង ។ ក្រោយពេលសេចក្ដីតក់ស្លុតបាត់ទៅ សេចក្ដីភ័យខ្លាចចំពោះភូត ខ្មោច បិសាច ក៏ចូលមកជំនួស ដោយមិនបានគិតដល់អ្វីទាំងអស់ ខ្ញុំករុណាបានរត់ចេញតម្រង់មកផ្ទះមួយរំពេច នៅតាមផ្លូវដួលហើយក្រោក វារផងលូនផងនៅពេលមកដល់មុខផ្ទះ ក៏ដួលបាត់ស្មារតីនៅនឹងមាត់ទ្វារផ្ទះនោះឯង ដឹងខ្លួនម្ដងទៀតគឺនៅឯមន្ទីរពេទ្យតែម្ដង ។ នៅពេលដែលខ្ញុំករុណាដឹងខ្លួន ខ្ញុំករុណាក៏ចង់ជួបនឹងព្រះអង្គចង់និយាយរ៉ាយរ៉ាប់រឿងទាំងអស់នេះដល់ព្រះអង្គ ហើយនិងសូមអភ័យទោសផង ។

នៅពេលបានស្ដាប់រឿងរបស់នាយ "ប៉ាន់" ចប់ហើយ អាត្មានៅស្ងៀម គិតចុះគិតឡើងក្នុងរឿងរ៉ាវនៃអាថ៌កំបាំងនេះអស់ពេលយ៉ាងយូរ បានយល់ថា រឿងរបស់នាយ ប៉ាន់នេះពិតជាមានអាថ៌កំបាំងអស្ចារ្យ ប្រហែលនឹងរឿងនិទានសម្រាប់ក្មេងៗ ដែលវាមិនគួរទៅជាយ៉ាងនេះសោះ ។

នៅសម័យបច្ចុប្បន្ន ដែលស្រុកទេសបានរុងរឿងចម្រើនដោយវិទ្យាសាស្ត្រនេះទៅហើយ ប៉ុន្តែមានភស្តុតាងសាក្សីដែលឃើញប្រាកដនៅចំពោះមុខ ដែលបញ្ជាក់ឲ្យឃើញច្បាស់អស់សេចក្ដីសង្ស័យថា រឿងនេះបានកើត

ឡើងពិតប្រាកដមែនហើយ បញ្ជាក់ថានៅក្នុងលោកដ៏ធំមហិមានេះ គឺនៅមានរឿងរ៉ាវអាថ៌កំបាំងជាច្រើនមុខច្រើនយ៉ាងទៀត ដែលមនុស្សយើងមិនអាចនឹងដឹងបាននោះ ប្រសាទសម្ផស្សទាំង ៥ ហើយនិងគ្រឿងដៃដែលជាវត្ថុផ្សេងៗ ។

- សូមឲ្យញោមជួយលាក់រឿងអាថ៌កំបាំងទាំងនេះ កុំនិយាយប្រាប់នរណាជាដាច់ខាត, អាត្មាបាននិយាយប្រាប់នាយប៉ាន់ មុននឹងចម្រើនពរលោគាត់ត្រឡប់មកកុដិវិញ

- គ្រានេះ ខ្ញុំកូណានឹងបដិបត្តិតាមពាក្យផ្ដែផ្ដាំរបស់ព្រះអង្គមួយជីវិត, គេបានទទួលពាក្យធានាយ៉ាងហ្មត់ចត់មែនទែន ហើយអាត្មាក៏ត្រឡប់មកវត្តវិញ ...

## កុំ

**ពាក្យប្រាំបី**

***កុំចេះតែចង់លង់តាមតណ្ហា កុំចេះតែថាវាចាឥតន័យ***
***កុំចង់តែបានពីអ្នកដទៃ កុំលះវិន័យនិងច្បាប់មាត្រា ។***
***កុំបង់សច្ចៈលះដាក់ខន្តី កុំលះធម៌បី ទាន សីល ភាវនា***
***កុំលះពាក្យពេចន៍ដែលបានសន្យា កុំប្រញាប់ថាការមិនទាន់កើត ៕***

ដោយឧបាសក មុិញ សារ៉ាង

# ៨. ម្ចាស់ទ្រព្យពិតប្រាកដ ?

វៀហូតដល់សៀវភៅថ្ងៃនោះ អាត្មាវិះតែនឹងភ្លេចនូវការបដិបត្តិធម៌ដូចធម្មតាអស់លើង ចិត្តគិតទៅតែរឿងរ៉ាវរបស់នាយ " ប៉ាន់ " ខិតខំព្យាយាមយ៉ាងណាៗក៏មិនសម្រេចចិត្តមួយនឹកអាណិតដល់គេ ដែលទៅជួបគ្រោះថ្នាក់ដល់ទៅ ២ ដង ក្តៅក្រហាយរឿងប្រាក់ហើយ នៅមកជួបអន្តរាយខាតកម្លាំងស្ទើរតែអស់ជីវិតទៀត តែចិត្តមួយទៀតនឹកនិះដៀលគេថា បណ្តោយចិត្តឲ្យទៅជាខ្ញុំកញ្ជះរបស់សេចក្តីលោភ មិនស្តាប់ពាក្យរបស់អាត្មា លបទៅជីកយកមហាសម្បត្តិដោយប្រាថ្នានឹងបានជាអ្នកមានឆាប់ៗ នៅទីបំផុតក៏បានទទួលនូវសេចក្តីអន្តរាយ ហើយអស់សង្ឃឹមថានឹងបានសម្បត្តិនោះ ។ នៅពេលកំពុងបន្ទោសនាយប៉ាន់ ហើយក៏នឹកបន្ទោសដល់ខ្លួនឯងដែរ ដែលថាបើនិយាយអាត្មាគឺជាអ្នកដើមចម ក្នុងការដែលកើតឡើងទាំងអស់នេះក៏មិនខុសដែរ មកពីប្រគល់សេចក្តីទុកចិត្តដល់គេដោយមិនបានពិចារណាឲ្យបានល្អិតល្អន់ជាមុនសិន ដល់ទៅហ៊ានប្រាប់នូវកន្លែងលាក់នូវទ្រព្យនោះទៅទៀត ។ ទុកជាយ៉ាងណាក៏ដោយ អាត្មាមានបទរៀនអំពីរឿងនេះ ២ "ខ" ។

- "ខ" ដំបូងគឺ **កុំឲ្យទុកចិត្តមនុស្ស ដែលនៅមានកិលេសគ្រាស់ ។**
- "ខ" ទីពីរគឺ **មនុស្សអាចទៅជាមនុស្សខូចបានពីព្រោះ**

ទ្រព្យសម្បត្តិ ដូចសុភាសិតបុរាណថា “**ឃើញប្រាក់ភក្ត្រស្រស់បស់ពព្រាយ ឃើញមាសរីករាយមុខប៉ុនភ្នំ**” ។

សេចក្តីព្រួយពិបាកទាំងអស់ដែលកើតឡើងនេះ ធ្វើឲ្យអាត្មាកើតសេចក្តីរាងចាល ចង់តែគេចទៅឲ្យឆ្ងាយពីការរំខានទាំងរបស់មនុស្សទាំងអមនុស្ស ។ នៅពេលដែលអាត្មាចេញបួស ក៏ដើម្បីនឹងរត់ចេញឲ្យផុតអំពីការរកចំណីមកចិញ្ចឹមឲ្យតណ្ហា ដែលមិនចេះចប់របស់មនុស្ស ប៉ុន្តែនៅទីបំផុតគេចមិនផុតរត់មិនរួចពីព្រោះសេចក្តីករុណា ដែលអាត្មាបានឲ្យខ្លួនឯងទៅជាប់នឹងសម្បត្តិ របស់សុចេរិតសី ពីព្រោះសេចក្តីករុណា ទើបបានដឹកនាំនាយ “ ប៉ាន់ ” ចូលមកជាប់ជាមួយ នៅទីបំផុតសេចក្តីពិបាកទាំងអស់ដែលកើតឡើង ហើយនៅមិនទាន់បានដឹងថាតើនឹងទៅដល់ណាទៀត សេចក្តីតឹងទ្រូង តឹងចិត្ត ធ្វើឲ្យអាត្មាតាំងចិត្តថាថ្ងៃនេះនឹងប្រាប់ថាឈប់ទាក់ទងជាមួយសុចេរិតសី សូមឈប់ទាក់ទងគ្នាជាមួយទ្រព្យសម្បត្តិរបស់គាត់តទៅទៀតហើយ

នៅពេលយប់ថ្ងៃហ្នឹង នៅពេលអាត្មាចូលធ្វើសមាធិ សុចេរិតសី បានមកជួបតាមដែលបានណាត់ ។

- ខ្ញុំម្ចាស់មកទទួលចម្លើយនូវការគាត់សេចក្តីរបស់ព្រះអង្គហើយ ប្រហែលជាសម្រេចចិត្តទទួលនូវសម្បត្តិរបស់ខ្ញុំកូណាហើយមើលទៅ ? ឥសីជរាពោលឡើង ឃើញថាគាត់ មិនទាន់បានដឹងនូវហេតុការណ៍ដែលបានកើតឡើងនៅឡើយ

អាត្មាអង្គុយស្ងៀមយ៉ាងយូរ ពីព្រោះមិនដឹងថានឹង

ចាប់ផ្ដើមនិយាយអំពីអ្វីមុនល្អ តែនៅទីបំផុតបានគាត់ចិត្ត និយាយនូវរឿងទាំងអស់នោះ ឲ្យគាត់ស្ដាប់ទៅតាមការពិត នៅពេលដែលអាត្មាបាននិយាយចប់ សង្កេតឃើញទឹកមុខរបស់គាត់ស្លុតព្រួយបញ្ហាក់យ៉ាងច្បាស់ ប៉ុន្តែនៅមានអ្វីមួយដែលធ្វើឲ្យអាត្មាប្លែកក្នុងចិត្តខ្លះទៀត គឺគាត់មិនមានការភ្ញាក់ផ្អើល ក្នុងហេតុការណ៍ដែលបានកើតឡើងនោះសោះ ។

- នៅទីបំផុត ហេតុការណ៍ដែលខ្ញុំកូណាព្រួយទុកមុននោះកើតឡើងពិតមែន, ឥសីជរានិយាយឡើងដោយសម្លេងព្រួយ ក្រោយពីនៅស្ងៀមអស់យូរ

- លោកបានដឹងមុនហើយឬ ថាហេតុការណ៍ខ្លាំងនេះនឹងកើតឡើង? អាត្មាសួរឡើង

- មិនដឹងទេ គ្រាន់តែភ័យព្រួយ!, ឥសីជរាឱនមុខឆ្លើយតប, ពីព្រោះរឿងដូច្នេះធ្លាប់កើតមានមកច្រើនលើកហើយ លើកក្រោយបំផុតមុនពេលនេះ កើតឡើងនៅពេលប្រហែលជា ៥០ ឬ ៦០ ឆ្នាំមកហើយ ពេលនោះមានព្រះសង្ឃមួយអង្គ ជាប្រធានសង្ឃ លោកបដិបត្តិល្អ គង់នៅវត្តនេះ ខ្ញុំកូណាឃើញថាព្រះអង្គមាំទាំ ទើបចូលទៅពន្យល់សប្តិប្រាប់ នៅកន្លែងដែលលាក់ទុកនៃសម្បត្តិមហាសាលឲ្យបានដឹង ប៉ុន្តែសូមឲ្យព្រះអង្គប្រជុំសង្ឃទាំងអស់សិន មុននឹងទៅជីកយកសម្បត្តិមហាសាលទាំងអស់នោះមកទុកជាសម្បត្តិរបស់វត្ត ។ លោកក៏កើតចិត្តលោភយ៉ាងខ្លាំងក្លា ហើយក៏លបលួចទៅជីកយកសម្បត្តិមហាសាល

នោះតែមួយអន្លើងទៀត ត្រូវទៅបែហុលទឹកយ៉ាងវេទនាលុះដល់ជីវិត ។ តាំងតែពីពេលនោះមក ខ្ញុំម្ចាស់មិនដែលនិយាយប្រាប់នរណាទៀតសោះ លុះត្រាមកដល់បានជួបព្រះអង្គនៅពេលនេះ...

- អាត្មាស្តាយណាស់ ដែលបានប្រាប់នៅកន្លែងនៃសម្បត្តិមហាសាលដល់នាយ ប៉ាន់ ដោយមិនបានពិចារណាឲ្យបានដិតដល់ជាមុន ពីព្រោះសេចក្តីអាណិតដល់គេហើយទុកចិត្តគេជ្រុលពេក អាត្មាត្រូវសូមទោសលោកផង រឿងមួយទៀតនោះ គ្រាន់តែអាត្មាយកខ្លួនចូលទៅពាក់ព័ន្ធវិល់ក្នុងទ្រព្យសម្បត្តិប៉ុណ្ណឹង អាត្មាបានជួបនូវសេចក្តីព្រួយពិបាកលុះត្រាខូចខាតនូវការបដិបត្តិធម៌អស់រលីងទៅហើយ ព្រោះដូច្នេះ អាត្មាសូមឈប់មិនវិល់ទាក់ទងក្នុងរឿងរបស់លោកឬរបស់អ្នកណាតទៅទៀតឡើយ

លោកឥសីជរា ងើយមុខសម្លឹងមើលមកអាត្មាដោយក្រសែភ្នែកបង្ហាញឲ្យឃើញនូវសេចក្តីអង្វរករ ហើយពោលថា ៖

- បើដូច្នោះខ្ញុំម្ចាស់ក៏នៅតែជាអ្នកចាំយាមទ្រព្យសម្បត្តិតទៅដោយមិនមានកំណត់ ?

ពាក្យពោលដែលគួរឲ្យអាណិតរបស់គាត់ ធ្វើឲ្យចិត្តអាត្មាទន់ទៅទៀត ប៉ុន្តែអាត្មាបានកាត់ចិត្តយ៉ាងដាច់ខាតហើយថានឹងឈប់វិល់ជាមួយទ្រព្យនោះទៀតដែរ ហើយមិនព្រមឲ្យសេចក្តីអាណិតនោះ មកធ្វើឲ្យសេចក្តីតាំងចិត្តនេះរលាយបាត់ទៅដែរ ។ ប៉ុន្តែជាការល្បងចិត្តឲ្យឥសីចាស់ជរា

នេះ ទើបបានពោលដោយពាក្យលើកទឹកចិត្តថា៖

- អាត្មាជឿថានៅពេលមិនយូរទេ លោកនឹងទៅជាមានសេរីភាពហើយ នៅពេលនាយប៉ាន់បានជាសះស្បើយហើយ គេនឹងព្យាយាមទៅយកនូវមហាសម្បត្តិនោះទៀតហើយ

ឥសីចាស់ដករសើចញឹមៗ ហើយពោលថា៖

- ចំពោះនាយ “ប៉ាន់” នោះ ឈប់និយាយអំពីគេទៅពីព្រោះថា នៅពេលគេដេកលក់ម្តងទៀតហើយក្រោកឡើងវិញ គេភ្លេចរឿងរ៉ាវទាំងអស់នោះអស់រលីងហើយ ដូចជា មិនដែលបានជួបប្រទះហេតុការណ៍ទាំងអស់នោះ កាលពីមុនមកសោះឡើយក្នុងមួយជីវិត ៗ ក្នុងពេលបានជួបមហាសម្បត្តិនៅក្នុងល្អាងភ្នំនោះ ខ្ញុំម្ចាស់បានធ្វើនូវពិធីអធិដ្ឋានទុកដូច្នោះ នៅពេលនេះប្រហែលជាគេបានភ្លេចអស់ហើយ នេះគឺថាគេមានបុណ្យច្រើនមែនទែនដែលអាចយកជីវិតរុំតមកបាន ភាគច្រើនត្រូវស្លាប់នៅពេលដែលកំពុងតែហែលសមុទ្រគោកនោះឯង ៗ

- ប៉ុន្តែមុនដែលគេនឹងដេកលក់ គេអាចនិយាយប្រាប់ទៅអ្នកឯទៀតស្តាប់ ហើយអ្នកដែលបានស្តាប់នោះនឹងអាចទៅជីកយកមហាសម្បត្តិនោះទាល់តែបាន, អាត្មាបាននិយាយនូវការដែលយល់ឃើញ

លោកតាឥសីគ្រវីក្បាលតិចៗ ហើយនិយាយថា៖

- មិនមានផ្លូវទេ អ្នកណាក៏ដោយដែលមិនមែនជា

*មនុស្សដែលខ្ញុំព្រះករុណាប្រាថ្នា មិនអាចទៅរកផ្លូវដែលទុកទ្រព្យសម្បត្តិនេះឃើញជាដាច់ខាត សូម្បីនឹងដើរគាត់ក្នុងបរិវេណនោះក៏ដោយ ក៏នឹងមើលឃើញទៅជាទីផ្សេងទៅវិញ ខ្ញុំម្ចាស់បានអធិដ្ឋានទុកដូច្នេះឯង*

*អាត្មា និងសុចេរិតសី អង្គុយស្ងៀមគិតអស់ពេលយ៉ាងយូរ ពីព្រោះមិនដឹងថាតើត្រូវធ្វើយ៉ាងណាល្អ នៅទីបំផុតអាត្មាក៏គិតឃើញផ្លូវមួយ ហើយយល់ថាជាការត្រឹមត្រូវ ដែលអាចជួយឲ្យលោកតាឥសីចាស់នេះមានសេរីភាពបាន វិធីដែលអាត្មាទើបតែគិតឃើញមកនេះគឺ ព្រះបរមសាស្ដាទ្រង់បានប្រើមកអំពីកាលមុននោះ នៅពេលព្រះអង្គចេញសាងព្រះផ្នួសនោះ អាត្មានឹងសាកល្បងប្រើនូវវិធីនេះឲ្យសុចេរិតសីម្ដងមើល ៗ*

- *លោកអ្នកមានសីល ! អាត្មាពោលឡើងដោយយកពាក្យពេចន៍ផ្អែមល្ហែម, អាត្មាមានចិត្តអាណិតស្រណោះដល់លោកណាស់ ដែលត្រូវមកនៅចាំយាមទ្រព្យសម្បត្តិនេះអស់ពេលជាច្រើនរយឆ្នាំ ព្រមទាំងមានចិត្តចង់ទៅកើតហើយបំពេញនូវបុណ្យបារមីតទៅទៀត អាត្មានឹងខិតខំព្យាយាម ជួយលោកឲ្យមានសេរីភាពលុះត្រាតែបានក្នុងថ្ងៃនេះ*

*ឥសីជរាឱនចុះក្រាបអាត្មាដោយឫកវិការយភ្លាមមួយរំពេចព្រមទាំងនិយាយត្រែកអរគខិបគខុប ៖*

- *ឱ! ជាព្រះគុណយ៉ាងខ្ពស់បំផុត តើព្រះអង្គគិតឃើញយ៉ាងណា ? ព្រះអង្គនឹងព្រមទទួលនូវទ្រព្យសម្បត្តិនេះឬ ?*

- អាត្មាមិនទទួលដោយខ្លួនឯងឡើយ គ្រាន់តែខន្ធ ៥ ដែលនៅជាមួយនឹងខ្លួនអាត្មានេះ ក៏វាចូលណាស់ទៅហើយ ដែលអាត្មាខំប្រាប់តែអាត្មាជួបនូវបុគ្គលដែលសមគួរអាចនឹងទទួលនូវទ្រព្យសម្បត្តិរបស់លោកបានហើយ

- តើគេជាអ្នកណា? នៅឯណា? គសិដ្ឋកសួរដោយភ្ញាក់ចង់ដឹង

- បុគ្គលដែលពោលមកនេះ គឺមិនមែនជានរណាទេ បានដល់លោកម្ចាស់ដើមរបស់សម្បត្តិទាំងនោះហ្នឹងឯង...

លោកគសិដ្ឋជ្រួញចិញ្ចើមជានិយសង្ស័យ ហើយក៏និយាយឡើងថា៖

- មានន័យថានៅពេលនេះ ព្រះរាជាមហាក្សត្រិយ៍កាលពីអតីតៈ ដែលនាំមកនូវសម្បត្តិទាំងអស់នោះមកថ្វាយព្រះធាតុ បានមកកើតជាមនុស្សហើយឬ? ហើយព្រះអង្គបានជួបអស់លោកទាំងអស់នោះមែនទេ

- មិនមែនទេ! អាត្មាឆ្លើយ, ព្រះរាជាមហាក្សត្រិយ៍ទាំងអស់នោះ មិនមែនជាម្ចាស់ពិតប្រាកដទេ ម្ចាស់ដែលពិតប្រាកដជាងនោះ នៅមានទៀត

នៅពេលឃើញគសិដ្ឋកអង្គុយឆ្ងល់ ដោយសេចក្ដីមិនយល់ ទើបអាត្មានិយាយតទៅទៀតថា៖

- ជានិច្ចអាត្មាសូមសួរលោកសិន លោកចូរសម្លឹងមើលនូវចីពរដែលអាត្មាគ្រងនៅពេលនេះ ចីពរនេះជាសម្បត្តិរបស់អាត្មា អាត្មាជាម្ចាស់របស់វា ប៉ុន្តែអាត្មាមិន

ពុំមែនជាម្ចាស់ដើមរបស់វាទេ ទម្រាំតែធ្លាក់មកជាកម្មសិទ្ធ របស់អាត្មា វាជាសម្បត្តិរបស់ញោមអ្នកនាំមកប្រគេន មុននឹងទៅទៀត វាជាសម្បត្តិរបស់ហាងលក់គ្រឿងរបស់ព្រះសង្ឃ មុននឹងទៅទៀតវាជារបស់តម្បាញ មុននឹងទៅទៀតជារបស់អ្នកដាំកប្បាសមុននឹងកើតជាដើមកប្បាស តើវាមកអំពីណា?

ឥសីជរានៅស្ងៀម គិតមួយសន្ទុះហើយក៏ឆ្លើយឡើងថា៖

- ឃើញថាមកអំពីផែនដី!

- ត្រូវហើយលោកឥសី! ឥឡូវនេះក្នុងផ្លូវផ្ទុយគ្នា ចីពររបស់អាត្មាមួយនេះបើសន្មតិថា ប្រសិនជាអាត្មាស្លាប់ទៅតើវាទៅណា?

- បើគេមិនដុតទៅជាមួយព្រះអង្គទេ នោះវានឹងអាចធ្លាក់ទៅជាសម្បត្តិរបស់ភិក្ខុដទៃ

- ចុះបើភិក្ខុដទៃស្លាប់ទៅទៀត តើវាទៅឯណា? អាត្មាសួរទៀត

- បើវាមិនទាន់រហែកទេនោះ វាធ្លាក់ទៅជាសម្បត្តិរបស់ភិក្ខុផ្សេងដទៃទៀតទៅ

- បើសន្មតិថា នៅក្នុងលោកនេះមនុស្សគ្រប់គ្នាបានស្លាប់ព្រមគ្នាទាំងអស់មិនមានសេសសល់សោះ, អាត្មានិយាយពន្យល់ឥសីជរាបន្តទៀត, អ្នកចាំទទួលទ្រព្យសម្បត្តិគឺចីពរមួយនេះ តើវានឹងទៅទីណា?

- វាក៏អាចនឹងគរនៅលើផែនដីនេះមួយរយៈ, លោកនសីជរាឆ្លើយ, ហើយមិនយូរប៉ុន្មានត្រូវសើម ស្លួយពុកផុយ ក្លាយទៅជាដីនោះទៅ

- លោកដែលទ្រង់សីល ! ពាក្យឆ្លើយរបស់លោកត្រូវពិតប្រាកដមែនហើយ លោកនឹងឃើញបានថា ចីពររបស់អាត្មាមួយនេះ ដើមកំណើតមុនដំបូងបង្អស់ក៏ចេញមកអំពីដីដែរ ហើយនៅពេលខាងក្រោយក៏ក្លាយទៅជាដីវិញដែរ ដូច្នេះ ម្ចាស់ដើមពិតប្រាកដរបស់ចីពរមួយនេះក៏គឺផែនដី អាត្មាបានមកពីផែនដីមកប្រើមួយរយៈប៉ុណ្ណោះ នៅវារៈចុងក្រោយក៏ត្រូវសងឲ្យម្ចាស់ដើមវិញ សូម្បីអាត្មាផ្ទាល់មិនព្រមសងឲ្យគេវិញក៏ដោយ នៅទីបំផុតចីពរនេះក៏នឹងត្រឡប់ទៅរកម្ចាស់ដើមរបស់គេ ពាក្យដែលអាត្មានិយាយមកនេះ តើលោកយល់យ៉ាងណាដែរ ?

លោកនសីអង្គុយឱនមុខគិតមួយរយៈ ហើយងក់ក្បាលដោយការយល់ស្របដោយពោលថា ៖

- ខ្ញុំម្ចាស់យល់ស្របជាមួយព្រះអង្គ ពីព្រោះជាការពិតបើចីពរគ្រាន់តែជាវត្ថុទ្រព្យមួយចំណិតនៃផែនដី ចុះទ្រព្យសម្បត្តិផ្សេងៗ ដែលមានកំណើតមកអំពីផែនដីដូចជាអាហារដែលអាស្រ័យ មាសប្រាក់ ពេជ្រត្បូង ដែលជាសម្បត្តិនោះតើជារបស់អ្នកណាដែរ ? អាត្មាសួរតទៅនសីជរា

- នេះគឺជាសម្បត្តិរបស់ផែនដីនោះឯង, នសីចាស់

ឆ្លើយយ៉ាងច្បាស់

- សម្បត្តិផ្សេងៗដូចបានពោលមកនេះ គឺនៅឆ្ងាយអំពីខ្លួនយើងជាសម្បត្តិខាងក្រៅ យើងឃើញបានច្បាស់ថាមកពីដី ហើយនឹងត្រឡប់ទៅជាដីវិញ បើនិយាយឲ្យច្បាស់ទៅទៀត សូម្បីតែសន្ធារាងកាយរបស់យើងដែលយើងស្រឡាញ់ហួងហែង ប្រកាន់ថាជារបស់យើងនេះក៏មិនមែនជារបស់យើងដែរ គឺជារបស់ផែនដី យើងខ្ចីគេប្រើមួយរយៈប៉ុណ្ណោះ នៅទីបំផុតក៏ត្រូវសងឲ្យម្ចាស់ដើមគេវិញ សូម្បីក្នុងខណៈដែលយើងកំពុងប្រើនេះ គេក៏មកទារយកគ្រប់ពេលវេលា គាន់តែជិតដល់និងដល់កំណត់សងគេវិញ គេក៏គាន់តែទាមទារយកយ៉ាងខ្លាំងក្លា ៗ កាលដែលធ្មេញរបស់យើងបាក់ទៅម្តងមួយៗនោះ បានន័យថាម្ចាស់ដើមរបស់គេទារយកទៅម្តងបន្តិចៗមុនហើយ នៅពេលដែលខ្នងរបស់យើងកោងឬទន់ទៅរាល់ពេលនោះ មានន័យថាម្ចាស់ដើមរបស់គេទាញឲ្យចុះទៅ ៗ នៅពេលការពិតកើតឡើងដូច្នេះ របស់យើងនោះមិនមានទេ ការដែលយើងនិយាយថា របស់នោះជារបស់ខ្ញុំ ជាពាក្យពោលដោយការយល់ខុស ដែលវង្វេងប្រកាន់នូវរបស់ផ្សេងៗថាជារបស់ខ្លួន ហើយក៏ចូលទៅប្រកាន់ធ្វើជាម្ចាស់សម្បត្តិរបស់អ្នកដទៃដោយមិនស្របច្បាប់ ៗ មនុស្សក្នុងផែនដីនេះ មិនស្គាល់នូវការពិតត្រង់កន្លែងនេះឯង ទើបវង្វេងប្រកាន់នូវរបស់នេះ នូវរបស់នោះ ជាប់នូវរបស់ឯណោះឲ្យខ្វល់ខ្វាយទៅទាំងអស់ នៅពេលរបស់ទាំងនោះវិល

ត្រឡប់ទៅម្ចាស់ដើមរបស់វាវិញ ក៏តាំងកើតសេចក្តីខុសបំណង ខូចចិត្ត យំសោកបោកខ្លួនទៅជាទុក្ខ បើមិនដូច្នោះទេ ក៏វង្វេងនៅចាំសម្បត្តិរបស់អ្នកដទៃ ដូចជាស្រមោចក្រហម ឬអន្ទ្រង់នៅចាំផ្លែស្វាយ លុះគ្រាមិនមានសេរីភាពផ្សេងៗនឹងទៅ ក៏ទៅមិនបាន ពីព្រោះការហួងហែង

- លោកមានដឹកនេះ គឺដូចជាថាឲ្យខ្ញុំកួណរពិតៗតែម្តង, ឥសីចាស់នេះពោលឡើង ញញឹមតិចៗ,

- ក៏ប៉ុន្តែលោកបានទទួលហើយឬ ថានេះគឺជាការពិតមែននោះ ? នៅពេលដែលសុចេរិតសីមិនឆ្លើយ ទើបអាត្មាទេសនាតទៅទៀត, ទ្រព្យសម្បត្តិដែលលោកទុកនៅក្នុងល្អាងនោះ លោកក៏បានដឹងហើយថា ជាសម្បត្តិរបស់ផែនដីមិនមែនរបស់លោកទេ តែពីព្រោះការវង្វេងខុស ទើបលោកជាប់ប្រកាន់ថាជារបស់លោក ហើយខាតពេលវេលានៅយាមរាប់ពាន់ឆ្នាំមកហើយ ថានឹងទៅកើតរកបំពេញបារមីទៅទៀតក៏មិនបាន ពីព្រោះសេចក្តីវង្វេងខុសនោះឯងចំណុចសំខាន់ដែលធ្វើឲ្យខ្លួនលោកចេញជុំតរូប ឲ្យមានសេរីភាពបាននោះ អាត្មាយល់ឃើញថាដូចជាមិនពិបាកទេមិនបាច់អស់ដើមទុន បញ្ចេញកម្លាំងអ្វីទាំងអស់ គ្រាន់តែលោកដកយកចេញនូវឧបាទាន សេចក្តីប្រកាន់ជាប់ថាទ្រព្យសម្បត្តិទាំងអស់នោះចេញទៅតែប៉ុណ្ណោះ លោកនឹងបានទទួលនូវសេចក្តីសុខកាយ សប្បាយចិត្តហើយ តើលោកអាចដកចិត្តបានដែរឬទេ ?

ឥសីចាស់នោះនៅស្ងៀមដដែល មើលទៅទឹកមុខ

*បង្ហាញឲ្យ ឃើញថាគាត់កំពុងតែគិតយ៉ាងហ្មត់ចត់ ។ អាត្មាយកឱកាសនោះនិយាយតទៅទៀត លោកអាចនឹកស្មានថា ៖*

- *លោកខំនៅថែរក្សានូវទ្រព្យសម្បត្តិនេះ មកយូរយារាប់រយឆ្នាំមកហើយ តើមកឲ្យលះបង់ចោលទៅយ៉ាងងាយៗបានដូចម្ដេចទៅកើត តែរូបលោកនេះប្រៀបដូចជាអ្នកទោសដែលត្រូវជាប់គុកជាច្រើនឆ្នាំមកហើយ ក្នុងរយៈពេលដែលជាប់គុកនោះ បានធ្វើសួនដាំផ្កានៅក្នុងគុកនោះ នៅពេលដែលផ្កាកំពុងតែរីកល្អស្អាត ស្រាប់តែដល់ពេលវេលាដែលត្រូវចាកចេញពីគុក ស្រាប់តែលោកនឹកស្មានថានូវផ្កានោះ ប៉ុន្តែតើនឹងមានមនុស្សប៉ុន្មាននាក់ ដែលព្រមនៅក្នុងគុកតទៅទៀតដើម្បីមើល ផ្កាដែលរីកស្រស់នោះ អាត្មាមានជំនឿជឿជាក់ថា អ្នកទោសទាំងអស់នោះ សុខចិត្តព្រមចោលនូវផ្កាទាំងអស់នោះ ដើម្បីប្ដូរយកសេរីភាពដែលរង់ចាំមកអស់ពេលយ៉ាងយូរ ចុះចំណែករូបលោកវិញយកសេរីភាពឬក៏នឹងនៅចាំថែទាំទ្រព្យសម្បត្តិរបស់ផែនដីតទៅទៀតហ្នឹង ?*

- *ជាការពិបាកណាស់ ដែលនឹងត្រូវលះបង់ នូវទ្រព្យសម្បត្តិមហាសាលនោះ ចោលចេញដោយងាយៗ, ឥសីចាស់នោះពោលរអ៊ូឡើងដោយសម្លេងខ្សាវៗ បង្ហាញឲ្យឃើញថានៅអាល័យទ្រព្យសម្បត្តិយ៉ាងខ្លាំង*

- *លោកអាចគិតថា ទ្រព្យសម្បត្តិរបស់លោកមានច្រើនណាស់ ប៉ុន្តែបើយកទៅប្រៀបធៀបជាមួយទ្រព្យ*

សម្បត្តិរបស់ព្រះអង្គម្ចាស់ **សិទ្ធត្ថ** នោះវិញ ទ្រព្យសម្បត្តិរបស់លោកនេះ ប្រៀបប្រហែលដីខ្សាច់មួយក្តាប់ប៉ុណ្ណោះ ព្រះអង្គម្ចាស់ សិទ្ធត្ថ មានប្រាសាទ ៣ ខ្នង, មានអ្នកបម្រើរាប់ពាន់, មានមាសពេជ្រ ត្បូងដាក់ទុករាប់បន្ទប់, មានព្រះជាយា និងព្រះឱរសដែលកំពុងពេញស្រឡាញ់ជាងអ្វីៗទាំងអស់, រាជបល្ល័ង្ករបស់ព្រះចៅចក្រពត្រាធិរាជ កំពុងតែរង់ចាំព្រះអង្គ សូម្បីប៉ុនហ្នឹងក៏ដោយ ក៏ព្រះអង្គទ្រង់លះបង់របស់ទាំងអស់នោះចោល លោកយាងចេញទៅព្រៃ ដេកលើផែនដី តើយដីខ្សាច់ ទាំងអស់នេះក៏ពីព្រោះព្រះអង្គទ្រង់ពិចារណាឃើញថា រាជសម្បត្តិដែលជាមហាសាលនោះ មិនអាចនិងជួយព្រះអង្គ ឲ្យរួចអំពីសមុទ្រទុក្ខបានឡើយ ប៉ុន្តែ ការដែលនៅក្នុងព្រៃអាចនាំព្រះអង្គចេញទៅដល់អមតធម៌ដ៏ប្រសើរវិសេស ទើបព្រះអង្គព្រមលះបង់នូវសម្បត្តិមហាសាលនោះចេញ ដើម្បីប្តូរយកអមតធម៌ នៅទីបំផុតព្រះអង្គក៏បានសម្រេច ហើយមិនយាងត្រឡប់ទៅរករាជបល្ល័ង្កនោះទៀតទេ ប្រៀបដូចបុរសដែលបាននូវកែវ ៧ ប្រការទុកនៅក្នុងដៃ ហើយក៏ចោលនូវដីដែលក្តាប់នៅដៃម្ខាងទៀត គ្រពើងចោលដោយមិនមានស្តាយអាល័យអាឡោះអ្វីសោះឡើយ

នៅពេលបានពោលមកដល់ត្រង់នេះ គសីចាស់ក៏ឱនក្រាបថ្វាយបង្គំអាត្មាម្តង ហើយពោលចេញមកយ៉ាងច្បាស់ថា ៖

- ខ្ញុំម្ចាស់សូមលះបង់នូវទ្រព្យសម្បត្តិទាំងអស់ ដែល

នៅក្នុងល្អាងនេះ ប្រគល់ឲ្យទៅម្ចាស់ដើមរបស់គេវិញ គឺជាតែនគឺ សូមមិនរើរើសអ្វីតទៅទៀតឡើយ...

- អាត្មាសូមអនុមោទនា នូវការគាត់ចិត្តគាត់ថ្លើម សម្រេចចិត្តយ៉ាងដាច់ខាតរបស់លោក ។ គ្រាន់តែគាត់ចិត្ត នូវក្នុងពេលនេះ ក៏ធ្វើឲ្យការអធិដ្ឋានបារមីរបស់លោកថែម ឡើងជាងមុនរាប់រយរាប់ពាន់ដងថែមទៀត ។ សូមឲ្យ លោករក្សានូវបារមីមួយនេះទុក ហើយនិងសម្រេចដល់ អមតធម៌ដោយឆាប់ឆងចុះ ។

ឥសីសុចេរិ អរគុណដល់អាត្មាដែលបានជួយឲ្យពន្លឺ ភ្លឺស្វាងក្នុងផ្លូវធម៌ លុះត្រាអាចយកឈ្នះឧបាទានរបស់ខ្លួន បាន ហើយក៏បានពោលនូវពាក្យគ្រាបលា ៖

- ខ្ញុំម្ចាស់សូមថ្វាយបង្គំលា ព្រះអង្គទៅមុនហើយ ក្នុងការធ្វើដំណើរក្នុងវិដ្តសង្សារយ៉ាងវែងឆ្ងាយនេះ យើងនឹងអាចបានជួបគ្នាទៀត ។

ចាំហើយលោកឥសីចាស់ ក៏បាត់ទៅក្នុងមួយពព្រេច ភ្នែក ។ អាត្មាបានចេញពីសមាធិ ហើយបានអង្គុយ សម្រាកដោយសេចក្តីសប្បាយចិត្តជាលើកដំបូង ក្រោយពី ការខ្វល់ខ្វាយចិត្ត អស់រយៈពេល ២ ថ្ងៃ ពេញៗមក ។

# ៩. ទុកចិត្តមនុស្ស ប្រទូស្តចិត្តយើង

**នៅ**ទីបំផុតបុណ្យសង្ក្រាន្ត ( ចូលឆ្នាំថ្មី ) យ៉ាងគគ្រឹកគគ្រេងរបស់នគរភិង ក៏ហួសអស់ទៅតាមកាលវេលា ។ អ្នកដើរលេងដែលមកពីទីផ្សេងៗ ក៏បាននាំគ្នាវិលត្រឡប់ទៅផ្ទះសម្បែង ស្រុកកំណើតរបស់ខ្លួនអស់ទៅ ហើយស្រុកឆៀងម៉ៃ បានត្រឡប់ទៅរកជីវិតធម្មតារបស់ខ្លួនដូចពីដើម ។ សង្ក្រាន្តនៃជីវិតដែលជាអាថ៌កំបាំងអាត្មា បានកន្លងផុតទៅដូចគ្នា របស់នៅសល់នោះគឺស្នាមដំបៅរបស់នាយ ប៉ាន់ ដែលនិតជាប់នៅលើរាងកាយរបស់គាត់ ព្រមជាមួយនូវអាថ៌កំបាំងដែលពុំមាននរណាដឹងក្រៅពីអាត្មានិងសុចេរិតសីប៉ុណ្ណោះ សូម្បីតែនាយ "ប៉ាន់" ខ្លួនឯង ក៏ភ្លេចនូវហេតុការណ៍នោះអស់រលីង ដោយកម្លាំងអធិដ្ឋានរបស់ឥសីចាស់នោះ ។ ការឆ្លើយតបនូវសំណួររបស់អ្នកដែលមកសួរសុខទុក្ខគឺបានត្រឹមតែថា "នៅយប់មួយ ខ្ញុំដេកលក់ជាធម្មតា នៅពេលភ្ញាក់ដឹងខ្លួនឡើង ក៏ស្រាប់តែឃើញថារាងកាយរបស់ខ្ញុំ ពេញទៅដោយស្នាមដាច់នៅពេញខ្លួន ប៉ុន្តែមិនបានដឹងសោះថា វាកើតឡើងដោយសារអ្វី" ។ ហើយម៉្យាងទៀតអ្វីដែលនៅសល់នោះ គឺសេចក្តីក្រខ្សត់របស់គ្រួសារនាយប៉ាន់ ។ រឿងមួយនេះមិនព្រមចាកចេញអំពីចិត្តរបស់អាត្មាសោះ វានៅចាំពញ្ញាក់ដាស់តឿននូវសតិរបស់អាត្មា ឲ្យនឹកអាណិតដល់គេជានិច្ច ហើយបានបន្តាប់

ឲ្យអាត្មាធ្វើនូវកិច្ចការដែលមិនចង់ធ្វើ ហើយមិនដែលធ្លាប់ធ្វើមកពីកាលមុនផង ពីព្រោះជានូវតែម៉្យាងដែលអាចជួយគេបាន ហើយជាវិធីតែមួយ ដែលនឹងសងនូវសេចក្ដីទុក្ខធំដែលគេបានទទួល ព្រោះតែរូបអាត្មាជាអ្នកនាំហេតុ ។ ជួនកាលមនុស្សយើង ចាំបាច់ត្រូវតែធ្វើកិច្ចការដែលផ្ទុយនឹងចិត្តខ្លួនឯង ដើម្បីជាការតបស្នងសងគុណដល់អ្នកដែលមានឧបការគុណ ។

នៅរសៀលថ្ងៃមួយ ក្រោយពេលបានលាប្រធានសង្ឃ និងមិត្តធម៌ក្នុងវិត្តរួចហើយ អាត្មាបានស្ពាយបាត្រនិងឆត្រ(ក្លត) ចុះពីអន្លង់ព្រះធាតុហើយឆៀងចូលទៅផ្ទះនាយ "ប៉ាន់" ។ គេនិងភរិយាមានការភ្ញាក់ផ្អើលប្លែកក្នុងចិត្តយ៉ាងខ្លាំងដែលឃើញអាត្មាមានគ្រឿងសម្រាប់ធ្វើដំណើរ ។

- តើលោកនឹងនិមន្តទៅណានេះទាន? នាយប៉ាន់សួរដោយឫកពារឆ្ងល់ចម្លែកក្នុងចិត្ត

- អាត្មានឹងចេញអំពីទីនេះ ប៉ុន្តែមិនទាន់ដឹងថានឹងទៅឯណាទេ!

- ដូចម្ដេចបានជាប្រញាប់និមន្តទៅម្ល៉េះព្រះអង្គ សូមនិមន្តព្រះអង្គគង់នៅបន្តទៅទៀតសិនបានឬទេ ? នាយប៉ាន់សួរអាត្មាដោយសេចក្ដីសោកស្ដាយ

- អាត្មាបានសម្រាកនៅទីនេះយូរល្មមហើយ គ្រប់តាមកំណត់ពេលដែលតាំងចិត្តទុកមក ទើបសុំលាញោមទៅតាមធម្មតាអាត្មាមិនចូលចិត្តនៅកន្លែងណាមួយឲ្យយូរហួស

ហេតុពេកទេ ពីព្រោះគារនៅកន្លែងណាយូរៗទៅ គឺធ្វើឲ្យកើតសេចក្ដីជាប់ជំពាក់ទីកន្លែង ជាប់ជំពាក់មនុស្ស ធ្វើឲ្យកើតបលិពោធកង្វល់ ក្លាយទៅជាឧបសគ្គដល់គារបំពេញព្យាយាមខាងផ្លូវចិត្ត ។

នៅពេលដឹងថា អាត្មានឹងមិនព្រមនៅតទៅទៀតហើយ នាយប៉ាន់ចាប់ផ្ដើមសួរអំពីទីដៅ ផ្លូវដែលអាត្មាចេញដំណើរទៅ ថែមទាំងសូមប្រគេនន្លូវតម្លៃយានជំនិះឲ្យអាត្មាទៀតផងមិនថាអាត្មាទៅទីណាក៏ដោយ ។

- អាត្មាសូមអនុមោទនា នូវបុណ្យកុសលចេតនារបស់ញោមនេះ ប៉ុន្តែសុំបដិសេធថា អាត្មាមិនបានគិតមុនថានឹងទៅទីណាទេ ចេះតែដើរទៅជានិច្ច យប់នៅទីណាក៏លាតក្រុតនៅទីនោះ ដូច្នេះមិនអាចជំរាបញោមបានទេថា តើអាត្មាទៅទីណា ! ហើយចំណែកឯតម្លៃជិះនេះ អាត្មាសូមអនុមោទនានិងអរគុណ ប៉ុន្តែអាត្មាតាំងចិត្តថានឹងដើរទៅរហូត ពីព្រោះមិនមានធុរៈអ្វីដែលគួរឲ្យប្រញាប់នឹងត្រូវជិះយានជំនិះ...

- បើដូច្នោះ ខ្ញុំកូណាសូមប្រគេនថ្លៃឡានដែលជិះពីជើងភ្នំនេះទៅដល់ខេត្តលឿង, នាយ "ប៉ាន់" សូមសំណូមពរធ្វើបុណ្យនៅពេលចុងក្រោយនេះ

- អាត្មាតាំងចិត្តទុកថានឹងដើរតិចៗ ចុះទៅតាមផ្លូវគាត់ដែលធ្លាប់មកនៅពេលដែលអាត្មាឡើងភ្នំនេះ ។ គារប្រើជើងរបស់ខ្លួនឯងឲ្យបានជាប្រយោជន៍ មុនពេលដែលវានឹងអន់ថយពលភាព ពីព្រោះគារចាស់ជរានេះហើយ ជាគារ

ដើរមើលធម្មជាតិដែលដុះទៅតាមផ្លូវនោះផង

នៅពេលឃើញថា នឹងយកឈ្នះអាត្មាមិនបានហើយ ពីរនាក់ប្ដីប្រពន្ធក៏អង្គុយមើលមុខគ្នា អាត្មាឃើញដូច្នោះក៏ឆ្លៀតឱកាសហូតយកក្រដាសមួយសន្លឹក ចេញពីថង់យាម ហុចទៅឲ្យនាយប៉ាន់ ។ គាត់ក៏បានទទួលយកទៅលាតមើល ហើយញញឹមដោយមានសេចក្ដីសុខ ហើយក៏ឱនក្រាបចុះនៅក្បែរជើងរបស់អាត្មា អាត្មាក៏មានចិត្តត្រេកអរ ដោយបានជួយគេឲ្យផុតអំពីសេចក្ដីក្រខ្សត់ ប៉ុន្តែមិនសប្បាយចិត្តសោះ ដែលបានធ្វើនូវរបស់ដែលខុសពី (ចិត្ត) មោទនធម៌របស់ខ្លួនឯង ។

អាត្មាចុះមកដល់វិត្តនៅជើងភ្នំក្នុងថ្ងៃនោះឯង កុដិតូចអាងទុកទឹក ហើយរបស់គ្រប់យ៉ាងនៅក្នុងសភាពដដែល ។ អ្នកដែលមកទទួលស្វាគមន៍អាត្មាមុនគេនោះគឺឆ្កែ ដែលអាត្មាធ្លាប់តែឲ្យបាយនៅសល់បាតបាត្រនោះឯង វិរត់មក ! បញ្ចេញសម្លេងងីសៗគ្រវីកន្ទុយដោយសប្បាយចិត្ត ហើយងើយមើលមុខអាត្មា បីដូចជាមកគួរសមទទួលអាត្មា ។ ឆាកុអាកាសល្អត្រជាក់ ពីព្រោះពេលយប់មិញមានភ្លៀងធ្លាក់មកដីនៅសើមហើយមានក្លិនចំហាយទឹក ដែលនៅពេលក្រោយភ្លៀងធ្លាក់នៅពេលគិម្ហរដូវ ធ្វើឲ្យមនុស្សនិងរុក្ខជាតិដែលស្ងួតហែងរហូតក្នុងគិម្ហរដូវនៅស្រស់សូម្បីនៅក្នុងរដូវនេះ ។ ប៉ុន្តែការដែលភ្លៀងមក បង្ហាញឲ្យឃើញថាគិម្ហរដូវជិតផុតហើយ វិស្សរដូវនឹងចូលមកជំនួសវិញ នេះជាសញ្ញាឲ្យអាត្មាដឹងថា ពេលវេលានូវការដើរទៅតាម

ផ្លូវក្នុងលោកដ៏ធំនេះ ដែលត្រូវដើរទៅតាមផ្លូវដ៏ធំបានមក ដល់ហើយ នៅមានសត្វជាច្រើនទៀតដែលនៅវង្វឹតទៅ ដោយអវិជ្ជា និងមោហៈ ហើយត្រូវការនូវពន្លឺ គឺព្រះធម៌ របស់ព្រះបរមសាស្តា សូម្បីតែខ្ញុំ គឺចិត្តអាត្មាខ្លួនឯងក៏នៅ វង្វឹតវង្វល់ ពោរពេញទៅដោយពពកនៃកិលេសាសវៈ ហើយត្រូវការនូវពន្លឺដូចគ្នាដែរ ។ ការដើរទៅដោយការ ប្រាសចាកសេចក្ដីអាល័យ ឲ្យជីវិតរស់នៅទៅតាមព្រៃភ្នំ លំនៅស្ងាត់ស្ងប់ គឺជួយឲ្យបន្ថយនូវមេឃ ពពកខ្មៅ គឺ កិលេស លះបានផលច្រើនណាស់ ។ អាត្មាតាំងចិត្តថានឹង សម្រាកនៅក្នុងវត្តជើងភ្នំប្រហែល ២ ឬ ៣ ថ្ងៃ រួចហើយនឹង ចេញដំណើរតទៅទៀត ។

ពេលព្រឹកឡើង ធ្វើកិច្ចវត្តរួចហើយ អាត្មាក៏គ្រងចីពរ ស្ពាយបាត្រចូលទៅបិណ្ឌបាតនៅតាមចន្លោះផ្ទះដែល នៅជិតវត្ត ។ មានញោមតិញោមដែលធ្លាប់ដាក់បាត្រជានិច្ច ជួបហើយគាត់សប្បាយចិត្ត ត្រេកអរ ដោយឃើញអាត្មា មកប្រោសទៀត ។ គ្រប់ៗគ្នាសាកសួរដំណើរអំពីសុខទុក្ខ ទៅតាមទំនៀមទំលាប់ ហើយសូមនិមន្តឲ្យនៅគង់ទីនេះឲ្យ បានយូរ ។

ញោម ខាំសែន ដែលបានរាប់អានអាត្មាមកជាយូរ ហើយនោះ ក៏ប្រញាប់ប្រញាល់ចុះពីលើផ្ទះមកអង្គុយលើក ដៃសំពះអាត្មា ហើយពោលថា៖

- ឱ ! ព្រះគុណម្ចាស់ចេះនិមន្តមកដល់ល្មម ខ្ញុំកូណា កំពុងតែចង់ជួបព្រះអង្គផងទាន

- មានកិច្ចការអ្វីឬញោម? អាត្មាសួរ
- មានទាន! បន្តិចទៀតព្រះអង្គនឹងបានជ្រាបហើយ សូមនិមន្តឡើងទៅលើផ្ទះសិន

អាត្មាដូចជាមិនសូវសប្បាយចិត្តសោះ ដែលមានគេមកនិមន្តនៅពេលកំពុងដើរបិណ្ឌបាត ពីព្រោះដើរទៅប្រោសសត្វមិនទាន់ចប់ ។ ផ្ទះផ្សេងៗដែលធ្លាប់ដាក់បាតអំពីមុនមក នៅពេលឃើញអាត្មាអំពីចម្ងាយប្រហែលកំពុងរៀបចំម្ហូបអាហារទុកដាក់បាតក៏អាចថាបាន ។ តែនៅពេលសង្កេតឃើញទឹកមុខដែលស្លូត ពោរពេញទៅដោយសេចក្ដីទុក្ខព្រួយរបស់ញោម ខាំសែន អាត្មាក៏នឹកអាណិតគាត់ ហើយយល់ថាប្រហែលជាគាត់មានរឿងទុក្ខព្រួយអ្វីមួយ ទើបព្រមទទួលនូវការនិមន្ត ។

នៅពេល ឡើងទៅអង្គុយលើផ្ទះបានស្រួលបួលហើយ ញោម ខាំសែន បានហៅប្រពន្ធរបស់គាត់ព្រមទាំងកូនៗបីនាក់ទៀតមកថ្វាយបង្គំអាត្មា ។ សង្កេតមើលទៅអ្នកទាំងអស់គ្នាមានទឹកមុខព្រួយទាំងអស់ ធ្វើឲ្យអាត្មាយល់ថា គ្រួសារញោម ខាំសែន ប្រហែលជាកំពុងធ្លាក់ចុះទៅក្នុងសេចក្ដីទុក្ខព្រួយពិតប្រាកដមែនហើយ ។

- ប្រញាប់ទៅនាំ “ដួងតា” មកថ្វាយបង្គំលោកទៅ! ញោម ខាំសែនប្រាប់ទៅភរិយារបស់គាត់

ភរិយារបស់គាត់ ដើរចូលទៅក្នុងបន្ទប់ដេកមួយសន្ទុះ ហើយក៏នាំ “ដួងតា” កូនស្រីបងគេដើរចេញមក ។ អាត្មាចាំគេបានច្បាស់ ដោយកាលពីមុនដែលឡើងទៅ

សម្រាកនៅលើភ្នំ គឺ "ដួងតា" ជាអ្នកដាក់បាតឲ្យរស់អាត្មាជារៀងរាល់ថ្ងៃ ។ នាង "ដួងតា" ម្នាក់នេះ នៅពេលដែលអាត្មាខ្វះសតិសម្បជញ្ញៈ អាត្មាធ្លាប់បានភ្លេចខ្លួនសរសើរនៅក្នុងចិត្តថា គេជាស្រីក្រមុំដែលអាចចាត់ថា ជាស្រីស្រស់ស្អាតមួយរូប រង្វង់មុខពងមាន់ ខ្ពស់ល្មម សាច់ស កែវភ្នែកមានមន្តស្នេហ៍ ប៉ុន្តែនៅពេលមានសតិសម្បជញ្ញៈមកវិញខំព្យាយាមមើលជារូបអសុភ ជាធាតុប្រកបដោយខន្ធ ៥ រួមគ្នាទៅជាតួទុក្ខ មានទ្វារទាំង ៩ ដែលហូរចេញមកជារបស់បដិកូល ហើយថែមទាំងឪពុកម្ដាយរបស់គេបាននិយាយប្រាប់អាត្មាជានិច្ចថា កូនស្រីនេះចូលចិត្តតែងខ្លួនទាន់សម័យ ការងារមិនសូវចូលចិត្តធ្វើទេ ហើយចូលចិត្តសេពគប់ជាមួយប្រុសៗ ហើយចាយធំ ។ អាត្មាយល់ឃើញថានេះជារឿងរបស់អ្នកស្រុកតែប៉ុណ្ណោះ មិនបានយកចិត្តទុកដាក់អ្វីសោះ ។

"ដួងតា" ដែលមកអង្គុយនៅខាងមុខអាត្មានៅពេលនេះ គឺមានរូបរាងខុសពី "ដួងតា" កាលពីលើកមុនស្រឡះឆេង ដូចជាមនុស្សផ្សេងគ្នា មុខរបស់គេស្លេកស្លាំង តាមរង្វង់ភ្នែកខ្មៅជាំ រាងកាយស្គមបីដូចជាមនុស្សឈឺជាទំងន់ គេឱនក្រាបថ្វាយបង្គំអាត្មាដូចជាហត់ហេវ ហើយក៏អង្គុយឈ្ងោកមុខយំមិនឈប់ ។

- តើនាងមានរឿងអ្វីឬ? អាត្មាសួរ រួចហើយសម្លឹងមើលទៅញោម ខាំសែន ដោយនឹកឆ្ងល់យ៉ាងខ្លាំង
- នេះគឺជារឿងដែលធ្វើឲ្យពិបាកមែនទែនព្រះអង្គ !

*ញោម"ខាំសែន"ឆ្លើយតប ព្រមទាំងគ្រវីក្បាលដោយសេចក្តីខូចចិត្តខ្លាំង, វាព្យាយាមចង់តែសម្លាប់ខ្លួនឲ្យស្លាប់ ២ ដងមកហើយ, លើកដំបូងលេបថ្នាំដែលសម្លាប់សត្វល្អិត ប៉ុន្តែសំណាងល្អ យើងបាននាំទៅមន្ទីរពេទ្យទាន់ហើយលោកគ្រូពេទ្យបានលាងក្រពះទាន់ពេលវេលា, លើកទីពីរ យប់មិញនេះឯង វាគិតនឹងចងកវាមួយខ្សែ ម្តាយបានជួយទាន់នៅពេលនេះត្រូវនៅចាំយាមផ្លាស់គ្នា ខ្ញុំកូណាពិបាកចិត្តណាស់ សូមព្រះអង្គមេត្តានិមន្តទេសនាឲ្យវាស្តាប់បន្តិចផងទៅទាន ព្រះកូណា!*

*- រឿងរ៉ាវតើមកពីអ្វី សាកល្បងនិយាយឲ្យអាត្មាស្តាប់ផងបានទេ ? បើបានដឹងនូវរឿងរ៉ាវទាំងនោះអាត្មានឹងអាចជួយបានខ្លះ*

*- "ដួងតា" ចូរនិយាយឲ្យលោកស្តាប់ទៅកូន! ម្តាយរបស់គេពោលឡើង, ហើយលោកនឹងអាចទេសនាពន្យល់ឲ្យកូនស្តាប់ កូននឹងអាចបានធូរស្បើយខ្លះណា៎!*

*"ដួងតា" នាងនៅស្ងៀម យំសសឹកងឹក ដែលគួរឲ្យអាណិតដល់ញោម "ខាំសែន" និងភរិយា ដែលខីតខំព្យាយាមយកចិត្តដល់កូន លួងលោម សូមឲ្យកូននិយាយរឿងរ៉ាវពិតដល់លោក ៗ ប៉ុន្តែមិនបានផល "ដួងតា" នៅតែមិនព្រមនិយាយសោះ សូម្បីតែបន្តិចបន្តួចឡើយ ៗ អាត្មាព្យាយាមធ្វើចិត្តឲ្យជាសមាធិ ធ្វើឲ្យសមាធិពោរពេញទៅដោយមេត្តាធម៌ហើយឲ្យកម្លាំងនៃចិត្តនោះទៅដល់ "ដួងតា" រួចហើយទើបនិយាយឡើងថា៖*

- ឱ "ដួងតា" អើយ! វេលានេះនាងកំពុងតែចង់ស្លាប់មែនទេ?

- មែន! (ដួងតា ពោលឡើងជាលើកដំបូង ធ្វើឲ្យអ្នកទាំងអស់គ្នាបានធូរចិត្ត)

- ល្អហើយ! អាត្មាពោលឡើង, អាត្មាបានយល់ចិត្តរបស់នាងហើយ ដែលនាងកំពុងតែធ្លាក់ចុះទៅក្នុងរណ្ដៅទុក្ខហើយចង់ស្លាប់ អាត្មាមិនហាម មិនឃាត់នាងទេ ផ្ទុយទៅវិញនឹងជួយឲ្យនាងបានស្លាប់ ដូចសេចក្ដីដែលនាងប៉ងប្រាថ្នាផង

នៅពេលបានឮពាក្យរបស់អាត្មាប៉ុណ្ណឹង គ្រប់ៗគ្នាភ្ញាក់ព្រើតស្ទើរតែ "ដួងតា" ខ្លួននាងក៏ឈប់យំដែរ ងើបមុខសម្លឹងមកអាត្មាដោយនឹកឆ្ងល់ ។ នៅពេលរហូតមក មានតែមនុស្សមកលួងលោម ជេរនិងហាមមិនឲ្យសម្លាប់ខ្លួន, ដោយមិនបានគិតសោះពីមុនមក, ទើបគេភ្ញាក់ហើយនឹកឆ្ងល់ ។ សេចក្ដីភ្ញាក់និងឆ្ងល់របស់គេនេះឯង ដែលជាចំណុចដំបូង ចាប់ផ្ដើមឲ្យគេមានសតិសម្បជញ្ញៈត្រឡប់មកវិញ ។

- តែមុននឹងនាងស្លាប់ អាត្មាចង់សូមនៅពេលវេលាសន្ទនាជាមួយនាងបន្តិចបន្តួច គឺអាត្មាចង់ដឹងដើមហេតុដែលនាងចង់សម្លាប់ខ្លួននៅពេលនេះ ចូរនាងនិយាយឲ្យអាត្មាស្ដាប់បន្តិច តើរឿងរ៉ាវនោះវាយ៉ាងម៉េចខ្លះទៅ?

"ដួងតា"នាងអង្គុយឈ្ងោកមុខគិតមួយសន្ទុះហើយក៏

និយាយថា៖

- មុនពេលបុណ្យចូលឆ្នាំថ្មី ប្រហែល ៧ថ្ងៃខ្ញុំកូណា បានជួបប្រុសកំលោះម្នាក់ មកពីស្រុកខាងលិចឈ្មោះ "ប្រាក់សើត" ។ គេឡើងមកលេងនូវពេលចូលឆ្នាំថ្មី ជាមួយមិត្តរបស់គេ ២ នាក់ទៀត មកសំណាក់នៅសណ្ឋាគារមួយនៅក្នុងខេត្ត ។ ថ្ងៃនោះជាថ្ងៃអាទិត្យ ខ្ញុំកូណាជាមួយមិត្ត២ នាក់ទៀត បានឡើងទៅលេងនៅខាងលើព្រះធាតុជើងភ្នំសុធេប នៅពេលដែលយើងកំពុងឡើងជណ្តើរនាគ "ប្រាក់សើត" ជាមួយមិត្តគេ ចូលមកនិយាយជាមួយយើង នាំពួកយើងនិយាយលេងដល់រឿងរ៉ាវផ្សេងៗយ៉ាងជិតស្និទ្ធ ។ នៅលើព្រះធាតុគេបានចែកទឹកឲ្យយើងផឹក ហើយគេបានថតរូបយើងគ្រប់ច្រកល្ហកផ្សេងៗ ។ "ប្រាក់សើត"មើលទៅឫកពារគេដូចជាចូលចិត្តខ្ញុំកូណា គេនាំនិយាយអំពីរឿងផ្សេងៗស្និទ្ធស្នាលដូចជាមិត្ត ។ នៅពេលចុះមក យើងនាំគ្នាទៅដើរដកគ្នាលេងនៅតាមសួនច្បារ "ប្រាក់សើត" គេនិយាយជាមួយខ្ញុំកូណា ឯមិត្តរបស់គេនិយាយជាមួយមិត្តស្រីរបស់ខ្ញុំកូណា២ នាក់ ។

"ប្រាក់សើត" និយាយឲ្យខ្ញុំកូណាស្តាប់ថា គេជាកូនប្រុសរបស់សិក្ខិប្អូនម្នាក់ ខ្លួនគេបានរៀនចប់មហាវិទ្យាល័យហើយ សព្វថ្ងៃកំពុងធ្វើការនៅក្នុងក្រុមហ៊ុនបារាំងមួយ បានប្រាក់ខែ ៤ ០០០ បាត គឺអាចចាយវាយសម្រាប់ខ្លួនគេម្នាក់ឯងបានយ៉ាងស្រួល ។ គេប្រាប់ថា គេអាយុ ២៥ ឆ្នាំតែមិនទាន់មានប្រពន្ធទេ គេចង់មករកនៅខេត្តនេះ

ពីព្រោះបានឮថាក្រមុំនៅខេត្តនេះស្អាតៗណាស់ ។ នៅពេលបានមកដល់ក៏ឃើញពិតមែន ហើយគេបានសរសើរនូវរូបរាងរបស់ខ្ញុំករុណាថាស្អាតពិតមែន ។ ប្រសិនជាគេបានគូគ្រងដូចខ្ញុំករុណាមែន គេមានសេចក្ដីសុខជាទីបំផុតក្នុងលោក ។ គេជាមនុស្សពូកែនិយាយណាស់ សរសើរយកចិត្តយកថ្លើមធ្វើឲ្យខ្ញុំករុណានឹកសរសើរ ហើយចូលចិត្តដល់គេ គឺពេញចិត្ត និងស្រឡាញ់គេភ្លាម ។

ថ្ងៃបន្ទាប់មក ខ្ញុំម្ចាស់បានជួបនឹង "ប្រាក់សឹត" ទៀត គេនាំខ្ញុំម្ចាស់ទៅមើលកុន ហើយទៅទទួលទានអាហារតាមភោជនីយដ្ឋានល្អៗ រួចគេទិញរបស់ផ្សេងៗទុកជាទីរឭកឲ្យខ្ញុំម្ចាស់ទៀតផង ។ យប់មួយ នៅពេលយើងអង្គុយជជែកគ្នានៅមាត់ទន្លេខាងច្រាំងម៉ែគីង រូបគេក៏បានសូមសារភាពថា គេស្រឡាញ់ខ្ញុំម្ចាស់ គេប្រាប់ថា គេមានចិត្តស្រឡាញ់តាំងតែពីថ្ងៃដំបូងម្ល៉េះ គេថាប្រហែលជាគូនឹងគ្នាអំពីជាតិមុនហើយ លោកនាំមកឲ្យបានជួបគ្នា នេះគឺជាបុណ្យរបស់គេពិតមែនហើយ ។ គេនិយាយតទៅទៀតថា ជីវិតរបស់គេ បើគាលណាខ្វះខ្ញុំម្ចាស់ គេមិនអាចរស់បានទេ គេសូមស្រឡាញ់ខ្ញុំម្ចាស់ ប៉ុន្តែខ្ញុំម្ចាស់មិនបានឆ្លើយតបអ្វីទាំងអស់ ថាខ្ញុំម្ចាស់ស្រឡាញ់គេ ប៉ុន្តែតារពិតបាននឹកស្រឡាញ់គេដែរ ។ ខ្ញុំម្ចាស់បានឲ្យយោបល់ទៅគេថា ឲ្យចូលមកនិយាយសូមពីលោកឪពុកនិងអ្នកម្ដាយសិន ស្អែកឡើងគេមកមែន ព្រមទាំងទិញរបស់របរជាច្រើន ។ លោកឪពុក អ្នកម្ដាយក៏ពេញចិត្តនូវនិស្ស័យរបស់គេច្រើន

ដែរ ប៉ុន្តែលោកមិនទាន់ទុកចិត្តគេទេ ក្រែងលោះជាល្បិច ល្បួងលោមរបស់មនុស្សស្រុកខាងលិច ពីព្រោះធ្លាប់ឮ ស្តាប់មកជាច្រើនណាស់មកហើយ ។ លោកបានពន្យល់ដល់ "ប្រាក់សីត" ថា បើមានចិត្តស្រឡាញ់ពិតប្រាកដហើយ គួរតែសូមឲ្យញាតិចាស់ទុំពីបាងកក ឡើងមករៀបចំចាត់ការសុំដណ្តឹងទៅតាមច្បាប់ប្រពៃណីមក លោកពេញចិត្តនិងជួយចាត់ចែងឲ្យតាមសេចក្តីប្រាថ្នា ។ "ប្រាក់សីត" ព្រមរ៉ាប់ទទួលពាក្យថា នឹងចាត់ចែងធ្វើតាមពាក្យរបស់គាត់ទាំងអស់ក្នុងពេលឆាប់ៗនេះ នៅពេលគេទៅបាងកកវិញ ។

សេចក្តីល្អរបស់ "ប្រាក់សីត" ពេលនៅឆៀងម៉ៃរហូតមក ធ្វើឲ្យខ្ញុំមានចិត្តស្រឡាញ់គេខ្លាំងមែនទែនអស់ពីដួងចិត្ត ។ នៅពេលបុណ្យចូលឆ្នាំនៅឆៀងម៉ៃចប់ហើយ គេបានប្រាប់ខ្ញុំម្ចាស់ថា គេនឹងត្រូវត្រឡប់ទៅបាងកកវិញហើយ ពីព្រោះគ្រប់កំណត់ត្រូវចូលធ្វើការវិញ ។ គេបានបបួលខ្ញុំកូណាទៅលេងនិងមើលទីក្រុងធំ គេបាននិយាយអំពីទេសភាពនៅទីក្រុងបាងកកដ៏ធំ សប្បាយហ៊ឺហារ សួនផ្កាពោរពេញដោយពណ៌ចម្រុះគ្រប់យ៉ាង ពេលយប់មានភ្លើងបំភ្លឺពាសពេញទីក្រុង ធ្វើឲ្យខ្ញុំម្ចាស់ចង់ទៅមើលយ៉ាងខ្លាំង ខ្ញុំម្ចាស់ បាននាំនូវរឿងរ៉ាវទាំងអស់នេះទៅពិភាក្សានឹងលោកឪពុក អ្នកម្តាយ ហើយសូមលោកអនុញ្ញាតទៅលេងទីក្រុង ប៉ុន្តែត្រូវលោកបដិសេធមិនឲ្យទៅ ដោយអាងថា យើងមិនទាន់ស្គាល់គេហើយមិនមែនជាអ្វីនឹងគេផង មិនគួរធ្វើដំណើរផ្លូវឆ្ងាយ ហើយទៅសំណាក់នៅជាមួយ

គេទេ ។

ការដែលលោកឪពុក អ្នកម្ដាយបានហាមឃាត់នេះ ធ្វើឲ្យខ្ញុំម្ចាស់មិនសប្បាយចិត្ត ហើយតូចចិត្តជាមួយលោក យ៉ាងខ្លាំង ថែមទាំងបានប្រកែកតវ៉ាជាមួយលោកថា មិន ឃើញមានការខូចខាតខុសអ្វីផង ដែលយើងស្រឡាញ់គ្នា ដោយបរិសុទ្ធហើយនោះ ។ ប៉ុន្តែលោកឪពុកអ្នកម្ដាយ បានពោលទៀតថា កុំទុកចិត្តផ្លូវ កុំសូវទុកចិត្តមនុស្ស នាំឲ្យ យើងខូចចិត្តការសេពគប់ មនុស្សត្រូវឲ្យស្គាល់ឲ្យបានពេល យូរសិន ទើបបានស្គាល់ការរាក់ជ្រៅគ្រាស់ស្ដើងរបស់គេ កុំអាលជឿតែពាក្យសំដីនិយាយតែប៉ុណ្ណោះ ពីព្រោះពាក្យ សំដី ជារបស់ដែលអាចតែង ឆ្លាក់ គូរ ទៅតាមចិត្តគេដែល បានគិតទុកមកបាន ចិត្តដែលពិតប្រាកដរបស់គេអាចទៅ ជារឿងផ្សេងក៏អាចបាន ។ ខ្ញុំម្ចាស់មិនបានឆ្លើយតបឬ ប្រកែកអ្វីជាមួយលោកឪពុកអ្នកម្ដាយទេ ប៉ុន្តែបានគិតក្នុង ចិត្តវាយឫកង និងរៀបផែនការក្នុងចិត្តរបស់ខ្លួនរួចស្រេច ហើយ ។

នៅទីបំផុត ខ្ញុំម្ចាស់បានលាក់ជាមួយប្រាក់សីតនឹង ចុះទៅបាងកក(ក្រុងទេព) ដោយមិនបាច់ជំរាបលោកឪពុក អ្នកម្ដាយ ពីព្រោះបើជំរាបគាត់ទៅ គាត់ក៏មិនអនុញ្ញាតឲ្យ ទៅដដែល ។ សេចក្ដីស្រឡាញ់យ៉ាងពិតច្រើនដល់ប្រាក់សីត បូកផ្សំជាមួយនឹងសេចក្ដីចង់ទៅមើលទីក្រុងធំផង ធ្វើឲ្យខ្ញុំ ម្ចាស់ភ្លេចឪពុក ម្ដាយ ភ្លេចទាំងកិត្តិយសឈ្មោះសម្ដែង ភ្លេចច្បាប់ប្រពៃណី ភ្លេចភាវៈឋានៈរបស់ខ្លួន ភ្លេចគ្រប់យ៉ាង

*ទាំងអស់ ៗ សេចក្តីស្រឡាញ់ធ្វើឲ្យភ្នែកខ្វាក់ជាការពិតប្រាកដណាស់ ហើយភ្នែកខ្វាក់នេះក៏ពីព្រោះសេចក្តីស្រឡាញ់នេះឯង ធ្វើឲ្យខ្ញុំម្ចាស់ត្រូវជួបនូវសេចក្តីខុសបំណង សេចក្តីក្រាំចិត្តទុក្ខព្រួយលុះត្រាតែចង់ស្លាប់នៅពេលនេះ ៗ*

*និយាយមកដល់ត្រង់នេះ ដួងតាឈប់និយាយហើយស្រែកទ្រហោយំហ៊ូចេញមកដោយសេចក្តីទុក្ខក្រាំចិត្ត និងសេចក្តីតូចចិត្ត ខ្លួនអាត្មាផ្ទាល់ក៏មានការតានតឹងចិត្តនិយាយមិនចេញ ម្តាយរបស់គេទឹកភ្នែករលីងរលោង យកដៃស្ទាបខ្នងកូនស្រីជាការលួងចិត្ត ឪពុករបស់គេងាកមុខចេញហើយគេចបាត់ទៅ, នាងពោលចេញមកដោយពាក្យញ័រៗ*

*- បើដឹងឪពុកម្តាយតាំងតែពីដើមមក ម៉្លេះគ្មានរឿងដូច្នេះសោះ !*

# ស្រមោច និង ស្គរ

## ពាក្យប្រាំពីរ

ស្រមោចតែងស្លាប់ក្នុងពាងស្ករ ស្រីអាងរូបល្អភ្លេចស្មារតី
ប្រុសព្រានលួងលោមដោយសម្តី ភ្លេចខ្លួនជាស្រីព្រោះក្តីលង់ ។
នៅពេលបានស្តាប់ពាក្យសរសើរ បញ្ចើចបញ្ចើរង្វេងលង់
ភ្លើតភ្លើនសប្បាយបង់កាយអង្គ ព្រោះតែចំណង់ក្នុងកាមា ។
បង់ខ្លួនខូចប្រាណបានក្តីទុក្ខ ចិត្តក្តួលក្តៅក្តុកចុកពើតផ្សា
អាប់អស់កិត្តិយសឈ្មោះសោភា ដូចជា "ដួងតា" ជឿប្រុសងាយ ៕

ដោយឧបាសក ម៉ិញ សារ៉ាង

# ១០. សេចក្ដីល្អ ដែលបានគិតសោធុចហើយ

"ផ្ទួងនា"យំសស្រីកងងឹកអស់ពេលយ៉ាងយូរ ហើយបាននិយាយថា៖

- លោកម្ចាស់! ខ្ញុំម្ចាស់ចង់តែស្លាប់ មិនចង់រស់នៅតទៅទៀតទេ ប្រហែលជាខ្ញុំម្ចាស់បានធ្វើអំពើឫកម្មអាក្រក់អ្វីអំពីជាតិមុនមកហើយទើបត្រូវគេបោកបញ្ឆោត ត្រូវគេបំផ្លាញអស់ខ្លួន អស់តម្លៃយ៉ាងនេះ ខ្ញុំម្ចាស់នឹកខ្មាសឪពុកម្ដាយ បងប្អូន ខ្មាសអ្នកជិតខាង មិនចង់នៅឲ្យគេឃើញមុខតទៅទៀតទេ ។ ក្នុងទ្រូងរបស់ខ្ញុំម្ចាស់ពោរពេញទៅដោយសេចក្ដីទុក្ខព្រួយ វាធ្វើបាបទារុណខ្លាំងណាស់ ខ្ញុំម្ចាស់មិនអាចទ្រាំនៅ តទៅទៀតបានទេ

- ឱ "ផ្ទួងនា" អើយ! អាត្មាបានប្រាប់ហើយតាំងតែអំពីដំបូងមកថា មិនហាមប្រាមនាងទេ នឹងឲ្យនាងស្លាប់តាមចិត្តប្រាថ្នា ប៉ុន្តែមុននឹងនាងស្លាប់អាត្មាចង់ស្ដាប់រឿងរ៉ាវរបស់នាងជាមុនសិន ចូរនាងនិយាយរឿងរបស់នាងឲ្យចប់ទើបនាងស្លាប់ទៅចុះ ប្រហែលជាមិនយូរប៉ុន្មានទេ យ៉ាងច្រើនណាស់ប្រហែលមួយម៉ោងប៉ុណ្ណោះ ។ ពេលវេលាត្រឹមតែមួយម៉ោងតើនាងមិនអាចលះបង់ឲ្យពួកយើងបានទេឬ ? ប្រសិនជានាងស្លាប់ទៅ យើងមិនអាចមានឱកាសសន្ទនាជាមួយនាងរហូតមួយជីវិត គិតថាយល់ដល់ចិត្តឪពុកម្ដាយបងប្អូន និងអាត្មាផងចុះ

"ដួងចន្ទ"អង្គុយនៅស្ងៀមមួយសន្ទុះហើយបានពោលឡើងថា៖

- បើដូច្នេះ ខ្ញុំម្ចាស់នឹងនិយាយតទៅទៀត ខ្ញុំម្ចាស់ភ្លេចទៅហើយ តើនិយាយដល់ត្រឹមណាហើយ?

- នៅពេលដែលឯងរត់តាម "ប្រាក់សីត" ចុះទៅបាងកក,អាត្មាប្រាប់...

- នៅពេលទៅដល់បាងកក គួរតែនាយ "ប្រាក់សីត" នាំខ្ញុំម្ចាស់ទៅជួបឪពុកម្ដាយឯផ្ទះរបស់គេ ត្រឡប់ជានាំខ្ញុំម្ចាស់ទៅសម្រាកនៅឯផ្ទះសំណាក់មួយកន្លែង គេប្រាប់ថាគេមិនទាន់បានជំរាបឲ្យឪពុកម្ដាយគេដឹងទេ ពីព្រោះភ្លាមៗស្រាប់តែនាំខ្ញុំម្ចាស់ទៅជួបនឹងគាត់ ធ្វើឲ្យគាត់មិនសប្បាយចិត្ត ហើយអាចឲ្យគាត់ខឹងដេញយើងទាំងពីរនាក់ចេញអំពីផ្ទះក៏បាន ។ គេសុំឲ្យខ្ញុំម្ចាស់សម្រាកនៅសណ្ឋាគារនេះមួយរយៈសិន នៅពេលគេទៅចរចាសម្រេចជាមួយឪពុកគេស្រួលបួលហើយ គេនឹងមកនាំខ្ញុំម្ចាស់ទៅនៅឯផ្ទះឲ្យសមឋានៈ ។ ខ្ញុំម្ចាស់យល់ចិត្តគេ ហើយក៏នៅសម្រាកក្នុងផ្ទះសំណាក់តាមពាក្យដែលគេពន្យល់ ។

នៅយប់ដំបូងនោះឯង ខ្ញុំម្ចាស់បានក្លាយទៅជាប្រពន្ធរបស់ប្រាក់សីតនៅពេលព្រឹកឡើងគេក៏ចេញទៅបាត់, គេត្រឡប់មកវិញនៅពេលសៀលដោយទឹកមុខខ្មៅរអែរ គេបានប្រាប់ខ្ញុំម្ចាស់ថា គេបាននិយាយសូមឪពុករបស់គេមិនបានសម្រេចទេ ឪពុករបស់គេខឹងយ៉ាងខ្លាំង រហូតដល់មិនឲ្យចូលផ្ទះ ហើយគេនឹងនាំខ្ញុំម្ចាស់ត្រឡប់ទៅឆៀងម៉ៃវិញ

ឈប់ទាក់ទងជាមួយគ្នាតទៅទៀតជាដាច់ខាត ។ ខ្ញុំម្ចាស់អស់សង្ឃឹម ខុសបំណងយ៉ាងខ្លាំង ខូចចិត្តលុះត្រាតែស្រែកទ្រហោយំម្នាក់ឯងនៅផ្ទះសំណាក់ ។ ពេលល្ងាចប្រាក់សឺតត្រឡប់មកផ្ទះសំណាក់វិញ ហើយប្រាប់ខ្ញុំម្ចាស់ថា នៅពេលនេះគេអស់ប្រាក់ហើយ មិនមានប្រាក់បង់ថ្លៃផ្ទះសំណាក់និងទិញអាហារបរិភោគទៀតទេ ប្រសិនជាខ្ញុំម្ចាស់មិនជួយទេ យើងទាំងពីរនាក់ត្រូវដាច់ពោះស្លាប់ជាមិនខាន ។ នៅទីបំផុត ខ្ញុំម្ចាស់បានដោះខ្សែក ចិញ្ចៀន ខ្សែដៃ និងនាឡិកាដៃ ប្រគល់ឲ្យគេដើម្បីយកទៅលក់ ។ ពេលល្ងាចថ្ងៃបន្ទាប់មក ប្រាក់សឺតត្រឡប់មកវិញ ប្រាប់ខ្ញុំម្ចាស់ថា ប្រាក់ដែលបានពីលក់គ្រឿងអលង្ការទាំងនោះ បានបាត់បង់អស់ទៅហើយ គេត្រូវពួកអ្នកលេងលុកហោប៉ៅនៅលើឡានក្រុង ។ គេប្រាប់ថាឲ្យខ្ញុំម្ចាស់ជួយគេម្ដងទៀត បើមិនដូច្នោះទេ យើងទាំងពីរនាក់នឹងត្រូវស្លាប់ ។ ខ្ញុំម្ចាស់ប្រាប់គេថា មិនអាចជួយគេទៀតបានទេ ពីព្រោះរបស់របរដែលមានតម្លៃដែលបានយកមកជាប់នឹងខ្លួន បានប្រគល់ឲ្យគេអស់ទៅហើយ។ ប្រាក់សឺតនៅស្ងៀមមួយសន្ទុះ ហើយបានពោលឡើងនៅពាក្យដែលខ្ញុំម្ចាស់មិនបាននឹកស្មានដល់ មិនបានគិតថានឹងបានឮពាក្យនេះ របូតចេញពីមាត់មនុស្សដែលខ្ញុំម្ចាស់វង្វេងស្រឡាញ់ បូជា ហើយថែមទាំងរត់ចោលឪពុកម្ដាយ ផ្ទះសម្បែងរត់តាមគេមក គឺគេប្រាប់ខ្ញុំម្ចាស់ថា ខ្ញុំម្ចាស់នឹងត្រូវដេកជាមួយចៅកែអ្នកមានម្នាក់ ដែលគេបានបង់ប្រាក់ឲ្យគេជាច្រើន ។ ខ្ញុំម្ចាស់សឹងតែខ្យល់គរ នៅពេលបានឮពាក្យ

គេប្រាប់ដូច្នេះ ។ នៅពេលរំសាយអំពីការស្គាល់គ្នាក់នេះ ហើយ ខ្ញុំម្ចាស់នឹកគ្រោធខឹងស្អប់ "ប្រាក់សីត" យ៉ាងខ្លាំង ហើយបានស្ទុះទៅទះកំផ្លៀងគេ ហើយជេរគេដោយពាក្យអាក្រក់ផ្សេងៗ ហើយវិលមករំសាប់ចិត្តវិញដោយទឹកភ្នែកហូរដូចដើម ។ "ប្រាក់សីត" អង្គុយនៅស្ងៀម មិនបានធ្វើអ្វីតបតមកវិញទេ ។ ខ្ញុំម្ចាស់ប្រាប់គេថា ប្រសិនជាប្រាក់សីតហ៊ានធ្វើដល់ថ្នាក់នេះ ជាមួយខ្ញុំម្ចាស់ហើយ គឺមានន័យថាគេឈប់ស្រឡាញ់ អស់សេចក្ដីលើកតម្កើងដល់ខ្ញុំម្ចាស់ហើយ ឬមួយគេអាចមិនធ្លាប់នឹកស្រឡាញ់ខ្ញុំម្ចាស់សោះក៏បាន គេគ្រាន់តែបោកប្រាស់ លួងលោមខ្ញុំម្ចាស់ដើម្បីទាញយកផលប្រយោជន៍របស់គេតែប៉ុណ្ណោះ ហើយនៅពេលនេះគេបានបញ្ចេញនូវមុខមាត់ពិតប្រាកដរបស់គេហើយ ។ នៅពេលដែលការពិត បានលាតត្រដាងចេញមកដូច្នេះ ហើយ ខ្ញុំម្ចាស់សុំកាត់ផ្ដាច់អំពីគេតាំងតែពីពេលនោះមក ហើយគិតនឹងរកផ្លូវត្រឡប់មកផ្ទះវិញ ហើយសូមឲ្យរឿងរ៉ាវទាំងប៉ុន្មាននេះចប់គ្នាទៅចុះ ។

ប្រាក់សីតអង្គុយនៅស្ងៀមរហូតមក ហើយក៏ចាប់ផ្ដើមនិយាយយ៉ាងច្បាស់លាស់ថា ចាប់តាំងពីពេលនេះតទៅ ខ្ញុំម្ចាស់ត្រូវស្ដាប់នូវពាក្យបញ្ជារបស់គេរហូតទៅ ។ ខ្ញុំម្ចាស់ បានធ្លាក់នៅក្នុងកណ្ដាប់ដៃរបស់គេហើយមិនបាច់តែប្រែទេ មិនមានផ្លូវនឹងរត់ទៅណារួចទេ ព្រោះមនុស្សដែលនៅក្នុងផ្ទះសំណាក់ទាំងអស់នេះ គឺជាមនុស្សរបស់គេទាំងអស់ ដូច្នេះទើបគ្មានផ្លូវដែលឲ្យខ្ញុំម្ចាស់រត់គេចរួចបាន

ឡើយ ។ គេក៏ស្ទុះស្ទារចេញពីបន្ទប់ ហើយបិទទ្វារចាក់សោ ឲ្យខ្ញុំម្ចាស់នៅម្នាក់ឯងខាងក្នុង ខ្ញុំម្ចាស់ដេកយំនៅក្នុងបន្ទប់ សឹងតែដាច់ខ្យល់ស្លាប់ដោយសេចក្ដីគ្រាំគ្រាចិត្ត បានយល់ ថាដូចជាខ្លួនឯងត្រូវគេនាំមកឃុំឃាំងទុក នៅក្នុងខ្ទមចាស់ រហែកហើយមានល្អែចចកមួយហ្វូងធំនៅជុំវិញ កំពុងតែ ស្រេកឃ្លាននូវសាច់ឈាម ។ នៅពេលដូច្នេះ ខ្ញុំម្ចាស់ចាប់ នឹកមកដល់លោកឪពុក អ្នកម្ដាយនឹកដល់ផ្ទះ ស្រណោះខ្លួន ខូចចិត្ត ដែលខ្លួនក្បាលរឹង មិនជឿលោក ទើបត្រូវយកទឹក ភ្នែកជូតក្បាលជង្គង់ ។ ខ្ញុំម្ចាស់ឱនគ្រាបក្បាលទៅនឹងខ្នើយ ហើយយំនឹកដល់លោកឪពុក អ្នកម្ដាយទឹកភ្នែកសឹងក្លាយ ទៅជាឈាម ។

មួយសន្ទុះធំហួសទៅ "ប្រាក់សីត" ត្រឡប់មកវិញ ជាមួយបុរសចិនអាយុប្រហែលកណ្ដាលមនុស្ស រូបរាង ធាត់ដុសពោះ មុខមាត់គួរឲ្យស្អប់គេបណ្ដោយឲ្យចិននោះ នៅក្នុងបន្ទប់ជាមួយខ្ញុំម្ចាស់ ហើយគេក៏ចេញពីបន្ទប់ទៅ ។ ខ្ញុំម្ចាស់បានព្យាយាម តស៊ូការពារខ្លួន អស់អំពីសមត្ថភាព ប៉ុន្តែមិនអាចតតាំងជាមួយកម្លាំងរបស់គេបាន ។ នៅទី បំផុត ខ្ញុំម្ចាស់ក៏ធ្លាក់ទៅជារបស់គេម្នាក់ទៀត ។ ចាប់តាំង តែពីពេលនោះមក ខ្ញុំម្ចាស់ក៏បានធ្លាក់ទៅជារបស់គេលក់ឲ្យ បុរសប្លែកមុខ ដែលនាំគ្នាមករកខ្ញុំម្ចាស់ក្នុងមួយថ្ងៃៗច្រើន គ្នា ជាចិនខ្លះ ជាថៃខ្លះ ជាចាមខ្លះ ។ ខ្ញុំម្ចាស់បានយល់ថាដូច ជាបានស្លាប់ពាក់កណ្ដាលខ្លួនទៅហើយ អ្នកណាចង់មក អ្នកណាចង់ទៅ ខ្ញុំម្ចាស់ឈប់ខ្វល់ ឈប់យកចិត្តទុកដាក់

ទៀតហើយ ជីវិតរាងកាយរបស់ខ្ញុំម្ចាស់នៅពេលនោះ គឺប្រៀបបានដូចជាគោលីនៅក្នុងសួន សាធារណៈដែលអ្នកណាមួយចង់មកអង្គុយក៏បានដែរ ។

សៀវភៅថ្ងៃមួយ ប្រាក់សីតបាននាំស្ត្រីចំណាស់អាយុកណ្តាលមនុស្សម្នាក់ចូលមក រូបរាងធាត់ ទាបសម្បុរខ្មៅ ចូលមកក្នុងបន្ទប់ ប៉ុន្តែមិនបាននិយាយអ្វីនឹងគ្នាទេ ។ ស្ត្រីម្នាក់នោះសំឡឹងមើលខ្ញុំម្ចាស់យ៉ាងពិនិត្យពិច័យ ហើយក៏ចាកចេញពីបន្ទប់ទៅ ។ នៅពេលស្ត្រីនោះចេញទៅមិនយូរប៉ុន្មាន "ប្រាក់សីត" បានប្រាប់ខ្ញុំម្ចាស់ថា យើងត្រូវប្តូរផ្ទះសំណាក់នេះទៅនៅឯផ្ទះមួយទៀត ពីព្រោះរស់នៅក្នុងផ្ទះសំណាក់គាប់ចំណាយអស់ច្រើន ។ គេក៏រៀបចំអីវ៉ាន់របស់ខ្ញុំម្ចាស់ដាក់ចូលក្នុងវ៉ាលីសហើយក៏បាននាំមុខខ្ញុំម្ចាស់ទៅ ។ នៅពេលដើរចុះពីផ្ទះសំណាក់ មានប្រុសកំឡោះមុខមាត់មាំ ២ នាក់ទៀតដើរអមខ្ញុំម្ចាស់ ។ គេនាំខ្ញុំម្ចាស់ឡើងឡានតាក់ស៊ីនៅខាងមុខផ្ទះសំណាក់ "ប្រាក់សីត" អង្គុយខាងមុខជាមួយអ្នកបើកបរ គេឲ្យខ្ញុំម្ចាស់អង្គុយខាងក្រោយអមដោយបុរសមុខមាំទាំងពីរ ។

នៅពេលឈប់រង់ចាំភ្លើងក្រហម នៅផ្លូវបែកជាបួននោះ ខ្ញុំម្ចាស់ឃើញមានភ្នាក់ងារនគរបាល ២ - ៣ នាក់ឈរចាំមើលការចរាចរណ៍ នៅក្បែរផ្លូវជិតឡានតាក់ស៊ីរបស់យើងដែលកំពុងចតនៅចាំភ្លើងបៃតង ។ នៅពេលនោះខ្ញុំម្ចាស់កើតមានគំនិតគិតចង់រត់យករួចខ្លួន ។ ក្នុងពេលភ្លាមៗនោះ ព្រមទាំងការគិតនោះឯង ខ្ញុំម្ចាស់បានលោត

ចេញតាមបង្អួច ដែលបើកព្រមទាំងស្រែកថា ៖ "ជួយផងៗ !" ស្រែករស់សម្លេង ខ្ញុំម្ចាស់ឥតបាននឹងថាកញ្ចក់បង្អួចឡាន បិទ ក្បាលរបស់ខ្ញុំក្លូណាទង្គិចនឹងកញ្ចក់យ៉ាងពេញទំហឹង ធ្វើឲ្យកញ្ចក់បែកខ្ចាយ ហើយកម្លាំងដែលប៉ះទង្គិចនោះក៏ ធ្វើឲ្យខ្ញុំម្ចាស់សន្លប់បាត់ស្មារតី អស់ពេលមួយសន្ទុះធំ ។

នៅពេលបាននឹងខ្លួនឡើង ស្រាប់តែឃើញខ្លួនឯង នៅក្នុងមន្ទីរនគរបាលមួយ, ខ្ញុំម្ចាស់មានរបួសដោយប៉ះ កញ្ចក់បង្អួចឡានដែលបែកខ្លះ ប៉ុន្តែមិនជាខ្លាំងទេ ព្យាបាល មិនយូរប៉ុន្មានក៏បានជាសះស្បើយទៅ ។

- លោកម្ចាស់អើយ ! នៅពេលខ្ញុំម្ចាស់បានជាសះ ស្បើយដូចធម្មតាហើយ ក្រុមនគរបាលបាននាំខ្ញុំម្ចាស់ទៅ សាកសួរចម្លើយ នៅពេលសាកសួរនេះហើយ ដែលបាន ដឹងនូវការពិតថា នាយ "ប្រាក់សីត" ដែលខ្ញុំម្ចាស់រៀបរង់ ស្រលាញ់គេអស់ពីបេះដូងនេះ មិនមែនជាកូនលោកសន្តិបិ- បូនអ្វីទេ ។ តាមពិតគឺជាមេចោរម្នាក់ដើរលួងលោមមនុស្ស តែប៉ុណ្ណោះ មុខរបររបស់គេគឺការដើរទៅបញ្ឆោតស្រីៗ ដែលល្អៗអំពីជនបទ តាមស្រុក យកមកបម្រើពួកចៅកែៗ អ្នកមាន រួចហើយយកទៅលក់ឲ្យមេបនស្រីផ្កាមាស ។

នៅពេលបាននឹងនូវការពិតនេះហើយ ការខឹងស្អប់ ស្អប់គេដែលមាន នៅក្នុងខ្លួនស្រាប់ហើយ បានថែមឡើង ទៀតជាទ្វេរគុណ ។ ខ្ញុំម្ចាស់គិតចង់សម្លាប់គេដោយ មធ្យោបាយផ្សេងៗ បើនឹងធ្វើពិតមែនក៏អាចធ្វើបានយ៉ាង ស្រួល ពីព្រោះគេនិងមិត្តភក្តិកំពុងជាប់ឃុំឃាំងនៅឯកន្លែង

ក្រុមនគរបាលជាមួយគ្នានោះឯង ។ ខ្ញុំម្ចាស់អាចទៅទិញចំណី ហើយយកថ្នាំពុលដាក់ចូលទៅ រួចយកទៅឲ្យគេហូប ដោយនិយាយពាក្យផ្អែមពីរោះ ធ្វើដូចជាខ្ញុំម្ចាស់នៅស្រលាញ់គេ តែប៉ុណ្ណោះគេអាចរំលត់ខន្ធតាមសេចក្ដីសងសឹកនូវកំហឹងរបស់ខ្ញុំកូណា ប៉ុន្តែគិតទៅគិតមក ខ្ញុំម្ចាស់បានកាត់ចិត្តមិនធ្វើកម្មពៀរតទៅទៀត គឺជាបាបកម្មទាបថោក ហើយបានគិតថា ពីអតីតជាតិ ខ្ញុំម្ចាស់ប្រហែលធ្លាប់ធ្វើបាបកម្មអាក្រក់ឲ្យគេឈឺចិត្ត ទើបនៅជាតិនេះ គេក៏ធ្វើនូវអំពើអាក្រក់ដល់ខ្ញុំម្ចាស់ដូច្នេះវិញ ។ ខ្ញុំម្ចាស់បានសងកម្មពៀរអស់ហើយ បើនឹងសម្លាប់គេទៀត ក៏នឹងអាចជាការតខ្សែកម្មពៀរវេរាតទៅទៀត ។ យើងទាំងពីរនាក់ត្រូវតាមចងពៀរគ្នាតទៅទៀតមិនចេះចប់ គិតបានដូច្នេះហើយទើបឈប់គិតនូវរឿងនោះទៅ បណ្ដោយឲ្យច្បាប់ផែនដីកាត់ទោសគេតទៅចុះ ។

ក្រោយមកទៀត ខ្ញុំម្ចាស់បែរមកគិតដល់ខ្លួនឯង តើគិតធ្វើយ៉ាងណាតទៅទៀត ខាងនគរបាលប្រាប់ថា នឹងចាត់ការនាំខ្លួនខ្ញុំម្ចាស់ត្រឡប់មកផ្ទះវិញ ។ ចិត្តមួយខ្ញុំម្ចាស់ចង់ត្រឡប់មកផ្ទះពីព្រោះនឹកឪពុកម្ដាយ និងប្អូនៗហើយនិងសេចក្ដីសុខស្ងប់នៅផ្ទះនឹកយ៉ាងខ្លាំង តែចិត្តមួយទៀតមិនចង់ត្រឡប់មកផ្ទះ ចង់ដើរទៅតាមយថាកម្មដោយគ្មានទីដៅដោយយល់ឃើញថា ខ្លួនឯងបានប្រព្រឹត្តអាក្រក់ហើយគួរតែដើរទៅតាមផ្លូវរបស់ខ្លួនទៅទៀតចុះ លុះគ្រាអស់ដង្ហើមចេញចូល ។ ខ្ញុំម្ចាស់ជាកូនអកតញ្ញូមិនស្ដាប់ពាក្យ

ទូន្មានរបស់ឪពុកម្ដាយ ត្រឡប់ទៅជឿអ្នកដទៃ ដែលខ្លួនឯងមិនទាន់បានស្គាល់គេច្បាស់ផង លុះគ្រាត្រូវគេធ្វើបាបទារុណយ៉ាងអស់ខ្លួន គ្មានអ្វីសេសសល់ឡើយ ប្រៀបបាននឹងក្រណាត់ជូតជើង នៅក្នុងកណ្ដាលប្រជុំជនប្លែកៗមុខគ្នា ។ នៅពេលគិតនឹកដល់ត្រង់នេះហើយ ខ្ញុំម្ចាស់នឹកស្អប់ដល់ខ្លួនឯងយ៉ាងខ្លាំង សឹងតែមិនចង់រស់នៅក្នុងលោក មិនចង់ត្រឡប់មកឲ្យឪពុកម្ដាយប្អូនៗ ឃើញមុខទៀតឡើយ ដូច្នោះហើយ ទើបខ្ញុំម្ចាស់ចង់ស្លាប់ឲ្យផុតស្រឡះ ។

- ឱ ! "ដួងតា"អើយ , អាត្មាពោលឡើង នៅពេលច្បាស់ក្នុងចិត្តថា "ដួងតា" បាននិយាយប្រាប់នូវរឿងរបស់ខ្លួនចប់ហើយ, តាំងតែពីបានស្ដាប់រឿងរបស់គេមក តាំងតែពីដំបូងអាត្មាឃើញថា រឿងរ៉ាវរបស់គេដូចជារឿងរបស់មនុស្សវង្វេងផ្លូវ ។ លុះដល់ចុងផ្លូវហើយ ប៉ុន្តែមិនបានជួបដូចចិត្តបំណង ទើបដើរថយត្រឡប់មករកផ្លូវដើមវិញ ហើយចាប់ផ្ដើមដើរទៅតាមផ្លូវដែលត្រូវវិញ ប៉ុន្តែនៅពេលចាប់ផ្ដើមដើរក៏ឈប់ង៉ក់ ហើយងាកត្រឡប់ដើរទៅតាមផ្លូវខុសទៀត តើដូចម្ដេចបានជាអាត្មាពោលដូច្នេះ ? គឺពីព្រោះថា គេបានធ្វើដំណើរវង្វេងទៅដល់បាងកក ហើយបានទទួលនូវសេចក្ដីទុក្ខទារុណគ្រប់យ៉ាង ហើយលុះគ្រាគេគិតនឹងសម្លាប់ខ្លួនឯងឲ្យស្លាប់ខ្លះ គិតនឹងដើរទៅឥតមានទីដៅខ្លះ តែនៅទីបំផុតគេក៏បានដើរទៅតាមផ្លូវខុសនោះតទៅទៀត ហើយគេបានត្រឡប់មកដើរតាមផ្លូវត្រូវ នៅពេលបានត្រឡប់មកដល់ផ្ទះ បានជួបឪពុកម្ដាយហើយ ប៉ុន្តែគេ

ត្រឡប់នឹងដើរទៅតាមផ្លូវខុសទៀត តើអ្នកយល់ឃើញថា ជាការគួរសមហើយឬ ?

នៅពេល "ដួងតារា" មិនឆ្លើយតប អង្គុយខ្ទិនមុខនៅស្ងៀមទើបអាត្មាទេសនាតទៅទៀត៖

- "ដួងតារា"អើយ ! អ្នកអាចនឹងឃើញថា ខ្លួនឯងនេះជាមនុស្សអាក្រក់ ជួជាតិ ជាមនុស្សចង្រៃ ប៉ុន្តែអាត្មាយល់ឃើញថា អ្នកជាមនុស្សល្អ ល្អជាងជនឯទៀតៗជាច្រើនទៅទៀត តើល្អយ៉ាងណា ? ប្រការដំបូងអ្នកមិនបានធ្វើនូវអំពើអាក្រក់ដោយមានសន្តានចិត្តអាក្រក់ ប៉ុន្តែធ្វើទៅដោយការមិនយល់ក្នុងអំពើនោះ ពីព្រោះការវង្វេងខុស ការខ្សោយទៅដោយបញ្ញា នៅពេលអ្នកបានទទួលនូវការឈឺចាប់ផ្លូវចិត្ត ដោយសារនាយប្រាក់សីតនោះហើយ ៗ នៅពេលអ្នកអាចនឹងសម្លាប់ "ប្រាក់សីត" ចោលក៏បាន ប៉ុន្តែអ្នកមិនបានសម្លាប់គេ មានមនុស្សជាច្រើននៅពេលដែលខ្លួនបានទទួលនូវការឈឺចាប់នេះហើយ តែងតែមានការសងសឹកគឺសម្លាប់អ្នកនោះចោលវិញ ដែលធ្វើឲ្យខ្លួនបានទទួលនូវការឈឺចាប់នោះចោលទៅ ដូចជាធ្លាប់បានឃើញនៅក្នុងសារព័ត៌មាន ដែលគេបានចុះផ្សាយរាល់ថ្ងៃនោះ ប៉ុន្តែអ្នកក៏មិនបានធ្វើ នេះជាការល្អប្រពៃណាស់ ៗ មនុស្សយើងភាគច្រើននៅពេលបានជួបប្រទះ នៅទុក្ខដ៏ធ្ងន់យ៉ាងនេះហើយ តែងតែទៅសម្លាប់គេ ឬក៏សម្លាប់ខ្លួនឯង ប៉ុន្តែអ្នកខ្លះទៀតបានសម្លាប់អ្នកឯទៀត ហើយសម្លាប់ខ្លួនឯងទៀត ប៉ុន្តែអ្នកបានទទួលរងទុក្ខព្រួយយ៉ាងធំនេះហើយ មិនបាន

ទៅសម្លាប់អ្នកដទៃ អាចរស់នៅមកបានដល់សព្វថ្ងៃនេះ ចាត់ទុកបានថាអ្នកជាមនុស្សល្អប្រសើរណាស់ ។ មនុស្ស ភាគច្រើននៅពេលធ្វើអាក្រក់ហើយ តែងមានចិត្តធ្វើ អាក្រក់តបត មិនអាចត្រឡប់ខ្លួនមកល្អវិញបាន ។ មាន ស្រីក្រមុំមកពីស្រុកខាងកើតជាច្រើន ត្រូវគេបញ្ឆោតឲ្យទៅ ខូចខ្លួននៅបាងកក និងនៅខេត្តផ្សេងៗ ។ ភាគច្រើនតែង ព្រមខូចខ្លួនរហូតអស់មួយជីវិត មានភាគតិចណាស់ដែល ត្រឡប់មកផ្ទះវិញ ហើយតាំងខ្លួនជាមនុស្សល្អវិញនោះ ប៉ុន្តែ អ្នកវិញខំព្យាយាមត្រឡប់ខ្លួនមករកឪពុកម្ដាយវិញ នេះជា ការកម្ររកបានណាស់ ។ មនុស្សភាគច្រើនឃើញតែ ប្រយោជន៍ផ្ទាល់ខ្លួន ចំណែកអ្នកវិញ សុខចិត្តធ្លាក់ចុះទៅក្នុង ទុក្ខធ្ងន់ហើយក៏ដោយ នៅគិតដល់អ្នកដទៃ គិតដល់ ឪពុកម្ដាយ នឹកដល់អ្នកជិតខាង តើគិតយ៉ាងណា ? ពីព្រោះ អ្នកបានប្រាប់ថា ជាមនុស្សនាំសេចក្ដីអាប់ឱនមកដល់ឪពុក ម្ដាយ និងអ្នកជិតខាង ទើបបានជាចង់ស្លាប់ឲ្យផុតទៅ នេះ មានន័យថាអ្នកយល់ឃើញដល់អ្នកដទៃជាងខ្លួនឯង ដែល រកបានដោយកម្រ ក្នុងសម័យនេះ ព្រោះហេតុនេះ អាត្មាយល់ឃើញថា អ្នកជាមនុស្សល្អពិត ដែលបានទទួល នូវការពិសោធន៍ ហើយអំពីហេតុការណ៍ពិតក្នុងជីវិតពិត មនុស្សភាគច្រើនអាចនឹងពោលបានថា ខ្លួនឯងជាមនុស្សល្អ នៅពេលហេតុការណ៍ពិតនៅមិនទាន់កើតឡើង ។ នៅ ពេលហេតុការណ៍ពិតៗកើតឡើង ក៏ឃោងខ្លួនមិនរួច នេះ ! អ្នកអាចយកខ្លួនឲ្យរួចផុតមកបានគ្រប់រយៈ ទើបចាត់

ទុកបានថា ជាកំពូលមនុស្សម្នាក់ អ្នកគួរតែពេញចិត្តហើយ ឪពុក ម្ដាយរបស់អ្នកក៏បានសប្បាយចិត្ត ។ នៅពេលនេះ អ្នកបានឈ្នះនូវហេតុការណ៍បានហើយ បើអ្នកនៅតែ គិតចង់សម្លាប់ខ្លួនទៀត មានន័យថា អ្នកព្រមចាញ់នូវ ហេតុការណ៍ អ្នកនឹងក្លាយទៅជាមនុស្សអាក្រក់ ដែលមិន មាននរណាអាណិតស្រណោះ សត្រូវរបស់អ្នក ពួកគេនឹង សប្បាយចិត្ត ឯមិត្តសម្លាញ់របស់អ្នកត្រូវខូចចិត្ត ប៉ុន្តែបើ សិនជាអ្នកនៅមានជីវិតវិញ សត្រូវរបស់អ្នក ពួកគេខូចចិត្ត ពីព្រោះពួកគេបានចាញ់អ្នក មិត្តរបស់អ្នកសប្បាយចិត្ត ឪពុកម្ដាយគាត់ត្រេកអរយ៉ាងខ្លាំងក្លា ។ ចូរអ្នកនឹកអាណិត ដល់លោកឪពុកអ្នកម្ដាយ, មិត្ត ឬនិងយោគយល់អាណិត ដល់សត្រូវ ?

- "ដួងតា" នៅអង្គុយស្ងៀម យំសសឹកងងឹកគិតចៗ នៅក្នុងរយៈពេលយ៉ាងយូរ, អាត្មាបានយល់ច្បាស់ថា ៖ អ្នក កំពុងមានសតិសម្បជញ្ញៈត្រឡប់មកវិញហើយ ។

# ចិត្តសត្វលោក

**បទពាក្យប្រាំពីរ**

**ឃើញប្រាក់កត្ដត្រស្រស់បស់ពព្រាយ ឃើញមាសរីករាយមុខប៉ុនភ្នំ**
**ពេលខកខូចចិត្តឆ្អិតទ្រូងយំ ពេលត្រូវអារម្មណ៍សើចក្អាកក្អាយ ។**
**ពេលដែលបានឈ្នះភ្លេចកាលចាញ់ ពេលបានចំណេញភ្លេចចំណាយ**
**ពេលចិត្តស្រឡាញ់លង់សប្បាយ ពេលស្អប់ខ្វល់ខ្វាយកង្វល់ចិត្ត ។**
**ពេលបានសរសើរភ្លេចនិន្ទា បានយសកោគាលង់គំនិត**
**បានសុខភ្លេចទុក្ខវង្វេងពិត នេះគឺជីវិតសព្វសត្តា ។**

# ១១. ឥទ្ធិពលនៃក្រសែផ្លូវលោក

"ថ្ងៃអិតា" នៅតែអង្គុយឈ្ងោកមុខនៅស្ងៀមដដែល ដោយពុំបាន ពោលតបមកអាត្មាសោះ ការនៅស្ងៀម មិននិយាយ មិនឆ្លើយនេះអាចមានន័យច្រើនយ៉ាងគឺ៖

- អ្នកត្រូវគេសួរអាចនៅស្ងៀម ពីព្រោះមិនមានពាក្យឆ្លើយក៏ថាបាន,

- ពីព្រោះមិនពេញចិត្តនឹងឆ្លើយក៏ថាបាន ឬក៏ព្រោះយល់ឃើញទៅតាមពាក្យអ្នកសួរក៏អាចថាបាន

ក្នុងករណីរបស់ "ឆ្លូអិតា" អាត្មាយល់ឃើញថា នាងបានយល់ឃើញស្រប ដោយមានហេតុផលតាមដែលអាត្មាបានពន្យល់ឲ្យស្តាប់ច្រើនជាង ៗ

- ឱ ! ឆ្លូអិតាអើយ! អាត្មាពោលតទៅទៀត, នៅពេលដែលគេកំពុងអង្គុយនៅស្ងៀមនោះ, អាត្មាសូមប្រាប់ថាជីវិតនេះគឺជាការរៀនដែលមិនងាយបានចប់ទេ រៀនតាំងតែពីកើតរហូតដល់ស្លាប់ ការបានរៀនអំពីសៀវភៅ អំពីគ្រូកាលនៅក្មេងនោះ ជាការរៀនតិចតួចទេ ដែលមានអ្នកដទៃ ដាក់កម្រិតឲ្យយើងរៀនមួយរយៈពេល មិនបានប៉ុន្មានឆ្នាំ អ្នកខ្លះយល់ថា ចេញពីសាលារៀនហើយអស់ការរៀនទៀតហើយ អ្នកនោះគឺជាមនុស្សល្ងង់ ៗ មេរៀនដែលពិតប្រាកដនោះ យើងរៀននូវពេលជួបប្រទះក្នុងជីវិតផែនដីទាំងមូល គឺជាសាលារៀនរបស់យើងរបស់គ្រប់

យ៉ាងដែលនៅជុំវិញខ្លួនយើង រួមទាំងខ្លួនយើងផង គឺជាគ្រូរបស់យើង ចាប់តាំងពីពេលយើងកើតមករហូតដល់ពេលស្លាប់ គឺជាពេលរៀនរបស់យើង មេរៀនដែលលោកនេះនឹងបង្រៀនយើង មានគ្រប់ផ្នែក គ្រប់យ៉ាង មានមេរៀនខ្លះសប្បាយគួរឲ្យរីករាយក្នុងចិត្ត ប៉ុន្តែមេរៀនខ្លះធ្វើឲ្យល្វីងជូរចត់ ហើយទារុណសាហាវសឹងតែស៊ូទ្រាំពុំបាន សូម្បីដល់ទារុណកម្មយ៉ាងណាក៏ដោយ គឺជាមេរៀន ៗ

នៅពេលមេរៀន ដែលពិបាកឃោរឃៅបានហួសទៅហើយ យើងនឹងឆ្លាតពូកែថែមទៀតជាច្រើន ដោយបានស្គាល់នូវលោកនេះ កាន់តែច្រើនឡើង មេរៀនខ្លះអាចមានតម្លៃថ្លៃ យើងអាចនឹងត្រូវបង់ថ្លៃរៀនដោយទ្រព្យសម្បត្តិ សេចក្តីសុខ កិត្តិយស ទឹកភ្នែក ហើយសូម្បីជីវិត ប៉ុន្តែកុំភ្លេចថា ជាមេរៀនដែលល្អតែងមានតម្លៃថ្លៃជានិច្ច ៗ

- ដួងតាអើយ ! ក្នុងលោកនេះមិនមានចេតនាអាក្រក់ដល់អ្នកទេ មិនមានចេតនានឹងធ្វើឲ្យអ្នកបានទទួលទុក្ខព្រួយផ្សេងៗទេ គ្រាន់តែឲ្យមេរៀនគ្រប់យ៉ាង ទៅតាមនាទីរបស់មេរៀននោះតែប៉ុណ្ណោះ សេចក្តីសុខ ឬសេចក្តីទុក្ខជារឿងរបស់អ្នក បើសិនជាអ្នកចូលចិត្តនូវមេរៀននោះ ហើយគឺមានចិត្តសប្បាយរីករាយ ប៉ុន្តែបើអ្នកស្អប់នូវមេរៀននោះក៏មានសេចក្តីទុក្ខ ៗ មនុស្សល្ងង់ តែងចូលចិត្តនូវមេរៀនងាយៗសប្បាយរីករាយ មានតម្លៃទាបៗ មេរៀនដែលមានតម្លៃខ្ពស់តែពិបាក ហើយតម្រាមជានិច្ច ៗ សូមពេញចិត្ត

ទៅចុះថា ពិភពលោកឲ្យកិត្តិយសដល់អ្នកយ៉ាងខ្ពង់ខ្ពស់ ដែលបាននាំមេរៀនយ៉ាងពិបាកនេះមកឲ្យអ្នករៀន ឥឡូវនេះមេរៀននោះបានហួសទៅអស់ហើយ តាំងពីពេលនេះតទៅ អ្នកនឹងយល់ជាក់ច្បាស់ ដោយស្គាល់នូវពិភពលោកបានល្អថែមទៀត មានចិត្តគំនិតខ្លាំងក្លាមាំទាំឡើង អ្នកគួរតែពេញចិត្ត ហើយអរគុណគេគ្រប់គ្នា រួមទាំងលោកប្រាក់សើតនោះផង ដែលមានចំណែកក្នុងមេរៀនដែលមានតម្លៃនេះ ។ អ្នកបានអត់ទ្រាំរៀននូវមេរៀន ដែលសែនពិបាកនេះបានដល់ទីបញ្ចប់ ទទួលបានការចេះដឹងហើយ អ្នកគួរតែអរគុណនូវសាលារៀន ពិភពលោកនេះហើយ ខំតាំងខ្លួនជាអ្នករៀនដ៏ល្អតទៅ អ្នកណាដែលបានទទួលមេរៀនពិបាកៗ ក៏ប្រញាប់លាចេញអំពីសាលារៀនដោយការសម្លាប់ខ្លួន អ្នកនោះឯងឈ្មោះថា ជាសិស្សល្អមិនបានទេ គេនឹងធ្លាក់ចុះទៅក្នុងសេចក្ដីល្ងង់ខ្លៅតទៅរហូត

អាត្មាឈប់និយាយ ដើម្បីសង្កេតមើលកិរិយារបស់ "ដួងតា" ស្រីក្រមុំនេះនៅអង្គុយស្ងៀមដដែល ទឹកមុខចុះប៉ុន្តែការយំបាត់ទៅហើយ...

- ពាក្យពោលរបស់ព្រះអង្គ មានហេតុផលពេញចិត្តខ្ញុំកូណាណាស់ បើខ្ញុំម្ចាស់បានគិតតាមផ្លូវហេតុផលរបស់ព្រះអង្គតាំងតែអំពីពេលដំបូងមក ប្រហែលជាខ្ញុំម្ចាស់មិនបានព្រួយឈឺចិត្តច្រើនយ៉ាងនេះសោះ ប៉ុន្តែមិនអីទេ ខ្ញុំម្ចាស់បានរៀនមេរៀន ដ៏មានតម្លៃតាមពាក្យរបស់ព្រះអង្គម្ចាស់បានពន្យល់មកនេះ ខ្ញុំម្ចាស់នឹងជាអ្នករៀន ជាកូនសិស្ស

ដ៏ឯលល្អរបស់សាលារៀន នៅក្នុងលោកនេះតទៅទៀត ។

ពាក្យពោលរបស់នាងស្រី នាំមកនូវសេចក្ដីរីករាយសប្បាយ ដល់អ្នកទាំងអស់គ្នាយ៉ាងខ្លាំងក្លា មាតារបស់ “ឡូងតា” ចូលតម្រង់មកឱបកូនស្រី ដោយសេចក្ដីត្រេកអរព្រមទាំងពាក្យចង់ពោលអ្វីមួយ ប៉ុន្តែនិយាយអ្វីមិនចេញ ដោយសេចក្ដីរីករាយត្រេកអរពេក ។

- ទៅរកមុជទឹកទៅកូន! បុរសជាឪពុកពោលឡើងដោយទឹកភ្នែករលីងរលោង, បន្តិចទៀតយើងនឹងរៀបចំចង្ហាន់ម្ហូប មកប្រគេនព្រះអង្គ ហើយយើងនាំគ្នាញ៉ាំបាយ

“ឡូងតា” គ្រាបសំពះអាត្មាហើយ ទើបក្រោកទៅយ៉ាងស្រួល មាតានិងប្អូនៗនាំគ្នាចូលទៅក្នុងផ្ទះបាយនាំគ្នាចាត់ចែងធ្វើម្ហូបយ៉ាងប្រញាប់ប្រញាល់ ដូចជាបរិយាកាសនៃសេចក្ដីសុខសប្បាយបានត្រឡប់មកវិញហើយ ចូលមកដល់គ្រួសាររបស់ញោមខាំសែនម្ដងទៀត ចំណែកអាត្មាក៏មានចិត្តសប្បាយដែរ ដែលមានចំណែកបានជួយនាំមកនូវសេចក្ដីស្ងប់សុខបានត្រឡប់មកវិញនេះ ។ នៅពេលបានដឹងថា សេចក្ដីសប្បាយចិត្តនេះកំពុងតែនឹងប្រែក្លាយជាសេចក្ដីព្រហើន អាត្មាឆាប់រម្ងាប់ចិត្តហើយកំចាត់វាចេញ ។ មិនយូរប៉ុន្មានគេបាននាំចង្ហាន់មកប្រគេនអាត្មា បានដួសបាយដាក់ចូលក្នុងបាត្រតែល្មម ហើយក៏ចាប់ផ្ដើមឆាន់ ។

- លោកម្ចាស់ ក្មេងក្នុងសម័យនេះពិបាកមែនទែន! ញោមខាំសែន ពោលឡើងនៅពេលដែលអាត្មាកំពុងឆាន់

- អាត្មាថាមនុស្សចាស់ក៏ពិបាកដូចគ្នាដែរ! អាត្មាពោល

ឡើងធ្វើឲ្យញោម "ខាំសែន" ញញឹមតិចៗ ហើយបានឆ្លើយទទួលថា៖

- មែនជាការពិត ខ្ញុំក្ដីណាយល់ថា មនុស្សសម័យនេះកិលេសគ្រាស់ តណ្ហាខ្លាំងជាងមនុស្សជំនាន់មុន, ញោមខាំសែនពោលមកដូចជាបណ្ដិតមួយ ៗ សង្កេតមើលមិនថាក្នុងសារព័ត៌មាន ក្នុងវិទ្យុពេញទៅដោយដំណឹងគម្រាមកំហែង ការលួច ការឆក់ប្លន់ឯស្នេហាគ្នា សម្លាប់គ្នា បាញ់គ្នាសម្លាប់ខ្លួន ពីព្រោះតែរឿងមានសហាយស្មន់ ការលួងលោមមនុស្សយកទៅលក់ នៅកន្លែងសម្បូរណ៍សោភិនីការមានប្រពន្ធចុង មើលទៅដូចជាវិការរស់អំពើល្អរស់ហើយ កាលអំពីជំនាន់មុន ខ្ញុំម្ចាស់មិនដែលបានឮបានឃើញដូច្នេះសោះគាត់ពោលហើយគ្រវីក្បាលតិចៗ

- អាត្មាយល់ឃើញថា កិលេសតណ្ហារបស់អ្នកនោះនៅសម័យណា ក៏ដូចគ្នាទាំងអស់ហ្នឹងឯង អាត្មាពោលឡើងជាបំណាំងជម្ងាស់ជាមួយ ញោម "ខាំសែន"

- អ៊ើ! បើដូច្នោះ បានជាជំនាន់មុន ទើបមិនមានរឿងរ៉ាវទាក់ទងខាងផ្លូវភេទច្រើនដូចសម័យនេះ? ញោមខាំសែនសួរ ហើយសម្លឹងមកមុខអាត្មាដោយមានប្រៀប

- អាត្មាគ្រាន់តែថា កិលេសរបស់មនុស្សកាលជំនាន់មុន និងជំនាន់ឥឡូវនេះមានប្រហែលៗគ្នា ប៉ុន្តែរឿងទាក់ទងជាមួយរឿងភេទនោះ សម័យនេះអាចមានច្រើនជាងពីសម័យមុន ដូចញោមឃើញនៅពេលការកើតឡើងខាង

ទេមានច្រើនឡើង គឺមានន័យថា មនុស្សសម័យនេះមាន កិលេសតណ្ហាច្រើនដែរ ពីព្រោះកិលេសនិងការធ្វើអាច ទាក់ទងនៅពេលមានកិលេសច្រើន ការធ្វើទៅតាមអំណាច កិលេសក៏ច្រើនដូចស្រមោលអន្ទោលតាមប្រាណ, ដូចជា អ្នកប្រាជ្ញខាងធម៌ អាត្មាពេញចិត្តនឹងស្តាប់គាត់ពោល ដើម្បី ឲ្យកើតអារម្មណ៍ ក្នុងការសន្ទនាណាដែលមានប្រយោជន៍, ការដែលបានកូនស្រីមិនព្រមស្លាប់ខ្លួន តទៅនេះប្រហែល ធ្វើឲ្យគេបានរីករាយសប្បាយ អាចសន្ទនាក្នុងធម៌បាន ។

ដែតាមឆ្នុតាញោម "ខាំសែន" ក៏ជាអ្នកចូលចិត្តក្នុងធម៌ អាចីដែរ ។ គាត់ស្លាប់សាកសួរនូវធម៌អាចីផ្សេងៗជាមួយ អាត្មា នៅពេលគាត់មកដាក់បាត្រព្រៅអំពីចូលចិត្តក្នុងធម៌ ហើយ គាត់ចូលចិត្តក្នុងហេតុការណ៍ស្រុកទេសទៀតផង នេះចាត់ទុកបានថា ជាអ្នកសិក្សាខាងផ្លូវលោក និងផ្លូវធម៌ នៅក្នុងភូមិម្នាក់ដែរ ។

- អាត្មាយល់ថា ការដែលប្រព្រឹត្តអាក្រក់ក្នុងផ្លូវភេទ ច្រើនដូច្នេះ ពីព្រោះប្រទេសគាន់តែរីកចម្រើនឡើងៗ មាន របស់ដែលធ្វើឲ្យកើតកាមារម្មណ៍ច្រើនឡើង នៅពេល កាមារម្មណ៍បានទទួលនូវការរុកគួន ក៏បញ្ចេញខ្លួនមកគ្រប ដណ្តប់នូវចិត្ត ធ្វើឲ្យចិត្តងងឹតងងល់ មិនឃើញហេតុផល ហើយនៅពេលតមក ចាប់ធ្វើនូវអំពើអាក្រក់ផ្សេងៗដូចជា គម្រាមកំហែង ធ្វើអាណាចារផ្សេងៗជាដើម ។

ញោម "ខាំសែន" អង្គុយគិតមួយសន្ទុះ ហើយសួរ ឡើងថា៖

- ព្រះអង្គពោលថា ប្រទេសរីកចម្រើនឡើងៗ មានរបស់ធ្វើឲ្យកើតកាមារម្មណ៍ច្រើនឡើងនោះ គឺដូចម្ដេចខ្លះ ?

- ការពិតញោម ក៏ជាអ្នកយកចិត្តទុកដាក់តាមដានរឿងរ៉ាវប្រទេសដែរគួរតែដឹង ប៉ុន្តែអាត្មានឹងអធិប្បាយឲ្យស្ដាប់ក៏បាន អាត្មាយល់ថា របស់ដែលមកបញ្ចេញឲ្យស្រើបស្រាលនោះគឺ រូបភាពស្ត្រីស្លៀកពាក់ត្បិតក្បៀតស្ដើងៗ ដែលមានរូបភាពទៅតាមទស្សនាវដ្តី តាមសារពត៌មានផ្សេងៗរាល់ថ្ងៃខ្លះ តាមខែខ្លះ ចេញតាមបងារូបភាពអនាចារទាំងអស់នេះ អ្នកបោះពុម្ពចេញធ្វើឡើងដោយចិត្តប្រាថ្នាតែម៉្យាងគឺប្រាក់ គេស្គាល់នូវធម្មជាតិរបស់មនុស្សច្បាស់ណាស់ មនុស្សចូលចិត្តកាមារម្មណ៍ ទើបគេធ្វើនុយទាក់ ដើម្បីឲ្យមនុស្សទិញទស្សនាវដ្តីរបស់គេ ផលប្រាកដថាមនុស្សចូលចិត្តទិញច្រើន លក់ដាច់ដូចចាក់ទឹក ៗ ផ្ទុយទៅវិញបើសារពត៌មាន ឬសៀវភៅណាមិនព្រម មិនមានសរសេររូប ឬ ដំណើរអាក្រាតទេនោះ គឺលក់មិនសូវដាច់ទេត្រូវរលំខាតនៅទីបំផុតត្រូវឈប់ធ្វើទៅ ៗ

- ខ្ញុំម្ចាស់មិនយល់ព្រមទេត្រង់ថា គ្រាន់តែមានរូបភាពប្រាសចាកជីវិតទៅលើសែនក្រដាសប៉ុណ្ណោះ អាចធ្វើឲ្យមនុស្សកើតកាមារម្មណ៍បានដូចម្ដេចកើត, ញោមខាំសែនមិនព្រមយល់ស្រប

- ចំណែកញោម ឬចំណែកស្ត្រី រូបភាពអនាចារទាំងអស់នោះអាចមិនមានសេចក្ដីរំភើបអ្វីមែន ក៏ប៉ុន្តែ

ចំណែកមនុស្សកំលោះឯលខូច និងមនុស្សមិនទាន់ចាស់ពេកនោះទេ, រូបភាពដូចបានពោលមកនេះមានន័យច្រើន ពីព្រោះតាមធម្មជាតិរបស់បុរសនោះ កាមារម្មណ៍តែងកើតនៅពេលបានឃើញនូវភាពស្រើបស្រាលតាមភ្នែក ចំណែកស្ត្រីភេទវិញ កើតកាមារម្មណ៍នៅពេលដែលរាងកាយទៅក្នុងពេលដ៏សមគួរមានសេចក្តីស្រឡាញ់ឬចូលចិត្តក្នុងបុរសដែលមានសម្លេងពីរោះ ឬបានទទួលនូវការប៉ះពាល់នូវរាងកាយប៉ុណ្ណោះ ភាពអនាចារសឹងតែគ្មានន័យសោះសម្រាប់ស្ត្រី ដូច្នេះនៅពេលញោមបានឮដំណាវឹងនូវការធ្វើខុសខាងភេទនោះ ញោមយល់ឃើញថា ផ្នែកបុរសជាអ្នកផ្ដើមមុនជានិច្ច

- ខ្ញុំករុណា យល់ថាព្រះអង្គដឹងរឿងធម្មជាតិខាងភេទរបស់មនុស្សបានយ៉ាងច្រើន, ញោមខាំសែនពោលឡើង

- កាលនៅជាគ្រហស្ថ អាត្មាធ្លាប់បានសិក្សាមកខ្លះដែរ

- ដូច្នេះពិតប្រាកដហើយ រូបភាពដែលស្លៀកស្ដើងពាក់តិចតួចនេះ ជាហេតុឲ្យកើតកាមារម្មណ៍ ចាត់ទុកថាជាដើមហេតុឲ្យមនុស្សធ្វើអំពើអាក្រក់ខាងផ្លូវភេទ ខុសសីលធម៌ ដូចម្ដេចបានជាម្ចាស់ទស្សនាវដ្ដីឬសារព័ត៌មាន ហ៊ានធ្វើនូវរបស់ដែលខុសនឹងសីលធម៌ដូច្នេះ គេមិនទទួលនូវការខុសត្រូវក្នុងសង្គមសោះឬក៏គេមិនមានសីលធម៌ក្នុងខ្លួន?

- ញោមអើយ ! អ្នកដែលត្រូវកាមារម្មណ៍គ្របសង្កត់នូវចិត្តហើយ គឺមិនអាចឃើញការខុសត្រូវអ្វីទេ ហ៊ានធ្វើ

ខុសផ្លូវភេទយ៉ាងណា អ្នកដែលត្រូវសេចក្ដីលោភក្នុងប្រាក់គ្របសង្កត់នូវចិត្តហើយ តែងមើលមិនឃើញនូវធម៌ដូច្នេះឯង កុំថាឡើយនូវមនុស្សដែលធ្វើសៀវភៅ ឬទស្សនាវដ្ដីសូម្បីអ្នកផ្សេងៗ ដែលស្រឡាញ់ប្រាក់ក៏ចូលគំនិតផ្សាយនូវរូបភាពនោះផងដែរ ដូចជានៅតាមរានកាសែ យកទៅបិទតាមខាងៗពេញពាសទាំងអស់ ហាងកាត់សក់ យកទៅដាក់គ្របញ្ជរតាមជញ្ជាំង និងខាងមុខតុកាត់សក់ តាមហាងរានផ្សេងៗ ។ នៅពេលចូលឆ្នាំថ្មី គេដើរចែកប្រតិទិនមានរូបភាពអនាចារ ពីព្រោះគេយល់ច្បាស់ថា មនុស្សសំឡឹងមើលហើយមើលទៀត

- ខ្ញុំករុណាចាប់ផ្ដើមយល់ឃើញ ស្របជាមួយព្រះអង្គហើយ នៅពេលរូបភាពទាំងនោះស្រួលធ្វើឲ្យខូចសីលធម៌ដែលល្អប្រសើរ តើដូចម្ដេចបានជាខាងរដ្ឋបណ្ដោយឲ្យគេធ្វើយ៉ាងនេះ យ៉ាងមានសេរីបានដូចម្ដេចមិនជួយហាមឃាត់ផង ឲ្យគេធ្វើទៅតាមអំពើចិត្តដូច្នេះ ?

- គេសំអាងថាជាសិល្បៈណាញោម នៅពេលដែលគេសំអាងថាជាសិល្បៈ ខាងរដ្ឋក៏មិនដឹងថាដូចម្ដេចដែរ

- រឿងនេះគាន់តែពិងឆ្ងាយទៅហើយ, ញោមខាំសែនពោលឡើង, តើជាសិល្បៈអ្វីដែរ ? សូមព្រះអង្គនិមន្តអធិប្បាយឲ្យខ្ញុំករុណាស្ដាប់បន្តិចមើល ! ខ្ញុំករុណាធ្លាប់បានស្ដាប់ដែរ ប៉ុន្តែមិនសូវយល់សោះតើមានន័យយ៉ាងណា ?

- អាត្មាក៏មិនសូវយល់ដូចគ្នាដែរតើអ្វី ! អាត្មាបានសួរ

គេច្រើនគ្នាហើយថាតើសិល្បៈជាអ្វី? តែគេគ្រប់គ្នាបានអធិប្បាយវិលទៅវិលមក មិនបានសេចក្តីអ្វីសោះ គ្រាន់តែពាក្យថាសិល្បៈជាពាក្យនិយាយថាៗទៅ ដោយមនុស្សមានអាងជានិច្ច ប៉ុន្តែនៅពេលស៊ើបសួរដល់ទីបញ្ចប់ គឺបានជួបនូវពាក្យថា ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួនរបស់គេនោះឯង ។

ញោមខាំសែន អង្គុយផ្អៀងក្បាលទៅខាងនោះបន្តិចទៅខាងនេះបន្តិច ដូចជាកំពុងគិតហើយពោលឡើងថា៖

- បានហើយលោកម្ចាស់ "សិល្បៈ" ក៏ជាសិល្បៈចុះ ចាំពេលក្រោយ មានពេលទំនេរខ្ញុំម្ចាស់នឹងទៅសួរអាចារ្យវិសេច លោកបង្រៀននៅខេត្ត ខ្ញុំម្ចាស់បានដឹងថា លោកប្រឡងជាប់បានសញ្ញាប័ត្រខាងសិល្បៈ បានពាក្យចម្លើយយ៉ាងណា ចាំខ្ញុំម្ចាស់ទូលព្រះអង្គ ក្រៅអំពីសំលៀកបំពាក់តិចទៅៗ ហើយតើមានរឿងអ្វីទៀតទេ?

- ក្រៅអំពីរូបភាពហើយ នៅមានរូបពិតៗទៀតណ៎ា ញោម, អាត្មាឆ្លើយ

- រូបពិតៗ តើជាអ្វីទៅលោកម្ចាស់?

- រូបមនុស្សយើងនេះហើយ ដែលកំពុងដើរទៅតាមផ្លូវនោះអាត្មាសំដៅទៅស្ត្រី ដែលនិយមស្លៀកពាក់សំពត់ផ្ទាំងតូចៗ ពាក់អាវបើក ចំហរខាងមុខ វាលខាងក្រោយ ខ្លះស្លៀកសំពត់ខ្លីៗលើជង្គង់ ស្លៀកសំពត់ ឬខោរឹបយ៉ាងតឹង លុះត្រាឃើញរាងរៅខាងមុខខ្លះ ខាងក្រោយខ្លះ នៅខាង

ចំហៀងខ្លះ លុះត្រាឃើញរាងច្បាស់ អាត្មាថារូបពិតនោះឯង នៅពេលបុរសបានឃើញរូបរាល់ថ្ងៃគ្រប់ទីកន្លែង ក៏កើតសេចក្ដីខាងផ្លូវកាមារម្មណ៍បាន នេះប្រហែលនឹងរូបភាព ឬអាចខ្លាំងជាងទៀតផងពីព្រោះជារបស់ពិត

- ពិតមែនហើយព្រះអង្គ! រឿងនេះខ្ញុំករុណាបានប្រាប់រំលឹកដល់ផ្លូងតាដែរ ប៉ុន្តែគេប្រាប់ថាត្រូវតែតែងខ្លួនឲ្យទាន់សម័យដែលគេកំពុងនិយម បើកាលណាយើងនៅតែតែងបែបបុរាណ ចូលគេមិនចុះទេ ខ្ញុំម្ចាស់មិនដឹងធ្វើយ៉ាងណាទើបបណ្ដោយឲ្យគេទាន់សម័យនោះទៅ

- អាត្មាក៏យល់ដូច្នោះដែរ ជាការតែងខ្លួនទាន់សម័យទៅតាមពេលវេលា ជាការបណ្ដោយខ្លួនឲ្យទៅតាមក្រសែលោក បើយើងជាមនុស្សនៅលើពិភពលោកហូរទៅខាងណាយើងត្រូវតែហូរតាមទៅជាមួយដែរ អាត្មាមិនយល់ទាស់អ្វីទេ ប៉ុន្តែនៅពេលក្រសែលោកនាំទៅរកសេចក្ដីទុក្ខព្រួយចិត្តមកដល់យើងដែរ ប៉ុន្តែសូមកុំស្រែកទ្រហោយំទៅបានហើយ គិតទុកជាមុនថា សេចក្ដីទុក្ខព្រួយនោះក៏ជាក្រសែរបស់ពិភពលោកដែលយើងត្រូវតែជួបជាធម្មតា ។ យើងស្រឡាញ់ពេញចិត្ត ព្រមដើរតាមក្រសែពិភពលោកគ្រប់យ៉ាង ត្រូវព្រមទទួលនូវក្រសែពិភពលោក ប៉ុន្តែនៅពេលជួបប្រទះនូវទុក្ខធ្ងន់ ត្រឡប់ទៅស្រែកជេរពិភពលោកយ៉ាងនោះឬ អាត្មាយល់ថា នៅមិនទាន់ធ្វើតាមក្រសែផ្លូវលោកឲ្យបានស្មើចុងស្មើដើម គ្រប់ជ្រុងជ្រោយឲ្យបានសិននៅឡើយទេ ។

- ខ្ញុំករុណាយល់ឃើញថា ការដែលតែងខ្លួនបែបធ្វើឲ្យបុរសមានការកើតកាមារម្មណ៍នោះ វាមានដើមកំណើតមកអំពីប្រទេសអឺរ៉ុប គួរតែទិះទៀនដល់ខាងប្រទេសនោះវិញ, ញោម "ខាំសែន" ពោលឡើង

- ពិតមែនដើម កំណើតចេញមកអំពីប្រទេសអឺរ៉ុប ប៉ុន្តែយើងរត់ទៅទទួលយករបស់គេមកខ្លួនឯង គេមិនបាននាំយកមកសកសៀតឲ្យយើង ហើយមិនបានបង្ខំឲ្យយើងយកតាមគេទេ បើដូច្នេះយើងទៅស្ដីបន្ទោសដល់គេមិនបានទេ

- ប៉ុន្តែខ្ញុំម្ចាស់យល់ឃើញថា គេគួរបានទទួលនូវការតិះដៀលនោះឯង ពីព្រោះគេជាអ្នកប្រឌិតធ្វើចេញមកស្រាវជ្រាវបានមក បើសិនជាគេមិនផ្ដើមគំនិតធ្វើនោះទេតើយើងបានមកពីណា ?

- ល្មើយចប់តែប៉ុណ្ណេះចុះទាន ! ខ្ញុំករុណាមិនចង់ប្រកែក ជាមួយព្រះអង្គម្ចាស់ក្នុងរឿងបន្តិចបន្តួចនេះទេ ខ្ញុំម្ចាស់ចង់ដឹងថា នៅប្រទេសបារាំងដែលគេបានបង្កើតសំលៀកបំពាក់នូវកំណាត់តូចៗ តើគេមានគិតដល់រឿងនេះដែរឬទេ ?

- ការដែលអាត្មាបានឃើញមកនូវការស្លៀកពាក់នោះពួកគេគិតជារឿងធម្មតា ពីព្រោះគេយល់ថា ការស្លៀកពាក់តិចនេះ ជាការធម្មតារបស់គេ គ្មានការខូចខាតអ្វីទេ ពីព្រោះវប្បធម៌របស់គេដូច្នោះឯង គេគ្មានប្រកាន់អ្វីទេ ប៉ុន្តែគេ

ប្រយ័ត្ននូវពាក្យសំដី មិនឲ្យខ្លាំងខ្លាត់ក្នុងកាមារម្មណ៍យ៉ាងពិតច្បាស់ ។ ចំណែកយើងវិញគឺផ្ទុយអំពីគេស្រឡះ គឺយើងគិតថា នៅពេលដែលបញ្ចេញនូវឥរិយាបថៈខ្លះក្នុងទីសាធារណៈ ជាការខូចខាតដែលគួរឲ្យខ្មាសគេ គឺស្ត្រីមិនគួរធ្វើ បើអ្នកណាធ្វើគឺអស់តម្លៃ ដូច្នេះការតែងខ្លួនរបស់យើងៗតែងបិទឲ្យជិតជានិច្ច អាវបិទតាំងពីករហូតដល់កដៃ បើសំពត់ស្លៀកបិទដល់កជើង ប៉ុន្តែមិនសូវប្រយ័ត្ននូវពាក្យនិយាយទេ គេនាំគ្នានិយាយអំពីរឿងភេទបានយ៉ាងច្បាស់នៅទីសាធារណៈ សូម្បីយើងមិនបាននិយាយទេ ប៉ុន្តែអ្នកចំរៀងបានច្រៀងនូវពាក្យមិនសមគួរ និងស្តាប់នៅពេលមានបុណ្យផ្សេងៗ ហើយមិនឃើញមាននរណាតិះដៀលថាអ្វីឲ្យសោះ យើងបានទៅជាសុខតាំងតែជីដូនជីតា តមកដល់យើង យើងបើកទ្វារទទួលយក ហើយទទួលគ្រប់យ៉ាងដោយមិនបានពិចារណា ។

# វេលាជាការពិសោធន៍

## ពាក្យប្រាំពីរ

**វេលាទុកជាការពិសោធន៍ ប្រាជ្ញប្រាយល្ងង់ឆោតស្តាប់សម្តី**
**ទោះជាខំក្លែងដូចម្តេចក្តី មិនយូរលែងអីបញ្ចាក់បាន ។**
**ធម្មតាវាចា និង ចរិត ចេញមកពីចិត្តជាប្រធាន**
**ទោះជាបាបបុណ្យគុណទោសមាន យូរឆាប់ចាប់បានអស់សង្ស័យ ៕**

ដោយឧបាសក ម៉ិញ សារ៉ាង

# មមាច និង ភ្លើងពណ៌

**ពាក្យប្រាំពីរ**

*សម័យចម្រើនដោយ* **Techno** *ស្រីៗច្រើន* **Show** *ស្លៀកខោខ្លី*
*សើចខ្លាំងលែបខាយលេងសម្ដី បង្អួតអ្វីៗដែលខ្លួនមាន ។*
*បង្ហាញសម្រស់សម្ផស្សកាយ ចូលចិត្តសប្បាយបញ្ចេញប្រាណ*
*ភ្លើតភ្លើនភ្លេចពាក្យចាស់ទូន្មាន ស្ដាប់ពាក្យបូរាណស្មានគ្មានន័យ ។*
*ប្រឹងខាងលោតឆ្លោះបោះជំហាន រត់ឈានឲ្យបានទាន់សម័យ*
*ស្រើបស្រាលទៅតាមកាមលោកិយ ពាក់ខើចស្លៀកខ្លីមិនគាប់គួរ ។*
*ដូចសត្វមមាចលង់សប្បាយ ហើរចូលប្រញាយឃើញភ្លើងពណ៌*
*នឹកស្មានបានឋានល្អសុខសួគ៌ គួរឲ្យអាសូរប្រាណត្រូវក្ស័យ ៕*

ដោយឧបាសក មុិញ សារ៉ាង

# ស្គាល់តែមុខទុកចិត្តមិនបាន

**ពាក្យប្រាំពីរ**

*កុំទាន់ទុកចិត្តអ្នកដទៃ ត្រឹមស្ដាប់សម្ដីពោលចរចា*
*ត្រូវត្រួតពិនិត្យចិត្តចរិយា តាមកាលវេលាឲ្យបានច្បាស់ ។*
*តាមពិតវាចានិងចិត្តមនុស្ស ពុំមែនត្រង់ស្មោះតែងវិបល្លាស*
*មាត់ផ្សឹងចិត្តផ្សេងចាំឲ្យច្បាស់ កុំឆាប់ជឿផ្ដាសនាំអន្តរាយ ៕*

ដោយឧបាសក មុិញ សារ៉ាង

# ១២. ជិនធ់កាមគ្រប់គ្រងផ្ទៃលោក

ញោម ខាំសែន នៅស្ងៀមគិតមួយសន្ទុះ ហើយទើបពោលឡើងជាពាក្យឆ្លើយឡើងថា ៖

- ប៉ុន្តែខ្ញុំកូណាយល់ថា រឿងដែលស្លៀកពាក់ខ្លីនេះណា ស្រីសៀមយើងតាំងតែពីដើមមក តែងនិយមនូវសម្លៀកបំពាក់តិចដូចគ្នា ជាពិសេសនៅពេលធ្វើការធ្ងន់ៗ ដូចជាដងទឹក បុកអង្ករ ឬធ្វើការផ្ទះ ស្ត្រីថៃបិទផ្នែកខាងលើនៃរាងកាយ ដោយកំណាត់ស្បៃមួយកំណាត់ ពេលខ្លះបើកចំហរ មិនមានអ្វីបិទបាំងសោះ

- ជាការពិត អាត្មាព្រមទទួល, តែអាត្មាចង់សួរញោមជាមុនថា ស្ត្រីដែលបើកចំហអវយវៈផ្នែកខាងលើនោះ, ដូចជាញោមពោលនេះ តើជាស្ត្រីក្មេង ឬជាស្ត្រីក្មេងវ័យកណ្តាលដែលមានគ្រួសារ មានកូនហើយឬគឺជាស្ត្រីមានប្តីនិងកូនហើយ ?

- នោះមានន័យថា ស្រីថៃចេះដឹងនូវកាលវេលាដែលគួរបើកនិងមិនគួរបើកចំហរ នៅវ័យក្រមុំនៅពេលអវយវៈនៅស្អាតល្អគេតែងបិទបាំង នៅពេលរៀបការរួចមានកូនច្រើនហើយ អស់សេចក្តីស្រស់ស្អាតទើបគេបើកចំហរ សូម្បីមាននរណាមកឃើញក៏មិនមានកើតសេចក្តីស្រឡាញ់ពេញចិត្តអ្វីដែរ

- ពិតមែនហើយព្រះអង្គ ! ញោមខាំសែនពោលឡើង

ពេលខ្លះពួកយើងនាំគ្នានិយាយកំប្លែងលេង នៅពេលគេផឹកកាហ្វេនៅជុំគ្នាថា ដូចស្បែកជើងចាស់ដែលគេឈប់ប្រើអញ្ចឹង ... ពោលហើយគេក៏នាំគ្នាសើច

នៅពេលដែលយើងកំពុងសន្ទនាគ្នានេះ ញោម ចិង និងអ្នកជិតខាងឯទៀត ៤ - ៥ នាក់ បានឡើងមកព្រមទាំងផ្តិលដាក់បាយ ។

- ខ្ញុំម្ចាស់រង់ចាំព្រះអង្គយូរហើយ នឹកស្មានថាព្រះអង្គនិមន្តទៅប្រោស... ញោម ចិង ពោលឡើង នៅពេលយកក្រណាត់សក្រាលហើយក្រាបថ្វាយបង្គំអាត្មា,នៅពេលមិនឃើញនិមន្តទៅទេ ហើយមានគេប្រាប់ថាឃើញលោកម្ចាស់និមន្តឡើងលើផ្ទះលោកខាំសែនទើបតាមមកធ្វើបុណ្យជាមួយផង

- សូមទោសផងណ៉ាំះអ៊ំ ! ញោម "ខាំសែន" លើកដៃសំពះញោម ចិង, អ្នកមានអាយុច្រើនជាង, ខ្ញុំមានរឿងក្តៅព្រួយ ចង់បានឱវាទពីព្រះអង្គទើបសូមនិមន្តលោកម្ចាស់ឡើងលើផ្ទះ

- រឿង ដូងតា នោះមែនឬទេ? ញោម ចិង សួរហើយលើកផ្តិលបាយប្រគេនអាត្មា, តើយ៉ាងម៉េចទៅហើយ ?

- បានស្រួលបួលហើយ, ញោម "ខាំសែន" ឆ្លើយ

- តើមានន័យយ៉ាងម៉េចដែរហ្នឹង? ញោម "កែវ" សួរដូចជាភ័យ, ពាក្យថា " បានស្រួលហើយ " នោះគឺមានន័យពីរយ៉ាង

- សុខសប្បាយជាទេ ! ញោម "ខាំស៊ែន" ឆ្លើយ, នុ៎ះ ! វា កំពុងមុជទឹកនៅខាងក្រោយផ្ទះ បន្តិចទៀតនឹងត្រឡប់មកវិញហើយ

- ពុទ្ធោ ! នឹកថាស្លាប់បាត់ទៅហើយ,ញោមចាន់ពោលឡើងម្តង, លើកក្រោយនិយាយអី ឲ្យវាច្បាស់បន្តិចទៅ !

ទាំងអស់គ្នាសប្បាយចិត្ត ដែលបានដឹងថា "ឌួងតា" បានស្រួលក្នុងចិត្តវិញហើយ ឈប់គិតពីរឿងសម្លាប់ខ្លួន ។ ពេលក្រោយមក ការសន្ទនាក៏វិលត្រឡប់មករកក្នុងសង្គមវិញ ប៉ុន្តែនៅពេលនេះមានការរីករាយឡើង ពីព្រោះមានមនុស្សច្រើនគ្នាមកចូលរួមក្នុងការសន្ទនានេះ ម្នាក់ៗមានយោបល់គ្រប់គ្នាគួរឲ្យចង់ស្តាប់ ។ ញោម "ចិង" គាត់មានអាយុច្រើនជាងគេ គាត់យល់ថាខ្សែភាពយន្តនេះហើយ ដែលជាមេអាទិ៍ ជាដើមហេតុធ្វើឲ្យសីលធម៌ខូច ពីព្រោះមានមនុស្សស្លៀកពាក់ស្តើង ហើយជាសំពត់ខើច ព្រមទាំងមានសម្តែងភាគស្នេហាដោយបែបផ្សេងៗយ៉ាងច្បាស់ បានបង្ហាញនូវរូបភាពមិនល្អដល់ប្រជាជន ។ ញោម "កែវ" យល់ថាការបង្ហាញនូវសេចក្តីស្នេហា ការព្រួយផ្សេងៗ នៅក្នុងសារព័ត៌មានចេញរាល់ថ្ងៃតម្លៃថោកៗ ជាការធ្វើឲ្យសីលធម៌សាបសូន្យ ជាងខ្សែភាពយន្តមានតម្លៃថ្លៃ ។ បើមើលក្នុងសៀវភៅ អាចទៅខ្ចីពីមិត្តភក្តិយកមកអានក៏បាន បើសិនជាពេញចិត្ត អាចមើលបានច្រើនដង ។ ញោម "ចាន់" គាត់ធ្លាប់ទៅលេងនៅបាងកកបានពោលថា៖

- ការពិតទៅដែលធ្វើឲ្យសីលធម៌អន់ថយនោះគឺ បារ

(night Club) ផ្ទះសំណាក់ កន្លែងធ្វើសរសៃ និងមុងទឹកផ្សេងៗនៅពេលដែលញោម "ចិង" មិនយល់ថា ផ្ទះសំណាក់ធ្វើឲ្យសីលធម៌ខូចដូចម្ដេច ញោម "ចន្ទ" បានពន្យល់បន្ថែមទៀតថា៖

- នៅទីក្រុងបាងកក មានផ្ទះសំណាក់ច្រើនណាស់ ហើយល្អៗ ស្អាតៗសប្បាយ ។ ចំណែកផ្ទះសំណាក់តូចៗនៅតាមច្រកល្ហកនោះ មិនសូវមានមនុស្សទៅសំណាក់ទេ ធ្វើឲ្យម្ចាស់ហាងនោះខាតដើម ខ្លះណាំត្រូវបិទចោល, ខ្លះណាំទៅរកស្រីៗសោភិនីមកនៅ ដើម្បីទាញភ្ញៀវឲ្យមកសំណាក់ ។

ចំណែកញោម "ច័យ" អង្គុយស្ដាប់មកយូរហើយ ក៏បានបញ្ចេញយោបល់មកខ្លះថា៖

- សម័យបច្ចុប្បន្ននេះណាំ! ការប្រឡងនូវសំលៀកបំពាក់ ជាការសំខាន់សម្រាប់ក្មេងៗ ។ នៅពេលនេះម្នាក់ៗជួយរកផ្លូវកែនៅក្នុងសង្គមតែមិនអាចកែបានទេ

លុះពេលអាត្មាឆាន់រួច ហើយយល់ឃើញថាត្រូវឲ្យយោបល់របស់អាត្មាខ្លះផង ទើបពោលថា៖

- ពិតមែន! បញ្ហានេះជារឿងធំ គ្រាន់តែមនុស្សពីរឬបីនាក់នេះមិនអាចកែបញ្ហានេះបានទេ នេះជាបញ្ហាដែលគ្មានផ្លូវចេញ សូមឲ្យញោមពិចារណាមើលឲ្យបានល្អ នឹងឃើញថាសូម្បីតែសីលធម៌កំពុងតែចុះយ៉ាងខ្លាំង តែមានអ្នកខ្លះនៅមិនព្រមចុះចាញ់ជាមួយផង ។ នៅមានក្មេងកំលោះជាច្រើនដែលមិនព្រមធ្វើនូវសេចក្ដីថោកទាប ដែល

មានឱកាសធ្វើបាន ព្រមទាំងមានគេមកបបួលទៀតផង ។ ទាំងអស់នេះអាចសម្ដែងឲ្យឃើញបានថា មនុស្សយើងមិនដូចគ្នាគ្រប់គ្នាទាំងអស់នោះទេ ថែមទាំងនៅក្នុងរបស់ជុំវិញដូចគ្នា ។ អ្វីទៅដែលធ្វើឲ្យមនុស្សប្រព្រឹត្តខុសគ្នា ? ពាក្យចម្លើយក៏គឺមនុស្សយើងមានចិត្តខុសៗគ្នា អ្នកខ្លះមានចិត្តអាចទប់ទល់បាន ស្គប់ខ្ពើមនូវអំពើអាក្រក់ តាំងចិត្តធ្វើនូវអំពើល្អ មិនជឿនរណាងាយៗ គេមានហេតុផល និងការសម្រេចដោយខ្លួនឯង មិនបណ្ដោយខ្លួនឲ្យរបស់ជុំវិញដឹកច្រមុះ តែមានអ្នកខ្លះចិត្តទន់ ជឿគេងាយៗ ខ្វះហេតុផល និងការសម្រេចចិត្តរបស់ខ្លួន បណ្ដោយខ្លួនឲ្យអ្នកដទៃឬរបស់ជុំវិញខ្លួន នាំទៅខាងផ្លូវល្អឬអាក្រក់បានដោយងាយ តើដូចម្ដេចបានជាមនុស្សមិនដូចគ្នា ? ពីព្រោះបានទទួលនូវការអប់រំមកផ្សេងៗគ្នា ។ ការអប់រំជាដំបូងដែលមានឥទ្ធិពលខ្លាំងជាងគេនូវផ្លូវចិត្តរបស់មនុស្ស គឺការអប់រំប្រៀនប្រដៅពីឪពុក - ម្ដាយ នេះឯង ។ ដូច្នេះវិធីកែមិនបាច់ទៅកែពីអ្នកដទៃ របស់ដទៃឡើយ គឺត្រូវកែពីឪពុក - ម្ដាយ និងគ្រួសារនេះជាដំបូងសិន...

នៅពេលដែល អាត្មាពោលមកដល់ត្រង់កន្លែងនេះ ញោមៗទាំងអស់សម្លឹងមុខគ្នាដោយនឹកឆ្ងល់ ពីព្រោះគេមិនបាននឹកគិតដល់ការពីមុនមកសោះថា ដើមហេតុដែលនាំឲ្យពិបាកក៏មកពីខ្លួនគេនេះឯង មិនមែនមកអំពីខាងក្រៅដែលបានយល់នោះទេ ។

មួយសន្ទុះក្រោយមក ញោម "ចង" ដែលចាស់ជាង

គេពោលឡើងថា៖

- ខ្ញុំបានប្រដៅវាដែរ ប៉ុន្តែវាមិនសូវស្តាប់ទេ ក្មេងៗសម័យឥឡូវនេះក្បាលរឹងណាស់ មិនសូវស្តាប់ចាស់ៗទេ មិនចូលចិត្តធ្វើការងារ គិតតែពីដើរលេង តើឲ្យខ្ញុំធ្វើដូចម្តេច?

- ញោមបានពោលថា ក្មេងៗសម័យឥឡូវនេះ មិនសូវស្តាប់ចាស់ៗទេ អាត្មាយល់ថាជាការពិតខ្លះ តែមិនពិតសម្រាប់ក្មេងៗទូទៅទេនៅមានក្មេងឯទៀតៗជាច្រើន ដែលគោរពស្តាប់ជឿមនុស្សចាស់ គេបង្រៀនងាយ ហើយស្តាប់ឪពុក-ម្តាយដែលជាអ្នកឧបត្ថម្ភ ដូចជាយើងនេះដែរ, អាត្មាគិតថា នៅពេលយើងបង្រៀនហើយ ក្មេងៗមិនស្តាប់ក៏មិនគួរស្តីថាឲ្យក្មេងតែម្យ៉ាង គួរងាកមកពិនិត្យខ្លួនឯងខ្លះត្រូវពិចារណាមើលថា វិធីបង្រៀនរបស់យើងនោះ តើដូចម្តេចបានជាមិនបានផល កាលណាពិចារណាហើយបានជួបប្រទះឃើញថា ការបង្រៀនរបស់យើងជួនកាលមានខុសគួរតែកែចេញ ។ នៅពេលកែប្រែចេញហើយ បើនៅតែមិនបានផលទៀត ត្រូវរកវិធីផ្សេងៗទៀត ។ ការអប់រំបង្រៀនមិនមែនតែម្យ៉ាងនោះទេ បើកាលណាវិធីមួយមិនបានផលត្រូវរិះរកវិធីមួយបែបថ្មីទៀត ។ មនុស្សមិនមែនជាគ្រឿងម៉ាស៊ីននោះទេ ដែលមិនមានចិត្ត វិញ្ញាណ ប៉ុន្តែមនុស្សជាសត្វមានចិត្ត មានឧបនិស្ស័យ មានសន្តានផ្សេងៗគ្នា ។ យើងត្រូវបង្រៀនឲ្យសមទៅតាមឧបនិស្ស័យរបស់គេម្នាក់ៗ ព្រះពុទ្ធអង្គនៅពេលនឹងបង្រៀនដល់នរណាម្នាក់ លោក

តែងតែពិសេសធម៌ ហើយនិងវិធីបង្រៀន ឲ្យត្រូវសមរម្យជាមួយឧបនិស្ស័យរបស់គេម្នាក់ៗនោះ ទើបការបង្រៀនរបស់ព្រះអង្គបានផលល្អ ជាការបង្រៀនដល់ ទេវតា និងមនុស្សឋានៈខ្ពស់ៗ ។ មនុស្សភាគច្រើនតែងបង្រៀននូវមនុស្សដោយវិធីតែមួយគត់ បើកាលណាមិនបានផលទេនោះ ក៏និយាយថាអ្នកនេះជាមនុស្សក្បាលរឹង មិនបានការដូច្នេះមានន័យថា យកតែចិត្តរបស់ខ្លួនឯងជាធំ កាលណាមិនបានសម្រេចដូចចិត្តរបស់ខ្លួនទេ ក៏គាំងមើលងាយអ្នកដទៃ អាត្មាយល់ឃើញថាជាការមិនត្រឹមត្រូវទេ ជាពិសេសក្មេងៗជំនាន់នេះ ចាស់ៗត្រូវមានមធ្យោបាយក្នុងការអប់រំ ហើយមានវិធីពន្យល់ផ្សេងៗយកមកនិយាយប្រាប់ ពីព្រោះក្មេងក្នុងសម័យនេះមានការចម្រើន ហើយឧបនិស្ស័យរបស់ក្មេងៗសព្វថ្ងៃ មានការចេះដឹងចម្រើនទៅតាមសង្គមដែលចម្រើនហើយ ដូច្នេះមានការខុសគ្នាអំពីយើងកាលពីជំនាន់ដើមឆ្ងាយណាស់ ។ កាលពីសង្គមចាស់យើងបានទទួលការអប់រំរបៀបចាស់ ទើបមានចិត្តពីកាលជំនាន់ចាស់ មនុស្សចាស់ខ្លះខំព្យាយាមទាញក្មេងៗឲ្យមកនៅក្នុងកាលជំនាន់ ៥០ ឬ ៦០ ឆ្នាំមកហើយនៅពេលក្មេងៗមិនព្រមស្តាប់ មនុស្សចាស់ថាវាក្បាលរឹង ដូច្នេះយើងគួរតែកុំព្យាយាមទាញក្មេង ឲ្យមកធ្វើតាមយើងតែម្យ៉ាងយើងត្រូវធ្វើខ្លួនឯងឲ្យចូលជាមួយក្មេងៗនោះផង ។ ពាក្យពេចន៍ដែលអាត្មាបានពោលមកនេះ តើញោមយល់ឃើញយ៉ាងណាដែរ ?

នៅពេលគ្មាននរណាឆ្លើយតបទេ ទើបអាត្មាពោលបន្តទៅទៀតថា ៖

- ដែលញោមៗ "ចង" ពោលថា ក្មេងៗជំនាន់នេះ គិតតែនាំគ្នាដើរលេងនោះ អាត្មាក៏ឃើញដូចគ្នាដែរ ពីព្រោះសម័យនេះ មានរបស់ដែលទាញក្មេងៗឲ្យសប្បាយត្រូវចេញពីផ្ទះច្រើនណាស់ រោងភាពយន្ត កន្លែងលេងកីឡាប្រដាល់ សួនកុមារ ហាងបាយ តៀមកាហ្វេជាដើម... ក្មេងៗកំពុងតែនៅក្នុងវ័យដែលចង់ឃើញ ចង់ស្គាល់ ៗ ពេលនៅខាងក្រៅ មានរបស់ដែលសប្បាយច្រើនជាងនៅផ្ទះ ទើបក្មេងៗមិនចូលចិត្តនៅផ្ទះ គេចូលចិត្តទៅដើរលេងតាមព្រៃ តាមបឹង ទឹក រកត្រីទៅតាមរឿងរបស់គេ ដល់ពេលល្ងាចទើបត្រឡប់មកផ្ទះវិញ ញុំាបាយហើយដេក ៗ ប៉ុន្តែក្មេងស្រុកស្រែមិនសូវខិលខូចទេ ពីព្រោះទីកន្លែងដែលគេទៅលេងនោះ គឺជាទីធម្មជាតិ មិនមានពិសពុលដល់ចិត្តថ្លើម មិនបាច់ចាយប្រាក់ មាសអ្វីទេ ប៉ុន្តែកន្លែងដែលក្មេងនៅទីក្រុងចូលចិត្តទៅដើរលេងនោះ មានភ័យដល់ផ្លូវចិត្ត ៗ ដូច្នោះក្មេងៗនៅទីក្រុង ទើបមានគ្រោះថ្នាក់ដល់ផ្លូវចិត្ត ទើបអាត្មាពោលថា វិធីកែឲ្យក្មេងចូលចិត្តនៅផ្ទះនោះ ត្រូវព្យាយាមរៀបចំផ្ទះឲ្យជាកន្លែងដែលគួរឲ្យចង់រស់នៅ ពេលក្មេងៗបាននៅហើយ មានសេចក្ដីសុខសប្បាយចិត្ត រកការណាដែលក្មេងពេញចិត្តចង់ធ្វើ កុំឲ្យមានពេលទំនេរច្រើនពេករកក្មេងដែលនៅជិតខាងមកលេងជាមួយ មនុស្សនោះក៏ត្រូវមើលឲ្យបានជិតស្និទ្ធផងដែរ ៗ ក៏ប៉ុន្តែពុំមែនជាការ

ឃាត់ឃាំងខ្លាំងពេកទេ, បើធ្វើបានយ៉ាងនេះអាត្មាជឿជាក់ថា ក្មេងៗជាប់ចិត្តនៅក្នុងផ្ទះ មិនចង់ចេញទៅខាងក្រៅទេ ពីព្រោះនៅក្នុងផ្ទះសប្បាយហើយ តើគេចេញទៅខាងក្រៅធ្វើអ្វី ? ។ ប៉ុន្តែនៅពេលនេះឃើញថា ឪពុក - ម្ដាយក៏មិនសូវចង់នៅផ្ទះដែរ ទើបបណ្ដោយឲ្យកូនទៅសេពគប់នឹងក្មេងមិនល្អ ទៅដើរលេងនៅកន្លែងមិនសម ហើយត្រូវខូចកូននោះទៅ ។ ដូច្នេះទើបចង់ឲ្យឪពុក - ម្ដាយ យកចិត្តទុកដាក់ដល់ក្មេងៗក្នុងការរស់នៅ ការលេង ការរៀនសូត្រ ហើយនិងការសេពគប់របស់ក្មេងឲ្យបានច្រើន ងបញ្ហាផ្សេងៗនឹងប្រព្រឹត្តទៅបានល្អដែរ ។ បើយើងមិនអាចទៅកែសង្គមបានទេ យើងមកកែខ្លួនយើងវិញ ។

អាត្មាបានពន្យល់ដល់ញាតិញោម ក្នុងគោលការណ៍បង្រៀននូវការអប់រំដល់កូនចៅ ។ លុះដល់ពេលរសៀលជ្រេលជ្រៃហើយ ទើបបានលាអនុមោទនាឲ្យពរ ត្រឡប់មកវត្តវិញ ។ នៅពេលរសៀលនេះអាត្មា បានទៅអង្គុយសំរាកនៅក្រោមដើមឈើនាមាត់អាងដាក់ទឹកតាមទម្លាប់ ហើយបានយកធម៌មួយ "១" មកពិចារណានូវពោធិ៍បក្ខ ដែលពោលអំពីធម្មវិន័យ ការគិតនូវធម៌ ជាការធ្វើផ្នែកផ្លូវចិត្ត ជាការសន្សំនូវបញ្ញា ។ ការងារផ្លូវចិត្តនេះ ជាការងារថ្នាក់ខ្ពស់ផ្លូវវាចាជាការកណ្ដាល កិច្ចការខាងផ្លូវកាយជាថ្នាក់ទាប តែមនុស្សភាគច្រើនបានយល់ថា ការធ្វើតាមផ្លូវកាយ ឬផ្លូវវាចាប៉ុណ្ណោះចាត់ទុកបានថាជាការគិត ផ្លូវចិត្ត មិនមែនជាការងារទេ ។ ដូច្នោះនៅពេលឃើញអ្នកណាម្នាក់អង្គុយ

ស្ងៀមៗ តែងចង់ឲ្យគេជាមនុស្សខ្ជិល មិនព្រមធ្វើអ្វី តែការពិតគេកំពុងធ្វើការជាន់ខ្ពស់ ។ លោកអ្នកដែលជាអ្នកដឹកនាំក្រុមគណៈ គឺត្រូវជាមនុស្សធ្វើការខាងផ្លូវចិត្តឲ្យបានច្រើនៗ បើយើងមើលទៅជុំវិញខ្លួនបានឃើញថា គ្រប់យ៉ាងជាផលនៃការងារ ដែលបានមកពីការគិតទាំងអស់ សូម្បីការបម្រើន និងការសាបសូន្យនៃប្រទេសក៏មកពីការគិតនោះដែរ ។ ដូច្នេះដែលព្រះពុទ្ធអង្គបានទ្រង់ត្រាស់ទុកមក៖

**ចិត្តេន នីយតិ លោកោ**

ពិភពលោកដែលចិត្តបាននាំទៅ ទើបជាការពិតមែន

សូម្បីព្រះពុទ្ធសាសនា លោកបានចែកកម្មចេញជា ៣ ផ្នែក គឺ កាយកម្ម, វចីកម្ម និងមនោកម្ម ។ មនុស្សភាគច្រើន តែងយកកាយកម្មនិងវចីកម្មជាសំខាន់ ។ ដូចជាឃើញមនុស្សខ្លះធ្វើអំពើល្អតាមកាយកម្ម តាមវាចាក៏បានល្អមដែរ ចិត្តថ្លើមទៅជាយ៉ាងណាៗក៏មិនសូវគិតដែរ ប៉ុន្តែតាមការពិតទៅ អ្នកកាន់ព្រះពុទ្ធសាសនាត្រូវចៀរចាគចំពោះអំពើអាក្រក់តាមផ្លូវចិត្ត ដូចគ្នានឹងចៀរចាគនូវអំពើអាក្រក់ខាងផ្លូវកាយនិងផ្លូវវាចាដែរ គួរតែធ្វើអំពើល្អតាមផ្លូវចិត្តឲ្យបានច្រើនជាងការធ្វើល្អតាមផ្លូវកាយ វាចាទៅទៀត ។

# ១៣. ជួបប្រទះនឹងមច្ចុរាជ

នៅពេលដែល អាត្មាកំពុងអង្គុយពិចារណាធម៌នៅលើគ្រែគ្រោមដើមឈើនោះឯង កើតមានឮសម្លេងប្រេះ - ប្រាវៗនៅលើដើមឈើធំខាងៗនោះ ហើយមានសម្លេងមួយទៀតធ្លាក់ចុះមកក្តុក អាត្មាឈប់ពិចារណាធម៌ ហើយសម្លឹងទៅកន្លែងឮសម្លេងនោះ ៗ ស្រាប់តែប្រទះឃើញពស់ខៀវ កន្ទុយក្រហមខ្នាតធំមួយនៅលើស្លឹកឈើស្ងួតចម្ងាយប្រហែល ៤ ជំហានប៉ុណ្ណោះពីអាត្មា វាឆ្វាយរង្វើលរួចហើយងើបក្បាលរេចុះឡើង សម្លឹងមើលមកខាងអាត្មាដោយឫកពារចង់ធ្វើអន្តរាយដល់អាត្មា ៗ ឯអាត្មាវិញក៏សម្លឹងទៅវាដោយសឹងតែមិនបានពព្រិចភ្នែកដូចគ្នា ៗ ការភ័យភ្ញាក់ខ្លាចតក់ស្លុត កើតឡើងក្នុងចិត្តតាមសញ្ជាតិញាណ តែខឹតខំព្យាយាមប្រមូលសតិសម្បជញ្ញៈត្រឡប់មកវិញ ហើយបណ្តោញនូវសេចក្តីខ្លាចចេញទៅមួយរំពេចដោយមិនពិបាកអ្វីទេ ពីព្រោះជាច្រើនឆ្នាំមកហើយដែលអាត្មាបានដើរ ហើយនិងនៅក្នុងព្រៃបានជួបប្រទះនូវសត្វសាហាវផ្សេងៗយ៉ាងច្រើនមកហើយ ប៉ុន្តែបានគេចផុតរួចមកជានិច្ច ៗ ទាំងនេះគឺអាស្រ័យនូវអានុភាពគឺមេត្តាធម៌ មនុស្សដែលនៅស្រឡាញ់ជីវិតហើយខ្លាចស្លាប់ នៅពេលបានជួបសត្វសាហាវ តែងមានសេចក្តីខ្លាចជាធម្មតា ៗ ប៉ុន្តែសត្វតាចក្នុងព្រៃ នៅពេលវាជួបនឹងមនុស្សតែងតែ

មានសេចក្តីភិតភ័យដោយមនុស្សយើងច្រើនដែរ ។ សេចក្តីខ្លាចនេះហើយ ដែលធ្វើឲ្យយើងទាំងពីរខាងរត់គេច ប៉ុន្តែបើជិតដល់ខ្លួនហើយរត់មិនទាន់ ក៏នឹងចូលមកសម្តែងនូវអាការៈសាហាវ ដើម្បីការពារខ្លួនឲ្យផុតភាពអន្តរាយ ។ មានសត្វភាគតិចដែលសម្លាប់មនុស្ស ដើម្បីយកសាច់ជាអាហារ ហេតុដែលវាធ្វើបាបមនុស្សពីព្រោះវាខ្លាច ហើយដើម្បីការពារខ្លួនវាតែប៉ុណ្ណោះ ។ សត្វវាយល់ច្បាស់ថាមនុស្សជាសត្វគួរឲ្យខ្លាចបំផុតក្នុងលោក ពីព្រោះមនុស្សប្រើអាវុធដែលមានប្រៀប ដូចជាកាំភ្លើង លំពែង ឈើស្រួចជាដើមចំណែកសត្វមិនមានអ្វីទេ ក្រៅពីចង្កូមតូចជាប់នឹងខ្លួនតែប៉ុណ្ណោះ ។ ខ្លាំងជាងនេះទៅទៀតមនុស្សជាសត្វដែលមានចិត្តកាចសាហាវខ្លាំងជាងសត្វទាំងឡាយ ពីព្រោះមនុស្ស ក្រៅអំពីសម្លាប់សត្វយកមកធ្វើជាអាហារហើយនៅសម្លាប់សត្វធ្វើជាកីឡាដើម្បីសេចក្តីសប្បាយទៀតផង។

នៅក្នុងលោកនេះ ដូចជាមានតែមនុស្សទេដែលរកនូវសេចក្តីសុខដល់ខ្លួន ដោយការកសាងនូវសេចក្តីទុក្ខឲ្យដល់អ្នកដទៃ សត្វដទៃ សត្វព្រៃអាចធ្វើបាបមនុស្សពីព្រោះការខ្លាចដែលពោលមកហើយនេះ បើមនុស្សយើងធ្វើខ្លួនឲ្យសត្វជឿបានថា យើងមិនមានភ័យអន្តរាយដល់វា ហើយមិនខ្លាចវា ផ្ទុយទៅវិញត្រឡប់ជាមានសេចក្តីស្រឡាញ់ និងមេត្តាដល់វាដោយបរិសុទ្ធសត្វវានឹងមិនធ្វើអ្វីឲ្យយើងភិតភ័យឡើយ ហើយអ្នកដែលបង្ហាត់បង្រៀននូវសត្វកាចៗទាំងពួង ចំណុចសំខាន់គឺកុំខ្លាចវា គេប្រាប់ថា បើ

សិនជាឈើងខ្លាចវា ព្រោះកាយរបស់ឈើងនឹងបញ្ចេញក្លិន ម្យ៉ាងចេញពីខ្លួនមក នៅពេលដែលសត្វកាចនោះបានធុំក្លិន ដូច្នេះ វាក៏កើតការតតាំង ឬធ្វើអន្តរាយដល់ឈើងមួយរំពេច ប៉ុន្តែបើឈើងមិនខ្លាចវាទេ ហើយស្រឡាញ់វា ឬមានចិត្តមេត្តាដល់វា ដោយវាចាទន់ភ្លន់ ដោយកាយដូចជាស្ទាបក្បាល ស្ទាបខ្នងវា សត្វនឹងមិនបានធុំក្លិនអាក្រក់នោះ ហើយអាចយល់ឃើញ ដល់ក្រសែមេត្តាធម៌របស់ឈើងយ៉ាងរហ័ស ដែលអាចក្លាយទៅជាមិត្តនឹងគ្នាមួយរំពេច ។

សូមកុំថាឡើយដល់មនុស្សនិងសត្វ សូម្បីតែមនុស្សដូចគ្នាអ្នកណាមានមេត្តាធម៌ ចិត្តថ្លើមខ្ពស់ អ្នកនោះឯងតែងមានស្នេហ៍ជាទីរាប់អានស្រឡាញ់ ដល់អ្នកដែលជួបបានឃើញ អ្នកណាបានចូលជិតគឺមានចិត្តសប្បាយរីករាយត្រជាក់ចិត្តយ៉ាងចំឡែក ។ ផ្ទុយទៅវិញបើអ្នកណាមានចិត្តកាចឫស្យា អាក្រក់ខ្វះមេត្តាតែងមានមុខមាំក្រៀមក្រោះ មិនមាននរណាចង់នៅជិត គ្រាន់តែជួបមុខ មានចិត្តមិនសប្បាយទៅហើយ មិនចង់នៅជិត សូម្បីតែសត្វតិរច្ឆានគាន់តែដឹងច្បាស់ជាងមនុស្សទៅទៀត ពីព្រោះចិត្តរបស់សត្វជាចិត្តស្មោះត្រង់បរិសុទ្ធ មានការដឹងលឿនជាពិសេសប្រហែលៗនឹងចិត្តរបស់ទារក មិនមានពុត មិនមានមាយាមិនមានសេចក្តីគិតរសេមរសាម ដូចចិត្តរបស់មនុស្សចាស់ ដូច្នេះសត្វនិងទារកទើបដឹងមុននូវអ្វីៗណាខ្លះ ដែលមនុស្សចាស់មិនបានដឹង ។

កាលនៅជាយព្រៃវាស អាត្មាធ្លាប់ឃើញស្ត្រីម្នាក់ដែល

អ្នកស្រុកបាននិយាយថា នាងជាមនុស្សដែលទទួលពន្លួតកូន ដល់ស្រីក្រមុំដែលមិនត្រូវការឲ្យមានកូន អាត្មាមិនដែលឃើញគេធ្វើ មិនសូវជឿច្បាស់ទេ ប៉ុន្តែមានរបស់មួយដែលគួរឲ្យចម្លែក ប្លែកទាក់ទងជាមួយស្ត្រីម្នាក់នោះ ។ គឺនៅពេលគេដើរទៅតាមផ្លូវ ឃើញអ្នកស្រុកពរកូននាំគ្នាលេង ក្មេងតូចៗគ្រប់គ្នាគ្រាន់តែបានឃើញភ្លាម ក៏ស្រែកទ្រហោយំលាន់រំពងរត់ចេញពីគេទៅឱបកម្ពាយ ឬបងសូម្បីនាងនោះសូមពយ៉ាងណាក៏ដោយ កូនក្មេងទាំងអស់នោះមិនព្រមងាកមើលសោះឡើយ ។

នៅមានរឿងមួយទៀតដែលសត្វវាដឹងអ្វីៗ ដែលមនុស្សយើងមិនដឹងនោះគឺ នៅពេលមួយអាត្មាដើរធុតង្គទៅខាងស្រុកឡៅង៉ាយ បានឃើញជនជាតិនៅលើភ្នំ(ឡៅអឺគរ) ចុះមកទិញអីវ៉ាននៅក្នុងផ្សារ មិនថាពួកនេះដើរទៅខាងទីណាទេ តែងតែមានឆ្កែលូជាប្អូរៗតែម្តង ។ ការពិតមានជនជាតិនៅលើភ្នំធ្លាប់បានចុះមកដែរ ប៉ុន្តែឆ្កែទាំងនេះមិនលូទេ ទើបតែមកលូចំពោះជនអឺគរនេះប៉ុណ្ណោះ ។ អ្នកលក់អីវ៉ាន់នៅក្នុងផ្សារបាននិយាយប្រាប់អាត្មាថា ជនអឺគរនេះចូលចិត្តទទួលទានសាច់ឆ្កែជាប្រចាំ ដូច្នេះទើបឆ្កែវាព្រួសតែចំពោះជនអឺគរ ។ ដូច្នេះមានន័យថា សូម្បីតែសត្វតិរច្ឆានក៏មានញាណពិសេសខ្លះៗ ដែលធ្វើឲ្យវាដឹងនូវចិត្តរបស់មនុស្សដែលមនុស្សយើងមិនដឹង កុំថាឡើយតែវាងសត្វនិងមនុស្ស សូម្បីសត្វដូចគ្នា កាលណាវាបានធ្វើនូវអ្វីម្យ៉ាងពេញទៅដោយគុណធម៌ខ្ពស់មិនចាញ់មនុស្សទេ ។

នៅពេលអាត្មាមិនទាន់ចូលបួស បានជួលផ្ទះមួយខ្នងតូច នៅម្នាក់ឯងក្នុងទីក្រុង ផ្ទះរបស់អាត្មាស្ថិតនៅជិតផ្ទះមួយធំ ដែលជាផ្ទះរបស់ម្ចាស់ផ្ទះ ដែលអាត្មាបានជួលនេះ គាត់មាន ចិញ្ចឹមឆ្កែជាច្រើន មានឆ្កែមេពីរធំៗយើងហៅវាថា "មេនួន" ពីព្រោះវាមានពណ៌ស៊ីនួន ។ មានឆ្កែមួយទៀតតូចឈ្មោះវា "មេដែង"ពីព្រោះវាមានពណ៌ក្រហម, ឆ្កែទាំងអស់នៅពេល វាស៊ីបាយនៅផ្ទះធំរួចហើយ វាក៏មកស៊ីបាយនៅផ្ទះរបស់ អាត្មាទៀត ពីព្រោះអាត្មាជាអ្នកស្រឡាញ់សត្វ ទទួលទាន បាយរួចហើយ នៅសេសសល់បានដាក់ចានចែកចាយឲ្យ ឆ្កែគ្រប់ៗទាំងអស់ស្មើៗគ្នា ។ ពេលតមក ឆ្កែតូចដែលដាក់ ឈ្មោះ "មេដែង" វាមានផ្ទៃពោះទៅតាមរដូវ ប៉ុន្តែមានរបស់ មួយដែលខុសពីធម្មតាកើតឡើងចំពោះ "មេដែង" គឺសូម្បីតែ ពោះរបស់វាធំជិតនឹងកើតហើយ ដោះរបស់វានៅតែតូច ដូចពីដើម មើលទៅមិនអាចនឹងឲ្យកូនវាបៅបានទេ ។ អាត្មាធ្លាប់បាននិយាយជាមួយម្ចាស់ផ្ទះនោះដែរ ថាបើនៅ ពេលវាសម្រាលកូនមកហើយ គ្មានទឹកដោះឲ្យកូនវាបៅតើ នឹងទៅជាយ៉ាងណា ? ។ នៅទីបំផុត"មេដែង" បានសម្រាល កូនមកនៅល្ងាចថ្ងៃមួយ អាត្មាបានដឹងថាវាសម្រាលកូន ហើយ ពីព្រោះឃើញពោះរបស់វាផតតូច និងនៅពេលវា មកស៊ីបាយ ឃើញនៅមានធ្លាក់ឈាមហូរមកទៀត ទើប អាត្មាបានទៅប្រាប់ម្ចាស់ផ្ទះថា "មេដែង" បានសម្រាលកូន ហើយ ។ ក្រោយមកយើងបាននាំគ្នារក ថាតើវាសម្រាល

កូននៅកន្លែងណា ? ។ នៅពេលបាយរួចហើយ យើង ឃើញវាលូនចូលទៅក្រោមផ្ទះបាយ ដែលបានក្រាលក្តារ ជាប់ជិតនឹងដី ។ យើងបានឱនចុះមើលទៅបានឃើញ "មេដែង" កំពុងឱបកូនធ្វើភ្នែកព្រឹមៗ នៅពេលវារត់ចេញ មក យើងបានឃើញដោះរបស់វាស្វិតងដែល អាត្មាក៏បាន និយាយជាមួយម្ចាស់ផ្ទះថា ប្រហែលថ្ងៃស្អែកដោះរបស់វា ឡើងហើយនឹងបានឲ្យកូនរបស់វាបៅបាន ។

នៅពេលយប់ថ្ងៃហ្នឹង អាត្មាបានឮសម្លេងឆ្កែយ៉ាង ច្រើនចេញទៅឈរលូនៅឯកណ្តាលថ្នល់ខាងក្រៅរបង ។ អាត្មាចាំសម្លេងបានច្បាស់ថា គឺជាសម្លេងរបស់ "មេដែង", "អ៊ីនួន" ហើយនិងឆ្កែឈ្មោលពីរទៀតនៅក្នុងផ្ទះនោះ វា ដង្ហើមគ្នាលូយ៉ាងយូរតែម្តង ។ នៅពេលបាត់សម្លេងលូ នោះទៅ នៅពេលព្រឹកឡើងអាត្មាប្រញាប់ប្រញាល់ទៅ ឈ្ងោកមើល "មេដែង" និងកូនរបស់វាជាដំបូង ។ ប៉ុន្តែអាត្មា មានការភ្ញាក់ផ្អើលក្នុងចិត្តយ៉ាងខ្លាំង ពេលដែលបានឃើញ ឆ្កែផ្សេងៗមកក្រាបលើកូននោះវិញ គួរតែជា "មេដែង" តែ ទៅជាឆ្កែពណ៌សម្បុរត្នោតចាស់ មកដេកក្រុងកូនឆ្កែជំនួស វិញ ។ វាសម្លឹងមើលមកអាត្មាដោយភ្នែកភ្ញាក់ផ្អើលមួយ សន្ទុះ ប៉ុន្តែនៅពេលអាត្មាផ្ទុះតំដៃឲ្យវាហើយហៅវាដោយ ពាក្យស្រទន់មក វាបានដេកធ្មេចភ្នែកព្រឹមៗឲ្យកូនឆ្កែទាំងពីរ បៅបន្តទៅទៀត ។ អាត្មាបានទៅហៅម្ចាស់ផ្ទះឲ្យមកមើល គាត់ក៏នឹកប្លែកក្នុងចិត្តដែរ ហើយដែលប្លែកខ្លាំងទៅទៀត

ដោយបានដឹងថាឆ្កែមួយនេះ ជាឆ្កែរបស់អ្នកជិតខាងដែលមានកូនខ្ចីដែរ ដែលផ្ទះនៅឆ្ងាយពីគ្នាប្រហែលជាកន្លះគីឡូម៉ែត្រ ។ តាមធម្មតា ឆ្កែមួយនេះធ្លាប់ដើរកាត់មុខផ្ទះយើងម្តងម្កាលដែរ ប៉ុន្តែរៀងរាល់ពេលឆ្កែរបស់យើងតែងតែដេញខាំគ្នារត់ស្ទើរតែមិនទាន់, មានន័យថាសម្លេងដែលឆ្កែផ្ទះរបស់យើងលូកាលពីយប់មិញនោះ គឺជាសម្លេងសូមជំនួយអំពីឆ្កែមួយនេះឯង ។

ចាប់តាំងពីពេលនោះមក ឆ្កែមួយនេះ តែងតែមកដេកឲ្យកូនឆ្កែទាំងពីរបៅដោះទាំងព្រឹកល្ងាច ចំណែក "មេដែង" ដែលមិនមានទឹកដោះឲ្យកូនបៅ ក៏នៅសប្បាយជាធម្មតា ។ អាត្មាយល់ស្របជាមួយម្ចាស់ផ្ទះថា សូម្បីតែឆ្កែដែលជាសត្រូវនឹងគ្នា នៅពេលមានភ័យអាសន្ន វាក៏អាចជួយគ្នាវាបានដែរ ។

អាត្មាបានផ្សាយមេត្តាធម៌ដល់ពស់ខៀវនោះ និងដល់ត្រកូលស្តេចពស់ទាំង ៤ គឺ ៖ **វិរូបក្ខៈ**, **ឯរាបថៈ**, **ឆព្យាបុត្តៈ** និង **កណ្ហាគោតមកៈ** ហើយក៏អង្គុយសម្លឹងមើលវាតទៅទៀត រំពេចនោះពស់ខៀវក៏ពាំយកស្លឹកឈើស្ងួតមួយ ហើយក៏ផ្តួលខ្លួនវាដេកបម្រះនៅលើស្លឹកឈើស្ងួត ដូចជាត្រូវគេវាយហើយបានទទួលនូវការឈឺចាប់ តែក្រោយមកវាក៏ងើបក្បាលឡើងជាធម្មតា សម្លឹងមករកអាត្មាមួយសន្ទុះ ហើយទើបវារចូលបាត់ទៅក្នុងរន្ធនៃដើមឈើនោះឯង ។ អាត្មានឹកប្លែកក្នុងចិត្ត នូវអាកប្បកិរិយាដ៏ចម្លែករបស់ពស់នោះយ៉ាងខ្លាំង ព្យាយាមគិតទៅគិតមកនូវហេតុផលនេះអស់

រយៈពេលយ៉ាងយូរក៏គិតមិនឃើញ ។

នៅពេល ដែលបានជួបប្រទះហេតុការណ៍គន្លងមកការប្រាកដខ្លួននៃពស់នេះ មានន័យសំខាន់តែម្យ៉ាងចំពោះខ្លួនអាត្មា គឺនៅពេលអាត្មាបានប្រព្រឹត្តខុសនូវវិន័យ "ខ" ណាមួយ ដោយមិនបានដឹងខ្លួនក្នុងវេលាថ្ងៃរសៀល លុះដល់ពេលល្ងាចហ្នឹងបានជួបពស់ ឬសត្វសាហាវណាមួយរាល់ដង ។ គ្រប់ពេលជួបប្រទះនឹងពស់ អាត្មាតែងពិនិត្យមើលនូវការបដិបត្តិរបស់ខ្លួន ក្នុងថ្ងៃហ្នឹងឲ្យបានហ្មត់ចត់ ហើយនៅទីបំផុត ក៏បានជួបនូវកំហុសណាមួយភ្លាម ។ ពេលប្រទះហើយ ក៏សម្តែងនូវការសោកស្តាយ ក៏ធ្វើការអធិដ្ឋានចិត្តថានឹងមិនធ្វើនូវកំហុសនេះទៀតទេ ។ នៅទីបំផុត ពស់នោះបានវារចូលទៅក្នុងព្រៃឬក្នុងរន្ធឈើបាត់ទៅ ។ លោកគ្រូអាចារ្យ របស់អាត្មាបានបង្រៀនហើយថា ពស់នោះ គ្រាន់តែជារុក្ខទេវតាប្រែភេទមកដាស់តឿនដោយអំពើល្អតែប៉ុណ្ណោះ ពីព្រោះអ្នកដែលបានឧទ្ទិសជីវិត ដើម្បីការបដិបត្តិ តាមពាក្យប្រៀនប្រដៅរបស់ព្រះបរមសាស្តា យ៉ាងពិតប្រាកដនោះ សូម្បីតែទេវតាក៏លោកទទួលស្គាល់ ហើយជួយថែរក្សា បើកាលណាឃើញមានអ្វីខុស មិនសមរម្យ លោកក៏មកជួយដាស់តឿនភ្លាម បើឃើញថាយើងបដិបត្តិបានល្អហើយ លោកជួយអនុមោទនានូវកុសលនេះជាមួយផង ហើយលោកនៅចាំជួយថែរក្សាការពារនូវអន្តរាយផ្សេងៗថែមទៀតផង ។

នៅក្នុងពេលនេះ អាត្មាព្យាយាមនឹករកមើលនូវការ

ប្រព្រឹត្ត បដិបត្តិនូវធម៌វិន័យរបស់ខ្លួនមួយរំពេច តែបានពិចារណាយ៉ាងល្អិតហ្មត់ចត់ហើយ តាំងតែពីព្រឹកព្រលឹមមកក៏នៅតែរកមិនឃើញមានអ្វីដែលខុសឆ្គងសោះ អាត្មាបានបដិបត្តិនូវកិច្ចវត្តគ្រប់យ៉ាង ដោយសតិសម្បជញ្ញៈពេញបរិបូណ៌ដូចរាល់ថ្ងៃដែរ បើដូច្នោះពស់នោះកើតឡើងដោយហេតុអ្វី ? នៅពេលគិតរកហេតុផលអ្វីមិនឃើញ អាត្មាក៏សម្រេចចិត្តទៅតាមសាមញ្ញលក្ខណៈថា ពស់មួយនោះជាពស់ធម្មតា ដែលភ្លាត់ធ្លាក់ចុះមកអំពីដើមឈើ ចំណែកអាការៈវិបរិតរបស់វានោះ ប្រហែលជាហេតុនូវសេចក្តីឈឺចុកសៀត ដែលកើតមកអំពីការធ្លាក់ពីទីខ្ពស់មកប៉ះដីតែប៉ុណ្ណោះឯង គឺមិនមែនជារុក្ខទេវតាមកដាស់តឿនជាពិតប្រាកដ ។ ពេលបានគិតដូច្នោះហើយ អាត្មាក៏កំចាត់នូវសេចក្តីគិតអំពីរឿងពស់នោះចោលអំពីចិត្តទៅ ហើយក៏ចាប់គិតពិចារណានូវធម៌តទៅ ។

អាត្មាត្រឡប់ទៅកុដិតូចនៅពេលល្ងាច ហើយក៏រៀបចំជូតក្តារក្នុងកុដិ បោសនៅបរិវេណជុំវិញហើយ ក៏អង្គុយសម្រាកនៅរានហាលនៃកុដិនោះ ។ នៅពេលកំពុងសម្រាកនោះ ភាពរបស់ពស់កន្ទុយក្រហមបានប្រាកដខ្លួនឡើងនៅក្នុងចិត្តទៀត ។ ជាធម្មតា អ្វីដែលយើងនៅមន្ទិលសង្ស័យ តែងតែប្រាកដចេញមករំខាននៅក្នុងចិត្តយើងជានិច្ច ដូចជាមកបញ្ឆោឲ្យយើងគិតម្តងទៀត ដើម្បីរកនូវពាក្យឆ្លើយឲ្យបាន ។ អាត្មាបានប្រើនូវពេលវេលាអង្គុយសម្រាកនោះដើម្បីគិតរិះរកហេតុផលអំពីពស់ទៀត តែមិន

បានជួបនឹងចម្លើយឆ្លើយតបនូវអ្វីៗដូចសព្វដងសោះ ។

នៅពេលកំពុងអង្គុយគិតនោះ ត្រចៀកបានឮសូរសម្លេងរថយន្តមកអំពីចំងាយ អាត្មាក៏មិនបានយកចិត្តទុកដាក់នឹងសម្លេងនោះទេ ពីព្រោះធ្លាប់មានរថយន្តចូលមកក្នុងវត្តនេះម្តងម្កាលជាធម្មតា ។ សម្លេងរថយន្តឮសូរចូលមកដល់ក្នុងវត្តមួយសន្ទុះហើយក៏ស្ងាត់បាត់ទៅ ប្រហែលជាញាតិញោមខ្លះមករកលោកមានកិច្ចការអ្វី ជាមួយព្រះសង្ឃក្នុងវត្តនេះជាមិនខាន ។ អាត្មាស្ងប់ចិត្តផ្សាយមេត្តាឲ្យដល់គ្រប់ៗគ្នា ដែលចូលមកក្នុងទីធ្លានៃវត្តអារាមនេះ ហើយក៏អង្គុយសម្រាកតទៅ ។

ពេលបន្តិចក្រោយមក អាត្មាឃើញមានបុរសចំណាស់ម្នាក់អាយុកណ្តាលមនុស្ស កំពុងតែដើរសំដៅមករកកុដិរបស់អាត្មាយ៉ាងប្រយ័ត្នប្រយែង គេដើរយឺតៗមើលឆ្វេងម្តង ស្តាំម្តងដោយភ្ញាក់ៗខ្លាចអ្វីម៉្យាង ។ នៅពេលគេមកឈរនៅចំពីមុខអាត្មាហើយ អាត្មាសង្កេតឃើញថា គេជាបុរសម្នាក់មានអាយុប្រហែល ៤០ ឆ្នាំមានសម្បុររាងស រូបរាងស្គម ស្លៀកខោពណ៌ខ្មៅចាស់ ពាក់អាវដៃវែងពណ៌គាគី ពាក់មួកពណ៌ខ្មៅខ្ចី មុខមាត់របស់គេដូចជាមិនមែនអ្នកស្រុកធម្មតាទេ ។ គេឈរសម្លឹងមើលមកអាត្មាដោយមុខមាត់មាំទាំ មិនដោះមួកទេ ហើយគេក៏មិនលើកដៃសំពះដែរ ដោយសញ្ជាត ញាណបានឲ្យដឹងថា គេនឹងមកប៉ងធ្វើអន្តរាយជាងមកបំណងល្អ តែទុកជាយ៉ាងណាក៏ដោយចុះ ត្រូវតែសួរឲ្យដឹងរឿងរ៉ាវសិន...

- ញោមមានការអ្វីឬ? អាត្មាសួរ

គេមិនឆ្លើយ ហើយថែមទាំងសួរមកអាត្មាវិញថា៖ លោកជា "ភិក្ខុធម្មឃោស" មែនឬទេ?

- មែន! អាត្មាឆ្លើយ ហើយក៏សួរទៅគេវិញថា៖

- ញោមមានការអ្វីជាមួយនឹងអាត្មាឬ?

- មាន! គេឆ្លើយកំបុតៗ, ធុរៈសំខាន់តែម្ដង

- បើដូច្នោះ សូមញោមអញ្ជើញអង្គុយសម្រាកឲ្យស្រួលសិនទៅ! អាត្មាឆ្លើយតប ហើយសង្រួមចិត្តផ្សាយមេត្តាឲ្យគេ, មើលឫកពាររបស់ញោម អាត្មាអាចទាយបានថាញោមកំពុងមានការសំខាន់ហើយ អញ្ជើញអង្គុយសិនអាត្មាទៅយកទឹកមកឲ្យពិសា

គេអង្គុយនៅលើគាំជណ្ដើរខាងមុខអាត្មា, ដូចជាប្រផេះបានអាយ អាត្មាបានឈោងដៃទៅយកផ្ដិលទឹក និងកែវទឹក ចាក់ទឹកហុចទៅឲ្យបុរសចម្លែកនោះ គេបានទទួលយកទៅទុកនៅក្បែរជញ្ជាំង ហើយសម្លឹងមើលមកអាត្មាស្ញៀមស្ងឹង...

- ញោមមានការអ្វីនិយាយមកចុះ?

- ខ្ញុំករុណាមកនេះដើម្បីសម្លាប់លោកម្ចាស់!

គេពោលឡើងយ៉ាងក្ដៅក្រហាយ, ពាក្យរបស់គេធ្វើឲ្យអាត្មាភ្ញាក់មែនទែន ប៉ុន្តែខំព្យាយាមប្រើសតិរំងាប់ចិត្ត ព្រមទាំងនឹកឆ្ងល់នូវស្ថានភាពនេះយ៉ាងខ្លាំង ពីព្រោះតាំងតែពីកើតមក មិនដែលមាននរណាមកនិយាយដូច្នេះចំពោះ

មុខសោះ ៗ អាត្មាខំព្យាយាមរំងាប់ចិត្តឲ្យស្ងប់ ហើយផ្សាយមេត្តាឲ្យដល់គេម្ដងទៀត ទើបនិយាយឡើងដោយសំឡេងឆម្មតាថា ៖

- ញោមនឹងសម្លាប់អាត្មាធ្វើអ្វី ?

- គឺសម្លាប់ឲ្យស្លាប់នោះអី, គេឆ្លើយតបភ្លាមៗដោយសម្លេងញ័រៗ

- បើញោមនឹងសម្លាប់អាត្មាគ្រាន់តែឲ្យអាត្មាស្លាប់នោះ ញោមមិនចាំបាច់សម្លាប់ នាំឲ្យមានកម្មពៀរវេរាបាបធ្ងន់ទេ ពីព្រោះមិនដល់ ១០០ ឆ្នាំទេ អាត្មាក៏ត្រូវស្លាប់បាត់ទៅហើយ អាត្មាក៏ចង់ដឹងដែរថា តើមានហេតុអ្វីទៅដែលញោមមកសម្លាប់អាត្មានេះ តើញោមខឹងអាត្មាដោយរឿងហេតុអ្វីដែរ ?

បុរសចម្លែកនេះអង្គុយស្ងៀមមួយសន្ទុះ គេមើលទៅនាយអាយដោយអាកប្បកិរិយាខ្វល់ខ្វាយក្នុងចិត្ត...

- លោកមិនបាច់ចង់ដឹងហេតុផលអ្វីទេ !គេឆ្លើយឡើងដោយគំបុតគំបុយ

- អាត្មាចង់ដឹង ! ពីព្រោះតាំងតែពីក្មេងមកដល់ពេលនេះ អាត្មាមិនដែលធ្វើនូវអំពើឫកម្មអាក្រក់ ដល់អ្នកណាម្នាក់សោះឡើយ លើកលែងតែធ្វើទៅដោយអចេតនាប៉ុណ្ណោះ ៗ អាត្មាចង់ដឹងថា តើអាត្មាបានធ្វើនូវកម្មអ្វីជាមួយញោម បើជាកម្មធ្ងន់អាចដល់ថ្នាក់សម្លាប់ អាត្មាក៏យល់ព្រមឲ្យញោមសម្លាប់ ហើយនិងឲ្យអភ័យដល់ញោម

*មិនឲ្យញោមមានកម្មពៀរ នឹងគ្នាតទៅទៀតជាការសងកម្មជាមួយគ្នាឲ្យអស់ទៅក្នុងជាតិនេះ អាត្មាមិនខ្លាចស្លាប់ទេ មិនស្តាយជីវិតសោះឡើយ ពីព្រោះអាត្មាបានទម្លាក់ចុះអស់ហើយ ប៉ុន្តែបើញោមចង់សម្លាប់អាត្មាដោយហេតុមិនសមគួរ ឬអាចសម្លាប់មនុស្សខុសដោយច្រឡំ នេះជាបាបកម្មរបស់ញោមខ្លួនឯង ។*

*- ប្រាកដជាមិនខុសមែន បើសិនលោកម្ចាស់ជា "ភិក្ខុឆម្មឃោស" ពិត !*

*- "ភិក្ខុឆម្មឃោស" អាចមានច្រើនអង្គក៏អាចបានដែរ តើញោមបានដឹងមកបានដូចម្តេចថា លោកណាជាលោកដែលញោមតាំងចិត្តនឹងសម្លាប់ សូមប្រាប់នូវហេតុការណ៍ឲ្យអាត្មាបានស្តាប់ជាមុនសិនផង*

*បុរសនោះក៏ដកយកកាំភ្លើងខ្លីចេញពីហោប៉ៅខោមកកាន់ ហើយតម្រង់ចុងកាំភ្លើងមករកអាត្មា...*

# ជៀសវាងអបាយមុខ

**ពាក្យបួន**

| | |
|---|---|
| ***ជៀសអបាយមុខ*** | ***នាំឲ្យសុខា*** |
| ***ជៀសផនពាលា*** | ***ចិន្តាមិនខ្វល់*** |
| ***ជៀសចេញចាកបាប*** | ***ភាពអកុសល*** |
| ***ចិត្តឥតកង្វល់*** | ***យល់ក្តីសុខសាន្ត ។*** |

ដោយឧបាសក មុិញ សារ៉ាង

# អាដ្ឋាជីវិត

**ពាក្យប្រាំពីរ**

*អាដ្ឋាភ័យពៀរនៅក្នុងលោក មានច្រើនគគោករាប់មិនបាន*
*កើតប្រចាំកាយចិត្តសន្ដាន មនុស្សសត្វគ្រប់ប្រាណគេចមិនផុត។*
*វិបត្តិភ័យខ្លះអាចដោះស្រាយ ដោយការលាក់កាយគេចពួនរត់*
*អំណោះជួយគ្នាបានប្រាកដ បញ្ញាកំណត់ជៀសផុតបាន ។*
*តែអាដ្ឋាមួយរន្ធត់ស្លុត មានជាក់ប្រាកដគ្រប់រូបប្រាណ*
*ចង់គេចពួនរត់ឥតផុតបាន ពុំមានទីឋានគ្រឿងការពារ ។*
*អាដ្ឋានោះគឺមច្ចុរាជ សាហាវកោងកាចគ្មានមេត្តា*
*ឥតបើយោគយល់ដល់សត្តា ផ្ដាច់បង់ប្រហារគ្មានប្រណី ។*
*គ្រប់រូបត្រូវជួបសេចក្ដីស្លាប់ មុនក្រោយយូរឆាប់ឥតសង្ស័យ*
*មិនថាក្មេងចាស់ប្រុសឬស្រី រាស្ត្រស្ដេចមន្ត្រីសេដ្ឋីអ្នកក្រ ។*
*ត្រូវខំព្យាយាមរៀនឲ្យយល់ បញ្ញាចូលដល់សច្ចធម៌*
*គឺព្រះត្រៃលក្ខណ៍ជាក់បវរ ជាឧបករណ៍ជួយស្ងួយចិត្ត ។*
*ពិចារណាឃើញនូវហេតុផល បញ្ញាស្គាល់យល់រឿងជីវិត*
*កំចាត់ភ័យស្លុតផុតបានពិត យល់ជាក់ជីវិតពិតមរណា ៕*

ដោយឧបាសក មុិញ សារ៉ាំង

# ១៩. យកឈ្នះអំពើអាក្រក់ ដោយអំពើល្អ

សត្វទាំងឡាយដែលនៅមានភ្នែក និងចិត្តងងឹតទៅដោយអវិជ្ជា ត្រូវតណ្ហា ឧបាទាន និងសក្កាយទិដ្ឋិចងជាប់ទុក តែងតែស្រឡាញ់នូវជីវិតរបស់ខ្លួន មិនចង់ស្លាប់ ប្រាថ្នាសេចក្ដីសុខសប្បាយ ស្អប់ខ្ពើមនូវទុក្ខ ។ នៅពេលមានភ័យខ្លាំង គឺសេចក្ដីស្លាប់មកដល់ តែងមានការភ្ញាក់ផ្អើលខ្លាចភ័យជាធម្មតា ចំណែកអាត្មាវិញ សូម្បីមានភ័យខ្លាចខ្លះពីព្រោះតែតម្លៃដែលបានសិក្សាអប់រំមកយូរហើយ ក្នុងគោលអនិច្ចំ ទុក្ខំ អនត្តា ឃើញនៅការកើតនិងការស្លាប់គ្រប់ខណៈចិត្ត ទើបអាចបន្ថយនូវសេចក្ដីភ័យខ្លាចនោះបានខ្លះ ។

បុរសដែលប៉ុនប៉ងអាក្រក់នោះ នៅតែកាន់កាំភ្លើងតម្រង់មករកអាត្មាដដែល ភ្នែកសម្លឹងមកពោរពេញទៅដោយសេចក្ដីខឹងក្ដៅក្រហាយ ញញឹមយ៉ាងក្រៀមស្ងួតហើយពោលដោយសម្លេងញ័រៗថា៖

- លោកធ្វើឲ្យខ្ញុំត្រូវចាកចេញចោលផ្ទះ ទៅលាក់ខ្លួនពួនអាត្មាមិនហ៊ានជួបមុខមនុស្ស លោកជាអ្នកបំផ្លាញនូវសេចក្ដីសុខ និងអនាគតរបស់ខ្ញុំយ៉ាងពិតប្រាកដ ខ្ញុំនឹងសម្លាប់លោក សម្លាប់ឲ្យសមនឹងការសងសឹក

អាត្មាមិនយល់នូវពាក្យរបស់គេនេះ សូម្បីតែបន្តិចសោះមិនដឹងថាគេកំពុងនិយាយអំពីរឿងអ្វី សូម្បីតែចង់សួរ

គេនៅក្នុងខណៈនោះក៏គង់មិនមានប្រយោជន៍អ្វីដែរ ព្រោះគេអាចកម្រើកម្រាមដៃរបស់គេ ធ្វើឲ្យគ្រាប់កាំភ្លើងនឹងសម្លាប់អាត្មាក្នុងមួយវិនាទីនេះក៏បាន ។ នៅពេលដែលពុំទាន់មានអ្វីនឹងអាចកែខៃខ្លឹកំចាត់ នូវមរណៈភ័យពេលនេះបាន ទើបអាត្មាប្រគល់ជីវិតឲ្យដល់ព្រះរតនត្រ័យ និងកម្មពៀរ ដោយអធិដ្ឋាននៅក្នុងចិត្តថា៖

- តាំងតែអំពីថ្ងៃដំបូង ដែលអាត្មាបាននាំខ្លួនចូលមកក្នុងអាណាចក្រនៃគាសាវពស្ត្រដ៏បរិសុទ្ធមក ខ្ញុំម្ចាស់បានប្រើនៅពេលវេលាគ្រប់វិនាទីនៅក្នុងការបដិបត្តិតាមពាក្យប្រៀនប្រដៅរបស់ព្រះបរមសាស្តា ដើម្បីសេចក្តីបរិសុទ្ធ និងការប្រៀនប្រដៅដល់ប្រជាជនឲ្យនៅក្នុងសម្មាទិដ្ឋិ មិនដែលគិតធ្វើបាបមនុស្ស ឬសត្វដទៃ ដោយកាយ វាចា ចិត្តនោះឡើយ តែបើបុរសនោះជាម្ចាស់កម្មពៀររបស់ខ្ញុំម្ចាស់មកពីជាតិមុន សូមឲ្យគេសម្លាប់ខ្ញុំម្ចាស់ទៅចុះ ខ្ញុំម្ចាស់ពេញចិត្តលះបង់នូវជីវិត ដើម្បីសងនូវកម្មចាស់ឲ្យអស់ទៅ ហើយនឹងមិនឈឺចិត្ត ចងកម្មពៀរជាមួយនឹងគេទៀតតទៅសូមឲ្យរួចគ្នាត្រឹមនេះ តែបើសិនជាខ្ញុំម្ចាស់មិនដែលបានធ្វើខុសទេ សូមឲ្យទេវតាទាំងឡាយជួយធ្វើជាសាក្សីដល់ខ្ញុំម្ចាស់ផង !

នៅពេលអាត្មាឧទ្ទិសអធិដ្ឋានចប់ហើយ ស្រាប់តែមានហេតុការណ៍មួយបានកើតឡើងគឺ មានព្រះសង្ឃមួយអង្គនិមន្តតម្រង់មករកកុដិរបស់អាត្មា ។ ព្រះសង្ឃអង្គនេះគឺលោក “វិជ្ជាណវាន់ថៈ” ដែលនៅចាំវត្តអារាមនេះ ហើយធ្លាប់មក សន្ទនាជាមួយនឹងអាត្មាជាញឹកញយនោះឯង ។

នៅពេលគេបានឃើញភិក្ខុ "វិដ្ឋារណវាន់ថៈ" បុរសចម្លែកនេះ ក៏ប្រញាប់យកគំនូរភ្លើងទៅលាក់ក្នុងអាវទុកវិញ ហើយសម្តែងនូវកិរិយាឫកពារហើតហក់ ដូចជាកើតនូវសេចក្តីខុសបំណងយ៉ាងខ្លាំង ដែលមានមនុស្សមករារាំងនូវផែនការណ៍របស់គេ ។

អាត្មាបានគួរចិត្ត ដូចជាមានមនុស្សមកលើកយកភ្នំចេញអំពីទ្រូង ដែល "ភិក្ខុវិដ្ឋារណវាន់ថៈ" មកជួយជីវិតទាន់ពេលវេលា ។ ប៉ុន្តែនៅពេលនឹងខ្លួនឡើងវិញ អាត្មាបានប្រមូលកម្លាំងចិត្ត កំចាត់នូវសេចក្តីត្រេកអរនេះចេញពីព្រោះលោកគ្រូធ្លាប់បង្រៀនអាត្មាជានិច្ចថា៖

- សេចក្តីត្រេកអរក៏ដោយ ខូចចិត្តក៏ដោយ នៅពេលកើតឡើងតែងធ្វើឲ្យចិត្តខូចគុណភាព ។ នៅពេលនឹងខ្លួនទើបលះចោលចេញ ហើយអាត្មាក៏បានបដិបត្តិតាមលោកជានិច្ចតមក

- ខ្ញុំម្ចាស់មានបញ្ហាខ្លះៗ ដែលចង់មកពិភាក្សាជាមួយនឹងព្រះអង្គ, ភិក្ខុ "វិដ្ឋារណវាន់ថៈ" ពោលឡើង នៅពេលមកឈប់នៅខាងមុខកុដិតូចរបស់អាត្មា ។ នៅពេលដែលលោកមានសន្សឹងកា ភ្នែករបស់លោកសម្លឹងជាប់នូវបុរសចម្លែកនោះរហូត, ខ្ញុំករុណាចង់សូមនិមន្តលោកទៅឯកុដិរបស់ខ្ញុំករុណាមួយភ្លែត

- ខ្ញុំករុណាកំពុងមានភ្ញៀវ! អាត្មាពោលឡើង, បើសិនជាកិច្ចការរបស់លោកមិនជាប្រញាប់ណាស់ណាទេ ខ្ញុំករុណាចង់និយាយជាមួយភ្ញៀវករុណាសិន...

អាត្មាសង្កេតឃើញថា បុរសចម្លែកនេះប្រហែលនឹកឆ្ងល់នូវពាក្យរបស់អាត្មាមិនតិចទេ ពីព្រោះគេសម្លឹងមើលមកអាត្មាដោយក្រសែភ្នែកងឿងឆ្ងល់ជាខ្លាំង

- ដូចជាប្រញាប់ផងទាន! ភិក្ខុវិជ្ជាណាភាន់ចិៈពោលឡើងមិនយូរទេទាន, ខ្ញុំកូណាសូមនិមន្តទានទៅជាមួយសិនចុះ

អាត្មាបានងាកទៅនិយាយជាមួយបុរសចម្លែក ដែលកំពុងតែអង្គុយឈ្ងោកមុខនៅស្ងៀមថា៖

- បើដូច្នេះ អាត្មាសូមចេញទៅមានធុរៈកិច្ចមួយភ្លែតសូមញោមអង្គុយចាំអាត្មានៅទីនេះចុះ អាត្មានឹងត្រឡប់មកវិញជាប្រញាប់, ពោលរួចហើយ អាត្មាក៏យកចង់ឃាមហើយក៏ទៅតាមភិក្ខុ "វិជ្ជាណាភាន់ចិៈ"

- ខ្ញុំកូណាកំពុងសរសេរនូវព្រះធម៌ សម្រាប់ចុះផ្សាយក្នុងសារព័ត៌មាន, "ភិក្ខុវិជ្ជាណាភាន់ចិៈ" ពោលឡើង នៅពេលឃើងមកដល់កុដិរបស់លោក, ហើយខ្ញុំកូណា ក៏កើតសេចក្តីសង្ស័យក្នុងព្រះធម៌មួយ ២ ទើបចង់មកសូមស្តាប់នូវទស្សនៈរបស់ព្រះអង្គ...

តអំពីនោះមក អាត្មាក៏បានអធិប្បាយនូវធម្មៈនោះទៅតាមដែលខ្លួនបានយល់បានចេះ ប្រគេនលោក វិជ្ជាណាភាន់ចិៈ លោកបានសួរបន្ថែមទៀត អាត្មាក៏បានពន្យល់អធិប្បាយលុះត្រាតែលោកពេញចិត្តអស់ហើយ ទើបអាត្មាលាត្រឡប់មកវិញ ។ នៅពេលត្រឡប់មកដល់កុដិវិញ ឃើញថាបុរសនោះបាត់ទៅណាហើយ ប្រហែលជាគេបានគិតថា អាត្មាមិនត្រឡប់មកវិញ ធ្វើជាចំណាំនៃគ្រាប់កាំភ្លើងរបស់គេទេ

មើលទៅ ទើបគេក៏រត់គេចទៅមុននោះទៅ ពីព្រោះមនុស្សទូទៅអាចនាំខ្លួនបានផុតអំពីគ្រោះថ្នាក់នេះហើយ គឺមិនមានអ្នកណាឡើយដែលនឹងវិលត្រឡប់មករកមច្ចុរាជទៀតទេ ។

នៅពេលនោះ ជាពេលាយប់ណាស់ទៅហើយ ធាតុអាកាសទូទៅស្ងប់ស្ងាត់ចិត្តវិវេក សមន្ទិការបំពេញធម៌អាថ៌ជាទីបំផុត ។ អាត្មាបានចូលទៅក្នុងកុដិចាប់យកទៀនសុទ្ធមួយដើមមកអុជ ហើយយកមកដាក់នៅក្នុងគោមសំពត់រួចយកទៅព្យួរនៅលើឈើខាងជញ្ជាំង បន្ទាប់មកក៏អង្គុយគិតមួយសន្ទុះ ស្រាប់តែបានឮសម្រិបជើងមនុស្សដើរលើស្លឹកឈើខាងៗស្រិបៗ ចេញពីបរិវេណកុដិមក ។ នៅពេលដែលស្រមោលនោះ ចូលមកដល់ខាងក្នុងកុដិត្រូវនឹងពន្លឺគោមចង្កៀង អាត្មាចាំបានថាគេនោះគឺជាបុរសចម្លែកមុននេះឯង ប្រហែលជាគេមកប្រាថ្នាសម្លាប់អាត្មាទៀតហើយ ។

- សូមទោស ដែលអាត្មាធ្វើឲ្យញោមនៅចាំអាត្មាយូរ អញ្ជើញមកអង្គុយនៅខាងលើ ! អាត្មាពោលឡើង

បុរសនោះឡើងមកអង្គុយនៅគាំងជណ្ដើរ ចំណែកអាត្មាក៏អង្គុយចុះនៅខាងមុខរបស់គេដូចកាលពីមុនដែរ ។ នៅក្រោមរស្មីនៃភ្លើងទៀន អាត្មាបានសង្កេតឃើញទឹកមុខនិងបុគ្គលិកលក្ខណៈរបស់គេបានប្ដូរផ្លាស់ទៅខ្លះៗ ប៉ុន្តែការព្រួយទុក្ខកង្វល់នៅមាននៅក្នុងចិត្តនៅឡើយ ។ កាលបើឃើញគេអង្គុយស្ងៀម អាត្មាក៏ពោលឡើងថា៖

- *អង្គុលិមាលបានត្រឡប់មកវិញហើយ បើញោមចង់ធ្វើអ្វីក៏អញ្ជើញតាមចិត្តចុះ!*

- *លោកជាមនុស្សចម្លែកបំផុត តាំងតែពីខ្ញុំកូណាបានឃើញមក! គេនិយាយឡើង*

- *ប្លែកយ៉ាងណា? អង្គុលិមាលសួរ*

- *លោកជាមនុស្សក្លាហានបំផុត មិនបានបញ្ចេញនូវសេចក្ដីភ័យខ្លាច ចំពោះសេចក្ដីស្លាប់សូម្បីតែបន្តិចឡើយ លោកចេញទៅផុតសេចក្ដីស្លាប់ហើយ នៅតែត្រឡប់មករកសេចក្ដីស្លាប់ទៀតដើម្បីរក្សានូវពាក្យសន្យា ខ្ញុំកូណាមិនដែលគិតសោះថា នឹងនៅមានមនុស្សយ៉ាងនេះទៀតក្នុងលោក ខ្ញុំកូណាធ្លាប់បានអានតែក្នុងសៀវភៅនិទាន ថ្ងៃនេះខ្ញុំកូណាបានជួបប្រទះមនុស្សពិតមែនហើយ ខ្ញុំកូណាសម្លាប់លោកមិនកើតទេ!*

*ការផ្លាស់ប្ដូរឫកពាររបស់គេ ធ្វើឲ្យអង្គុលិមាលមានចម្ងល់ក្នុងចិត្តយ៉ាងខ្លាំង អង្គុលិមាលបានសួរទៅបុរសចម្លែកនោះវិញថា*

- *តើដូចម្ដេចបានជាញោមផ្លាស់ប្ដូរចិត្ត? ក្រែងញោមតាំងចិត្តមកសម្លាប់អង្គុលិមាលមែនឬទេ?*

- *មែន! ប៉ុន្តែអំពើល្អរបស់លោក ធ្វើឲ្យខ្ញុំកូណាប្ដូរចិត្ត ខ្ញុំកូណាមិនទាន់ជាគាចសាហាវដល់ថ្នាក់ទៅសម្លាប់មនុស្សល្អដូចលោកនេះទេ*

- *ល្អហើយចុះ! បើមិនសម្លាប់អង្គុលិមាលទេក៏ល្អដែរ អង្គុលិមាលនឹងអាចមានឱកាស ធ្វើប្រយោជន៍ដល់ពិភពលោកតទៅ*

ហើយញោមក៏មិនបានធ្វើបាបចូន់ ប៉ុន្តែអាត្មាចង់ដឹងថា តើហេតុដូចម្ដេចបានជាញោមចង់មកសម្លាប់អាត្មា ចូរនិយាយរឿងរ៉ាវនេះឲ្យអាត្មាបានស្ដាប់ផងមើល

- រឿងនោះវែងសមគួរដែរ, គេក៏ចាប់ផ្ដើមនិយាយរឿង, ហើយខ្ញុំករុណាសូមរៀបរាប់ប្រគេនលោកម្ចាស់ឲ្យអស់សេចក្ដី...

- ខ្ញុំករុណាឈ្មោះ "បាន់ហាន" ជាពាណិជ្ជករនៅក្នុងស្រុកវៀងនេះឯង ក្រៅអំពីលក់ដូរហើយ នៅមានលក់កន្ទុយលេខទៀត សូម្បីជាការរកស៊ីខុសច្បាប់ ក៏ខ្ញុំករុណានៅលួចលាក់ធ្វើ ពីព្រោះជាការងាររកស៊ីស្រួល មានចំណេញច្រើន ។ នៅពេលមិនយូរប៉ុន្មានមកនេះ មានបុរសម្នាក់ឈ្មោះ "ប៉ាន់" ផ្ទះនៅលើ(ដយ) សំអាងថាបានលេខល្អអំពីព្រះសង្ឃវិសេស បានចុះទៅទិញយកទាំងអស់ដែលគេត្រូវការ ដោយប្រាក់មួយចំនួនធំ ។ ខ្ញុំករុណាបានដឹងថាគេជាមនុស្សក្រលំបាក ប៉ុន្តែដោយជឿច្បាស់នូវលេខនោះ ទើបព្យាយាមយកផ្ទះសម្បែងទៅបញ្ចាំ ហើយយកមកទិញលេខនៅកន្លែងខ្ញុំករុណា ។ ឃើញគេធ្វើដូច្នេះហើយ ទើបខ្ញុំករុណាអង្គុយញញឹម ព្រោះគិតថាគេនឹងតែចាញ់ទៀតហើយម្ដងនេះ នឹងត្រូវអស់ទ្រព្យសម្បត្តិពីខ្លួនប្រាកដពីព្រោះគេវង្វេងជឿគ្រូទាយដែលជាពិសេសខាងកន្ទុយលេខទាំងអស់នោះ ដូចគ្នាអំពីពេលមុនៗដែលគេធ្លាប់បានចាញ់លិចលង់មកហើយ ។ ប៉ុន្តែនៅពេលដែលថ្ងៃឆ្នោតចេញនោះប្រាកដឃើញថាគេត្រូវពិតៗ ទើបខ្ញុំករុណារលំដួលទាំង

ជីវិត ដោយការភ្ញាក់ផ្អើល គឺមកពីប្រាក់ដែលខ្ញុំកូណានឹងត្រូវសងឲ្យគេនោះមានចំនួនដល់ទៅសែនបាត បើសិនជាខ្ញុំកូណាសងគេ ខ្ញុំកូណានឹងមិនមានប្រាក់នៅសល់ក្នុងធនាគារទៀតឡើយ ទើបខ្ញុំម្ចាស់សម្រេចចិត្តគេចពួននៅទីនេះខ្លះ នៅទីនោះខ្លះ នៅតាមផ្ទះរបស់មិត្តភក្តិខ្លះ នៅពេលជាមួយគ្នានេះ ខ្ញុំកូណាបញ្ជូនកូនចៅឲ្យទៅស៊ើបមើលថាតើ លោកអាចារ្យវិសេសនោះគឺជានរណា នៅឯណា ស៊ើបទៅស៊ើបមកក៏បានដឹងច្បាស់ថាលោកម្ចាស់នេះឯង ខ្ញុំកូណាទើបសម្រេចចិត្តមកសម្លាប់ព្រះអង្គនេះ ពីព្រោះលោកម្ចាស់នេះជាដើមហេតុ ធ្វើឲ្យខ្ញុំកូណាបានជួបនូវសេចក្តីទុក្ខព្រួយនៅពេលនេះ ព្រោះបើលោកម្ចាស់នៅមានជីវិត លោកអាចប្រាប់អ្នកដទៃតទៅទៀត មានន័យថាលោកម្ចាស់ជាអ្នកបំផ្លាញនូវរបររកស៊ីរបស់ខ្ញុំម្ចាស់ បើសិនជាលោកស្លាប់ទៅ ខ្ញុំកូណាអាចជួបប្រទះនូវការបង់ខាតតែម្តង តទៅអាចដំណើរការបានទៀត ហេតុដូច្នេះបានជាខ្ញុំគិតសម្លាប់លោកចោល

នៅពេលដែលបានស្តាប់រឿងរបស់លោកបាន់ហានចប់ហើយ អាត្មាបាននឹកឃើញភ្លាមថា ខ្លួនឯងនេះក៏មានចំណែក ក្នុងការលំបាកលំបិននៅគ្រានោះជាមួយនឹងគេដែរ ពីព្រោះអាត្មាជាអ្នកប្រាប់លេខឆ្នោតឲ្យទៅនាយ "ប៉ាន់" ទិញ ហេតុដែលប្រាប់គេនោះ ព្រោះសេចក្តីអាណិត ឃើញគេក្រពោក ដោយមិនបានគិតមុនថានឹងមានរឿងរ៉ាវយ៉ាងនេះនឹងកើតមានឡើងដូចជាការជួយមនុស្សដោយវិត្ត ព្រោះសេចក្តី

មេត្តារបស់អាត្មា គួរតែនាំមកនូវសេចក្ដីសុខមកឲ្យនាយ "ប៉ាន់" ផ្ទុយទៅវិញ ទៅជាការនាំឲ្យខុសបំណង ព្រួយភ័យ សេចក្ដីអាឃាត ព្យាបាទ មកឲ្យដល់មនុស្សដែលទាក់ទង ច្រើនគ្នា ហើយនាំទុក្ខភ័យមកដល់ខ្លួនឯងទៀតសេចក្ដីរំភើត ចិត្តខ្លាចនៅក្នុងលោកនេះ ធ្វើឲ្យអាត្មាស្មារលាចាប់ពីពេល នេះតទៅ នឹងឈប់ជួយអ្នកណាក្នុងរឿងទ្រព្យសម្បត្តិតទៅ ទៀតហើយ និងតាំងចិត្តជួយក្នុងព្រះធម៌តែប៉ុណ្ណោះ ៗ ទុកជាយ៉ាងណាក៏ដោយ នៅពេលគិតដល់នាយ "ប៉ាន់" សេចក្ដីអាណិតក៏ត្រឡប់មកសង្កត់នូវបេះដូងអាត្មាទៀត គេ ខុសបំណងហើយកើតទុក្ខក្រៀមក្រំយ៉ាងណាទៅ ? នៅ ពេលដែលខ្លួនបានត្រូវលេខហើយគួរតែបានជួយដល់គេៗ គាលលើកទីមួយជួយគេមិនបានសម្រេចផល គួរតែជួយ តទៅទៀតលុះត្រាសេចក្ដីតាំងចិត្តឲ្យបានសម្រេច ៗ

- ដែលអាត្មាបានស្ដាប់រឿងរបស់ញោមតាំងតែពីដើម មក ល្មមនឹងយល់សេចក្ដីបានហើយ បាននិយាយថារហូតមក ដល់ពេលនេះ ញោមនៅមិនទាន់បង់ប្រាក់ទៅឲ្យនាយប៉ាន់ នៅឡើយទេ មែនទេ ? តើញោមដឹងទេថាគេនៅឯណា ពេលនេះ គេកំពុងធ្វើអ្វី ?

- គេកំពុងតែតាមសម្លាប់ខ្ញុំកូណាពិតប្រាកដ, លោក បាន់ហ៊ាន ឆ្លើយហើយក្រឡេកមើលជុំវិញគៀនៗខ្លួនដោយ សេចក្ដីភ័យខ្លាច, មិនចំពោះតែខ្លួនគេម្នាក់នោះទេ សូម្បីតែ ញាតិបងប្អូន មិត្តភ័ក្តិរបស់គេ ក៏នាំគ្នាតាមរកសម្លាប់ខ្ញុំ កូណាដែរ គេប្រកាសថា ជួបខ្ញុំកូណានៅទីណា ពេលណា

នឹងសម្លាប់ចោលភ្លាមមួយរំពេច

- មើលទៅរឿងនេះច្របូកច្របល់ល្អមើលដែរ, អាត្មាពោលឡើង, នាយ "ប៉ាន់" តាមសម្លាប់ញោម ញោមតាមសម្លាប់អាត្មា ល្អហើយចុះនៅពេលនេះញោមកំពុងធ្លាក់ចុះនៅក្នុងសេចក្ដីទុក្ខធំ មានសត្រូវតាមរកសម្លាប់ជុំវិញខ្លួន ញោមខំលាក់ខ្លួនពួនអាត្មានៅតាមផ្ទះមិត្តភក្តិ បាយមិនបានសំរាន្តមិនលក់ ត្រូវចោលប្រពន្ធ គារវការ កិត្តិយសនិងកេរ្តិ៍ឈ្មោះ អាត្មានឹកអាណិតដល់ញោមណាស់ ចង់ជួយឲ្យញោមរួចអំពីទុក្ខក្នុងពេលនេះ អាត្មាជឿថាអាចមានផ្លូវជួយឲ្យញោមផុតទុក្ខបើសិនជាញោមចូលរួមផង

- លោកម្ចាស់ តើឲ្យខ្ញុំកូណាធ្វើដូចម្ដេចទៅទាន? សូមនិមន្តប្រាប់មកចុះ បើមិនពិបាកធ្ងន់ពេកទេនោះ ខ្ញុំកូណានឹងធ្វើតាមដោយពេញចិត្ត ខ្ញុំកូណាសែនធុញទ្រាន់នឹងរឿងនេះពេញទីហើយទាន

- អាត្មាយល់ឃើញថា សេចក្ដីទុក្ខទាំងអស់នេះកើតឡើងដោយញោមមិនព្រមបង់ប្រាក់ឲ្យទៅគេ បើសិនជាញោមបង់ឲ្យគេតាំងតែអំពីពេលមុនមកទៅ ហេតុការណ៍ទាំងអស់ក៏គង់តែស្រួលបួលដោយរៀបរយ បើញោមចង់ឲ្យផុតនូវទុក្ខនៅពេលនេះ មិនមានផ្លូវឯទៀតក្រៅពីបង់ប្រាក់ឲ្យទៅគេទៅ រឿងនេះត្រូវចប់ដោយស្រួល

អាត្មាសង្កេតមើលកិរិយាឫកពាររបស់ "បាន់ហាន" នៅពេលនេះយល់ថា គេកំពុងតែធ្លាក់ចុះទៅក្នុងការពិបាកចិត្តយ៉ាងខ្លាំង គេមិនទាន់ឆ្លើយនូវសំណួររបស់អាត្មាទេ

គ្រាន់តែបញ្ចេញនូវអាកប្បកិរិយាស្រស់ស្រាយយ៉ាងខ្លាំង ហើយនិងងងស្អើមឆំ

- អាត្មាជឿជាក់ថា បើនាយ “ប៉ាន់” មិនបានទទួលប្រាក់ចំនួននេះអំពីញោមទេ គេនឹងត្រូវអស់ពីខ្លួន ពីព្រោះញោមបាននិយាយប្រាប់អាត្មាថា គេបាននាំយកផ្ទះទៅបញ្ចាំ យកប្រាក់មកលេងឆ្នោត ផ្ទះរបស់គេត្រូវគេអូស ហើយប្រពន្ធកូនគេនឹងត្រូវវេទនាអត់ឃ្លាន ចំណែកញោមវិញ បើសិនបង់ប្រាក់មួយចំនួននេះឲ្យទៅនាយ “ប៉ាន់” តើញោមនឹងធ្លាក់ខ្លួនក្រដូចជានាយ “ប៉ាន់”ដែរឬទេ ? សូមញោមប្រាប់អាត្មានូវការពិតមកមើល ?

- គឺមិនដល់អស់ពីខ្លួននោះទេទាន ! លោក បាន់ហាន ឆ្លើយដោយសម្លេងតិចៗ

- មានន័យថាញោមនៅមានប្រាក់សល់ទុកខ្លះ នៅមានហាងលក់ដូរ និងកិច្ចការលក់ទិញដែលធ្វើឲ្យមានប្រាក់កម្រៃឬចំណូលដល់ញោម នៅមានផ្ទះ មានដីរបស់ខ្លួនឯង តើមែនឬទេ ? អាត្មាសួរ

- ករុណាពិតមែន ! លោក “បាន់ហាន” ឆ្លើយ

- បើដូច្នេះ ញោមនៅមានឋានៈប្រសើរជាងនាយប៉ាន់ច្រើនរាប់រយ រាប់ពាន់ដង ។ បង់ឲ្យទៅគេទៅញោម ! នឹកដល់ចិត្តអ្នកក្រខ្សត់នេះទៅចុះ បើកាលណាញោមបានបង់ប្រាក់ឲ្យទៅគេរួចហើយ រឿងរ៉ាវគ្រប់យ៉ាងទាំងអស់អាចបានស្រួលជាប្រាកដ ហើយនាយប៉ាន់ព្រមទាំងមិត្តភក្តិនិង

ញោគិក៏ឈប់ធ្វើនូវអំពើអាក្រក់ ញោមក៏អាចវិលត្រឡប់ទៅផ្ទះរស់នៅជាមួយកូនប្រពន្ធបានយ៉ាងសុខសប្បាយ ដូចគាលពីមុន បើញោមមិនព្រមបង់ប្រាក់ឲ្យគេទេ នៅថ្ងៃមួយញោមនឹងត្រូវស្លាប់ដោយសារស្នាដៃរបស់គេ បើមិនទាន់ស្លាប់ទេ គឺត្រូវរត់គេចឰនៗយ៉ាងនេះឯង អស់សេរីភាពអស់សេចក្តីសុខ ព្រាត់កូនប្រពន្ធ ខូចកិច្ចការ ត្រូវមនុស្សគេស្អប់ គេប្រទេចផ្តាសា សូម្បីតែញោមត្រឡប់ទៅបន្តកិច្ចការដូចមុន ក៏គ្មាននរណាគេជឿទុកចិត្តញោមទៀតហើយ គឺញោមនេះហើយជាអ្នកបំផ្លាញនូវមុខរបរ និងអនាគតរបស់ញោមដោយខ្លួនឯង មិនមែនជាអាត្មាទេ សូមឲ្យញោមគិតឲ្យមែនទែន ថាតើញោមសុខចិត្តបង់ប្រាក់ឬបង់ជីវិត?

លោក "បាន់ហាន" អង្គុយសម្លឹងមើលមកអាត្មាមួយភ្លែត រួចហើយក៏ឱនចុះមកក្រាបជិតជើងអាត្មា ព្រមទាំងពោលដោយសម្លេងញ័រៗថា៖

- លោកម្ចាស់! ធម៌ទេសនារបស់លោកម្ចាស់ធ្វើឲ្យខ្ញុំកើតមានពន្លឺភ្លឺស្វាងចេញមក ឲ្យចិត្តមើលឃើញហេតុការណ៍ភ្លឺថ្លាស្រឡះទាំងអស់ តើដូចម្តេចហ្ន៎ពេលពីដំបូងខ្ញុំកូណាម្ចាស់នឹកគិតមិនឃើញដូច្នេះ បើខ្ញុំកូណាម្ចាស់គិតឃើញយ៉ាងនេះ សេចក្តីទុក្ខព្រួយគង់មិនកើតឡើងទេ ខ្ញុំសូមក្រាបលាលោកម្ចាស់ហើយ សូមអរព្រះគុណដល់លោកម្ចាស់មួយពាន់ដង ដែលបាននឹកនាំខ្ញុំកូណាឲ្យចូលដល់ផ្លូវត្រូវ បើមិនបានជួបលោកម្ចាស់ទេ ប្រហែលជាខ្ញុំកូណាត្រូវទទួលនូវទុក្ខទោសព្រួយ តទៅទៀតពីងឆ្ងាយ

ស្អែកនេះខ្ញុំករុណានឹងទៅទាក់ទងជាមួយនាយប៉ាន់ ណាត់គេឲ្យមកទទួលយកប្រាក់នេះទៅ ខ្ញុំករុណាសូមក្រាបថ្វាយបង្គំសូមអភ័យទោសអំពីព្រះអង្គផង ដែលបានធ្វើនូវអំពើមិនសមគួរដល់ព្រះអង្គនៅពេលដំបូងនោះ ពីព្រោះនៅពេលនោះ ខ្ញុំម្ចាស់ត្រូវសេចក្ដីក្រោធគ្របសង្កត់ស្ទើរតែទៅជាឆ្កួតទៅហើយ

- អាត្មាពេញចិត្តនឹងឲ្យនូវការអភ័យទោសដល់ញោមហើយសូមជួយអនុមោទនា ដែលញោមបានប្រែគំនិតតែកុំភ្លេចថា ដើមហេតុធំនៃសេចក្ដីពិបាកខ្វល់ទាំងអស់នេះ នៅត្រង់ដែលញោមបានធ្វើជាមេលក់គន្លុយលេខឆ្នោត តែបើសិនជាញោមឈប់លេងឬធ្វើមេឆ្នោតនេះទៅ ញោមនឹងរកមករកនូវមុខរបរផ្សេងៗដែលសុចរិតតទៅ នោះអាត្មាសូមអនុមោទនាខ្លាំងឡើងទៀត បើញោមមិនព្រមបញ្ឈប់ទេសេចក្ដីពិបាករវល់នោះ នឹងកើតឡើងទៀតជាពិតប្រាកដនៅថ្ងៃណាមួយជាមិនខាន

- នាយបាន់ហាន ទទួលនូវពាក្យរបស់អាត្មាដែលបានដាស់តឿនទុកពិចារណា ហើយក៏ក្រាបលាចេញទៅ...

# ឈ្នះ

**ពាក្យប្រាំពីរ**

*ឈ្នះក្រោធដោយការមិនតបត ឈ្នះអាក្រក់ដោយល្អគ្រប់វេលា*
*ឈ្នះជនចិត្តបាបមិនល្អជា ដោយមិនចងពៀរបន្តកម្ម ។*
*ឈ្នះជនពាលាអសប្បុរស ដោយធម៌សប្បុរសជាប្រចាំ*
*ឈ្នះជនមុសាពោលសាំញ៉ាំ ដោយការអត់ទ្រាំមិនតបស្តី ។*
*ឈ្នះជនកំណាញ់មិនធ្វើទាន ដោយចិត្តប្រោសប្រាណឲ្យយប់ថ្ងៃ*
*ឈ្នះកិច្ចការងារដោយខន្តី ឈ្នះលូង់ក្រក្រីដោយព្យាយាម ៕*

ដោយឧបាសក ម៉ិញ សាវ៉ាង

# កុំឲ្យខុសទៀត

**ពាក្យបួន**

*បើធ្វើខុសហើយ កុំឲ្យខុសទៀត*
*ត្រូវព្យាយាមឆ្លៀត លះចោលកំហុស*
*ត្រូវខំរៀនយល់ ឲ្យស្គាល់គុណទោស*
*កុំធ្វើជាមនុស្ស រស់ទម្ងន់ដី ។*

ដោយឧបាសក ម៉ិញ សាវ៉ាង

# ១៥. កុំឲ្យអភ័យទោសដល់ខ្លួនឯង

យប់ថ្ងៃនោះ ក្រោយពេលដើរចង្ក្រម ដើរទៅដើរមករវាងដើមបេងពីរដើមក៏ហត់ទៅហើយ ។ អាត្មាក៏ត្រឡប់មកអង្គុយសម្រាកនៅសំយ៉ាបកុដិតូច នៅពេលកំពុងអង្គុយនោះ ពាក្យប្រៀនប្រដៅរបស់លោកគ្រូអាចារ្យ ក៏បានកើតកម្រើកឡើងនៅក្នុងចិត្តម្តងទៀត ។ លោកធ្លាប់បង្រៀនថា នៅពេលឈានចូលទៅក្នុងទីកន្លែងណាជាដំបូង បានដឹងថាកក់ក្តៅហើយស្រួលនៅពេលនោះភ្លាម ត្រូវយល់ថា កាលពីជាតិមុន ជាតិណាមួយ យើងធ្លាប់កើតឬនៅទីនោះមកពីកាលមុន បើជាព្រៃយើងធ្លាប់កើតជាសត្វឬអារក្សទេវតានៅក្នុងទីនោះ ។ បើសិនជាផ្ទះ យើងធ្លាប់កើតជាមនុស្សធ្លាប់នៅទីនោះ បើដូច្នោះមិនគួរនៅយូរទេ ពីព្រោះធ្វើឲ្យយើងកើតការជាប់ជំពាក់ក្នុងទីកន្លែង ជាប់ក្នុងបុគ្គល ជាឱកាសដែលធ្វើឲ្យសេចក្តីកង្វល់ចិត្តទាក់ទងនូវផ្លូវពេលវេលា ថាតើអាចដើរទៅដល់ទីដៅដែរឬទេ ដែលបានកំណត់ទុក ? ធ្វើឲ្យខូចសេរីភាព និងសេចក្តីសុខសប្បាយខាងផ្លូវចិត្ត ហេតុដូច្នេះទើបអាត្មាមិនមានកំណត់ផ្លូវ មិនគិតពេលវេលា គិតតែដើរទៅមុខជានិច្ច ដូចជាដុំពពកបេះតែអណ្តែតទៅតាមផ្ទៃមេឃ

នៅពេលរសៀល អាត្មាបានដើរមកដល់ផ្លូវចាក់កៅស៊ូមួយខ្សែ ទើបកាត់ចិត្តដើរតាមផ្លូវនេះតម្រង់ទៅទិសខាងលិច ។ គំរស្មីនៃព្រះអាទិត្យនាពេលអស្តង្គតមានកម្តៅ

គួរសមដែរ ប៉ុន្តែនៅត្រជាក់ជាងភ្លើងកិលេស ដែលដុតចិត្តមនុស្ស ។ ធាតុអាកាសក្តៅ ធ្វើឲ្យអាត្មាស្រេកទឹក ប៉ុន្តែគ្មានឃើញកន្លែងណាមានទឹកសោះ អាចធ្វើឲ្យឃើញច្បាស់ឡើងថា ការស្រេកទឹកក៏ជាទុក្ខមួយដែរ ប៉ុន្តែនៅចាញ់សេចក្តីស្រេករបស់មនុស្សដោយតណ្ហា ។

អាត្មាបានឈប់សម្រាកនៅក្រោមដើមឈើមួយ ដែលនៅជិតថ្នល់ ពីព្រោះឲ្យជង្គង់បានចាប់ផ្តើមឈឺដោយការធ្វើដំណើរឆ្ងាយនោះ ឲ្យបានសម្រាកបន្តិច ។ ក្នុងពេលសម្រាកនេះ ក៏មិនបណ្តោយឲ្យវេលាហួសទៅដោយឥតប្រយោជន៍ ពីព្រោះលោកគ្រូអាត្មាបានបញ្ជាក់យ៉ាងច្បាស់លាស់ថា ទ្រព្យសម្បត្តិគ្រប់យ៉ាងក្នុងលោកនេះ សូម្បីនឹងរលាយសាបសូន្យទៅក៏ដោយ នៅមានពេលត្រឡប់មកវិញ ប៉ុន្តែពេលវេលានៃជីវិតបើផុតហួសទៅហើយ គ្មានផ្លូវនឹងបានត្រឡប់មកវិញទេ ដូច្នេះកុំបណ្តោយឲ្យពេលវេលាហួសទៅទទេៗ ដោយមិនបានធ្វើប្រយោជន៍ឲ្យខ្លួន និងអ្នកដទៃ ។ ប្រយោជន៍តែងជូនដល់អ្នកធ្វើគ្រប់វិនាទី ឲ្យបានជាប្រយោជន៍ បើធ្វើតាមផ្លូវកាយមិនបាន ចូរធ្វើតាមផ្លូវវាចា បើសិនធ្វើតាមវាចាមិនបាន ចូរធ្វើតាមផ្លូវចិត្ត គឺនឹកគិតក្នុងរបស់ដែលល្អ មានប្រយោជន៍ ។ លោកគ្រូអាចារ្យធ្លាប់ពន្យល់ថា បើមិនមានអ្វីនឹងធ្វើតាមកាយ វាចា ចិត្ត ហើយមិនចង់ធ្វើអ្វី ចូរចាប់យកសៀវភៅសុភាសិតមកបើកអាន ប្រទះសុភាសិតត្រង់ណាល្អ ឲ្យអានហើយអានទៀតនូវសុភាសិតនោះ លុះត្រាតែចាំបាន ហើយពិចារណា និងធ្វើឲ្យកើតសេចក្តីដឹងយល់ទាក់ទងនឹង

ជីវិតបានច្រើន ពីព្រោះឃ្លាក្នុងសុភាសិតនីមួយៗ លោកអ្នកប្រាជ្ញបានគិតគាត់តែងឡើង គឺដោយការយល់របស់លោកផ្ទាល់ហើយ របស់ដទៃដែលបានពិចារណាយ៉ាងល្អិតល្អន់ហ្មត់ចត់ អស់រយៈពេលយ៉ាងយូរ លុះត្រាប្រាកដច្បាស់ក្នុងចិត្តថាជាការពិតត្រឹមត្រូវល្អហើយ ទើបចងក្រងជាសុភាសិតឡើង ទុកបង្រៀនកូនចៅជំនាន់ក្រោយ ។ សុភាសិតផ្សេងៗ សូម្បីជាពាក្យពេចន៍ខ្លីៗ ប៉ុន្តែបានបញ្ជាក់នូវសេចក្តីពិតរបស់ជីវិត របស់សង្គមមនុស្ស និងការពិសោធន៍របស់លោកទុកក្នុងហ្នឹងទាំងអស់ ដូច្នេះនៅពេលដែលបានជួបនូវសុភាសិតផ្សេងៗ កុំមើលរំលងចោល ចូរយកមកពិចារណាឲ្យបានល្អិតល្អន់ នឹងបានជួបនូវសេចក្តីចេះដឹងប្រហាក់ប្រហែលនឹងសៀវភៅធំៗទាំងនោះដែរ ។ តាំងតែអំពីពេលនោះមក ទើបអាត្មាចូលចិត្តនូវសុភាសិតផ្សេងៗ ទើបយកសៀវភៅតូចៗ ដែលបានដកស្រង់អំពីសុភាសិតផ្សេងៗដាក់ជាប់តាមខ្លួន ពេលជួបប្រទះនូវសុភាសិតល្អៗ មិនថារបស់ជាតិណាឬភាសាណាទេ ត្រូវតែសរសេរទុកក្នុងកូនសៀវភៅនោះភ្លាម នៅពេលទំនេរក៏ដកចេញមកអាន ហើយពិចារណា ។ វិធីអានមិនបាច់បើកតាំងតែពីទំព័រដំបូងនោះទេ បើកត្រូវត្រង់ណាចាប់អានត្រង់នោះតែម្តង ហើយក៏ចាប់ផ្តើមពិចារណានូវសុភាសិតនោះទៅ ។ នៅក្នុងពេលនេះ អាត្មាចាប់យកកូនសៀវភៅនោះចេញពីថង់យាមមកបើកអាន ក៏ជួបប្រទះនឹងសុភាសិតជាភាសាអង់គ្លេសមួយបទថា៖ “Forgive others but yourself never” ដែលប្រែមកថា “**ចូរអ្នកឲ្យអភ័យដល់អ្នក**

**ដទៃ តែកុំឲ្យអភ័យដល់ខ្លួនឯងជាដាច់ខាត** ” ។ អាត្មាចាប់ផ្ដើមត្រិះរិះពិចារណា នូវសាច់រឿងរបស់សុភាសិតនោះភ្លាម ។ សុភាសិតបទនេះ មានន័យក្នុងផ្លូវបង្រៀនធ្វើចិត្តឲ្យបានល្អ ពីព្រោះមនុស្សយើងគ្រប់គ្នា តែងមានសេចក្ដីស្រឡាញ់ខ្លួនជាមូលដ្ឋានជានិច្ច សមដូចពាក្យរបស់ព្រះសម្មាសម្ពុទ្ធមួយឃ្លាថា៖ **នត្ថិ អត្ត សមំ បេមំ** ដែលប្រែថា **សេចក្ដីស្រឡាញ់ស្មើដោយខ្លួនមិនមាន** ។ នៅពេលមនុស្សស្រឡាញ់ខ្លួន តែងតែចូលខាងខ្លួន ឃើញតែខ្លួនឯង នៅពេលខ្លួនធ្វើការអ្វីបន្តិចបន្តួច ចង់ឲ្យអ្នកដទៃទទួលស្គាល់ ចង់បានមុខមាត់ ចង់ឲ្យគេសរសើរ ផ្ទុយទៅវិញ បើខ្លួនបានធ្វើអ្វីមិនល្អ ធ្វើអំពើអាក្រក់ហើយ ត្រឡប់ជាមិនចង់ទទួលស្គាល់នូវអំពើអាក្រក់នោះ បើទទួលវិញប្រកាន់ខុសបន្តិចបន្តួច ហើយឲ្យគេអភ័យដល់ខ្លួនឯងយ៉ាងងាយ ។ មានអ្នកខ្លះមិនត្រឹមតែមិនទទួលនូវកំហុសដែលខ្លួនបានធ្វើហើយនោះទេ ថែមទាំងបោះឬទម្លាក់កំហុសដែលខ្លួនបានធ្វើហើយនោះទៅឲ្យអ្នកដទៃថែមទៀត ធ្វើឲ្យកើតមានពាក្យសម្ដីឡើង ឈ្លោះប្រកែកដាក់កំហុសគ្នា ទើបអ្នកប្រាជ្ញលោកចងក្រងជាសុភាសិតនេះឡើង ដើម្បីបង្រៀនដល់មនុស្សឲ្យព្យាយាម ឃ្លាំមើលនូវកំហុសរបស់ខ្លួនជានិច្ច បើបានឃើញនូវកំហុសរបស់ខ្លួនហើយ សូម្បីបន្តិចបន្តួច ក៏កុំគិតថាជារឿងតូចតាច សូមឲ្យគិតថាជារឿងធំ ហើយត្រូវព្យាយាមរកវិធីដោះស្រាយនិងលាងជម្រះ ទើបធ្វើឲ្យមនុស្សបានល្អឡើង បានស្អាតបរិសុទ្ធ ពីព្រោះដូចជាលាងជម្រះនូវរបស់ស្មោកគ្រោកចេញ អំពីមនុស្សគ្រប់ៗពេល

ដែលមានរបស់ស្នេហាគ្រោគមកប៉ះត្រូវខ្លួន ។ ផ្ទុយទៅវិញ បើខ្លួនបានធ្វើខុសហើយមិនព្រមទទួលខុស ឲ្យអភ័យដល់ខ្លួនឯង ស្មើនឹងមិនព្រមលាងនូវរបស់ស្មោកគ្រោកចេញអំពីខ្លួន សេចក្តីស្មោកគ្រោកនោះ នឹងបន្ថែមឡើងគ្រប់ពេល លុះត្រាតែក្លាយទៅជាគំនរសេចក្តីស្មោកគ្រោក ស្អុយមិនមាននរណាចង់ចូលទៅជិតឬក្បែរ មិនចង់សេពគប់ជាមួយ ។

នៅពេលដែលអាត្មាកំពុងអង្គុយគិតនូវវិសុភាសិតនោះ មានគំនិតមួយបានកើតឡើង គឺគិតថា បើសិនជាមានរថយន្តឈ្នួលមក នឹងសូមគេជិះទៅផង អាចធ្វើឲ្យការហត់នឿយនេះបានសម្រាកសម្រាន្តខ្លះ ៗ គិតដូច្នេះហើយក៏អង្គុយរង់ចាំរថយន្ត ហើយនឹងពិចារណាត្រិះរិះសុភាសិតបណ្តើរៗទៅ ។

មួយសន្ទុះធំកន្លងផុតទៅ ត្រចៀកអាត្មាបានឮសូរសម្លេងរថយន្តបរមកអំពីចម្ងាយអំពីទិសខាងត្បូង សប្បាយចិត្ត ក៏ប្រញាប់រូតរះដើរចេញមកឈរលើចិញ្ចើមថ្នល់ ហើយលើកដៃបក់ជាសញ្ញាឲ្យរថយន្តឈប់ តាមតែធ្លាប់ធ្វើមក ។ តែអាត្មាសង្កេតឃើញថា រថយន្តនេះមិនបានបន្ថយល្បឿនដើម្បីឈប់ទទួលអាត្មាទេ វាបើកហួសទៅយ៉ាងលឿន ។ អាត្មាសង្កេតឃើញថារថយន្តនេះមានផ្ទុកមនុស្សពេញណែន សូម្បីតែនៅលើដំបូលក៏ផ្ទុកពេញដែរ ពោរ-ពេញទៅដោយអីវ៉ាន់ផ្សេងៗនោះ ក៏ជាហេតុមួយដែលឲ្យគេមិនព្រមឈប់ទទួលអាត្មាដែរ ពីព្រោះពិបាកនឹងរកកន្លែងឲ្យព្រះសង្ឃគឺមិនមែនជាការងាយទេ ដូច្នេះអ្នកបើកបរខ្លះទើប

មិនចង់ទទួលព្រះសង្ឃ ។ អាត្មាក៏ត្រឡប់មកអង្គុយនៅក្រោមដើមឈើនោះវិញ នៅរង់ចាំរថយន្តផ្សេងៗតទៅទៀត ការស្រេកទឹកកាន់តែខ្លាំងឡើងៗ លុះត្រាស្ងួតក ហើយទឹកមាត់ក៏ស្អិត ។

មួយសន្ទុះធំក្រោយមក មានរថយន្តឈ្នួលមួយមកទៀតអំពីទិសខាងត្បូង អាត្មាក៏ប្រញាប់ចេញទៅឈរជិតថ្នល់បក់ដៃជាសញ្ញាម្តងទៀត តែរថយន្តនោះបានបើកហួសទៅទៀតដោយមិនមានក្តីអាណិតអាសូរបន្តិចសោះ សូម្បីនៅលើរថយន្តនោះមានមនុស្សជិះមិនច្រើនផងក៏ដោយ ។ អាត្មានឹកអន់ចិត្តបន្តិចបន្តួចកើតឡើងក្នុងចិត្តដែរ ប៉ុន្តែនៅពេលមានសតិត្រឡប់មកវិញ ក៏ប្រញាប់រម្ងាប់អារម្មណ៍នេះចេញភ្លាម ដោយគិតថា យើងជាអ្នកដទៃ មិនមែនជាម្ចាស់របស់គេ បើសិនជាម្ចាស់របស់គេវិញនោះ គេនឹងឈប់ទទួលភ្លាមគិតដូច្នេះហើយ អាត្មាចូលមកអង្គុយទ្រាំនឹងសេចក្តីស្រេកទឹកនៅក្រោមដើមឈើតទៅទៀត ។

ពេលវេលាបានកន្លងហួសទៅ ប្រហែលជាកន្លះម៉ោងក៏បានឮសម្លេងរថយន្តលេចចេញពីទិសខាងត្បូងមកទៀត ។ អាត្មាចេញមកឈរនឹងបក់ដៃដូចមុនទៀត តែនៅពេលនេះធ្វើៗទៅដោយមិនមានសេចក្តីសង្ឃឹមទេ ពីព្រោះរថយន្តពីរហើយដែលបានបើកហួសទៅ ធ្វើឲ្យអាត្មាបានមេរៀនមួយថា ៖ ការប្រាថ្នារបស់ណាមួយ បើខុសបំណងតែងតែកើតទុក្ខដូច្នេះ ចូរធ្វើអំពើល្អជានិច្ច បើបានសម្រេចក៏ល្អ បើជាខុសបំណងក៏កុំកើតទុក្ខ ពីព្រោះយើងមិនបានប្រាថ្នាទុកជាមុនទេ

តែមានរបស់ខ្លះយើងមិនបានប្រាថ្នាទុកទេតែបានកើតឡើង.. ពេលនោះស្រាប់តែរថយន្តនោះឈប់នៅមុខអាត្មា ហើយក្មេងលក់សំបុត្រចុះមកជួយអាត្មា យកបាត្រ យកក្រូតឡើងទៅលើរថយន្ត ។ នៅពេលអាត្មាបានអង្គុយនៅខាងក្រោយរថយន្តហើយ រថយន្តក៏បានបើកចេញទៅ ។ សង្កេតឃើញថា អ្នកដំណើរនៅអង្គុយខាងមុខមិនច្រើនទេ ទើបគេអាចឈប់ទទួលអាត្មាបាន ។

នៅពេលមួយសន្ទុះធំមក ក្មេងយកប្រាក់ពីរនាក់ធ្វើដំណើរមកឈប់ឈរនៅខាងមុខអាត្មា ហុចដៃមកទារយកថ្លៃជិះ អាត្មានឹកភ័យបន្តិចបន្តួចដែរ ពីព្រោះគ្មានប្រាក់បង់ថ្លៃឈ្នួល ហើយមិនបានគិតថា គេនឹងយកថ្លៃជិះអំពីព្រះសង្ឃ ពីព្រោះអាត្មាធ្លាប់សូមជិះតាមផ្លូវជាច្រើនដងមកហើយ នៅតាមស្រុកខេត្ត មិនដែលបង់ប្រាក់ថ្លៃយានជំនិះទេ ពីព្រោះគេមិនដែលយកថ្លៃជិះអំពីព្រះសង្ឃ ។

ដោយអាត្មាមិនមានប្រាក់ជាប់នឹងខ្លួនមកសោះ អាត្មាបាននិយាយជាមួយក្មេងទារប្រាក់នោះថា ៖

- សូមអាស្រ័យធ្វើដំណើរទៅទទេរបានឬទេ? ទៅមិនជាឆ្ងាយទេ នៅពេលទៅដល់ភូមិគេខាងមុខ ឬបើមានអ្នកឡើងជិះច្រើន អាត្មានឹងចុះភ្លាម!

ក្មេងដែលដើរទារប្រាក់ឈ្នួលនោះ ឈរសម្លឹងមើលមកអាត្មា ដោយក្រសែភ្នែកមិនពេញចិត្តចំពោះអាត្មាមួយសន្ទុះ ហើយក៏ត្រឡប់ទៅខាងមុខ គេឱនមុខទៅនិយាយជាមួយអ្នកបើកបរមួយសន្ទុះ រថយន្តក៏បន្ថយល្បឿនយឺតៗ

ហើយក៏ឈប់ង៉ក់នៅខាងផ្លូវ ។ ក្មេងដើរទារប្រាក់បានដើរមកឈរជិតអាត្មា ហើយពោលយ៉ាងខ្ទេងខ្ទើងថា៖

- សូមនិមន្តលោកម្ចាស់ចុះពីឡាន!

អាត្មាសម្លឹងមើលមុខគេដោយឆ្ងល់ ហើយក៏ស្រវាយកបាត្រ និងក្រុតដើរចុះពីរថយន្ត ។ នៅពេលដែលអាត្មាកំពុងឈរនៅជណ្តើររថយន្ត ជើងម្ខាងឈានចុះសឹងតែមិនទាន់ដល់ដីផង រថយន្តក៏បើកចេញទៅដោយកញ្ជ្រក់យ៉ាងខ្លាំង ធ្វើឲ្យអាត្មាធ្លាក់ធ្លាក់ចុះពីរថយន្ត ដួលដេកទៅលើថ្នល់ បាត្រនិងក្រុត បានធ្លាក់នៅលើថ្នល់ផ្សេងៗពីគ្នា ។ អាត្មាខំក្រោកឡើងបោសធូលីចេញពីចីពរ សម្លឹងមើលពីក្រោយរថយន្តនោះ ដោយសេចក្តីក្រោធពុះចេញមកពីក្នុងចិត្តដោយអត្តនោម័តិ តែនៅពេលមានសតិមកវិញ អាត្មាខឹតខំព្យាយាមរម្ងាប់វាចេញ ដោយគិតថា ការដែលគេដេញអាត្មាឲ្យចុះអំពីរថយន្តគេនោះ ជាការធ្វើដោយមានហេតុមានផលហើយ ពីព្រោះគេត្រូវការប្រាក់នាំយកទៅចិញ្ចឹមកូនប្រពន្ធញាតិមិត្រនិងខ្លួនឯង ។ នរណាមានប្រាក់ឲ្យគេ គេពេញចិត្តនឹងទទួលអ្នកនោះដោយរីករាយ អ្នកណាមិនមានប្រាក់បង់ថ្លៃជិះនោះទេ គេក៏មានសិទ្ធមិនទទួលឲ្យជិះ បើនៅតែឡើងជិះហើយគ្មានប្រាក់បង់ទេនោះ មានន័យថាធ្វើខុសនូវសិទ្ធរបស់គេ គេអាចមានសិទ្ធដេញឲ្យចុះពីរថយន្តរបស់គេគ្រប់ពេល ។ ដូច្នេះការដែលអាត្មាត្រូវគេដេញឲ្យចុះនេះ ព្រោះមិនបង់ប្រាក់ថ្លៃរថយន្តឲ្យគេ ទើបគេធ្វើយ៉ាងនេះជាការសមគួរហើយ ។ នៅពេលដូច្នេះហើយ សេចក្តីក្រោធខឹងក៏បាន

ចេយចុះ តែនៅមិនទាន់អស់ស្លើងទេ ពីព្រោះនៅគិតដល់ហេតុការណ៍ដែលគេជេញអាត្មាឲ្យចុះយ៉ាងទារុណ ឲ្យអាត្មាធ្លាក់អំពីរថយន្ត ដែលធ្វើដោយមិនមានហេតុផល មិនគួរលើកទោសបានទេ ។ ប៉ុន្តែអាត្មាបានព្យាយាមរម្ងាប់នូវសេចក្តីក្រោធដែលនៅសេសសល់បន្តិចបន្តួច ដោយគិតថាគេបានធ្វើដូច្នេះដោយចេតនា គឺសម្គាល់ថាគេជាមនុស្សអាក្រក់ ចិត្តថ្លើមរបស់គេត្រូវលោភៈ ទោសៈ មោហៈ គ្របសង្កត់ទើបជាចិត្តខ្វាក់ងងឹត ។ បើការធ្វើនូវអំពើអាក្រក់មានផលជាទុក្ខពិតមែន គេកំពុងតែដើរទៅរកសេចក្តីទុក្ខ ប្រៀបដូចជាមនុស្សខ្វាក់ ដែលកំពុងតែធ្វើដំណើរទៅរកជ្រោះជ្រៅបើសិនជាគេភ្លេចសតិ ដើរមកជាន់ជើងរបស់យើងហើយតើយើងគួរខឹងនឹងគេ ឬគួរអាណិតគេ ឲ្យអភ័យទោសដល់គេគ្រប់ៗគ្នា ជាជាងប្រកាន់ទោសពៃរ៍គេ ? អាត្មាពោលជាមួយខ្លួនឯងថា ៖ "Forgive others but yourself never" ហើយក៏រៀបទុកបាត្រ និងក្រនូតចេញដើរតាមផ្លូវតទៅទៀតដោយបានតាំងចិត្តថាឈប់សូមដោយសាររថយន្តណាទៀតហើយ ។

# ខ្វាស !!!

**ពាក្យបួន**

| | | |
|---|---|---|
| ខ្វាសលោភទើបបាន | ចែកទានលះធន | |
| ខ្វាសទោសៈមុន | ទើបមានមេត្តា | |
| ខ្វាសមោហៈល្ងង់ | ប្រុងរកវិជ្ជា | |
| ខ្វាសជនពាលា | ស្វែងរកបណ្ឌិត | ។ |
| ខ្វាសបុណ្យខ្លាចបុណ្យ | ចិត្តទន់ទៅបាប | |
| ខ្វាសបាបខ្លាចបាប | ចិត្តឆាបរកបុណ្យ | |
| ខ្វាសចិត្តមក្ខៈ | ពិតដាក់ឃើញគុណ | |
| ខ្វាសភាពទំរន់ | ធុននឹងការងារ | ។ |
| ខ្វាសអាក្រក់បានល្អ | ខ្វាសក្របានមាន | |
| ខ្វាសល្ងង់ខំរៀន | ទើបមានវិជ្ជា | |
| ខ្វាសខ្ជិលធ្វើចិត្ត | ឲ្យគិតឧស្សាហ៍ | |
| ខ្វាសចិត្តឥច្ឆា | មានការសន្តោស | ៕ |

ដោយឧបាសក មុិញ សារ៉ាង

# ១៦. កល្យាណមិត្ត

កាំរស្មីដ៏ទារុណនៃព្រះអាទិត្យនាពេលរសៀល ផ្លូវថ្នល់ក្ដៅហែង ធាតុអាកាសដ៏ធ្ងន់ធ្ងរហើយស្អុះស្អាប់ ថែមទាំងសេចក្ដីស្រេកទឹកដែលផ្ដល់នូវសង្សារ បានទទួលសេចក្ដីទុក្ខវេទនាគ្រប់ពេលវេលា ធ្វើឲ្យអាត្មាឃើញច្បាស់ខ្លាំងឡើងថា ខន្ធប្រាំគឺសេចក្ដីទុក្ខ ជីវិតរាងកាយគឺផ្ទុំនៃសេចក្ដីទុក្ខយ៉ាងធ្ងន់ដែលយើងត្រូវលីស្ពាយដើរទៅក្នុងវដ្ដៈ ហើយនិងលះចោលបាន ក៏លុះត្រាដល់ទ្វារនៃព្រះនិព្វាន ។ នៅពេលដែលកំពុងត្រូវភ្លើងទុក្ខដុតនូវចិត្តនោះឯង ចិត្តរបស់អាត្មាបាននឹកគិតដល់ពាក្យប្រៀនប្រដៅ របស់លោកគ្រូអាចារ្យម្ដងទៀត ។ លោកគ្រូធ្លាប់បង្រៀនថា សេចក្ដីទុក្ខ នូវប្រការផ្សេងៗដូចជារងា ក្ដៅ ឃ្លាន ស្រេក ឈឺបន្ទោរបង់តូចធំ ឈឺចាប់តាមខ្លួន ហេវហត់ ឈឺចាប់ទៅតាមរាងកាយរហូតដល់ចាស់ ឈឺ ស្លាប់ ជាការធម្មតាដែលមាននៅប្រចាំក្នុងសង្សារទាំងពួង សូម្បីតែសង្សាររបស់ព្រះបរមសាស្ដាសម្មាសម្ពុទ្ធក៏ត្រូវចាស់ ត្រូវឈឺ ត្រូវស្លាប់ ដូចគ្នានឹងសង្សាររបស់សាមញ្ញជនគ្រប់គ្នា គ្រាន់តែខុសគ្នាថា ពេលសង្សារជាទុក្ខ ព្រះទ័យរបស់ព្រះអង្គមិនជាទុក្ខទៅជាមួយ, នៅពេលសង្សារស្រេកឃ្លាន ព្រះទ័យរបស់ព្រះអង្គមិនស្រេកឃ្លាន, នៅពេលសង្សារហត់នឿយ ព្រះទ័យរបស់ព្រះអង្គមិនរុញរា នៅពេលសង្សារឈឺចាប់ ព្រះទ័យរបស់ព្រះ

អន្តមិនឈឺចាប់ជាមួយ ពីព្រោះហេតុអ្វី ? ព្រោះថាព្រះអង្គទ្រង់ផ្ចិតនូវអនត្តានុទិដ្ឋិ សេចក្តីយល់ថាខន្ធ ៥ ជាតួខ្លួនជារ ដាច់ខាតហើយ ទ្រង់ឃើញច្បាស់ថា សង្ខាររាងកាយគ្រាន់តែសភាវធម៌បានកើតឡើងចាស់ទៅ ហើយក៏រលត់ទៅតាមសភាពរបស់វា ដូចគ្នានឹងសង្ខារទាំងឡាយក្នុងសាកលចក្រវាល មិននៅក្រោមអំណាចរបស់នរណាម្នាក់ឡើយ មិនមែនរបស់អ្នកណា ព្រះអង្គទ្រង់រង់ចាំមើលការកើតការឈឺ ការស្លាប់ និងសេចក្តីទុក្ខនៃសង្ខាររបស់ព្រះអង្គឯងដោយព្រះទ័យដែលស្ងប់សុខ ដូចនឹងបុរសដែលអង្គុយលើច្រាំង ហើយសម្លឹងមើលក្រសែទឹកក្នុងទន្លេ ដែលហូរទៅមិនឈប់ តាមសភាពរបស់វា មិនជាទុក្ខ មិនក្តៅក្រហាយមិនក្រវល់ក្រវាយយ៉ាងណាឡើយ ។

ចំណែកជនសាមញ្ញ ជាអ្នកពោរពេញទៅដោយសក្កាយទិដ្ឋិដោយអត្តានុទិដ្ឋិ នៅឃើញថាខន្ធ ៥ ជាខ្លួន ជាខន្ធ ៥ ៗជារបស់ខ្លួន ហើយប្រកាន់យកទុកដោយឧបាទាន នៅពេលខន្ធ ៥ ស្រេកឃ្លាន ហត់នឿយ ឈឺ តែងស្រេកឃ្លាន ហត់នឿយ ឈឺជាមួយ គេមិនដឹងការពិត ប្រកាន់ថាជីវិតរាងកាយជារបស់នៃខ្លួន ទើបប្រាថ្នាចង់ឲ្យសង្ខារប្រព្រឹត្តទៅតាមអំណាចរបស់ខ្លួន ។ នៅពេលសង្ខារទាំងឡាយមិនដូចប្រាថ្នា តែងទៅតាមផ្លូវរបស់វាយ៉ាងពិតប្រាកដ គេតែងតែខុសបំណង ទៅជាកើតទុក្ខ ក្តៅក្រហាយយំសោកខូចចិត្ត សោកសៅ ដូចជាទារកមិនយល់កិច្ចការចង់បានដួងព្រះចន្ទយកមកកាន់លេងនៅដៃ នៅពេលមិនបានសម

ដូចប្រាថ្នា ក៏ត្រេកឃំ ។

អាត្មាដើរទៅបណ្ដើរ គិតនៅពាក្យប្រៀនប្រដៅរបស់លោកអាចារ្យបណ្ដើរ លុះត្រាអាចបន្ធូរបន្ថយនូវអត្តានុភាពចុះទៅខ្លះ បានសប្បាយចិត្តឡើងច្រើនតែម្ដង លុះត្រានឹងភ្លេចសេចក្ដីក្ដៅក្រហាយ និងសេចក្ដីហត់នឿយ និងការស្រេកឃ្លាន បាននឹងខ្លួនម្ដងទៀត ។

នៅពេលឮសម្លេងរថយន្ត បន្លឺមកតាមផ្លូវខាងក្រោយ ពេលនោះសេចក្ដីគិតដែលថានឹងសូមដោយសារទៀត មិនមានសូម្បីតែបន្តិចបន្តួច ចិត្តស្ងប់ផ្សាយមេត្តាឲ្យដល់ម្ចាស់រថយន្តនេះឲ្យបានសុខ, សម្លេងចេះតែមកជិតឡើងៗនៅគៀនផ្លូវ ។ ដើម្បីមិនឲ្យប៉ះពាល់នៅផ្លូវបើកបររបស់គេ ហើយក៏ដើរតទៅទៀតដោយចិត្តជាធម្មតាៗ ចិត្តសប្បាយ ដែលបានប្រើជើងរបស់ខ្លួនឯងជាប្រយោជន៍ ដោយមិនបាច់អាស្រ័យអ្នកណា ។ សម្លេងរថយន្តមួយគ្រឿងនេះ បានឮសូរកាន់តែខិតមកជិតឡើងៗ ហើយក៏បើកហួសអាត្មាទៅ ។ អាត្មាមិនមានសេចក្ដីពេញចិត្ត ហើយក៏មិនគិតនឹងមើលថែមទៀតផង ប៉ុន្តែត្រូវតែមើល ពីព្រោះរថយន្តនេះ មិនមែនជារថយន្តឈ្នួលធម្មតា តែជារថយន្តតូចមួយ បានបែរមកគៀនផ្លូវហើយក៏ឈប់ស្ងៀមនៅខាងមុខអាត្មា ។ ទ្វាររថយន្តបានបើកឡើង ហើយមនុស្សប្រុសវ័យកណ្ដាលម្នាក់ ក្នុងសម្លៀកបំពាក់ស្អាតបាតបានចុះពីរថយន្ត ដើរមករកអាត្មា លើកដៃសំពះហើយ ញញឹមសួរថា៖

- លោកម្ចាស់ និមន្តទៅណាទាន?

អាត្មាឈប់ឈរបន្តិច មិនបានឆ្លើយតបភ្លាមទេ ពីព្រោះមិនដឹងនឹងឆ្លើយយ៉ាងណាល្អ...

- ដោយថាអាត្មាមិនមានបំណងទៅទីណាពិតប្រាកដ, អាត្មាចេះតែដើរៗទៅ

បុរសម្ចាស់រថយន្ត សម្លឹងមើលមកអាត្មាដោយឆ្ងល់ហើយពោលថា៖

- បើដូច្នោះ សូមលោកម្ចាស់និមន្តឡើងឡានមកទៅជាមួយខ្ញុំករុណាល្អជាង លោកម្ចាស់និមន្តទៅណាខ្ញុំករុណាជូនទៅ ឬចង់ចុះនៅកណ្ដាលផ្លូវត្រង់ណា ខ្ញុំករុណានឹងឈប់ឲ្យចុះទាន

- សូមញោមអញ្ជើញទៅតាមសម្រួលចុះ កុំរវល់នឹងអាត្មាអី អាត្មាមិនមានកិច្ចការអ្វីប្រញាប់ទេ គាំងចិត្តថានឹងដើរៗទៅ ដល់ភូមិណាក៏នឹងឈប់សម្រាក, អាត្មាឆ្លើយហើយបានគិតក្នុងចិត្តថា មនុស្សយើងនេះ សូម្បីតែមានអាយុវៈរាងកាយដូចគ្នា ប៉ុន្តែមានចិត្តខុសគ្នាដូចមេឃនឹងដី នៅពេលដែលអ្នកខ្លះមិនព្រមឈប់ឡានទទួល សូម្បីតែអាត្មាបក់ដៃសុំឲ្យឈប់, ម្នាក់នេះមកឈប់ដោយខ្លួនឯងដោយអាត្មាមិនបានសុំ, អ្នកខ្លះដេញអាត្មាឲ្យចុះពីឡានគេដោយព្រហើន, អ្នកនេះបែរត្រឡប់ជាសូមនិមន្តឲ្យឡើងឡានរបស់គេវិញ

- លោកម្ចាស់ប្រហែលមិនដែលនិមន្តមកស្រុកនេះទេ, បុរសនោះពោលឡើងញញឹម, នៅឆ្ងាយទៀតណាស់លោក

ម្ចាស់ ទំរាំនឹងដល់ភូមិអ្នកស្រុកខាងមុខនោះ ខ្ញុំករុណាគិតថា លោកម្ចាស់និមន្តដើរដល់ពេលយប់ ក៏នៅមិនទាន់ដល់ភូមិអ្នកស្រុកនោះដដែរទាន និមន្តទៅជាមួយខ្ញុំករុណាទៅល្អជាង,

ពោលហើយ គេក៏មកទទួលបាត្រនិងក្រុតអំពីអាត្មាដែលធ្វើឲ្យអាត្មាចាំបាច់ត្រូវតែឆ្លងសទ្ធារបស់គេដោយល្អ ។ នៅពេលឡើងក្នុងរថយន្តបានស្រួលបួលហើយ គេក៏បញ្ឆេះរថយន្តឲ្យចេញទៅតាមផ្លូវ ហើយគេបានណែនាំខ្លួនគេថាឈ្មោះចំណាន ជាម្ចាស់រោងចក្រផលិតសន្លឹកថ្នាំនៅច្រើនកន្លែងនៃភាគខាងត្បូង នៅពេលនេះគេបានចេញពីគេហដ្ឋានដែលនៅក្នុងខេត្តឆៀងម៉ៃ ដើម្បីទៅត្រួតមើលកិច្ចការតាមរោងចក្រផ្សេងៗ ដែលនៅតាមផ្លូវក្នុងចំណុចផ្សេងៗជិតតាមផ្លូវនេះ ។ អាត្មាសង្កេតមើលទៅគេ ឃើញថាគេជាមនុស្សចេះដឹង និយាយមានន័យសមរម្យ ហើយប្អូកពោរជាអ្នកបុណ្យ ។

- ខ្ញុំករុណាជាអ្នកចូលចិត្តព្រះពុទ្ធ, គេពោលឡើងនៅពេលគេកំពុងបើកបរសម្លឹងទៅខាងមុខ, ឃើញព្រះសង្ឃព្រះពុទ្ធមិនបាន គឺចង់តែធ្វើបុណ្យភ្លាម ធ្វើបែបណាក៏បាន ក៏ធ្វើបែបនោះទៅតាមកម្លាំង អាចប្រគេនបាយម្ហូបអាហារក៏បានថ្វាយទៅ បើប្រគេនទ្រូវទឹកបានក៏ប្រគេនទឹកទៅ បើជួយកិច្ចការផ្សេងៗបាន ក៏ជួយលោកទៅ ពេលធ្វើរួចហើយសប្បាយចិត្ត

- ល្អហើយ អាត្មាសូមអនុមោទនាផង! អាត្មាបានឆ្លើយទៅតាមទម្លាប់ ពីព្រោះមិនទាន់រកពាក្យឆ្លើយឲ្យបាន

ល្អដូងនេះ

- លោកម្ចាស់មើលចុះទាន! គេលើកនឹងឆ្វេងពីចង្កូត ហើយចង្អុលទៅខាងក្រោយ, នៅខាងក្រោយឡានរបស់ខ្ញុំកូណា ពាសពេញទៅដោយរបស់ទាំងនោះទាន, អាត្មាបាន ងាកទៅមើលខាងក្រោយរថយន្តនោះ បានឃើញរបស់ផ្សេងៗជាច្រើនដូចជាត្រីយ ស្បៀងអាហារ សាប៊ូ ថ្នាំដុសធ្មេញ ថ្នាំរក្សារោគផ្សេងៗជាដើម

- តើញោមនាំយករបស់ទាំងនេះ ទៅធ្វើបុណ្យនៅឯណា? អាត្មាសួរ

- មិនបានយកទៅចូលរួមនៅឯណាទេទាន! ម្ចាស់រថយន្តបានឆ្លើយតបទាំងទឹកមុខញញឹម, តាមធម្មតា បើគាលណាមានធ្វើបុណ្យធំៗ ខ្ញុំកូណាមិនសូវបានទៅចូលរួមទេ ព្រះសង្ឃលោកមានបរិបូរណ៍ហើយ ខ្ញុំកូណាធ្វើដោយខ្លួនឯង ទាំងអស់នេះគឺយកទៅប្រគេនលោកនៅតាមវត្ត នានា ដែលនៅតាមភូមិជិតៗនេះ និងរោងចក្ររបស់ខ្ញុំកូណា ពីព្រោះខ្ញុំកូណាបានសង្កេតឃើញថា ព្រះសង្ឃដែលគង់នៅតាមជនបទស្រុកក្រៅមានការខ្វះខាតច្រើន ស្បៀងអាហារ សម្រាប់អានដើម្បីបង្រៀនដល់ញាតិញោមក៏គ្មានដែរ ទើបខ្ញុំកូណារៀបចំយកទៅប្រគេនតាមមានតាមបាន រាល់ពេលដែលបានចេញទៅត្រួតមើលកិច្ចការ

- ល្អហើយ អាត្មាសូមអនុមោទនាផង! អាត្មាបាន ឆ្លើយទៅតាមទម្លាប់

- នៅពេលនោះ បុរសចិត្តបុណ្យបានដាក់ប្រហ្វាំងឈប់

យ៉ាងប្រញាប់ លុះគ្រាតែអាត្មាប៉ះក្បាលទៅខាងមុខមុនពេលដែលអាត្មានឹងសួរថា តើមានកើតហេតុការណ៍អ្វីឡើងនោះ គេបានបើកទ្វារឡានខាងស្ដាំហើយក៏ប្រញាប់ចុះទៅរួចហើយគេដើរទៅមុខរថយន្ត ទើបចុះយកដុំថ្មខ្នាតធំល្មម ដើរខ្លួនគោងៗយកទៅចោលក្នុងព្រៃជិតថ្នល់ ហើយបោសដៃដើរត្រឡប់មករថយន្តវិញ

- មិនដឹងជានរណាគេយកដុំថ្មដ៏ធំនេះ មកដាក់នៅចំកណ្ដាលផ្លូវអញ្ចឹង! គេពោលដោយឥន្ទ្រក់នៅពេលគេបើកឡានចេញទៅ, បើសិនជាបើកលឿនហើយប៉ះដុំថ្មធំដូច្នេះប្រហែលជាមានគ្រោះថ្នាក់ ជួនកាលអាចក្រឡាប់ ជួនកាលអាចបែកកង់មានគ្រោះថ្នាក់ធំណាស់ ៗ មនុស្សយើងមានចំណង់ប្លែកៗ អ្នកខ្លះចង់សប្បាយកំប្លែង ដោយមិនបានគិតដល់សេចក្ដីសុខរបស់អ្នកដទៃ ខ្ញុំកូណាជាមនុស្សចំឡែកនៅពេលបានឃើញអ្វីទើសត្រចៀក ទើសភ្នែក ដែលជាអន្តរាយដល់អ្នកដទៃ អត់ទ្រាំមិនបានត្រូវតែកែតម្រង់សូម្បីជារឿងបន្តិចបន្តួច ឬជាការធ្វើឲ្យខូចខាតប្រយោជន៍ ខូចខាតពេលវេលានិងសេចក្ដីសុខរបស់ខ្លួនក៏ព្រមធ្វើដែរ ដូចជាដុំថ្មនោះជាដើម រថយន្តឯទៀតបើកមកមិនដឹងជាប៉ុន្មានហើយទេ តែគ្រប់រថយន្តទាំងអស់ គ្មាននរណាម្នាក់ប្រើពេលវេលាដើម្បីយកវាចេញសោះ តែខ្ញុំកូណាទ្រាំពុំបានពេលយកវាចេញរួចហើយសប្បាយចិត្តណាស់

- ល្អហើយ អាត្មាសូមអនុមោទនាផង! អាត្មាឆ្លើយនូវពាក្យដដែល

- បើងផិតទៅដល់ភូមិ ផ្ទះនៅខាងមុខហើយ, លោកចំណាននោលឡើង,ប៉ុន្តែខ្ញុំកូណាមិនឈប់នៅភូមិអ្នកស្រុកនេះទេ បើសិនជាលោកម្ចាស់ចង់ចុះ ខ្ញុំកូណានឹងឈប់ឲ្យចុះ បើសិនជា លោកម្ចាស់ចង់និមន្តទៅជាមួយខ្ញុំកូណាបន្តទៅទៀតសូមនិមន្តទាន

ក្រោយពេលបានសន្ទនាជាមួយនឹងម្ចាស់ឡាន អ្នកជ្រះថ្លានេះមួយរយៈពេលខ្លី អាត្មាកើតសេចក្តីចូលចិត្តនូវនិស្ស័យរបស់គេជាច្រើន យល់ថាគេជាកល្យាណមិត្ត ជាបណ្ឌិត ។ ការសន្ទនាជាមួយគេ ធ្វើឲ្យកើតសេចក្តីចេះដឹងថ្មីៗ ប្លែកៗ ព្រោះហេតុនោះទើបប្រាប់គេថា សូមដោយសារទៅជាមួយនឹងគេ ហើយគេក៏មានសេចក្តីពេញចិត្តឲ្យឃើញយ៉ាងច្បាស់ ។

នៅពេលរថយន្តបើកមកដល់ភូមិអ្នកស្រុក អាត្មាសង្កេតឃើញថាគេបានបន្ថយល្បឿនភ្លាម បើកបរយ៉ាងប្រយ័ត្នប្រយែង នៅកន្លែងនោះមានឆ្កែ ២ រត់ដេញគ្នាឆ្លងថ្នល់ កាត់ពីមុខរថយន្តយ៉ាងប្រផិត ជើងស្តាំលោកចំណានជាន់ហ្វ្រាំងឮសូរឆ្អឹត ធ្វើឲ្យរថយន្តឈប់ង៉ក់មួយរំពេច ។ អាត្មាគិតក្នុងចិត្តថា ប្រហែលជាគេជេរប្រទេចឆ្កែទាំងពីរក្បាលនេះពេញក្នុងឡានហើយមើលទៅ ប៉ុន្តែផ្ទុយទៅវិញគេគាមមើលឆ្កែដោយព្រួយបារម្ភ ហើយដកដង្ហើមធំដោយបានធូរស្រាលក្នុងចិត្ត

- ខ្ញុំកូណាមិនស្រួលចិត្តសោះ គិតថាបើសិនជាខ្ញុំទប់ល្បឿនរថយន្តនេះមិនទាន់ទេ, គេង៉ាកមកនិយាយជាមួយ

អាត្មាព្រមទាំងបញ្ឈរថយន្តផង, ការបើកបរនេះមិនមែនជាការងាយស្រួលនោះទេ ត្រូវរវាំងគ្រប់វិនាទី ជាពិសេសនៅពេលបកបរចូលមកក្នុងភូមិអ្នកស្រុក ត្រូវប្រយ័ត្នប្រយែងមែនទែន មនុស្សមិនសូវជាអ្វីទេ តែប្រយ័ត្ននូវសត្វធាតុមានការពិបាកមែនទែន ត្រូវឡានកិនស្លាប់ជាញឹកញយ ខ្ញុំក្ដីភាក៏ធ្លាប់កិនឆ្កែស្លាប់ដែរ ពីព្រោះគេចមិនទាន់ពិតៗ បើកឡានកិនឆ្កែស្លាប់ម្ដងៗ ធ្វើឲ្យមិនសប្បាយចិត្តជាច្រើនថ្ងៃ ត្រូវធ្វើបុណ្យច្រូចទឹក ឧទ្ទិសចំណែកបុណ្យឲ្យទៅវាគ្រប់ពេល

- ល្អហើយ អាត្មាសូមអនុមោទនាផង! អាត្មាឆ្លើយទៅតាមច្បាប់

នៅពេលយើងមកដល់កណ្ដាលភូមិ លោកចំណានបានឈប់រថយន្តនៅមុខរានលក់អីវ៉ាន់មួយ ហើយបើកទ្វារដើរចុះទៅក្នុងរាននោះ ។ អាត្មាសង្កេតឃើញថាមានបុរស ៤-៥ នាក់ដែលអង្គុយក្នុងរាននោះ នាំគ្នាក្រោកឡើង ហើយលើកដៃសំពះយ៉ាងរាក់ទាក់ ជាមួយនឹងការគោរព ។ អាត្មាបានឮតែពាក្យថា "ឱពុកចិញ្ចឹមៗ" ឮចេញមកអំពីក្រុមនោះ ។ នៅពេលមិនយូរ លោកចំណានបានត្រឡប់មកជាមួយការហ្វេទឹកកក ១ កែវធំ យកមកប្រគេនអាត្មា ហើយត្រឡប់ទៅសន្ទនាជាមួយក្រុមមនុស្សនោះយ៉ាងជិតស្និទ្ធ ។ អំពើរបស់គេ ធ្វើឲ្យអាត្មាឃើញភ្លាមថា គេជាអ្នកធ្វើដូចពាក្យនិយាយ ហើយនិយាយដូចគេធ្វើ ។ ការហ្វេទឹកកកមួយកែវនេះ ជួយរំងាប់នូវសេចក្ដីស្រេករបស់អាត្មាបាន

យ៉ាងល្អប្រសើរណាស់ ។ នៅពេលកិច្ចការគ្រប់យ៉ាងបាន ស្រួលបួលហើយ បញ្ហាបន្តិចបន្តួចបានកើតឡើង ពោលគឺ ម្ចាស់គារហ្វេមិនព្រមយកប្រាក់តម្លៃគារហ្វេ ចំណែកលោក ចំណានខំព្យាយាមសែកឲ្យ តវ៉ាគ្នាមួយសន្ទុះ លោកចំណាន បានដាក់ប្រាក់នៅលើតុ ហើយប្រញាប់មកឡើងរថយន្តវិញ នៅពេលដែលរថយន្តជិតចេញ ម្ចាស់រានខំរត់យកប្រាក់ តម្លៃគារហ្វេបោះចូលមកក្នុងឡាន ឲ្យមកវិញទាល់តែបាន

- មនុស្សថៃដូច្នេះឯងទាន អញ្ជើញហើយទើបធ្វើជំនួញ មិនសូវបានចំណេញច្រើន ដោយមានចិត្តល្អហួសពេក, លោកចំណានពោលទាំងទឹកមុខញញឹម នៅពេលរថយន្ត បរចេញទៅ

នៅពេលយើងចាកចេញអំពីភូមិប្រហែលជា ៥ គីឡូ ម៉ែត្រ យើងបានឃើញមនុស្សមួយហ្វូងធំកំពុងតែឈរប្រជុំ គ្នានៅខាងមុខ

- កើតហេតុអ្វីឡើងនោះ ? លោកចំណានពោលឡើង យ៉ាងភ្ញាក់ផ្អើល ថែមទាំងបន្ថែមល្បឿនរថយន្តឲ្យរឹតតែ លឿនទៅមុខ នៅពេលយើងមកដល់កន្លែងហ្នឹង បានជួប ប្រទះនូវហេតុការណ៍ភ្លាម, អាត្មាក៏ចុះទៅមើលដែរ

- ឡានក្រឡាប់ទាន , បុរសម្នាក់ដែលមានស្នាមឈាម ប្រឡាក់ពាសពេញខ្លួន បានឆ្លើយនូវពាក្យសួររបស់លោក ចំណានយ៉ាងរឡេបរឡប់, នុ៎ះហ្ន៎ដេកផ្ងារពោះនៅខាង ក្រោមនោះ ! នៅពេលក្រឡេកមើលតាមដៃរបស់គេចង្អុល នោះទៅ បានឃើញរថយន្តឈ្នួលមួយគ្រឿងក្រឡាប់ផ្ងារ

ពោះនៅខាងផ្លូវខាងក្រោម ៗ កង់ឡានខាងឆ្វេងវាបែក នៅពេលរថយន្តមកដល់ផ្លូវកោងនេះ រថយន្តបានធ្លាក់ចុះពីថ្នល់ ហើយក្រឡាប់ពីរបីក្រឡប់

- មាននរណាកើតអីទេ? លោកចំណានសួរយ៉ាងរួសរាន់, ក្មេងអ្នកយកប្រាក់ ត្រូវឡានសង្កត់ស្លាប់ ពីព្រោះគេលោតចេញមុន ក្នុងពេលដែលរថយន្តធ្លាក់ចុះទៅពីផ្លូវថ្នល់នោះ ៗ ដេកនៅឯណោះ, ប្រុសឯដែលបានឆ្លើយចង្អុលទៅខាងផ្លូវ រូបរាងមួយដែលមនុស្សយកសំពត់ដាកន្សែងគ្របខ្លួនឲ្យ

អ្នកបើករថយន្តរបួសខ្លាំង អ្នកដំណើរផ្សេងៗ បែកក្បាលខ្លះ របួសរៀងៗខ្លួន ៗ សភាពមនុស្សធ្វើដំណើរដែលមានរបួស ឈឺ ដេកស្រែកដោយការឈឺចាប់នៅនឹងដី មានមិត្តដែលធ្វើដំណើរជាមួយគ្នាផ្សេងៗ អង្គុយនៅជុំវិញជួយលួងលោម និយាយអង្វរ ឲ្យថ្នាំទៅតាមសភាពដែលអាច ៗ គួរឲ្យអាណិតយ៉ាងខ្លាំង អ្នកទាំងអស់គ្នានោះជាអ្នកជនបទ ដែលឡើងធ្វើដំណើរមកតាមរថយន្ត ឡើងជិះតាមផ្លូវទាំងអស់ ៗ

នៅពេលដែលកំពុងកើតហេតុការណ៍ជ្រួលច្របល់ពាសពេញកន្លែងនោះ អាត្មាបានដើរសំដៅទៅរកសាកសពរបស់ក្មេងយកប្រាក់នោះ ដើម្បីពិចារណានូវសេចក្ដីសង្វេគ និងសូត្រធម៌ឧទ្ទិសបុណ្យឲ្យទៅគេ ៗ មានបុរសពីរបីនាក់ទៀត ដែលអង្គុយនៅចាំសព បានលើកដៃសំពះអាត្មា ហើយបានបើកក្រណាត់សបិទមុខក្មេងគួរឲ្យអាណិត

*នោះចេញ នៅពេលឃើញមុខក្មេងវង្វេងគ្រោះនោះ អាត្មាភ្ញាក់ស្មើលតែម្តង ព្រោះចាំបានយ៉ាងច្បាស់ថា គឺជាក្មេងយកប្រាក់ពីអ្នកធ្វើដំណើរក្នុងឡានរៀងរាល់ថ្ងៃ ជាអ្នកបានដេញអាត្មាឲ្យចុះចេញយ៉ាងទារុណនោះឯង ។*

# ជនពាលមិនស្គាល់បាប

**ពាក្យប្រាំពីរ**

***ជនពាលធ្វើបាបដរាបណា នាំឲ្យចិត្តាក័ន្តច្រឡំ***
***ថាបាបរសផ្អែមដូចទឹកឃ្មុំ វង្វេងសម្ងំសន្សំបាប ។***
***លុះបាបឲ្យផលដល់កាលណា ទទួលទុក្ខារៀងដរាប***
***ក្រហល់ក្រហាយកាយផុនដាប ធ្លាក់ក្នុងសភាពទុក្ខសោកសៅ ៕***

ដោយឧបាសក មុិញ សារ៉ាង

# កុសលមូល

**ពាក្យប្រាំពីរ**

***លោភៈ ទោសៈ និងមោហៈ កើតមានពិតដាក់កុំសង្កា***
***នៅក្នុងចិត្តនៃបុគ្គលណា រមែងប្រហារបុគ្គលនោះ ។***
***ឲ្យដល់នូវក្តីមរណា ទាំងអស់គ្រប់គ្នាទោះស្រីប្រុស***
***ដូចដើមឫស្សី ចេក បបុស ព្រោះផ្លែផ្កានោះដើមត្រូវស្លាប់ ៕***

ដោយឧបាសក មុិញ សារ៉ាង

# ១៧. ពុទ្ធរូប និង បុគ្គលពិសេស

ដើម្បីឲ្យប្រាកដក្នុងចិត្តកាន់តែច្បាស់ថែមទៀត អាត្មាបានងាកទៅមើលរថយន្តឈ្នួល ដែលដេកគ្រឡាប់ផ្ងារពោះធ្លាក់ក្នុងប្រឡាយថ្មល់ម្ខាងទៀត ។ ក្រោយពីបានមើលយ៉ាងល្អិតល្អន់ពីទ្រង់ទ្រាយរបស់រថយន្ត មួយសន្ទុះមកអាត្មាមានសេចក្តីប្រាកដថា ឡាននេះហើយដែលបានដេញអាត្មាចុះ ។ នៅពេលដែលអាត្មាកំពុងឈរមើលដោយការងឿងឆ្ងល់នឹងសេចក្តីសង្វេគស្លុតចិត្តនោះ ស្រាប់តែមានបុរសម្នាក់ដើរចូលមករកលើកដៃសំពះហើយពោលថា ៖

- លោកម្ចាស់ ! សូមនិមន្តទៅប្រោសអ្នកបើកឡានបន្តិចទាន អាការៈរបស់គេធ្ងន់ធ្ងរណាស់

ឃើញថាមិនរស់ពិតៗ អាត្មាដើរតាមបុរសនោះទៅដូចជាមនុស្សត្រូវវិលវង្វេងចិត្ត ។

ពេលបានឃើញបុរសអ្នករងគ្រោះនោះមួយភ្លែត , អាត្មាចាំបានភ្លាមថា គេគឺជាអ្នកបើករថយន្តមួយនោះឯង កំពុងថ្ងូរចង្អោកដេកដកដង្ហើម ហើយនៅទៀលនៅលើដី ព័ទ្ធជុំជិតដោយអ្នកធ្វើដំណើរ ដែលកំពុងសម្លឹងមើលដោយសេចក្តីខ្វល់ខ្វាយ សូម្បីតែមនុស្សដែលមានកំហឹងជាមួយគេ ព្រោះតែការបើកបររបស់គេលឿនហួសហេតុ រហូតដល់ជួបឧប្បត្តិហេតុដ៏គួរឲ្យស្លុតនេះយ៉ាងណា ក៏ពួកគេគ្រប់គ្នាដូចជាមានចិត្តអាណិតដល់អ្នកបើកបរនេះទៅវិញ ។

- មានព្រះសង្ឃមកប្រោសហើយ ! បុរសម្នាក់ឱនចុះឱ្យបងរាក់ត្រចៀករបស់គេ, អ្នកបើកឡានខំបើកភ្នែកឡើងហើយសម្លឹងមកអាត្មា ដោយដំខ្សែភ្នែកពោរពេញដោយភាពភ័យខ្លាច គេព្យាយាមលើកដៃទាំងពីរឡើងសំពះ តែធ្វើបានត្រឹមតែលើកដៃខាងស្តាំឡើងមកដាក់លើដើមទ្រូង , ភ្នែករបស់គេប្តូរពីភាពភ័យខ្លាច ទៅជាក្រសែភ្នែកអង្វរករ និងមានទឹកភ្នែក ហូរចេញសើមៗពេញកែវភ្នែក គេបិទភ្នែកជូតទឹកភ្នែកទៅខាងកន្ទុយភ្នែក ។

- លោកម្ចាស់ ! គេនិយាយមកខ្សាវៗសឹងតែស្តាប់មិនសូវបាន, សូមមេត្តាលើកទោសឱ្យខ្ញុំម្ចាស់ផង ខ្ញុំម្ចាស់ជាអ្នកខុសព្រោះមិនយល់កិច្ចការ កម្មតាមស្ទួងមកខ្ញុំហើយ

ពាក្យនិយាយរបស់គេធ្វើឱ្យមនុស្ស ដែលអង្គុយជុំវិញទីនោះ មិនយល់ថាស្អីជាស្អី ។

- អាត្មាលើកទោសឱ្យហើយ ! អាត្មានិយាយដោយសម្លេងរាងខ្លាំងបន្តិចដើម្បីឱ្យគេបានស្តាប់ឮ, សុំធ្វើចិត្តឱ្យបានល្អៗទៅ កុំគិតអ្វីច្រើន អាត្មាមិនដែលប្រកាន់ទោសនិងខឹងជាមួយញោមទេ គ្មានអ្វីឱ្យធ្ងន់នោះទេ , គេបិទភ្នែកហើយព្យាយាមលើកដៃសំពះទៀត ។

- សុំឱ្យញោមសម្រាន្តនៅឱ្យស្ងៀមៗ, អាត្មាពោលបន្តទៀត, តាំងចិត្តនឹកដល់គុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងគិតដល់បុណ្យកុសលដែលញោមធ្លាប់បានធ្វើកន្លងមក ធ្វើចិត្តឱ្យថ្លាស្អាតរឿងអាក្រក់ទាំងប៉ុន្មានចូរបំភ្លេចឱ្យអស់ សូមទន្ទេញនូវពាក្យថា “**អរហំៗ**” នៅក្នុងចិត្ត ។

គេរាងញញើមតិចៗ លើផ្ទៃមុខដ៏ស្លេកស្លាំងរបស់គេ ហើយក្រោយអំពីនោះក៏ស្ងាត់ទៅ ខ្យល់ដកដង្ហើមរបស់គេតិចទៅៗ មានការកន្ត្រាក់ហៀបជាពេលចុងក្រោយបំផុត ហើយ គេក៏ស្ងៀមរហូតទៅ ។ អាត្មាទាញយកក្រណាត់ ឬ ក្រមាបិទមុខរបស់គេ ហើយសូត្រធម៌ឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធរបស់គេឲ្យទៅកាន់សុគតិភព រួចក្រោកឡើងឈរងាកទៅមើលអ្នកដំណើរផ្សេងៗទៀត ដែលអង្គុយនៅជុំវិញនោះ ពួកគេទាំងអស់គ្នាកំពុងឈ្ងោកមុខដូចជាត្រូវមន្តសន្តត់ សម្លឹងមើលរាងកាយ ដែលប្រាសចាកវិញ្ញាណរបស់អ្នកបើករថយន្ត ដោយសេចក្ដីរន្ធត់ជាខ្លាំង ដោយសេចក្ដីសង្វេគតក់ស្លុតចិត្ត នៃសេចក្ដីមិនទៀងទាត់របស់សង្ខារ គឺបានរលត់សូន្យបាត់ទៅចំពោះមុខពួកគេ ក្នុងខណៈពេលនេះ គឺជាសាក្សីយ៉ាងច្បាស់ឥតមានការសង្ស័យអ្វីឡើយ នេះហើយជីវិតយើងទាំងអស់គ្នា គឺដូច្នេះឯង ។ អាត្មាយល់ឃើញថា នៅពេលនេះគឺជាឱកាសដែលគួរនាំប្រជាជនទាំងនោះឲ្យបានឃើញសង្ខារ និងប្រញាប់ខំធ្វើអំពើល្អ ទើបពោលឡើងថា៖

- នេះហើយញាតិញោមទាំងឡាយ! គឺជាវារៈចុងក្រោយ នៃជីវិតរបស់យើងរាល់ៗរូប នឹងត្រូវជួបប្រទះនៅថ្ងៃណាមួយមិនខាន មិនថាយើងជាអ្នកមាន ឬ ជាអ្នកក្រ អ្នកធំមានបុណ្យស័ក្តិ ឬ តូចទាប អ្នកឆ្លាត ឬ អ្នក ល្ងង់អ្នកល្អ ឬ អ្នកអាក្រក់ទេ នៅទីបំផុតត្រូវដូច្នេះឯង គ្មាននរណាម្នាក់អាចគេចផុតបានទេ លោកមច្ចុរាជនឹងមិនដែលភ្លេច

សូម្បីតែម្តង គឺកំពុងរង់ចាំឃើង និងលោកមិនបានណាត់ពីខែណា ឆ្នាំណាឲ្យបានដឹងមុននោះដែរ តែដល់ពេលវេលាហើយ គឺលោកនឹងមកជួបឃើងភ្លាមមួយរំពេច ដូចញាតិញោមបានជួបប្រទះនឹងអ្នកបើកឡានមួយនេះ ក្នុងថ្ងៃនេះដូច្នេះដែរ ។ ចំណែកឃើងមិនដឹងសោះឡើយថា លោកមច្ចុរាជនឹងមកយក ឃើងនៅថ្ងៃណាទៀតនោះទេ លោកអាចនឹងមកនៅថ្ងៃនេះ ថ្ងៃស្អែក ខែក្រោយ ឬ ឆ្នាំក្រោយក៏ថាបាន ។ ឃើងគ្រប់គ្នានឹងត្រូវតែស្លាប់យ៉ាងប្រាកដ ហើយក៏មិនប្រាកដថានឹងស្លាប់នៅពេលណាទេ ។ ដូច្នេះហើយទើបបាន ជាព្រះបរមសាស្តានៃឃើងបានបង្រៀន ឲ្យឃើងកុំប្រមាទភ្លើតភ្លើន ជាមួយអារម្មណ៍នឹងផ្លូវលោកឲ្យហួសហេតុពេក ។ អ្នកដែលវង្វេងនូវសេចក្តីប្រមាទ រកតែសេចក្តីសប្បាយរីករាយ ភ្លើតភ្លើនឲ្យដល់ខ្លួនឯង មិនបានធ្វើគុណធម៌ ប្រព្រឹត្តអំពើល្អទុកឲ្យហើយទេ នៅពេលមច្ចុរាជមកទារយកជីវិតទៅ តែងសោកស្តាយ ខូចចិត្ត និងមិនមានសង្ឃឹមថាបានសេចក្តីសុខ ។ អ្នកមិនប្រមាទប្រញាប់ធ្វើនូវអំពើល្អទុក គ្រប់ពេលតែងមិនភ្ញាក់ផ្អើល និងភ័យខ្លាចពីមាត់មច្ចុរាជ ទោះបីសេចក្តីស្លាប់នោះខិតជិតមកដល់យ៉ាងណាក្តីក៏មិនភ័យ មិនព្រួយ ប្រៀបដូចជាមនុស្សដែលបានត្រៀមនូវស្បៀងអាហារទុករួចរាល់ហើយ គឺមិនព្រួយមិនភ័យកើតទុក្ខក្នុងផ្លូវ ដែលបានធ្វើដំណើរទៅព្រមទាំងចេញដំណើរ ដោយសេចក្តីញញឹមរីករាយទៀតផង ។

អាត្មាក៏ពោលបន្តទៀតថា ៖

- ញាតិញោមទាំងឡាយ បាយ ត្រីម្ហូប អាហារ មាស ប្រាក់ គឺជាស្បៀងសម្រាប់ការដើរផ្លូវលោក ចំណែកឯបុណ្យកុសលវិញ គឺជាស្បៀងសម្រាប់ដើរផ្លូវក្នុងវដ្តសង្សារដ៏វែងឆ្ងាយ ។ ជនណាមានបុណ្យកុសលបានសន្សំទុកមកបានច្រើន បុគ្គលនោះនឹងឈាន ឡើងជណ្ដើរទៅកាន់សុគតិ និងឆ្ពើងំសើរឆ្ពោះទៅកាន់ទ្វារព្រះនិញ្វាននៅទីបំផុត ។ ជនណាមិនបានខំប្រឹងសន្សំបុណ្យកុសលទុកទេ ជននោះឯងនឹងជួបប្រសព្វតែសេចក្ដីអន់ឃ្លាន ពិបាករហូតដល់អស់កាលយូរទៅនៅក្នុងទុគ្គតិ មាននរកប្រេត អសុរកាយ និងកំណើតសត្វតិរច្ឆានជាដើម ហើយវិលវល់ស្លាប់កើតៗ ជួបប្រទះនូវទុក្ខ នៅក្នុងកន្លែងងងឹតនៃវដ្ដៈមិនមានទីបញ្ចប់ ។ ដូច្នេះចាប់តាំងពីថ្ងៃនេះតទៅ សូមឲ្យអ្នកទាំងអស់គ្នាគាត់ចំណាំងនាវានៃជីវិតរបស់ខ្លួន ទៅតាមទិសដែលត្រូវគឺផ្លូវបុណ្យ ផ្លូវកុសលតរៀងទៅ ។

នៅពេលអាត្មាទេសនាចប់ ញាតិញោមទាំងនោះនាំគ្នាក្រាបចុះដល់ដីដោយសទ្ធាជ្រះថ្លា ហើយក៏ក្រោកឈរឡើង នាំគ្នាចូលមកកោមជិតអាត្មា មានបុរសម្នាក់សួរឡើងថា៖

- មុនដែលបុរសម្នាក់នោះជិតដាច់ខ្យល់ ខ្ញុំកូណាបានឮគេសុំអភ័យទោសពីលោកម្ចាស់ ខ្ញុំកូណាចង់ដឹងថា គេបានធ្វើការខុសឆ្គងអ្វីទៅលើលោកម្ចាស់យ៉ាងណាខ្លះ សូមមេត្តានិមន្តប្រាប់ឲ្យពួកខ្ញុំកូណាស្ដាប់ផងទាន!

អាត្មានៅស្ងៀមអស់ពេលមួយរយៈធំ ដោយគិតមិន

ចេញថានឹងឆ្លើយទៅគេយ៉ាងណាឲ្យសម បើសិននិយាយរឿងអាត្មាត្រូវគេដេញឲ្យចុះអំពីរថយន្តឲ្យគេស្តាប់ ក៏ក្រែងថា គេនឹងយល់ថា អាត្មាជាព្រះសង្ឃដែលស័ក្តិសិទ្ធ អាចធ្វើឲ្យកើតភ័យវិបត្តិដល់បុគ្គលដែលល្មើស និងដល់បុគ្គលដែលមើលងាយព្រះសង្ឃបាន ។ ហើយក្រោយមកនាំគ្នាមកជុំ សូមនិមន្តហើយដើរតាមជាឋានៈជនវិសេស លុះត្រាមិនមានពេលវេលាដែលនឹងបងិបត្តិគាត់គាយ វាចា ចិត្តដើម្បីសេចក្តីបរិសុទ្ធ ឲ្យដល់នូវចំណុចដ៏ខ្ពង់ខ្ពស់បំផុតក្នុងព្រះពុទ្ធសាសនា តែនៅពេលនឹងឆ្លើយតបនៅរឿងផ្សេងៗអំពីការពិត ក៏ជាការពោលមុសាខុសព្រះវិន័យបញ្ញត្តិនៃព្រះបរមសាស្តា អាចជាសេចក្តីខុសខ្លាំងជាងការនិយាយនូវការពិតទៅទៀត ។ ពេលគិតមើលល្អហើយ ទើបឆ្លើយតបគ្រាន់តែខ្លីៗថា ៖

- គេធ្លាប់មើលងាយអាត្មាម្តង យូរមកហើយគ្រាន់តែរឿងបន្តិចបន្តួច ដែលអាត្មាមិនបានយកចិត្តទុកដាក់អ្វីច្រើនផង

- ខ្ញុំករុណាបានឮគេនិយាយថា កម្មតាមឲ្យផលខ្ញុំហើយ មានន័យថា ដែលគេមានគ្រោះថ្នាក់នៅពេលនេះ មែនទេទាន ? បុរសដដែលសួរទៀត

- ដូចជាមិនប្រាកដទេ ! អាត្មាឆ្លើយ, រឿងរបស់កម្ម ជារឿងហួសវិស័យធម្មតា ដូចជាយើងនឹងដឹងនូវការដែលគេបានជួបគ្រោះកម្មនៅពេលនេះ អាចជាផលកម្មចាស់ ដែលគេបានធ្វើក្នុងជាតិនេះក៏បាន អាចជាផលនៃសេចក្តីប្រមាទ

ព្រហើនរបស់គេផ្ទាល់ក៏បាន អាចជាហេតុចៃដន្យផុតវិស័យក៏បាន អ្នកណានឹងទៅដឹង ?

នៅពេលអាត្មាឆ្លើយជាទំនងគាត់ៗ ដូច្នេះហើយបុរសម្នាក់នោះ ក៏មិនបានសួរអ្វីតទៅទៀតទេ ៗ អាត្មានឹកសប្បាយចិត្ត ដែលអាចកាត់នូវបញ្ហាពិបាកនេះបានរួច, តែម្ចាស់នៃសេចក្ដីមិនពិតប្រាកដមួយនេះហើយ ធ្វើឲ្យកើតរឿងឡើងទាល់តែបាន ពោលគឺមានអ្នកធ្វើដំណើរម្នាក់ដែលជាជនជាតិចិន គាត់បានឃើញហេតុការណ៍នៅពេលអាត្មាត្រូវគេបណ្ដេញចុះពីរថយន្ត ដោយភ្នែកខ្លួនឯងផ្ទាល់ដើរតេះតះចូលមករកអាត្មា នៅពេលមកដល់ឱនចុះជិតជើងរបស់អាត្មា បណ្ដាលធ្វើឲ្យចម្លែកចិត្តដល់មនុស្សទាំងឡាយ ហើយអង្គុយលុតជង្គង់ប្រណម្យដៃ ពោលឡើងយ៉ាងរងិបរងុប ដោយសម្លេងខ្លាំងជាមួយនឹងភាសាថៃ ដែលមិនសូវច្បាស់ថា ៖

- លោកម្ចាស់! ជាកុសលរបស់ខ្ញុំព្រះករុណាណាស់ទាន ដែលបានជួបលោកម្ចាស់នៅទីនេះទៀតទាន, ខ្ញុំនឹករលឹកថា ប្រហែលស្លាប់បាត់ទៅហើយក្នុងខណៈពេលឡានក្រឡាប់, បើសិនមិនបានព្រះអង្គជួយការពារ ខ្ញុំម្ចាស់ប្រហែលជាស្លាប់បាត់ហើយ, គាត់គ្រវីក្បាលទាំងមិននឹកស្មានដល់, អាត្មាក៏នឹកឆ្ងល់ដូចគ្នានឹងអ្នកដទៃផ្សេងៗទៀតដែរ ពីព្រោះចាំមិនបានថា ធ្លាប់ជួបជាមួយនឹងបុរសជនជាតិចិនវ័យកណ្ដាលម្នាក់នេះនៅទីណាមកពីមុនទេ

- លោកម្ចាស់ទាន! គេពោលបន្ទាប់ពីបានអង្គុយគ្រាប

មួយសន្ទុះ, នៅពេលគេដេញលោកម្ចាស់ចុះពីឡាននោះ ខ្ញុំឃើញផ្ទាល់ភ្នែក ស្ដាប់ឮផ្ទាល់ត្រចៀក ខ្ញុំមានសេចក្ដីខឹងក្រោធនឹងអ្នកបើកឡាន និងអ្នកយកប្រាក់ឡើងញ័រខ្លួន តែមិនអាចធ្វើអ្វីបាន ពួកគេចិត្តបាបអាក្រក់ខ្លាំងណាស់ទាន, នៅពេលដែលឡានភ្លូក, ក្នុងពេលនោះខ្ញុំគិតថា នេះជាកម្មតាមតបស្នងពិតៗ សមមុខហើយ

- កុំទៅបន្ថែមឲ្យគេទៀតញោម! អាត្មាពោលឡើង, ពួកគេក៏បានស្លាប់ទៅហើយ ឲ្យអភ័យដល់ពួកគេផងចុះ, អាត្មាមិនប្រកាន់ខឹងដល់ពួកគេទេ

- ពួកគេដេញលោកចុះនៅពេលណាចៅកែ? បុរសដំបូងដែល បានសួររឿងកម្មតាមស្នងជាមួយអាត្មា រួចបានសួរទៅចៅកែចិននោះ

- ប្រហែលជាពីរម៉ោងមុននេះឯង! គឺអាក្រក់ខ្លាំងណាស់, ហេតុម្ដេចបានជាគេដេញព្រះអង្គឲ្យចុះ ? បុរសនោះសួរតទៅទៀត

- អ៊ូស្ដាប់មិនច្បាស់ដែរ តែឮពួកគេពោលថា លោកមួយអង្គនេះ មិនមានប្រាក់បង់ថ្លៃធ្វើដំណើរទេ ពួកគេមានចិត្តបាបខ្លាំងណាស់ សូម្បីតែព្រះសង្ឃក៏ពួកគេទារយកប្រាក់ដែរ, ចៅកែចិនតប

នៅពេលសង្កេតឃើញអាការៈបុរសចិនម្នាក់នេះក្ដៅក្រហាយ និងខឹងជំនួសអាត្មាហើយ សេចក្ដីនឹកសង្ស័យឃើញតែប្រយោជន៍ផ្ទាល់ខ្លួន របស់ចៅកែចិនក៏បានកើតឡើងក្នុងចិត្តថា បើគេពិតជាក្ដៅក្រហាយអាណិតអាត្មា

និងមានបំណងល្អជាមួយអាត្មាពិតមែននោះ ចុះហេតុស្ដេច គេមិនព្រមធ្វើបុណ្យជាមួយនឹងអាត្មាទៅ ដោយព្រមចេញ ថ្លៃឡានឲ្យអាត្មាក្នុងគ្រានោះ គ្រាន់តែជាបច្ច័យបន្តិចបន្តួច តែប៉ុណ្ណោះ ។ នៅពេលមានសតិមកវិញថា សេចក្ដីនឹក សង្ស័យនូវច្នោះជាសេចក្ដីនឹកឃើញតែខ្លួនឯង អាត្មាក៏សង្កត់ ចិត្តកំចាត់វាចោល ហើយផ្សាយមេត្តាដល់បុរសចិននោះ ៖

- អញ្ចឹងចៅតែមិនប្រគេនថ្លៃឡានជំនួសព្រះអង្គទៅ ?

បុរសថៃបានសួរឡើង ដោយប្រហែលយល់ស្របនឹងគំនិត របស់អាត្មាដែរ

បុរសចិននោះនៅស្ងៀមមួយសន្ទុះ ហើយតបព្រម ព្រមទាំងគ្រវីក្បាល ៖

- ភ្លេចទៅ ! គិតមិនទាន់ ព្រោះនឹកខឹងខ្លាំងពេកទាល់ តែពេលព្រះអង្គចុះពីឡានហើយ ទើបគិតឃើញឡើង ដោយសោកស្ដាយនឹងទង្វើរបស់ខ្លួនឯងក៏មិនតិចដែរ

គេងាកមុខមករកអាត្មា ជាការអង្វរហើយពោលថា ៖

- លោកម្ចាស់! ខ្ញុំម្ចាស់សូមអភ័យទោសផង ខ្ញុំម្ចាស់ ភ្លេចគិតមែនទាន ខ្ញុំម្ចាស់ចង់តែខ្លួនចង់និមន្តលោកម្ចាស់ ទៅធ្វើបុណ្យនៅផ្ទះខ្ញុំម្ចាស់ម្ដង គឺនៅលំភូន ខ្ញុំនឹងទៅឆ្លាម បើគាលណាមានឡានមកឈប់នៅខាងមុខ ខ្ញុំម្ចាស់សូម និមន្តព្រះអង្គទៅលំភូនជាមួយនឹងខ្ញុំម្ចាស់

បុរសចិននោះនិយាយមិនទាន់ចប់ពាក្យផង អ្នក ឯទៀតៗ ក៏ផ្ដើមគ្នានិយាយឡើងឮសូរសម្លេងទ្រហឹង អឺងកង ម្នាក់ៗពោលពាក្យសុំនិមន្ត អាត្មាទៅផ្ទះរបស់ពួកគេ

រៀងៗខ្លួន នៅទីបំផុតអាត្មាគិតថា អាត្មាបានក្លាយទៅជាបុគ្គលពិសេសទៅហើយ ក្នុងក្រសែភ្នែករបស់ពួកគេ ព្រោះការបកស្រាយនូវរឿងរ៉ាវរបស់បុរសចិននោះ អ្នកកាន់ព្រះពុទ្ធសាសនាថៃ-ចិន ទូទៅតែងមាននិស្ស័យភ្ជាប់ស្នើលចំពោះព្រះសង្ឃដ៏ស័ក្តិសិទ្ធិ និងពូកែ មានមនុស្សភាគតិចណាស់ ដែលមានចិត្តតស៊ូរៀនសូត្រធម៌ និងបដិបត្តិតាមដំបូន្មានរបស់ព្រះបរមសាស្តា ។ ពិតប្រាកដណាស់ ពេលបានដំណឹងថា មានបុគ្គលវិសេសនៅទីណាហើយ គឺតែងរត់ទៅរក ទាំងនេះក៏ព្រោះមនុស្សត្រូវការផ្លូវកាត់ ចង់បាននូវរបស់អ្វីដែលងាយៗ ដោយមិនចាំបាច់ចុះដើម ចុះកម្លាំងរង់ចាំ ។ ហេតុនេះទើបក្លាយជានុយរបស់ជនខិលខូចមួយចំនួនជានិច្ចជាកាល ខណៈពេលនេះក៏ដូចគ្នាដែរ ដោយសាររថយន្តល្អមួយនេះបានដេញអាត្មាចុះ បន្ទាប់មកក៏បានកើតឧប្បត្តិហេតុក្រឡាប់នេះ ពួកគេគិតថា បណ្តាលមកពីការដាក់បណ្តាសារបស់អាត្មា រួចហើយពួកគេគិតទៀតថា អាត្មាមានវាចាស័ក្តិសិទ្ធិអាចដាក់ទោស ដល់មនុស្សដែលធ្វើនូវអំពើបាបកម្មដល់ខ្លួនបាន ក៏អាចមានវាចាស័ក្តិសិទ្ធិឲ្យពរដល់ជនណា ដែលបានធ្វើល្អដល់ខ្លួន ជួបប្រសព្វតែជោគលាភអ្វីៗក៏បាន ព្រោះដូច្នោះ ហើយទើបគ្រប់ៗគ្នាចង់ធ្វើបុណ្យជាមួយអាត្មា និមន្តឲ្យទៅផ្ទះរៀងៗខ្លួន ដើម្បីបានធ្វើបុណ្យផង និងបានសូមរបស់ដែលពួកគេត្រូវការផង ចេតនាពីក្រោយកុសលរបស់ពួកគេ គឺប្រយោជន៍ផ្ទាល់ខ្លួននោះឯង ។

នៅពេលអាត្មាឈរស្មៀមនោះ គេរងស្ងើមគ្នាស្ងួម និមន្តអាត្មាឮស្បូរសម្លេងកាន់តែខ្លាំងឡើងៗ មានអ្នកខ្លះ បរិរមកទាញចាប់ចីពរបស់អាត្មាទុក អ្នកខ្លះច្រានគ្នាឯង អាត្មាដូចជាពិបាកចិត្ត ហត់នឿយខ្លាំង ទើបគេចចេញ ពីទីប្រជុំជន ទៅអង្គុយសម្រាកនៅលើទីទួលជិតផ្លូវថ្នល់ ។ ក្រុមមនុស្សនៅតែមកតាមចោមរោមអាត្មា ដោយមិនព្រម ចេញទៅណាឆ្ងាយ ។ សេចក្ដីចង់បានអាត្មានេះ ធ្វើឲ្យ អ្នករាល់គ្នាភ្លេចនូវហេតុការណ៍អាក្រក់ ដែលទើបតែកើត ឡើងនោះឲ្យភ្លេចសាកសពដែលដេកនរនៀលលើដី ភ្លេច មិត្តភក្តិរងគ្រោះធ្ងន់ធ្ងរ ដែលនៅដេកបម្រះដោយការឈឺ ចាប់ សំខាន់ជាងនេះទៅទៀត ពួកគេភ្លេចនូវឱវាទរបស់ អាត្មាដែលទើបតែឲ្យថ្មីៗ នេះហើយឥទ្ធិពលនៃសេចក្ដី លោភលន់ឃើញតែប្រយោជន៍ផ្ទាល់ខ្លួន ។

ដោយហេតុឃើញថាមិនមានផ្លូវណា នឹងអាច ឃាត់ឃាំងពួកគេទាំងនេះឲ្យស្ងប់បាន ទើបអាត្មារិះរកវិធី មួយ គឺបន្លាមុតយកបន្លាដួស អាត្មាពោលឡើងដោយ សម្លេងខ្លាំងថា៖

- ញាតិញោមទាំងអស់! ញោមជឿឬទេថាអាត្មាគឺជា បុគ្គលវិសេស មានវាចាសិក្តិសិទ្ធិអាចនិយាយឲ្យអ្នកណា ម្នាក់បានជួបនូវភ័យអន្តរាយ ឬមានជោគលាភអ្វីនោះបាន ញោមជឿ ឬទេ?

- ជឿទាន! មនុស្សទាំងអស់ឆ្លើយព្រមគ្នា

- ល្អហើយ! បើដូច្នេះអាត្មាសូមឲ្យអ្នកទាំងអស់គ្នា

ស្ងាត់ហើយនៅឲ្យស្ងៀមកុំចូលមកជិតអាត្មា ហើយកុំពោលពាក្យនិមន្ត ឬស្នើសុំអ្វីទាំងអស់ បើមិនអញ្ជើងទេអាត្មានឹងឲ្យអ្នកនោះជួបនឹងភាពអន្តរាយ

នៅពេលអាត្មាពោលចប់ប៉ុណ្ណឹង អ្នកដែលនៅជិតៗអាត្មានាំគ្នាថយចេញ ហើយគ្រប់គ្នានៅស្ងៀមស្ងាត់ដូចជាត្រូវសណ្ដំចិត្ត ។ ពេលឃើញគ្រប់គ្នាស្ងប់ស្ងាត់ល្អហើយទើបអាត្មាពោលឡើងថា ៖

- ល្អហើយ ! ដែលញោមទាំងអស់គ្នាបានដល្ហើមគ្នានិមន្តអាត្មានោះ អាត្មាទទួលមិនបាន ពីព្រោះចាំបាច់ត្រូវធ្វើដំណើរបន្តទៀត ប៉ុន្តែអាត្មាមិនធ្វើឲ្យញោមខកបំណងទេ អាត្មានឹងឲ្យពរដល់ញោមគ្រប់ៗគ្នា សូមឲ្យជួបលាភសោភជ័យ ដែលខ្លួនប្រាថ្នា រូបញោមមិនបាច់និមន្តអាត្មាទៅផ្ទះទេ បើអាត្មាមាន វាចាសក្តិសិទ្ធិឲ្យពរនៅទីនេះ ឬទីណាក៏ដូចគ្នាដែរ អាត្មានឹងឲ្យពរដល់អ្នកទាំងអស់នៅទីនេះ សូមឲ្យអ្នកទាំងអស់គ្នាលើកដៃប្រណម្យឡើង ហើយអធិដ្ឋានក្នុងចិត្តចង់បានអ្វីៗប្រាថ្នាតាមចិត្តចង់ តែឲ្យត្រឹមត្រូវទៅតាមធម៌ណា៎

ទាំងអស់គ្នាលើកដៃប្រណម្យឡើង ហើយធ្មេចភ្នែកអធិដ្ឋាន ធ្វើមាត់ជីបអូចៗធ្វើតាមភ្លាម មួយសន្ទុះធំក្រោយមក ទើបអាត្មាពោលឡើងថា ៖

- បានហើយ ! តទៅនេះអាត្មាសូមឲ្យពរ សូមឲ្យអ្នកទាំងអស់គ្នា បានប្រកបជួបនូវសេចក្តីប្រាថ្នារបស់លោកអ្នកប្រាថ្នាគ្រប់ៗប្រការចុះ កុំសូមអ្វីពីអាត្មា ហើយឈប់និមន្តអាត្មាទៀត

ក្រោយអំពីនោះ ហេតុការណ៍ក៏បានស្ងាត់ស្ងៀម អាត្មាអាគតទៅ មើលរថយន្តតូចរបស់លោកចំណាន ដែលអាត្មាបានជិះមកជាមួយនោះ គេមិនឃើញមានគេប្រាប់អាត្មាថា គាត់បានប្រញាប់យកអ្នករបួសធ្ងន់ៗឡើងឡាន ហើយបើកត្រឡប់ទៅក្នុងស្រុក ដើម្បីនាំចូលមន្ទីរពេទ្យ ទៅហើយ តែគាត់នឹងត្រឡប់មកវិញ ។ អាត្មាគិតក្នុងចិត្តថា៖

- នៅពេលដែលជនដទៃគិតតែប្រយោជន៍ផ្ទាល់ខ្លួន , ស្របពេលដែលមនុស្សមួយចំនួន កំពុងធ្លាក់ចុះក្នុងគំនរទុក្ខ លោកចំណានត្រឡប់ជាលះបង់នូវប្រយោជន៍ និងសេចក្ដីសុខផ្ទាល់ខ្លួនគ្រប់យ៉ាង ជួយដល់មនុស្សដោយគ្មានសេចក្ដីនឿយហត់ថែមទាំងមិនទទួលបានថ្លៃឈ្នួលសូម្បីតែបន្តិច ។ បើអាត្មាមានសម្ដីស័ក្ដិសិទ្ធិមែន អាត្មាចង់ឲ្យពរជ័យដល់មនុស្សបែបនេះតែប៉ុណ្ណោះ ។

# ចង់តែស្រណុក ជួបទុក្ខមិនខាន

**ពាក្យប្រាំបី**

**សេរីហួសខេត្តជាហេតុក្ដៅក្រហាយ ចង់តែសប្បាយនឹងក្លាយជាទុក្ខ**
**សង្ឃឹមរាសនាបាត់បង់ក្ដីសុខ ចង់តែស្រណុកមុខជាពិបាក ។**
**បើចង់តែបានមានតែពីខ្វះ ពឹងតែលើព្រះសំពះឥតស្រាក**
**ការងារមិនធ្វើមុខជាគោកយ៉ាក ទុក្ខឥតស្រាន្តស្រាកព្រោះតែបន់ស្រន់៕**

ដោយឧបាសក ម៉ិញ សារ៉ាង

# ជៀសពាលផុតទុក្ខ សេពសុខគប់ប្រាជ្ញ

**ពាក្យប្រាំពីរ**

**សេពគប់ជនពាលនាំកើតទុក្ខ ក្តៅពើតផ្សាចុកទាំងយប់ថ្ងៃ**
**ប្រៀបដូចសត្រូវចាំប្រល័យ ឲ្យដល់នៅក្ដីមរណា ។**
**សេពគប់អ្នកប្រាជ្ញប្រាណបានសុខ កាយចិត្តស្រណុកគ្រប់វេលា**
**ប្រដូចពួកញាតិចាំការពារ ជួយថែរក្សាផុតព្រួយភ័យ ៕**

ដោយឧបាសក ម៉ិញ សារ៉ាង

# ចន្ទ្រា និង តារា

**ពាក្យប្រាំពីរ**

***តារាទោះរះពេញមេឃា ក៏មិនសោភាដូចដួងចន្ទ្រ***
***មានតែមួយដួងគង់គ្រប់គ្រាន់ តារារយពាន់ពុំអាចស្មើ ។***
***តារាពុំអាចមានរស្មី បំភ្លឺរាត្រីឲ្យប្រសើរ***
***ព្រះចន្ទ្រមួយដួងនោះទេតើ ពន្លឺចាំងស្មើត្រចះបាន ។***
***មនុស្សល្ងង់ទោះមានពេញបុរី លើភពផែនដីច្រើនប៉ុន្មាន***
***ពុំអាចញុំាងគុណប្រយោជន៍បាន ត្រកាលថ្កើងថ្កានសោះឡើយណា ។***
***ចំណែកអ្នកប្រាជ្ញទោះមានម្នាក់ ជាទីពឹងពាក់ជនច្រើនគ្នា***
***ញុំាងគុណប្រយោជន៍កើនគ្រប់គ្រា សាងជាតិសាសនាវឌ្ឍនាបាន ៕***

ដោយឧបាសក ម៉ិញ សារ៉ាង

# ១៥. មនុស្ស ភ្លឺបិសាចលបញ្ឆោត

បន្ទាប់ពីនោះមកក៏មានរថយន្តឈ្នួលមួយ មកពីទិសខាងលិច បានមកដល់កន្លែងកើតឧប្បត្តិហេតុ អ្នកបើកបរបានបន្ថយល្បឿន ហើយឈប់ចតនៅក្បៀនថ្នល់ខាងឆ្វេង ធ្វើឲ្យញាតិញោមដែលជួបនូវឧប្បត្តិហេតុម្នាក់ៗសប្បាយចិត្ត នឹងបានឡើងរថយន្តរត់ឲ្យផុតពីភាពគ្នរឲ្យតក់ស្លុតនេះគ្រប់ៗគ្នា ម្នាក់ៗប្រញាប់ប្រញាល់យកអីវ៉ាន់ឡើងរថយន្តឈ្នួលនោះ អ្នកណារបួសធ្ងន់ក៏បានមិត្តភក្តិធ្វើដំណើរជួយគ្រាទៅឡើងរថយន្ត អ្នកដែលរបួសរាងស្រាលក៏ព្យាយាមដើរសន្សឹមៗទៅខ្លួនឯង ៗ ភាពឃើញតែប្រយោជន៍ខ្លួនរបស់មនុស្ស បានបញ្ចេញឲ្យឃើញយ៉ាងច្បាស់ម្តងទៀត ក្នុងពេលនេះទាំងអស់គ្នាព្យាយាមប្រញាប់ប្រញាល់ទៅឡើងរថយន្តរៀងៗខ្លួន ៗ ពេលកំពុងជ្រួលច្របល់នោះ មានក្មេងកម្លោះម្នាក់ដើរខ្មើចៗមករកអាត្មា ហើយពោលដោយសម្លេងរនិបរនុបថា៖

- ព្រះអង្គទាន! ព្រះអង្គត្រូវគង់នៅជាមួយខ្ញុំម្ចាស់ណា៎! សុំនៅជាមួយខ្ញុំម្ចាស់ កុំទៅចោលខ្ញុំកូណាទាន, ពោលហើយគេដើរមកចាប់ចីពររបស់អាត្មាទុក

អាត្មាសម្លឹងទៅគេដោយងឿងឆ្ងល់ហើយសួរថា៖

- ញោមនៅទីនេះធ្វើអីទៀត? ប្រញាប់ឡើងឡានជាមួយនឹងគេទៅ ប្រយ័ត្នទៅមិនទាន់គេ ឆាប់ទៅៗ...

ក្មេងប្រុសនោះមើលមកអាត្មាដោយខ្សែភ្នែកអង្វរករ មានទឹកភ្នែក ហូរសើមៗចេញមកពេញរង្វង់ភ្នែក រួចឆ្លើយថា៖

- ព្រះអង្គ! ឲ្យខ្ញុំម្ចាស់ទៅចោលសពមិត្ត និងសពបងរបស់ខ្ញុំម្ចាស់បានដូចម្ដេចទៅទាន? ខ្ញុំម្ចាស់ត្រូវនៅរង់ចាំនៅទីនេះលុះត្រាប៉ូលីសមកគក់ត្រាសួរហេតុការណ៍ជាមុនសិន

នៅពេលបានឮពាក្យឆ្លើយរបស់គេ អាត្មាចាំបានភ្លាមថា គេជាក្មេងចាំយកថ្លៃធ្វើដំណើរម្នាក់ទៀតលើរថយន្តឈ្នួលគ្រោះថ្នាក់នេះ គេប្រហែលជាគត់ស្លុតខណៈពេលអ្នកឯទៀតកំពុងប្រញាប់ឡើងរថយន្តឈ្នួលថ្មីនោះ ដោយទុកគេចោលជាមួយសាកសព និងរថយន្តក្រឡាប់នៅក្នុងព្រៃតែម្នាក់ឯង ។ ដោយហេតុគ្មាននរណាជាទីពឹងបានទើបចូលមកអង្វរករដល់អាត្មា ពីព្រោះអស់ផ្លូវហើយ ។ ក្នុងពេលមានទុក្ខព្រួយ ជីវិតស្ថិតក្នុងមហន្តរាយ តែងគ្មានទីពឹងដែលអាចផ្ដល់នូវភាពកក់ក្ដៅប្រសើរជាងព្រះរតនត្រ័យ ។ ក្មេងកំលោះនេះបែបឆ្លាប់សូត្រធម៌ សង្ឃំ សរណំ គច្ឆាមិរាប់មិនអស់ក្នុងជីវិតរបស់គេ និងយល់នូវអត្ថន័យដ៏ប្រៀបច្បាស់ទៀតដោយមិនចាំបាច់សូត្រ ។

- ញោមកុំព្រួយ! អាត្មាឆ្លើយ, ក្មេងប្រុសនេះញញឹមចេញទាំងទឹកភ្នែកហើយឱនក្រាបអាត្មា

នៅពេលអ្នកធ្វើដំណើរ ឡើងអង្គុយស្រួលបួលហើយ រថយន្តឈ្នួលនោះក៏ចេញដំណើរបាត់ទៅតម្រង់ទៅទិសខាងត្បូង ជាមួយនឹងស្មៀងសព្រាតពីខាងក្រោយ

ហេតុការណ៍ទាំងអស់ដែលបានកើតឡើង ហើយផុតអស់ទៅយ៉ាងរហ័សដូចឈុតឆាកដែលគេតែងកាត់មួយៗ ក្នុងភាពយន្តរឿងភឹង អាត្មានឹកចង់សើចក្នុងចិត្តនៅពេលមុននេះបន្តិច មនុស្សទាំងអស់នោះនាំគ្នាមកចោមរោមអាត្មាដណ្ដើមគ្នានិមន្តឲ្យទៅផ្ទះរបស់ពួកគេ តែដល់ពេលមានរថយន្តឈ្នួលមកដល់ ក៏នាំគ្នាត្រឡប់ទៅផ្ទះវិញរៀងៗខ្លួន ។ គ្រប់គ្នាឡើងរថយន្តយ៉ាងប្រញិបប្រញាប់ មិនមាននរណាសូម្បីតែម្នាក់ ហាមាត់សុំនិមន្តឲ្យអាត្មាទៅជាមួយ ឬសូម្បីតែពោលពាក្យលា ។ យ៉ាងណាក៏ដោយអាត្មាបានស្ងប់ចិត្តបានផ្សាយមេត្តាចិត្តឲ្យគ្រប់ៗគ្នា និងអធិដ្ឋានឲ្យពួកគេត្រឡប់ទៅដល់ផ្ទះជួបតែសេចក្ដីសុខ រួចក៏ងាកមកមើលក្មេងកំលោះ ដែលកំពុងអង្គុយមើលរថយន្ត ដោយសេចក្ដីអស់សង្ឃឹម គេងាកទៅមើលច្នុល់ទិសងត្បូងម្ដងៗ ហើយក៏ដកដង្ហើមធំ ពេលវេលាពិតជាដើរយឺតៗ សម្រាប់អ្នកកំពុងរង់ចាំ ។

ព្រះអាទិត្យ បានទន់ទាបរៀបអស្ដង្គតបន្តិចម្ដងៗ បានសេចក្ដីថា ស្បៃរាត្រីកាលកំពុងខិតជិតមកដល់ ធាតុអាកាសនៅជុំវិញបរិវេណនោះ ក៏ចាប់ផ្ដើមត្រជាក់និងមានភាពស្ងាត់ជ្រងំយ៉ាងខ្លាំង ។ អាត្មាសង្កេតឃើញថា ក្មេងប្រុសដ៏គួរឲ្យអាណិតនេះបានក្រោកចុះក្រោកឡើង សម្ដែងឲ្យឃើញនូវភាពខ្វល់ខ្វាយក្នុងចិត្តជាខ្លាំង ដោយមិនទាន់មានឃើញសមត្ថកិច្ចណា មកនៅឡើយ ។

គេនិយាយចេញមក ដោយអាការៈភ័យព្រួយខ្លាំង

ពីមនទៀន

- បើពួកគេមិនមកទៀត តើយើងគិតធ្វើយ៉ាងម៉េចទៅព្រះគុណម្ចាស់?

- យើងត្រូវអង្គុយចាំសពនៅទីនេះ លុះត្រាតែពួកគេមកដល់ណាញោម, អាត្មាឆ្លើយ

- បើយប់នេះពួកគេមិនមករហូតដល់ភ្លឺនោះ ? គេនិយាយតែភ្នែកបស់គេសម្លឹងមើលសាកសព ដែលប្រាសចាកវិញ្ញាណនៃមិត្តនិងបងប្អូនជីដូនមួយគេ,

- យើងក៏ត្រូវអង្គុយចាំនៅទីនេះរហូតដល់ភ្លឺ

- តើញោមខ្លាចឬ ? សំណួររបស់អាត្មាបានទៅចាក់ដោតចិត្តល្ងង់ខ្លៅរបស់ក្មេងកម្លោះនេះ គេភ្ញាក់យ៉ាងខ្លាំងហើយងាកទៅមើលជុំវិញខ្លួន មួយសន្ទុះធំទើបងាកមកសួរអាត្មា មិនទាន់បានឆ្លើយផងគេពោលថា៖

- ព្រះអង្គមិនខ្លាចទេឬ ?

- ខ្លាចស្អី ? អាត្មាសួរ

ក្មេងកម្លោះមិនឆ្លើយ គ្រាន់តែសម្លឹងទៅសពមិត្តរបស់គេដោយមិនព្រិចភ្នែក ធ្វើឲ្យអាត្មាទាយបានថា តើគេខ្លាចស្អី ។

- ពីមុនអាត្មាក៏ធ្លាប់ខ្លាចខ្មោចដូចគ្នា ! អាត្មានិយាយបន្តទៀត, តែពេលនេះអាត្មាឈប់ខ្លាចហើយ

- លោកម្ចាស់ធ្វើយ៉ាងណាទើបឈប់ខ្លាច ? ក្មេងប្រុសនេះសួរដោយចង់ដឹងរឿងរ៉ាវ

- ចាំអាត្មានិយាយឲ្យស្តាប់, ពេលបួសដំបូងអាត្មានៅ

ក្នុងប៉ារឆាជាមួយលោកគ្រូ ថ្ងៃនិបូងលោកគ្រូបញ្ជាឲ្យដាក់ក្រុតនៅក្រោមដើមឈើ ក្បែរកន្លែងកប់ខ្មោចតែហោង ដែលអ្នកជិតនោះបានប្រាប់ថា ជាខ្មោចគាចណាស់ធ្លាប់លងគេច្រើនគ្នាហើយ ចំណែកលោកគ្រូទៅដាក់ក្រុតនៅកន្លែងមួយទៀតឆ្ងាយជាងប្រមាណ ២០០ ម៉ែត្រ ។

អាត្មាបានប្រាប់លោកគ្រូថា ថ្ងៃនិបូងសុំនៅជិតៗនឹងលោកសិន ។ លោកគ្រូស្ដីឲ្យ ហើយប្រាប់ថា៖

- ជាព្រះសង្ឃ គឺមានសីល ២២៧ បរិបូរណ៍ប្រសើរជាងមនុស្ស និងអមនុស្សឯទៀតៗហើយតើនៅខ្លាចអីទៀត? ម្យ៉ាងទៀតហេតុដែលនាំឲ្យលោកមកនៅប៉ារឆា នេះក៏ព្រោះលោកបានសិក្សានូវសេចក្ដីខ្លាច និងស្វែងយល់ពីមុខមាត់របស់សេចក្ដីខ្លាច នឹងអាចយកឈ្នះសេចក្ដីខ្លាចបាននៅទីបំផុត ។

ពេលយប់ហ្នឹង អាត្មាត្រូវបង្ខំចិត្តនៅជិតរណ្ដៅកប់ខ្មោចនោះរហូតអស់ពេលមួយយប់ ។ ពេលយប់ឡើងអាត្មាប្រញាប់ចូលក្នុងក្រុត ថ្វាយបង្គំព្រះ សូត្រមន្ត និងផ្សាយមេត្តា ហើយក៏អង្គុយសមាធិ នៅពេលអង្គុយបានមួយភ្លែត ក៏បានឮសម្លេងឆ្កែលូយ៉ាងគ្រលួចចេញមកពីភូមិអ្នកស្រុកចំងាយប្រហែល ២ គីឡូម៉ែត្រ ។ អាត្មានឹកខ្លាចឡើងព្រឺរោមខ្នាកពេញខ្លួន ក៏មានចិត្តខ្វល់ខ្វាយរហូតដល់ធ្វើសមាធិលែងកើត ។ នៅពេលឆ្កែឈប់លូពីផ្ទះអ្នកស្រុកហើយ ស្រាប់តែឮសម្លេងឆ្កែលូនៅជិតប៉ារឆាម្ដងទៀតយ៉ាងគ្រលួចក្បែរៗអាត្មា ។ រាល់ពេលបានឮឆ្កែលូ ធ្វើឲ្យអាត្មា

ព្រឺឆ្អឹងខ្នង ព្យាយាមរម្ងាប់ចិត្តធ្វើសមាធិ តែមិនអាចបង្ក្រាប ចិត្តដែលកំពុងរសាប់រសល់អន្ទះអន្ទែង ដោយសេចក្តីភ័យខ្លាចនោះបាន ចិត្តគិតថា ខ្មោចតែហោងកំពុងមកធ្វើអ្វីដល់យើងហើយ ។ រួចពេលស្តែកឈប់លូបាត់ស្ងាត់ទៅ ក៏មានសម្លេងសន្ធឹកដើមឈើ ឮសូរងក្បាលនិលោក អាត្មាភ្ញាក់ដោយសេចក្តីភ័យខ្លាចមែនទែន គិតថាពេលនេះខ្មោចតែហោងមកនៅលើដើមឈើប្រាកដហើយ ពេលនោះគ្មានចិត្តណាអាចធ្វើសមាធិតទៅទៀតឡើយ គិតថានឹងរត់ទៅរកលោកគ្រូតែម្យ៉ាង ប៉ុន្តែបើធ្វើយ៉ាងនេះក៏នឹកខ្មាសខ្លួនឯង ទាំងនឹកក្រែងចិត្តលោកគ្រូ ទើបខំទ្រាំអត់ធ្មត់នៅក្នុងក្រុតនោះដោយសេចក្តីទុក្ខវេទនាជាទីបំផុត ។ អាត្មាក៏ធ្វើការនានាក្នុងចិត្ត សុំឲ្យពេលយប់ដែលគួរឲ្យខ្លាចនេះឆាប់ផុតអស់ទៅឆាប់ៗ តែយល់ថាដូចជានៅយប់ដដែល ។

ថ្ងៃហ្នឹងជាថ្ងៃ ៣ រោច ខែផល្គុន ព្រះចន្ទមានពន្លឺភ្លឺចែងចាំង ធ្វើឲ្យប៉ាឆានៅកន្លែងនោះមិនសូវងងឹតប៉ុន្មានទេ មើលទៅតាមក្រណាត់មុងក្រុត ចេញទៅក្រៅអាចមើលឃើញដើមឈើនុះទ្រុបលេចចេញជារូបរាងយ៉ាងច្បាស់ ។ ខណៈពេលដែលចិត្តកំពុងតែភ័យខ្លាចមកគ្របដណ្តប់ដូច្នេះ មែកឈើពេលសម្លឹងមើលទៅដូចជា ខ្មោចបិសាចកំពុងសម្លឹងមើលមកវិញ ហាក់បីដូចហក់សង្គ្រប់មកលើអាត្មា អាត្មាធ្មេចភ្នែកហើយ ខំប្រឹងសូត្រធម៌ ការពារខ្មោចបានយ៉ាងញាប់មាត់ តែជាការសូត្រចាំមុខភ្លេចក្រោយ ខុសខ្លះត្រូវខ្លះពីព្រោះគ្មានសតិនឹងធឹងទេ ។ ទោះបីជាធម៌នេះអាច

គារពារខ្លោចបាន ឮតែយ៉ាងណាក៏ដោយ ក៏មិនអាចជួយអាត្មាបានទេក្នុងពេលនោះ ។

ក្រោយមកមិនយូរប៉ុន្មាន មានសម្លេងឮឡើងពីលើដើមឈើ អាត្មាលើកដៃទាំងពីរខ្ពោបក្បាលដោយមិនដឹងខ្លួនគិតថា នៅពេលនេះ ខ្មោចតែហោងប្រហែលលោតចុះមកធ្វើបាបពិតហើយ ។ ស្រាប់តែគ្មានអ្វី កើតឡើងសោះ អាត្មាដកដៃចេញតិចៗពីក្បាល ហើយងាកមើលទៅខាងលើ តែមិនឃើញមានអ្វីទេ ក្រៅអំពីងងឹតស្លុត និងភាពងងឹត ។ អាត្មាដកដង្ហើមយ៉ាងវែងៗ រួចក៏ចាប់ផ្ដើមសូត្រធម៌សារជាថ្មី តែមិនយូរប៉ុន្មានបានឮសម្លេងគួរឲ្យខ្លាចព្រឺព្រួចនៅលើដើមឈើនោះទៀត ។ វាជាសម្លេងប្លែកដែលអាត្មាមិនធ្លាប់បានឮពីមុនមកទេ មានសម្លេងដូចជាគេស្រែករំពងពេញទីប៉ាឆា អាត្មាយល់ថា ខ្លួនដែលអាចស្រែកនូវសម្លេងនេះបាន ប្រហែលជាខ្លួនរបស់វាធំមហិមាហើយ សម្លេងនេះឮឡើងទៀតជាច្រើនដង ម្ដងៗធ្វើឲ្យអាត្មាព្រឺក្បាល និងព្រឺឆ្អឹងខ្នងខ្លាំងៗ រាល់ពេលដែលសម្លេងនេះឮឡើង តែងមានសម្លេងឮដូចគ្នាបន្ទរពីក្រោយឆ្ងាយពីសម្លេងប្លែកនោះ ។ មួយសន្ទុះក្រោយមក មានតែធាតុអាកាសត្រជាក់ដ៏សែនស្ងាត់នៅលានទីប៉ាឆា ។

អស់ពេលយ៉ាងយូរក្រោយមក អាត្មាក៏គិតថា ប្រហែលគ្មានអ្វីទេ ដែលគួរឲ្យខ្លាចនឹងកើតឡើងទៀតទេនោះ ប្រហែលខ្មោចតែហោងដែលគេនិយាយមិនអាចតស៊ូជាមួយកម្លាំងធម៌របស់អាត្មាមិនបានឬ អាចស៊ូបានតែមិន

លងបំភ័យអ្វីតទៅទៀតទេ ។ អាត្មានឹកសប្បាយចិត្ត ក្រៃលែង ទើបលើកជើងឡើងតិចៗ ដើម្បីឲ្យជើងដែល អង្គុយបត់មួយសន្ទុះនោះបានស្រួលឡើងវិញ ។ អាត្មាបាន បោសស្លឹកឈើស្ងួតៗ ប្រមូលរួចយកសំពត់ង្ងូតមកក្រាល ពីលើធ្វើជាកន្លែងសម្រាប់សឹង ។ ពេលកំពុងកម្រើកខ្លួន ក្នុងពេលាដ៏ស្ងាត់ដូច្នោះមានសម្លេងតិចៗ ឆ្ងាយជាសម្លេងឮ គួរសមដែរ គឺជាសម្លេងរបស់អាត្មាប្រែជើងនោះឯង ។ ស្រាប់តែឮសម្លេងខ្លាំងប្លែកឡើងៗ ចេញពីបរិវេណជិតៗ ក្លុតរបស់អាត្មា គឺឮតាមផ្លូវចូលទៅក្នុងប៉ារាដូចជា សម្លេង សត្វដ៏ធំរត់កាត់ស្លឹកឈើស្ងួត កំពុងតែរត់គេចដោយភាព ភ័យខ្លាច ។ សម្លេងនេះធ្វើឲ្យអាត្មាភ័យខ្លះៗ តែមិនភ័យ ខ្លាំងទេ ទោះបីជាស្អីក៏ដោយ បើវារត់ទៅមានន័យថា វាខ្លាច យើង បើវាខ្លាចយើង យើងក៏មិនត្រូវខ្លាចវាទេ ។

